ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា

# វិទ្យាសាស្ត្រ



នាយកដ្ឋានអប់រំកុមារតូច ព.ស ២៥៦៦ គ.ស ២០២២

ក្រសួងអប់រំ យុវជន និងកីឡា

# សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា

# វិទ្យាសាស្ត្រ

នាយកដ្ឋានអប់រំកុមារតូច

ឆ្នាំ ២០២២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ១០៩៨ **អយក.**ប្រក

# ប្រកាស

## ស្តីពី

## ការអនុញ្ញាតឱ្យបោះពុម្ពផ្សព្វផ្សាយ សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញប្រកាសលេខ ១១១៩ អយក.ប្រក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានអប់រំ
- បានឃើញប្រកាសលេខ ៣០២ អយក.ប្រក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស
- តាមសំណើរបស់ក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ

## សម្រេច

**ប្រការ១ .-**

អនុញ្ញាតឱ្យបោះពុម្ព «**សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា**» ដែលរៀបចំដោយក្រុមការងារបច្ចេកទេស និងកែសម្រួលកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាសាធារណៈ។

**ប្រការ២ .-**

សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សានេះ មាន ៥(ប្រាំ) មុខវិជ្ជាគឺ៖

១- ចិត្តចលភាព

២- វិទ្យាសាស្ត្រ

៣- សិក្សាសង្គម

៤- បុរេគណិត

៥- ភាសាខ្មែរ

ខ្លឹមសារលម្អិតនៃសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានអប់រំកុមារតូច ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានធានាគុណភាពអប់រំ និងគ្រប់ប្រធានអង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៩រោច ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០២២

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យរដ្ឋមន្ត្រី ក្រសួង អយក

"ដើម្បីជូនជ្រាប"

- គ្រប់អង្គភាពក្រោមឱវាទក្រសួង អយក
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ដូចប្រការ ៣

"ដើម្បីអនុវត្ត"

- ឯកសារ កាលប្បវត្តិ នា.អកត អ.យ.ក

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# សមាសភាពគណៈកម្មការ

## គណៈកម្មការដឹកនាំ

| | | | |
|---|---|---|---|
| ១- ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន | ណារ៉ុន | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ២- លោកជំទាវ | គឹម | សេដ្ឋានី | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៣- លោកជំទាវ | យុន | រចនា | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៤- ឯកឧត្តម | ពុត | សាមិត្ត | អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ |
| ៥- ឯកឧត្តម | ឡេង | ធវណ្ណា | អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ |
| ៦- ឯកឧត្តម | ប្រាក់ | កុសល | ប្រធាននាយកដ្ឋានអប់រំកុមារតូច |

## គណៈកម្មការនិពន្ធ និងរៀបរៀង

| | | | |
|---|---|---|---|
| ១- លោក | សុក | សុខុម | ប្រធានការិយាល័យផែនការ និងស្រាវជ្រាវ |
| ២- លោកស្រី | ឈឹម | កល្យាណ | អនុប្រធានការិយាល័យអប់រំកុមារតូច |
| ៣- លោកស្រី | ហេង | ចាន់សារ៉ាត | ប្រធានការិយាល័យរដ្ឋបាល(សគមម) |
| ៤- កញ្ញា | ហ៊ូ | ចាន់សារ៉ា | មន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា |
| ៥- លោក | សៀង | គឹមឈឿន | មន្ត្រីនាយកដ្ឋានអប់រំកុមារតូច |
| ៦- លោកស្រី | សម | ស្រីលីន | មន្ត្រីនាយកដ្ឋានអប់រំកុមារតូច |
| ៧- លោក | ប៉ុក | បូរក្សា | មន្ត្រីនាយកដ្ឋានអប់រំកុមរតូច |

៨- ក្រុមបច្ចេកទេសអប់រំកុមារតូច នៃមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ

៩- ក្រុមបច្ចេកទេសអប់រំកុមារតូច នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង

១០- ក្រុមបច្ចេកទេសអប់រំកុមារតូច នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្ដាល

១១- ក្រុមបច្ចេកទេសអប់រំកុមារតូច នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះសីហនុ

១២. ក្រុមបច្ចេកទេសអប់រំកុមារតូច នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យ

១៣- ក្រុមបច្ចេកទេសអប់រំកុមារតូច នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តកែប

១៤- អង្គការ PLAN INTERNATIONAL

## គណៈកម្មការកុំព្យូទ័រ និងរចនាបថ

| | | | |
|---|---|---|---|
| ១- លោកស្រី | រ័ត្ន | ម៉ារិន | ប្រធានការិយាល័យរដ្ឋបាល |
| ២- លោក | ណយ | សុចិត្រា | អនុប្រធានការិយាល័យរដ្ឋបាល |
| ៣- លោក | លី | ចាន់ថុល | អនុប្រធានការិយាល័យរដ្ឋបាល |
| ៤- លោក | ទៀង | សុភាព | អនុប្រធានការិយាល័យរដ្ឋបាល |
| ៥- លោក | យូ | តុនី | មន្ត្រីការិយាល័យរដ្ឋបាល |
| ៦- លោក | សៅ | ដារ៉ុង | មន្ត្រីការិយាល័យរដ្ឋបាល |

## គណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់

| | | | |
|---|---|---|---|
| ១- លោកស្រី | ផ្លុង | មុនីកុសល | អនុប្រធាននាយកដ្ឋានអប់រំកុមារតូច |
| ២- លោក | ឈួន | ប៊ុនឈឿន | អនុប្រធាននាយកដ្ឋានអប់រំកុមារតូច |

| | | | |
|---|---|---|---|
| ៣- លោក | ឃិន | ធី | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា |
| ៤- លោកបណ្ឌិត | ឈូក | ច័ន្ទធាយា | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| ៥- លោក | ប៉ាត់ | គឹមនីន | នាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម |
| ៦- លោកស្រី | សេង | សុខវណ្ណា | នាយិការងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# បុព្វកថា

ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការកែលម្អកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា ស្របទៅនឹងក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស សំដៅពង្រឹងការកសាងធនធានមនុស្សប្រកបដោយសក្តានុពល ក្នុងគោលដៅឆ្ពោះទៅកាន់សង្គមពុទ្ធិ និងវិបុលភាព ធានាបាននូវកម្លាំងពលកម្ម ដែលមានចំណេះដឹង បំណិន ជំនាញវិជ្ជាជីវៈ មានវប្បធម៌ជ្រៅជ្រះ មានផលិតភាព និងភាពប្រកួតប្រជែងខ្ពស់ នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចសកលភាវូបនីយកម្ម ឆ្លើយតបយ៉ាងសមស្រប និងទាន់ពេលវេលាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងសេចក្តីត្រូវការរបស់ប្រទេសជាតិ ជាពិសេសក្នុងពេលដែលកម្ពុជាបានកំណត់ចក្ខុវិស័យប្រែក្លាយពីប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបនាបច្ចុប្បន្ន ទៅជាប្រទេសដែលមានប្រាក់ចំណូលកម្រិតមធ្យមនៅឆ្នាំ២០៣០ និងក្លាយទៅជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។

ផ្អែកលើមូលដ្ឋាននេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា ជាយន្តការអនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា ពង្រឹងនិងលើកកម្ពស់ការបង្រៀននិងរៀន ដើម្បីបណ្តុះសញ្ញាណ ឧបនិស្ស័យ បុគ្គលិកលក្ខណៈ និងបំណិនសតវត្សរ៍ទី២១ ដល់កុមារតូច ឱ្យប្រែក្លាយជាពលរដ្ឋពេញលេញនៅពេលអនាគត។

សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សានេះ ត្រូវបានបញ្ចូលខ្លឹមសារសំខាន់ៗទាក់ទងនឹងគរុកោសល្យ ដើម្បីឆ្លើយតបសមភាពយេនឌ័ររវាងកុមារីនិងកុមារា ដែលមានទិដ្ឋភាពគ្រប់ដណ្តប់ទាំងផ្នែកទ្រឹស្តីនៃការអប់រំកុមារតូច និងវិធីសាស្ត្រអនុវត្តការបង្រៀននិងរៀននៅគ្រប់កម្រិតមត្តេយ្យសិក្សា ក្នុងន័យអភិវឌ្ឍសមត្ថភាពកុមារតូចលើផ្នែករាងកាយ និងសុខភាព ផ្នែកសីលធម៌ និងវប្បធម៌ ផ្នែកចិត្តសង្គម និងអារម្មណ៍ ផ្នែកពិចារណា និងការយល់ដឹង និងផ្នែកភាសា ដែលជាមូលដ្ឋានគ្រឹះក្នុងការជួយកុមារតូច ឆ្ពោះទៅបន្តការសិក្សា ប្រកបដោយប្រសិទ្ធភាពនៅគ្រប់កម្រិត។

ក្រសួងអប់រំ យុវជន និងកីឡា មានសុទិដ្ឋិនិយមថា គ្រប់អង្គភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ នឹងចូលរួមសហការនិងគាំទ្រដល់ការអនុវត្តសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សានេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីជាឧត្តមប្រយោជន៍សម្រាប់កុមារតូចនៅកម្ពុជា ។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា និងដៃគូអភិវឌ្ឍ ជាពិសេសអង្គការ **Plan International** ព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួម និងដើរតួនាទីស្នូលក្នុងការសម្របសម្រួល ដឹកនាំរៀបចំតាក់តែងសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សានេះឱ្យសម្រេចជាផ្លែផ្កាឡើងនាខណៈនេះ។

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# អារម្ភកថា

ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើមូលដ្ឋានីយកម្មក្របខណ្ឌកម្មវិធិសិក្សាចាប់កម្រិតមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស និងបានដាក់ចេញវិធានជាយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា សំដៅជានាប្រសិទ្ធភាព និងគុណភាពលទ្ធផលសិក្សានៅគ្រប់កម្រិត។

ទន្ទឹមនឹងនេះ សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា ត្រូវបានក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា ដោយមានចូលរួមពីអង្គភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសកិច្ចសហការគាំទ្រទាំងផ្នែកបច្ចេកទេស និងធនធានថវិកាពីអង្គការ **Plan International** រៀបចំឡើងក្នុងគោលដៅលើកកម្ពស់ស័ក្តសិទ្ធភាព នៃដំណើរការសកម្មភាពបង្រៀននិងរៀន ឱ្យមានភាពកាន់តែប្រសើរឡើងនៅកម្រិតមត្តេយ្យសិក្សា។

សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា មាន ៥(ប្រាំ) មុខវិជ្ជាគឺ **មុខវិជ្ជាចិត្តចលភាព មុខវិជ្ជាវិទ្យាសាស្ត្រ មុខវិជ្ជាសិក្សាសង្គម មុខវិជ្ជាបុរេគណិត និងមុខវិជ្ជាភាសាខ្មែរ**។ ក្រុមការងារ បានសិក្សាប្រមូលដកស្រង់ខ្លឹមសារពីឯកសារពាក់ព័ន្ធចាំបាច់ក្នុងបរិបទប្រទេសកម្ពុជា ប្រៀបធៀបទៅនឹងបរិបទបណ្ដាប្រទេសមួយចំនួនក្នុងតំបន់ ធ្វើការបន្សុំ និងសំយោគ ដើម្បីប្រែក្លាយពីទ្រឹស្ដីនៃការអប់រំកុមារតូច ទៅជាវិធីសាស្ត្របង្រៀននិងរៀនជាក់ស្តែងនៅកម្រិតមត្តេយ្យសិក្សា។ សៀវភៅសិក្សាគោលនេះ បានបង្ហាញនិងលើកឡើងពីទស្សនាទានទូទៅនៃសកម្មភាពបង្រៀននិងរៀននៅកម្រិតមត្តេយ្យសិក្សា គោលដៅសិក្សាតាមមុខវិជ្ជានីមួយៗ វិធីសាស្ត្របង្រៀននិងរៀន ការរៀបចំបរិស្ថាន សាលា/ថ្នាក់មត្តេយ្យសិក្សា និងវង្វាយតម្លៃលទ្ធផលសិក្សារបស់កុមារ ព្រមទាំងគរុកោសល្យបង្រៀននិងរៀនដើម្បីឆ្លើយតបសមភាពយេនឌ័ររវាងកុមារីនិងកុមារានៅមត្តេយ្យសិក្សា។

ក្នុងនាមក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា យើងខ្ញុំ សូមសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅជូនចំពោះ**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលជាមគ្គុទេសក៍ដ៏ឆ្នើម ប្រកបដោយឆន្ទៈមុតស្រួចលើការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ និងដឹកនាំការអភិវឌ្ឍវិស័យអប់រំ ប្រកបដោយវឌ្ឍនភាពជាបន្តបន្ទាប់ក្នុងចក្ខុវិស័យវែងឆ្ងាយ។ ជាមួយនេះ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសអង្គការ **Plan International** ដែលបានគាំទ្រ និងសម្របសម្រួលការរៀបចំតាក់តែង និងអភិវឌ្ឍសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា ដ៏មានសារសំខាន់នេះ រហូតសម្រេចបានជាស្ថាពរ។

**ក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ**
**និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា**

គឹម សេដ្ឋានី

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# បញ្ជីឈ្មោះរូបភាព


រូបភាពទី 1 ៖ ការអភិវឌ្ឍកុមារក្នុងកំឡុងពេល ១០០០ ថ្ងៃដំបូង ........ 10

រូបភាពទី 2 ៖ ទីកន្លែងសម្រាប់សកម្មភាពទស្សនាសង្កេត ........ 33

រូបភាពទី 3 ៖ ការសង្កេតវត្ថុពិត........ 34

រូបភាពទី 4 ៖ ប្រភព គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ........ 35

រូបភាពទី 5 ៖ សង្កេតដោយប្រើផ្ទាំងរូបភាព ........ 36

# មាតិកា


ប្រកាស ..... i
សមាសភាពគណៈកម្មការ ..... iii
បុព្វកថា ..... v
អារម្ភកថា ..... vi
បញ្ជីឈ្មោះរូបភាព ..... vii
មាតិកា ..... viii
សេចក្តីផ្តើម ..... 1

ជំពូក១

ទស្សនាទាននៃបង្រៀន និងការរៀនមុខវិជ្ជាវិទ្យាស្ត្រ

១.១. ទស្សនាទានកុមាររៀននៅមត្តេយ្យសិក្សា ..... 5
១.២. ការវិវឌ្ឍន៍ខួរក្បាលកុមារ ..... 9
១.៣. គោលការណ៍បង្រៀនត្រូវធានាការរីកចម្រើន ..... 11
១.៤. ទស្សនៈ និងរបកគំហើញក្នុងបរិបទថ្មី ..... 13
១.៥. អន្តរបញ្ញត្តិសម្រាប់កុមារ ..... 15
១.៦. អន្តរាគមន៍គ្រប់ជ្រុងជ្រោយ ..... 16
១.៧. អន្តរកម្មគ្រប់ជ្រុងជ្រោយសម្រាប់កុមារ ..... 18

ជំពូក២

គោលដៅសិក្សានៃមុខវិជ្ជាវិទ្យាស្ត្រ

២.១. ក្របខណ្ឌអភិវឌ្ឍសមត្ថភាព ..... 20
២.២. ការផ្សារភ្ជាប់ទៅនឹងវិទ្យាសាស្ត្រ ..... 20
២.៣. លទ្ធផលរំពឹងទុកនៃមុខវិជ្ជាវិទ្យាសាស្ត្រ ..... 22

ជំពូក៣

វិធីសាស្ត្រអនុវត្តការបង្រៀន និងរៀនមុខវិជ្ជាវិទ្យាស្ត្រ

៣.១. សញ្ញាណវិទ្យាសាស្ត្រនៅមត្តេយ្យសិក្សា ..... 28
៣.២. ប្រធានបទមុខវិជ្ជាវិទ្យាសាស្ត្រ ..... 31
៣.៣. វិធីសាស្ត្របង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនៅមត្តេយ្យសិក្សា ..... 31
    ៣.៣.១. ទស្សនាសង្កេត ..... 31
    ៣.៣.២. សង្កេត ..... 33
    ៣.៣.៣. ពិសោធន៍ ..... 37
៣.៤. ការគ្រប់គ្រងដំណើរការបង្រៀន ..... 38
    ៣.៤.១. លំនាំបង្រៀន ..... 38



t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

៣.៤.២. ការអនុវត្ត ........ 42
៣.៤.៣. សកម្មភាពចម្រុះនៃមុខវិជ្ជាវិទ្យាសាស្ត្រ ........ 43
**៣.៥. ដំណើរការបង្រៀន** ........ 51
**ជំពូក៤**
**ការរៀបចំបរិស្ថានសិក្សា នៃមុខវិជ្ជាវិទ្យាស្ត្រ**
**៤.១. យន្តការអនុវត្ត** ........ 81
**៤.២. ការស្វែងរកការគាំទ្រផ្សេងៗ** ........ 83
**ជំពូក៥**
**ការពិនិត្យតាមដាន និងវាយតម្លៃ**
**៥.១. តួនាទីរបស់កុមារ** ........ 87
**៥.២. តួនាទីរបស់គ្រូ** ........ 87
**ឧបសម្ព័ន្ធទី ១** ខ្លឹមសារនៃសកម្មភាពគោលមុខវិជ្ជាវិទ្យាសាស្ត្រ ........ 91
**ឧបសម្ព័ន្ធទី ២** គរុកោសល្យរៀន និងបង្រៀនដើម្បីឆ្លើយតបសមភាពយេនឌ័ររវាងកុមារី និងកុមារា នៅមត្តេយ្យសិក្សា ........ 100
**ឯកសារពិគ្រោះ** ........ Error! Bookmark not defined.

# សេចក្ដីផ្ដើម

ទ្រឹស្ដីគរុកោសល្យនៅមត្តេយ្យសិក្សា ការអភិវឌ្ឍន៍កុមារ គឺផ្អែកទៅលើសមត្ថភាពមានស្រាប់របស់កុមារ ផ្សារភ្ជាប់ទៅរកចំណេះដឹង និងជំនាញថ្មីៗ ដែលនាំទៅការការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ និងបណ្ដុះបំណិន និងពុទ្ធិបញ្ញា។ ដូចនេះ នៅមត្តេយ្យសិក្សា ការបង្រៀនមិនត្រូវក្លាយជាទម្រង់មួយជាក់លាក់កាត់ជាផ្នែកៗ នោះទេ។ ការបង្រៀននៅមត្តេយ្យសិក្សាត្រូវមានភាពប្រទាក់ក្រឡាគ្រប់មុខវិជ្ជា ដោយមិនត្រូវមានមេរៀន ឬមុខវិជ្ជាណាមួយដាច់ដោយឡែកនោះទេ និងបន្ទាប់មកទៀតមេរៀនពញ្ញាក់អារម្មណ៍... ដែលនីមួយៗ សុទ្ធតែភ្ជាប់ដោយលំហាត់ពីក្រោយនោះទេ។ ការយល់ដឹងអំពីការអប់រំ និងការរៀបចំនេះ ពុំមានតួនាទីតែនៅក្នុងសាលាមត្តេយ្យសិក្សានោះទេ បើផ្អែកទៅលើអាយុរបស់កុមារ លើការអភិវឌ្ឍរបស់កុមារនៅដំណាក់កាលនេះ និងដោយផ្អែកទៅលើតម្រូវការ និងលទ្ធភាពទាំងឡាយរបស់កុមារ។ ផ្ទុយទៅវិញ នៅសាលាមត្តេយ្យសិក្សា កុមារគួរតែអភិវឌ្ឍគ្រប់សមត្ថភាពជាមូលដ្ឋាន តាមរយៈល្បែង ចលនា សកម្មភាព ធ្វើដោយដៃ ការសង្កេត ការពិសោធផ្សេងៗ នៅក្នុងលក្ខខណ្ឌដែលថាគ្រប់សកម្មភាពទាំងអស់នេះ ត្រូវភ្ជាប់ទៅនឹងការសម្ដែងមតិ ការនិយាយ ការកត់សម្គាល់ និងការប្រាស្រ័យទាក់ទងគ្នា។ ការបង្រៀននៅមត្តេយ្យសិក្សាគ្រាន់តែបង្កើតស្ថានភាពជាក់ស្ដែងឱ្យកុមារធ្វើ និងអនុវត្តតាមព្រមទាំងរកដំណោះស្រាយផ្សេងៗ នៃបញ្ហាងាយៗ ប៉ុណ្ណោះ។ ប្រការនេះ បង្ហាញឱ្យឃើញពីការបង្រៀននៅមត្តេយ្យសិក្សាមិនមែនបានសេចក្ដីថាគេមិនចាំបាច់មានវត្ថុបំណងច្បាស់លាស់នោះឡើយ។

ផ្ទុយទៅវិញរឿងនេះចង់និយាយថា ការទាញយកផលចេញពីស្ថានភាពមួយត្រូវតែបង្កលក្ខណៈឱ្យមានការងារមួយនៅក្នុងវិស័យផ្សេងៗ មាន ភាសាការដាស់ស្មារតីស្របតាមមុខវិជ្ជាវិទ្យាសាស្ត្រ ចិត្តចលភាព បុរេគណិត ភាសាខ្មែរ សិក្សាសង្គម។ គំនិតនៅមត្តេយ្យសិក្សាកើតមានឡើងព្រមគ្នាជាមួយនឹងភាពចាំបាច់នៃបរិស្ថានសង្គម និងឆន្ទៈរបស់អាជ្ញាធរក្នុងការធ្វើឱ្យការអនុវត្តគរុកោសល្យចម្រើនទៅមុខ និងធ្វើឱ្យការអប់រំជាផ្លូវការទាំងឡាយអភិវឌ្ឍឈានឡើង។ ដូចនេះ ឯកសារនេះ គឺជាចំណែកមួយក្នុងចំណោមចំណែកទាំងឡាយសម្រាប់រៀបចំការអភិវឌ្ឍនេះ។

ការប្រើប្រាស់ឯកសារនេះ ត្រូវបានទទួលឱ្យអនុវត្តជាទូទៅដោយស្ថាប័ននៃក្រសួងអប់រំ យុវជន និងកីឡា ដែលជាអ្នកបានចូលរួមនៅក្នុងការរៀបចំចងក្រងឡើង។ ជាការពិតប្រាកដណាស់ ស្នាដៃស្ដីពីវិទ្យាសាស្ត្រនេះ គឺជាឯកសារបំពេញឱ្យឯកសារមុនៗ ដែលស្ដីអំពីគរុកោសល្យនៃបរិស្ថាន បុរេសំណេរ និងចិត្តចលភាព។ ឯកសារទាំងអស់បង្ហាញឱ្យឃើញពីគរុកោសល្យមួយដែលកុមារធ្វើសកម្មភាព សង្កេត ទស្សនាសង្កេត ពិសោធន៍ ទម្លាប់កុមាររិះគិត ពិចារណា និងបង្កើតថ្មី ដោយប្រើប្រាស់ញាណទាំងប្រាំ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ១. គោលបំណង

ដើម្បីជានាចំណេះដឹងផ្នែកវិទ្យាសាស្ត្រធម្មជាតិ និងសង្គម យល់ច្បាស់ពីកម្មវិធីមត្តេយ្យសិក្សាទាំងបីកម្រិត ប៉ិនប្រសប់ក្នុងការជ្រើសរើសប្រធានបទនៃមុខវិជ្ជាវិទ្យាសាស្ត្រ (ទស្សនាសង្កេត សង្កេត និងពិសោធន៍) ព្រមទាំងមានវិធានការ និងប្រើវិធីសាស្ត្របង្រៀនសមស្របក្នុងពេលដឹកនាំសកម្មភាពបង្រៀន។ ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនៅមត្តេយ្យសិក្សាមានគោលបំណង៖

- ប្រាប់បានពីនិយមន័យ អត្ថប្រយោជន៍ និងភារកិច្ចនៃមុខវិជ្ជាវិទ្យាសាស្ត្រសម្រាប់កុមារ
- កំណត់ និងប្រើប្រាស់បាននូវខ្លឹមសារមេរៀនក្នុងការអប់រំកុមារតូច
- បណ្តុះស្មារតី និងទម្លាប់កុមារតូចឱ្យមានឥរិយាបថវិជ្ជមានក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

## ២. គោលដៅរួមនៃការសិក្សា

ការសិក្សារៀនសូត្ររបស់កុមារបានចាប់ផ្តើមឡើងពីការប្រើប្រាស់ញាណ និងចិត្តចលភាព តាមរយៈការលេង និងសកម្មភាពដោយផ្ទាល់របស់កុមារ។ ការផ្សារភ្ជាប់ការលេងរបស់កុមារទៅនឹងការច្នៃប្រឌិតតាមរយៈវិធីសាស្ត្រខុសៗគ្នា វានឹងផ្តល់នូវមូលដ្ឋានចំណេះដឹង និងជំនាញមួយចំនួន ដូចជា សមត្ថភាពគិតពិចារណា វិនិច្ឆ័យ ម្ចាស់ការ ការចូលរួម និងសហការ សញ្ញាណនៃមុខវិជ្ជាមួយចំនួនត្រូវបានដាក់បញ្ចូលក្នុងគោលដៅសិក្សានៅមត្តេយ្យសិក្សា ដើម្បីផ្សារភ្ជាប់ចំណេះដឹង និងបំណិនទៅបឋមសិក្សា។ នៅពេលបញ្ចប់មត្តេយ្យសិក្សាកុមារនឹងមានសមត្ថភាពផ្នែក៖

- ការស្វែងយល់ដោយការសង្កេត
- ការយល់ដឹងអំពីរាងកាយផ្ទាល់ខ្លួន
- ចំណេះដឹងអំពីសហគមន៍
- ចំណេះដឹងពីនិមិត្តសញ្ញាជាតំណាងឱ្យវត្ថុនានា
- ចំណេះដឹងមូលដ្ឋានអំពីក្រុមអាហារ និងអាហារូបត្ថម្ភ
- ការទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារ និងសង្គម
- ការយល់ដឹងពីការប្រតិបត្តិខ្លួនដើម្បីសុវត្ថិភាព
- លក្ខណៈវត្ថុគ្មានជីវិត និងសត្វមានជីវិត
- ការប្រើប្រាស់សម្ភារៈតាមបច្ចេកវិទ្យា
- ការយល់ដឹងពីហេតុ និងផល ដែលទាក់ទងលក្ខណៈមេឃ អាកាសធាតុ
- លក្ខណៈរូបធាតុរបស់មនុស្ស សត្វ រុក្ខជាតិ អាកាសធាតុ និងវត្ថុផ្សេងៗ

## ៣. សារប្រយោជន៍

### ក. ការសិក្សាវិទ្យាសាស្ត្ររួមចំណែកក្នុងការធ្វើឱ្យលូតលាស់ផ្នែកផ្លូវចិត្ត គំនិត និងបញ្ញា

ការសិក្សាវិទ្យាសាស្ត្របានរក្សាតួនាទីសំខាន់ក្នុងលក្ខណៈពិសេសនៃលំនាំចំណេះដឹង (សញ្ចេតនាដែលជួយកុមារយល់បានពីមុខសញ្ញាមួយ។ ដូចនេះ ពេលណែនាំកុមារឱ្យសិក្សាវិទ្យាសាស្ត្រ ត្រូវប្រមូលផ្តុំបម្រុងប្រយ័ត្នកុមារដោយប្រើវិធីសង្កេត សន្ទនា និងបង្កលក្ខណៈឱ្យញាណរបស់កុមារធ្វើការបានរហ័សវាងវៃ ធាប់យល់ដឹងពិសេសត្រូវជួយកុមារឱ្យមានការលូតលាស់ផ្នែកសមត្ថភាពវិភាគ ត្រិះរិះ ប្រៀបធៀប បំព្រួញគោលគំនិតធំៗ រួចសង្ខេបមកវិញ។ ឆ្លងតាមសកម្មភាពខាងលើនេះ កុមារមានការលូតលាស់ផ្នែកសមត្ថភាពចំណេះដឹងបានយ៉ាងល្អប្រសើរ។

### ខ. ការសិក្សាវិទ្យាសាស្ត្រជួយលើកកម្ពស់ និងបើកទូលាយនូវចំណេះដឹងរបស់កុមារ

កុមារមត្តេយ្យ គឺជាវ័យមួយដែលមានការលូតលាស់ផ្នែករាងកាយ និងបញ្ញា រហ័សណាស់ ព្រោះក្នុងវ័យនេះ ជាវ័យមួយដែលកំពុងស្រេកឃ្លាននូវចំណេះដឹង និងមានចំណង់មិនចេះចប់។ ដូចនេះ ចាំបាច់គេត្រូវរៀនដោយខ្លួនឯងតាមរយៈអ្នកដែលនៅជុំវិញខ្លួនគេ។ ប៉ុន្តែដោយទុននៃការយល់ដឹងមានតិចតួច និងដោយគ្មានអ្នកជួយណែនាំ ឬកែតម្រូវ នោះកុមារនឹងមានទម្លាប់ទៅតាមការយល់ត្រូវ ឬខុសរបស់ខ្លួន។ ហេតុនេះ គ្រូត្រូវជួយណែនាំ និងផ្តល់ចំណេះដឹងប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ ទើបនាំឱ្យកុមារយល់ ចេះហៅត្រូវចំឈ្មោះ ស្គាល់លក្ខណៈពិសេសនៃការគួបផ្សំផ្នែកខាងក្រៅ និងចេះរបៀបប្រើប្រាស់មុខសញ្ញាដែលគេបានជួបប្រទះ។ ទន្ទឹមនឹងនោះ កុមារចេះវិភាគប្រៀបធៀបវត្ថុមួយទៅនឹងវត្ថុមួយទៀត ព្រមទាំងយល់បានពីមូលហេតុនៃបាតុភូតនៅជុំវិញខ្លួន។ ទាំងនេះធ្វើឱ្យកុមារមានការរីកចម្រើនផ្នែកចំណេះដឹងកាន់តែស្មុគស្មាញ ឯការចង់ចេះ ចង់ដឹងរបស់កុមារកាន់តែទូលំទូលាយ។

### គ. ការសិក្សាវិទ្យាសាស្ត្ររួមចំណែកក្នុងការអប់រំផ្នែកសញ្ចេតនារបស់កុមារ

ពេលដែលកុមារសិក្សាវិទ្យាសាស្ត្រ គ្រូបង្កលក្ខណៈ ឬបំផុសនូវចំណង់ចំណូលចិត្តរបស់កុមារ និងធ្វើយ៉ាងណាឱ្យកុមារមានជំនក់ចិត្តក្នុងការសង្កេត។ ក្នុងពេលនោះ គ្រូត្រូវឱ្យកុមារមានទំនាក់ទំនងចំពោះអ្វីដែលល្អដើម្បីឱ្យកុមារមានចិត្តរំភើបនឹងអ្វីដែលល្អនោះ ពេលនោះកុមារនឹងលូតលាស់ខ្លាំងនូវផ្នែកសញ្ចេតនា។ ដូចជាសកម្មភាពគ្រូយកផ្លែស្វាយទុំរលោងឱ្យកុមារសង្កេតដោយប្រើតុក្កតា ដើម្បីធ្វើឱ្យកុមារចាប់អារម្មណ៍ទៅលើផ្លែស្វាយ។ កុមារបានស្ទាប កាន់ ហិត ភ្លក់ បានផ្លាស់ប្តូរយោបល់ជាមួយគ្រូ និងមិត្តភក្តិ ធ្វើឱ្យកុមារសប្បាយរីករាយក្នុងការទទួលយកចំណេះដឹង។ ការជំរុញលើកទឹកចិត្ត និងការសរសើររបស់គ្រូ ធ្វើឱ្យចិត្តរំភើបរបស់កុមារបានកើតឡើង។ ពេលនោះកុមារបានកើតឡើងនូវមនោសញ្ចេតនា ស្រឡាញ់ ថែទាំ ចូលចិត្តចង់ដាំដើមស្វាយ។

### ឃ. ការសិក្សាវិទ្យាសាស្ត្រ និងលំហាត់ភាសា គឺជាមធ្យោបាយពង្រីកផ្នែកភាសា

ក្នុងពេលសិក្សាវិទ្យាសាស្ត្រ កុមារសង្កេត និងសន្ទនា ធ្វើឱ្យកុមារយល់ច្បាស់អាចឆ្លើយជាមួយនឹងដៃគូ ឬមិត្តភក្តិនូវប្រធានបទដែលខ្លួនបានសង្កេត ពេលនោះហើយដែលកុមារត្រូវប្រើទុននៃពាក្យរបស់ខ្លួនគួបផ្សំនឹងពាក្យ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ថ្មីដែលទើបនឹងចេះមករៀបជាឃ្លានិយាយ។ កត្តាទាំងនេះ គឺជាមធ្យោបាយពង្រីកផ្នែកភាសា ធ្វើឱ្យភាសារបស់កុមារកាន់តែរីកចម្រើនលូតលាស់។ ប៉ុន្តែជានិច្ចកាល គ្រូត្រូវយកចិត្តទុកដាក់លើការបញ្ចេញវាក្យស័ព្ទ និងឃ្លានិយាយរបស់កុមារឱ្យត្រូវតាមក្បួនវេយ្យាករណ៍។ ដូចនេះ ការសិក្សាវិទ្យាសាស្ត្រ បានរក្សាតួនាទីសំខាន់ក្នុងការពង្រីកភាសាកុមារ។

### ង. ការសិក្សាវិទ្យាសាស្ត្រ និងលំហាត់ភាសារួមចំណែកជំរុញការលូតលាស់ផ្នែករាងកាយ

មានរូបភាពជាច្រើនដែលជួយឱ្យកុមារសិក្សាវិទ្យាសាស្ត្រ និងលំហាត់ភាសា ដូចជា ការដើរកម្សាន្តទស្សនាសង្កេត ពលកម្ម សកម្មភាពលេងសប្បាយ ជាដើម ដែលធ្វើឱ្យកុមារបានរួមប្រាស្រ័យដោយផ្ទាល់ជាមួយធម្មជាតិ( ពន្លឺ ទឹក អាកាសធាតុ...) នាំឱ្យកុមារមានសុខភាពល្អ ។ តាមរយៈសកម្មភាពពលកម្ម គ្រូបង្ហាត់កុមារឱ្យប្រើសមត្ថភាពងាយៗ មួយចំនួន ដូចជា រៀបចំថ្នាក់ ឱ្យចំណីសត្វ បោចស្មៅ ជ្រោយដី ស្រោចទឹក ដាក់ជី។ល។

## ៤. វិសាលភាព

សៀវភៅសិក្សាគោលមុខវិជ្ជាវិទ្យាសាស្ត្រដែលក្រុមការងារបានរៀបចំចងក្រងឡើងនេះ សម្រាប់អនុវត្តនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ ឯកជន សហគមន៍ និងអ្នកពាក់ព័ន្ធដែលអនុវត្តកម្មវិធីអប់រំកុមារតូចទូទាំងប្រទេសកម្ពុជា។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

# ជំពូក១

# ទស្សនាទាននៃការបង្រៀន និងរៀន
# មុខវិជ្ជាវិទ្យាសាស្ត្រ

# ជំពូក១ ទស្សនាទាននៃបង្រៀន និងការរៀនមុខវិជ្ជាវិទ្យាសាស្ត្រ

## ១.១. ទស្សនាទានកុមាររៀននៅមត្តេយ្យសិក្សា

តាមការសិក្សាស្រាវជ្រាវបង្ហាញថា នៅចុងដំណាក់កាលឥន្ទ្រីយ៍ចលករ កុមារអាចប្រើប្រាស់គំនូសបំព្រួញសកម្មភាពជាច្រើន។ ក៏ប៉ុន្តែគំនូសបំព្រួញទាំងនេះ នៅដំណើរការជាមួយចលនាកុមារក៏មិនចាំបាច់រកនឹកដល់អតីតកាល ចងចាំព័ត៌មាន និងរៀបចំផែនការដែរ។ នៅដំណាក់កាលបុរេប្រតិបត្តិរបស់លោក Piaget ដើម្បីឱ្យកុមារអាយុពី ២ ទៅ ៧ឆ្នាំ ចងចាំព័ត៌មាន និងរៀបចំផែនការ កុមារត្រូវអនុវត្តតាមជំហានដែលលោក Piaget ហៅថា «ប្រតិបត្តិការ» ឬសកម្មភាពដែលត្រូវគិតក្នុងខួរក្បាលទៅមុខ និងថយក្រោយ ដោយមិនមានចលនា។

កុមារចាប់ផ្តើមអនុវត្តប្រតិបត្តិការខួរក្បាល តែនៅមិនទាន់ស្ទាត់ជំនាញនៅឡើយ ពោលគឺជាដំណាក់កាល «បុរេប្រតិបត្តិ» (Preoperational)។ តាមមតិរបស់លោក Piaget ការគិតដែលផ្តាច់ចេញពីសកម្មភាពជាការបង្ហាញនិមិត្តរូបនៃគំនូរបំព្រួញ។ សមត្ថភាពរបស់កុមារក្នុងការបង្កើត និងប្រើប្រាស់និមិត្តរូប ដូចជាពាក្យ ការធ្វើដៃជើង សញ្ញា និងរូបភាព ជាសមិទ្ធផលដ៏ធំ ដែលជំរុញកុមារឱ្យមានភាពស្ទាត់ជំនាញនៅក្នុងដំណាក់កាលប្រតិបត្តិបន្ទាប់។ នៅពេលដែលកុមារលេងលើកកែវទទេធ្វើជាផឹកទឹក ឬយកក្រាស់ទៅដាក់លើក្បាលធ្វើជាសិតសក់ សកម្មភាពនេះបង្ហាញថាគំនូរបំព្រួញរបស់ពួកគេមានលក្ខណៈទូទៅ ហើយមិនពាក់ព័ន្ធនឹងសកម្មភាពចលនាទេ។ នៅក្នុងដំណាក់កាលនេះ កុមារចាប់ផ្តើមសង្កេតនូវអ្វីៗ ដែលនៅជុំវិញខ្លួនកុមារបង្កើតបានជាភាសា។ ការរៀននិយាយ គឺជាការលូតលាស់ដ៏សំខាន់ ហើយនៅចន្លោះអាយុ ២ ទៅ ៤ឆ្នាំ កុមារចេះពាក្យពី ២០០ ទៅ ២០០០ ពាក្យ(Wool folk, 2016) គោលការណ៍អភិរក្ស (Conservation)។

លោក Piaget បង្កើតពាក្យ «អភិរក្ស» នេះឡើង ដើម្បីពិពណ៌នាអំពីការយល់ឃើញរបស់កុមារតូចនៅដំណាក់កាលបុរេប្រតិបត្តិនេះ ដែលយល់សើៗ អំពីព្រឹត្តិការណ៍ទៅតាមអ្វីដែលគេមើលឃើញ ហើយមិនអាចយល់ស៊ីជម្រៅបានឡើយ(Berk, 2003)។ គោលការណ៍អភិរក្សមានន័យថា៖ «បរិមាណ ឬចំនួននៃរបស់អ្វីមួយមិនផ្លាស់ប្តូរឡើយ ទោះបីជាគេយកវាទៅរៀបចំសារជាថ្មីក៏ដោយ ប្រសិនបើគេមិនបន្ថែម ឬដកចេញវត្ថុនោះ»។ លោក Piaget បានពិសោធជាមួយ Leah ដែលមានអាយុ ៥ឆ្នាំ ដោយបង្ហាញកែវធំពីរទំហំប៉ុនគ្នាតែមានកម្ពស់ខ្លី ដែលមានទឹកពណ៌ស្មើគ្នា។ Leah យល់ព្រមថាទឹកក្នុងកែវទាំងពីរមានបរិមាណស្មើគ្នា។ បន្ទាប់មកអ្នកពិសោធបានយកកែវមួយចាក់ទៅក្នុងកែវមួយទៀត ដែលមានទំហំតូច និងមានកម្ពស់វែងជាងកែវមុន។ បន្ទាប់មកយកកែវវែងទៅប្រៀបធៀបជាមួយកែវចាស់ដែលធំតែខ្លី។ Leah ចង្អុលថាកែវក្រោយនេះមានទឹកច្រើនជាមុន ដោយកម្ពស់ទឹកខ្ពស់ជាងកែវមុន។ លោក Piaget ពន្យល់បាតុភូតនេះថាកុមារតូច Leah ផ្តោតការយកចិត្តទុកដាក់ (Centering) លើកម្ពស់ហើយមិនអាចយល់អំពីស្ថានភាពច្រើនជាងមួយ ក្នុងពេលតែមួយបានឡើយដោយផ្តោតទាំងលើកម្ពស់ និងទំហំ (de-centering)។ ដូចនេះ កុមារបុរេប្រតិបត្តិមិនអាចយល់ទេថា ប្រសិនបើគេកាត់បន្ថយទំហំកែវនោះកម្ពស់នឹងកើនឡើង (Woolfolk, 2016) តាមការស្រាវជ្រាវរបស់លោក Piaget កុមារនៅក្នុងដំណាក់កាលនេះមានចរិត «មជ្ឈត្តនិយម» (Egocentrism) ដែលចាត់ទុកថា៖ ១)ខ្លួនឯងថាសំខាន់ជាងគេ ២)អ្វីៗទាំងអស់ជារបស់ខ្លួន ៣)អ្នកដែលនៅជុំវិញខ្លួនត្រូវតែយកចិត្ត-

ទុកដាក់ទៅលើខ្លួនតែម្នាក់ ៤)មិនយកចិត្តទុកដាក់លើអ្នកដទៃ ៥)មិនសូវស្តាប់បង្គាប់និងរឹងរូសប្រឆាំងនឹងមនុស្សចាស់ដែលជាវិបត្តិ LUS (MOEYS-TTD, 2016)។

ដូចនេះ នៅសាលាមត្តេយ្យសិក្សាគ្រូបង្រៀនត្រូវ (Woolfolk, 2016)៖

- ១)បង្រៀនសិស្សដោយប្រើប្រាស់វត្ថុ និងសម្ភារឧបទេសដែលជាក់ស្តែង និងដោយប្រើប្រាស់ពណ៌ដើម្បីឱ្យកុមារបុរេប្រតិបត្តិអាចយល់បាន។ ឧទាហរណ៍៖ ក្នុងការពន្យល់លេខ ត្រូវប្រើចង្កឹះដើម្បីពន្យល់ពីការបូក និងដក។
- ២)និយាយខ្លីៗ និងប្រើសកម្មភាពមួយៗ ក្នុងពេលតែមួយ ដោយប្រើប្រាស់វិធីបង្រៀនជាពាក្យសំដីផង និងបង្ហាញសកម្មភាពផង ជាពិសេសបង្រៀនតាមរយៈល្បែង ដើម្បីឱ្យកុមារយល់។
- ៣)ដើម្បីកាត់បន្ថយចរិត «មជ្ឈត្តនិយម» គ្រូត្រូវបង្រៀនឱ្យកុមារស្វែងយល់អំពីអារម្មណ៍ និងមតិយោបល់អ្នកដទៃ បង្រៀនឱ្យចេះចែករំលែក ចេះរបៀបរបបខ្ញី និងឱ្យកុមារឯទៀតខ្ចីរបស់លេង។
- ៤)បង្រៀនកុមារឱ្យមានបំណិនជាក់ស្តែង ដើម្បីអាចរៀនបំណិនស្មុគស្មាញ ដូចជា រៀនអានពាក្យសាមញ្ញៗ និងរៀនលេងជាមួយកុមារឯទៀត ដើម្បីបណ្តុះបំណិនសហការ។
- ៥)ផ្តល់ឱកាសឱ្យកុមារមានបទពិសោធន៍ច្រើន ដើម្បីពង្រឹងមូលដ្ឋានគ្រឹះ សម្រាប់យល់ទស្សនាទានថ្មីៗ និងរៀនភាសា ដូចជា នាំកុមារទៅមើលសួនសត្វ ចូលបណ្ណាគារ ស្តាប់រឿងនិទាន ស្តាប់ភ្លេង និងបង្រៀនកុមារឱ្យចេះរៀបរាប់សកម្មភាពដែលគេបានធ្វើ បានស្តាប់ បានឃើញ បានភ្លក់រសជាតិ ជាដើម។

ក្នុងវ័យកុមារតូច បទពិសោធន៍របស់កុមារជាកត្តាសម្រួចការអភិវឌ្ឍខួរក្បាលរបស់ពួកគេ។ ការចូលរួមនៅក្នុងសកម្មភាពទាំងអស់ ជួយនាំឱ្យកុមារមានការគិតត្រិះរិះពិចារណា វិភាគ និងការបង្កើតទំនាក់ទំនងថ្មីៗ។ ទំនាក់ទំនងកោសិកានៅក្នុងខួរក្បាលរបស់កុមារដែលត្រូវបានប្រើប្រាស់ញឹកញាប់ និងកាន់តែរឹងមាំ ហើយជួយឱ្យកុមារធ្វើសកម្មភាពយ៉ាងលឿន។ ទំនាក់ទំនងកោសិកាខួរក្បាលដែលមិនត្រូវប្រើនឹងស្លាប់ទៅវិញ។ ការផ្តល់ឱកាសឱ្យកុមារហ្វឹកហាត់ជំនាញថ្មីៗ ឬដោះស្រាយបញ្ហាតាមរបៀបថ្មីៗ ជួយពង្រឹងតំណភ្ជាប់ទំនាក់ទំនងក្នុងខួរក្បាល ដែលផ្តល់ការគាំទ្រដល់សមត្ថភាពទាំងនេះ។ លើសពីនេះ កុមារកសាងទំនុកចិត្តលើខ្លួនឯង និងមានគំនិតវិជ្ជមានខ្លួនឯងនៅពេលដែលពួកគេចេះស្ទាត់នូវជំនាញថ្មីៗ និងយកជំនាញថ្មីៗទាំងនេះទៅអនុវត្ត។

សកម្មភាពនានា ដែលបង្ហាញក្នុងឯកសារជំនួយស្មារតីនេះ រៀបរាប់ពីសកម្មភាពនៅកម្រិតមូលដ្ឋាន កម្រិតមធ្យម និងកម្រិតខ្ពស់ ដោយបង្ហាញពីឧទាហរណ៍ពីរបៀបធ្វើឱ្យសកម្មភាពនេះ កាន់តែពិបាកទៅៗ នៅពេលដែលកុមារកាន់តែមានភាពស្ទាត់ជំនាញ។ ការហ្វឹកហាត់មិនមែនគ្រាន់តែជាការធ្វើសកម្មភាពអ្វីមួយដដែលៗ នោះទេ ក៏ប៉ុន្តែជាការធ្វើសកម្មភាពដោយមានគោលដៅកំណត់ច្បាស់លាស់ និងត្រូវអមដោយការឆ្លុះបញ្ចាំងលើដំណើរការដែលប្រើប្រាស់សម្រាប់ធ្វើការដោះស្រាយបញ្ហា។ ដូច្នេះ ជានិច្ចជាកាល គ្រូត្រូវរៀបចំសកម្មភាពហ្វឹកហាត់ដោយប្រើប្រាស់ជំនាញ និងចំណេះដឹងដែលមានស្រាប់របស់កុមារ ក្នុងគោលដៅឱ្យ



t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

កុមារចេះយកចំណេះដឹងនេះ ទៅប្រើប្រាស់សម្រាប់ដោះស្រាយបញ្ហាថ្មីៗ ដែលមានលក្ខណៈស្មុគស្មាញជាងមុន។ ផ្តល់ឱ្យកុមារនូវបរិយាកាសដែលជួយភ្ញោចការអភិវឌ្ឍរបស់ពួកគេ និងដែលដាក់នៅចំណោទថ្មីៗ សម្រាប់ឱ្យពួកគេធ្វើការដោះស្រាយនៅក្នុងបរិយាកាសដែលភ្ញោចដល់ការអភិវឌ្ឍរបស់កុមារ និងបរិយាកាសដែលកុមារទទួលបាន។ ចំណោទកាន់តែពិបាកសម្រាប់ធ្វើការដោះស្រាយកុមារ កាន់តែអាចរៀនចេះនូវបំណិនកាន់តែមានលក្ខណៈស្មុគស្មាញបន្ថែមទៀត បន្ទាប់ពីពួកគេទទួលបានភាពស្ទាត់ជំនាញនៅកម្រិតមូលដ្ឋានរួចហើយ។

ទ្រឹស្តីរបស់លោក Daniel Everett's ៖ មនុស្សដើមចាប់ផ្តើមបញ្ចេញសំឡេងតាំងតែ ២លានឆ្នាំ ម្ល៉េះ។ មនុស្សដើមរបស់មនុស្សបច្ចុប្បន្នដែលគេហៅថា «Homo Erectus» ដែលមាន «Homo sapiens» និង «Neander thals» មានខួរក្បាលធំៗ ដើរត្រង់ខ្លួន និងចិញ្ចឹមជីវិតដោយការប្រមូលផល និងការបរបាញ់។ ដើម្បីបរបាញ់ដំរីធំៗ (mammoth)បានពួកគេត្រូវការភាសាដើម្បីប្រាស្រ័យទាក់ទង និងសម្របសម្រួលការបរបាញ់។ ពួកគេធ្វើដំណើរឆ្លងកាត់សមុទ្រដោយជិះក្បូនជាមួយគ្នាជាក្រុម ដូចនេះ ត្រូវប្រើភាសាដើម្បីទាក់ទងគ្នា និងដោះស្រាយបញ្ហាដល់ក្រុមមនុស្សរួមដំណើរ។

ទ្រឹស្តីអន្តរសកម្មសង្គមរបស់លោក Vygotsky តាមទ្រឹស្តីរបស់លោក Vygotsky ភាសាកើតមកពីសង្គមមនុស្ស។ ចាប់តាំងពីកើតចេញពីផ្ទៃម្តាយ កុមារចូលរួមក្នុងអន្តរសកម្មសង្គមដែលជួយឱ្យកុមារអភិវឌ្ឍសមត្ថភាពពុទ្ធិ បញ្ញា ជាពិសេស ភាសា និងគំនិត។ តាមទ្រឹស្តីរបស់ Vygotsky ការធ្វើអន្តរសកម្មសង្គមត្រូវកើតឡើងមុនការអភិវឌ្ឍពុទ្ធិបញ្ញា (cognition) និងការអភិវឌ្ឍភាសា។

ទ្រឹស្តីស្ថាបនានិយមរបស់លោក (Piaget តាមទ្រឹស្តីរបស់លោក Piaget ភាសាត្រូវបានស្ថាបនាបន្ទាប់ពីការអភិវឌ្ឍពុទ្ធិបញ្ញា។ មនុស្សអភិវឌ្ឍបំណិនភាសា និងស្ថាបនាចំណេះដឹងរួមរបស់ខ្លួន ដោយឈរលើមូលដ្ឋានបទពិសោធន៍របស់ខ្លួន។ ម្យ៉ាងវិញទៀត ទ្រឹស្តីរបស់លោក Piaget ផ្តោតលើសារជាតិនៃប្រាជ្ញាដោយលោកបានចែកការអភិវឌ្ឍពុទ្ធិបញ្ញាជា ៤ ដំណាក់កាល៖ ទី១ ដំណាក់កាលឥន្ទ្រីយ៍ចលករ (ពី 0 ទៅ ២ឆ្នាំ) ទី២ ដំណាក់កាលបុរេប្រតិបត្តិ (ពី ២ ទៅ ៧ឆ្នាំ) ទី៣ ដំណាក់កាលប្រតិបត្តិជាក់ស្តែង (ពី ៧ ទៅ ១០ឆ្នាំ) និងទី៤ ដំណាក់កាលប្រតិបត្តិរៀបរយ (ពី ១២ឆ្នាំ ឡើងទៅ)។

ទ្រឹស្តីអាកប្បកិរិយានិយមរបស់លោក Skinner លោក Everett ចាត់ទុកការកកើតភាសាបណ្តាលមកពីតម្រូវការរបស់សង្គម ដែលមនុស្សម្នាក់បង្កើត រួចប្រើប្រាស់សម្រាប់ការប្រាស្រ័យទាក់ទងគ្នាដោយមនុស្សច្រើននាក់។ តាមទ្រឹស្តីនេះ គ្មានទេវេយ្យាករណ៍សាកលសម្រាប់ភាសាទាំងអស់។ ផ្ទុយទៅវិញ ទ្រឹស្តីអាកប្ប-កិរិយានិយមមានលក្ខណៈខុសពីទ្រឹស្តីទាំងពីរខាងលើ។ លោក B.F. Skinner ដែលជាចិត្តវិទូ អាកប្បកិរិយានិយមបានបង្កើតទ្រឹស្តីសិក្សាភាសាតាមបែបអាកប្បកិរិយានិយម។ លោកបានសន្និដ្ឋានថា ការរៀនភាសាមានលក្ខណៈដូចរៀនបំណិនឯទៀតដែរ ដែលត្រូវរៀនតាមរយៈការសង្កេត ការធ្វើត្រាប់តាម ការរំលឹក ការធ្វើខុស ការផ្តល់ការលើកទឹកចិត្ត និងការដាក់ទណ្ឌកម្ម ដែលលោក Skinner tum (Operant Conditioning)។ លោក Skinner ចាត់ទុកការអភិវឌ្ឍភាសាថាជាការរៀនអាកប្បកិរិយាថ្មី។

នៅពេលដែលកុមាររៀននិយាយដំបូង កុមារធ្វើត្រាប់តាមអាកប្បកិរិយារបស់មាតាបិតា និងមនុស្សធំជុំវិញខ្លួន។ ភាសាអភិវឌ្ឍដោយឆ្លើយតបទៅនឹងរំញោចពីបរិស្ថាន។ នៅពេលដែលមាតាបិតាឱបកូន នៅពេលឃើញកូនបញ្ចេញសំឡេងជាលើកដំបូង គឺជាការលើកទឹកចិត្តដែលជំរុញឱ្យកុមារខំប្រឹងរៀនថែមទៀត។

ដូចនេះ កុមារមត្តេយ្យអាចទទួលរង្វាន់ ឬទទួលទណ្ឌកម្ម នៅក្នុងដំណើរការរៀនភាសានៅសាលារៀន។ ក៏ប៉ុន្តែទ្រឹស្តីនេះ មិនត្រឹមត្រូវទាំងអស់ទេ ពីព្រោះមាតាបិតាមួយចំនួនមិនបានយកចិត្តទុកដាក់ទៅលើអ្វីដែលកូននិយាយឡើយ ដោយសារកុមារនិយាយមិនច្បាស់។

ជាការពិតណាស់ ក្នុងការរៀនភាសា កុមារធ្វើត្រាប់តាមមាតាបិតារបស់គេ មនុស្សធំជុំវិញខ្លួន និងបរិស្ថានជុំវិញខ្លួនរបស់ពួកគេ។ ទ្រឹស្តីវេយ្យាករណ៍សាកលរបស់លោក Chomsky ក៏ប៉ុន្តែគ្រាន់តែធ្វើត្រាប់តាមបរិស្ថានជុំវិញមិនគ្រប់គ្រាន់ទេក្នុងការអភិវឌ្ឍភាសា។ ការអភិវឌ្ឍភាសា ជាដំណើរការដ៏ស្មុគស្មាញមួយនៃមនុស្សជាតិ។ ដូចនេះហើយលោក Noam Chomsky បានបង្កើតទ្រឹស្តីទិតៀនទ្រឹស្តីអាកប្បកិរិយានិយម ដោយអះអាងថា ភាសាកើតឡើងពីក្នុងខ្លួនកុមារតែម្តង ហើយកុមារមានលក្ខណៈសម្បត្តិជីវសាស្ត្រក្នុងការរៀនភាសា។

តាមទ្រឹស្តីរបស់លោក Everett ភាសាគឺជាឧបករណ៍សង្គមដែលមនុស្សបង្កើតឡើង ដើម្បីប្រាស្រ័យទាក់ទង ចែករំលែកចំណេះដឹង និងដោះស្រាយបញ្ហា។ ផ្ទុយទៅវិញ លោក Noam Chomsky យល់ឃើញថាភាសាកើតឡើងពីក្នុងខ្លួនមនុស្សតែម្តង។ តាមទ្រឹស្តី «វេយ្យាករណ៍សកល» របស់លោក មនុស្សកើតឡើងជាមួយនឹងសមត្ថភាពក្នុងការចេះភាសាតែម្តង។ កុមារកើតមកមានខួរក្បាលមានឧបករណ៍សម្រាប់រៀនភាសាតែម្តង ដែលគាត់ហៅថា «ឧបករណ៍រៀនភាសា» (Language Acquisition Device LAD)។ ដោយមានឧបករណ៍នេះ កុមារអាចរៀនចេះភាសាបានយ៉ាងលឿន។

ការសិក្សាស្រាវជ្រាវអំពីខួរក្បាលមិនបានបញ្ជាក់សម្មតិកម្មរបស់លោក Chomsky ឡើយ។ មនុស្សជាតិមានភាសារួមមួយដែលជាប្រភពនៃភាសាផ្សេងៗ ទៀត របស់មនុស្សដែលមានជាតិសាសន៍ផ្សេងគ្នា។ ហើយវេយ្យាករណ៍ គឺជាប្រព័ន្ធ និងរចនាសម្ព័ន្ធនៃភាសាដែលមាន៖

- ១) ប្រព័ន្ធវាក្យសម្ព័ន្ធ (syntax) តាមតួនាទី ដូចជា ប្រធានកិរិយាស័ព្ទ និងកម្មវត្ថុ ឱ្យក្លាយទៅជាល្បះ
- ២) ប្រព័ន្ធសិក្សាអំពីរចនាសម្ព័ន្ធនៃពាក្យ (morphology) ដូចជា ឫសនៃពាក្យ និងឈ្នាប់
- ៣) វិធីបញ្ចេញសំឡេង (phonology)
- ៤) ការសិក្សាអំពីន័យរបស់ពាក្យ (semantics)។

ប្រការនេះមានន័យថា កុមារចាប់ផ្តើមពីការសង្កេត និងដកស្រង់បទពិសោធន៍បរិស្ថានជុំវិញខ្លួនប្រចាំថ្ងៃបង្កើតជាវាក្យស័ព្ទថ្មីៗ។ ភាសារបស់មនុស្សត្រូវមានវេយ្យាករណ៍រួមស្រដៀងគ្នា ដើម្បីឱ្យជាតិសាសន៍នីមួយៗ អាចអភិវឌ្ឍភាសារបស់ខ្លួនបាន។ ការរៀនចេះច្បាស់ភាសារបស់ជនជាតិមួយនឹងជួយដល់ការរៀនភាសារបស់ជនជាតិមួយទៀតឱ្យឆាប់ចេះ ដោយសារភាសាទាំងអស់មាន វេយ្យាករណ៍សាកលរួមគ្នា និងស្រដៀងគ្នា។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ទ្រឹស្ដីអភិវឌ្ឍភាសារបស់លោក Arnold Gesell នៅឆ្នាំ១៩២៥ អ្នកប្រាជ្ញជនជាតិអាមេរិក លោក Arnold Gesell បានបង្កើតទ្រឹស្ដីនៃការអភិវឌ្ឍភាសា ដោយបង្ហាញឥទ្ធិពលនៃសេណេទិចក្នុងការអភិវឌ្ឍភាសា និងអាកប្បកិរិយាដទៃទៀត។ លោកជឿជាក់ថាបំណិនរបស់មនុស្ស ដូចជា បំណិនបន្សំ បំណិនចលករ និងភាសា អភិវឌ្ឍនិងរីកលូតលាស់តាមធម្មជាតិទៅតាមលក្ខណៈជីវសាស្ត្ររបស់មនុស្សម្នាក់ៗ។ ប៉ុន្តែលោកមិនបានផាត់ចោលកត្តាបរិស្ថាន ក្នុងការអភិវឌ្ឍកុមារឡើយ ទោះបីលោកយល់ថាបរិស្ថានមានឥទ្ធិពលតិចតួចជាងសេណេទិច ក្នុងការអភិវឌ្ឍភាសាក៏ដោយ។ ដូចនេះហើយទើបការសិក្សាស្រាវជ្រាវរបស់លោក Gesell ផ្ដោតលើការអភិវឌ្ឍសរីរាង្គរបស់កុមារ ដែលជាដំណើរធំធាត់របស់កុមារ (maturation) ហើយចាត់ទុកដំណើរអភិវឌ្ឍរបស់កុមារអាស្រ័យលើការលូតលាស់នៃប្រព័ន្ធសរសៃប្រសាទ ដូចជា ខួរក្បាល ខួរឆ្អឹងខ្នង ជាដើម។ លោក Gesell បានចាត់ទុកថាដំណាក់កាលសំខាន់នៃការអភិវឌ្ឍភាសាអាចចែកចេញជា ៥ ដំណាក់កាល ពីអាយុ ៤០សប្ដាហ៍ ដល់ ៥ឆ្នាំ៖

- ដំណាក់កាលទី១ អាយុ ០-៥០សប្ដាហ៍៖ កុមារចេះបន្លឺសំឡេងដែលមានន័យ។
- ដំណាក់កាលទី២ ពីអាយុ ១-២ឆ្នាំ៖ កុមារចេះប្រើឈ្មោះវត្ថុ និងឃ្លា។
- ដំណាក់កាលទី៣ ពីអាយុ ២-៣ឆ្នាំ៖ កុមារចេះប្រាស្រ័យទាក់ទងដោយនិយាយបានមួយឃ្លាទាំងស្រុង។
- ដំណាក់កាលទី៤ ពីអាយុ ៣-៤ឆ្នាំ៖ កុមារប្រើភាសាជាឧបករណ៍ក្នុងការទទួលបានចំណេះដឹងពីពិភពលោកជុំវិញខ្លួន។
- ដំណាក់កាលទី៥ ពីអាយុ ៤-៥ឆ្នាំ៖ កុមារចេះនិយាយបានយ៉ាងស្ទាត់ជំនាញ។ លោក Gesell បានចាត់ទុកថាកុមារដែលមានអាយុក្រោម ១០ឆ្នាំ មានឧបនិស្ស័យ ក្នុងការរៀនភាសាទី២ និងទី៣ ហើយពួកគេរៀនភាសាដោយក្ដីសប្បាយរីករាយ។ យើងឃើញថា ទ្រឹស្ដីនៃការអភិវឌ្ឍភាសាទាំងអស់ផ្ដោតលើឥទ្ធិពលបរិស្ថាន និងសេណេទិច ហើយអ្នកស្រាវជ្រាវផ្សេងៗ ជឿជាក់ថា ភាសាអភិវឌ្ឍដោយសារកត្តាសេណេទិចរបស់មនុស្សផង និងដោយសារការធ្វើអន្តរសកម្មផង។ ទ្រឹស្ដីនៃការអភិវឌ្ឍភាសាភាគច្រើនចាត់ទុកការអភិវឌ្ឍភាសាជាការគួបផ្សំរវាងធម្មជាតិ និងការអប់រំ។

តាមការសិក្សាទ្រឹស្ដីខាងលើបានបញ្ជាក់ថា មុខវិជ្ជាវិទ្យាសាស្ត្រ ជាមូលដ្ឋានគ្រឹះក្នុងការបណ្ដុះនូវភាសាសំបូរបែប តាមរយៈការប្រើប្រាស់ញាណពីក្នុងខ្លួនរបស់កុមារផ្សារភ្ជាប់បរិស្ថានរស់នៅរបស់កុមារដោយការសង្កេត អនុវត្ត ឬពិសោធន៍។

## ១.២. ការវិវឌ្ឍន៍ខួរក្បាលកុមារ

តាមការសិក្សាស្រាវជ្រាវបានរកឃើញថា ៨៥% នៃការអភិវឌ្ឍខួរក្បាលកើតមានអំឡុងរយៈពេល ១០០០ថ្ងៃដំបូងនៃជីវិតកុមារ ហើយការរីកចម្រើនយ៉ាងឆាប់រហ័សនេះបន្តមានរហូតដល់អាយុ ៦ឆ្នាំ។



ទារកមិនបានទទួលការថែទាំ



ទារកបានទទួលការថែទាំ

*រូបភាពទី 1 ៖ ការអភិវឌ្ឍកុមារក្នុងកំឡុងពេល ១០០០ ថ្ងៃដំបូង*

គុណភាពនៃការថែទាំដែលកុមារទទួលបានអំឡុងពេលពីរ បីឆ្នាំដំបូង រួមមាន ការថែទាំសុខភាព អាហារូបត្ថម្ភ ការប្រាស្រ័យទាក់ទងសង្គម ការភ្ញោច ការអប់រំមុនចូលសាលារៀន ការអប់រំនៅទារកដ្ឋាន ការអប់រំនៅសាលាមត្តេយ្យសិក្សារដ្ឋ ឬមត្តេយ្យសិក្សាសហគមន៍ នឹងមានឥទ្ធិពលយូរអង្វែងដល់ខួរក្បាលកុមារ។ ការរៀនសូត្រ គឺមានតាំងពីកំណើតមកម្ល៉េះ។ ការប្រាស្រ័យទាក់ទងជាមួយសង្គម និងការភ្ញោចដ៏សកម្មដល់កុមារបានទាន់ពេលវេលា តាមអាយុកាល គឺជាអាហារដ៏សំខាន់សម្រាប់ការអភិវឌ្ឍខួរក្បាលកុមារ។ វាប្រៀបដូចជាការផ្តល់ចំណីអាហារដល់កុមារដូច្នោះដែរ។ ការភ្ញោច គឺមានសារៈសំខាន់ខ្លាំងសម្រាប់ការអភិវឌ្ឍខួរក្បាល។ ការអភិវឌ្ឍខួរក្បាល និងប្រព័ន្ធសរសៃប្រសាទក្នុងវ័យកុមារភាពក៏នៅតែបន្តកើតមានគួរឱ្យកត់សម្គាល់ដែរ។ ការលូតលាស់ខួរក្បាល និងប្រព័ន្ធប្រសាទកាន់តែប្រសើរឡើង គឺឥរិយាបថ និងការយល់ដឹងកាន់តែស្មុគស្មាញដែលធ្វើឱ្យកុមារកាន់តែមានសមត្ថភាព។

ខួរក្បាលមានពីរផ្នែកគឺ អឌ្ឍគោលខួរខាងឆ្វេង និងអឌ្ឍគោលខួរខាងស្តាំ។ អឌ្ឍគោលខួរទាំងពីរមានការរីកចម្រើនក្នុងអត្រាផ្សេងៗគ្នា ដោយអឌ្ឍគោលខាងឆ្វេង មានការរីកចម្រើនយ៉ាងពេញលេញក្នុងវ័យកុមារភាព (អាយុ ២ ទៅ ៦ឆ្នាំ) អឌ្ឍគោលនេះ មានផ្ទុកជាពិសេសគឺ ភាសា ការសរសេរ និងបំណិនសង្កេតបុរេគណិត...។ រីឯសមត្ថភាពផ្នែកច្នៃប្រឌិត ផ្នែកសិល្បៈ តន្ត្រី ឬមុខងារនៃការប្រើប្រាស់រាងកាយច្រើនស្ថិតនៅអឌ្ឍគោលខាងស្តាំ។ តែទោះជាអឌ្ឍគោលទាំងពីរមានមុខងារផ្សេងៗគ្នាក៏ដោយ ក៏ម៉ាស់នៃខួរក្បាលទាំងពីរតែងតែសម្របមុខងាររបស់ខ្លួនហើយធ្វើការជាមួយគ្នា។ ទិដ្ឋភាពមួយទៀតនៃការអភិវឌ្ឍខួរក្បាលគឺ ការប្រើដៃ ឬចំណង់ចំណូលចិត្តក្នុងការប្រើដៃម្ខាង។ ក្នុងពេលនេះត្រូវបង្កើនការយកចិត្តទុកដាក់ពង្រឹងសមត្ថភាពលើការប្រើដៃម្ខាងនេះដើម្បីឱ្យមានភាពរឹងមាំ។ ប្រជាជនទូទៅប្រហែល ៩០% ច្រើនប្រើដៃស្តាំ។ ការបង្ខំ ឬដាក់ទណ្ឌកម្មឱ្យប្រើដៃម្ខាងណាមួយនោះ ដែលគេមិនមានចំណង់ចំណូលចិត្ត គឺជាការបំបាក់ស្មារតីធ្វើឱ្យកុមារវង្វេងវង្វាន់ក្នុងពេលប្រើដៃ។ ជាធម្មតាការកាន់ដៃស្តាំត្រូវបានផ្សារភ្ជាប់ជាមួយឥទ្ធិពលខាងស្តាំនៃខួរក្បាល និងប្រើដៃឆ្វេងដោយឥទ្ធិពលខួរក្បាលខាងស្តាំ។ ទោះជាខួរក្បាលមានអឌ្ឍគោលពីរផ្សេងគ្នាក៏ខួរក្បាលត្រូវបានបែងចែកជាផ្នែកផ្សេងៗ និងមានមុខងារផ្សេងៗ គ្នាដែរ។ ក្នុងចំណោមផ្នែកផ្សេងៗ នៃខួរក្បាល មានផ្នែកមួយដែលហៅថាខួរតូច ហើយមានមុខងារទទួលខុសត្រូវចំពោះចលនា។ ខួរតូច គឺជាផ្នែក

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

បន្ថែមនៃខួរក្បាលដែលមានសារៈសំខាន់សម្រាប់ចិត្តចលភាព ខួរតូចគ្រប់គ្រងចលករតូចក៏ដូចជាតុល្យភាព និងការសម្របសម្រួល។

## ១.៣. គោលការណ៍បង្រៀនត្រូវធានាការរីកចម្រើន

ការសិក្សាវិទ្យាសាស្ត្រនៅមត្តេយ្យសិក្សាមានសារៈសំខាន់ និងមានអត្ថប្រយោជន៍ចំពោះកុមារ ព្រោះជួយឱ្យកុមារបានស្វែងយល់ រុករក ស្រាវជ្រាវតាមរយៈការសង្កេត ទស្សនាសង្កេត និងពិសោធន៍ងាយៗ សមស្របតាមវ័យរបស់ពួកគេ។ ដូចនេះ ទាមទារឱ្យគ្រូបង្រៀនត្រូវយកចិត្តទុកដាក់ខ្ពស់ដល់ការអនុវត្តជាក់ស្តែងប្រកបដោយភាពច្នៃប្រឌិត និងផ្តល់ឱកាសគ្រប់គ្រាន់ឱ្យកុមារបានជួបប្រាស្រ័យដោយផ្ទាល់ជាមួយកម្មវត្ថុមុខសញ្ញាដែលត្រូវសិក្សាពិសេសគ្រូត្រូវចេះដឹកនាំសកម្មភាពសិក្សាដោយប្រើគោលវិធីសិស្សមជ្ឈមណ្ឌល ការបង្រៀនវិទ្យាសាស្ត្រ គឺជាក្បួនច្បាប់មួយដែលមានការកំណត់ជាក់លាក់អំពីរបៀប វិធីនៃការបង្រៀន និងរៀនអំពីវិទ្យាសាស្ត្រងាយៗ នៅមត្តេយ្យសិក្សារបស់គ្រូ និងកុមារ។ គ្រូត្រូវអនុវត្តតាមដើម្បីឱ្យកុមារសិក្សាវិទ្យាសាស្ត្រ និងលំហាត់ភាសាបានល្អ ប្រកបដោយគុណភាព ត្រូវមានគោលការណ៍ ៤ ដូចខាងក្រោម៖

### ក. គោលការណ៍ជានាលក្ខណៈអប់រំ

ការសិក្សាវិទ្យាសាស្ត្រមានគោលបំណងជួយបំពេញបន្ថែមទៅលើបុគ្គលិកលក្ខណៈ ដែលមានស្រាប់របស់កុមារឱ្យមានការលូតលាស់កាន់តែល្អប្រសើរ។ ដូចនេះ ការបង្រៀនវិទ្យាសាស្ត្រ ត្រូវជានាលក្ខណៈអប់រំពោល គឺជានាបាននូវការបង្រៀន និងរៀនមួយ ដែលធ្វើឱ្យមានការផ្លាស់ប្តូរឥរិយាបថទម្លាប់ពីអវិជ្ជមានទៅវិជ្ជមានមានន័យថាធ្វើឱ្យកាន់តែប្រសើរឡើងនូវការទទួលយកចំណេះដឹង និងបំណិនផ្សេងៗ ព្រមទាំងចេះប្រើប្រាស់បានសមស្របទៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ នៅពេលបង្រៀនវិទ្យាសាស្ត្រ គ្រូត្រូវមានទេពកោសល្យក្នុងការជ្រើសរើសមុខសញ្ញា ខ្លឹមសារសង្កេត ទស្សនាសង្កេត និងពិសោធន៍ ដែលមានលក្ខណៈអប់រំ ទើបអាចជួយកុមារឱ្យមានសក្តានុពលបន្តការសិក្សានៅកម្រិតបឋមសិក្សា និងថ្នាក់លើបន្តបន្ទាប់ទៀតបានល្អប្រសើរ។ ឧទាហរណ៍៖ ទស្សនាសង្កេត សួនសាធារណៈ។ ការអប់រំកុមារឱ្យចេះស្រឡាញ់ និងមានគំនិតជួយថែរក្សាការពារ ទ្រព្យសម្បត្តិសាធារណៈ។

### ខ. គោលការណ៍ជានាលក្ខណៈវិទ្យាសាស្ត្រ

ការសិក្សាវិទ្យាសាស្ត្រនៅមត្តេយ្យសិក្សាមានសារៈសំខាន់ និងមានអត្ថប្រយោជន៍ចំពោះកុមារ ព្រោះជួយឱ្យកុមារបានស្វែងយល់ រុករក ស្រាវជ្រាវតាមរយៈការសង្កេត ទស្សនាសង្កេត និងពិសោធងាយៗ សមស្របតាមវ័យរបស់គេ។ ដូចនេះ ទាមទារឱ្យគ្រូបង្រៀនត្រូវយកចិត្តទុកដាក់ខ្ពស់ដល់ការអនុវត្តជាក់ស្តែងប្រកបដោយភាពច្នៃប្រឌិត និងផ្តល់ឱកាសគ្រប់គ្រាន់ឱ្យកុមារបានបានជួបប្រាស្រ័យដោយផ្ទាល់ជាមួយកម្មវត្ថុមុខសញ្ញា ដែលត្រូវសិក្សា ពិសេសគ្រូត្រូវចេះដឹកនាំសកម្មភាពសិក្សាដោយប្រើគោលវិធីសិស្សមជ្ឈមណ្ឌល។

### គ. គោលការណ៍ជានាលក្ខណៈជាក់ស្តែង

គោលការណ៍ជានាលក្ខណៈជាក់ស្តែងមានន័យថា ជាការផ្តល់ចំណេះដឹងសមស្របទៅតាមការអនុវត្តជាក់ស្តែងស្របតាមក្រឹត្យក្រមរីកចម្រើននៃសង្គម ដោយគួបផ្សំជាមួយនឹងសមត្ថភាពចំណេះដឹងមាន

ស្រាប់របស់កុមារតាមវ័យនីមួយៗ នោះទើបកុមារស្គាល់ យល់ និងទទួលបានចំណេះដឹងពិតប្រាកដទៀតរបស់កុមារ។ ដូច្នេះ ខ្លឹមសារសង្កេត ទស្សនាសង្កេត និងពិសោធន៍ ត្រូវមានទំនាក់ទំនងគ្នាអាស្រ័យទៅតាមតំបន់ មូលដ្ឋាននីមួយៗ។ ឧទាហរណ៍៖ នៅជនបទគ្រូអាចនាំកុមារទៅទស្សនាសង្កេត ដូចជា ការដកស្ទូង ឬការភ្ជួរដីដោយត្រាក់ទ័រ ការចិញ្ចឹមគោ...។

### ឃ. គោលការណ៍ជានាលក្ខណៈគរុកោសល្យ

គោលការណ៍ជានាលក្ខណៈគរុកោសល្យបង្ហាញឡើងនូវខ្លឹមសារៈសំខាន់ដូចខាងក្រោម៖

❖ **ការជានាលក្ខណៈរូបីៈ** លក្ខណៈពុទ្ធិរបស់កុមារ គឺច្បាស់លាស់ ការគិតរបស់កុមារ គឺជាការគិតបែបរូបី។ ដូច្នេះ ពេលឱ្យកុមារសិក្សាវិទ្យាសាស្ត្រចាំបាច់ត្រូវឱ្យកុមារប្រើគ្រប់ញាណទាំងអស់ក្នុងការប្រាស្រ័យទាក់ទងដោយផ្ទាល់។ ឧទាហរណ៍៖ ពិសោធន៍ វត្ថុលិច និងអណ្តែត (សម្រាប់ថ្នាក់កម្រិតខ្ពស់)។ សម្ភារៈបង្រៀនត្រូវជានាលក្ខណៈ សោភ័ណ និងជាក់ស្តែង (ក្រូចឆ្មារ ដុំថ្ម ក្រដាស ឬស្មៅ)។ បង្កលក្ខណៈឱ្យកុមារបានស្ទាប កាន់ សាកល្បងហើយបញ្ចេញការយល់ឃើញរបស់ខ្លួន។

❖ **សមស្របនឹងវ័យកុមារ**

- បរិមាណចំណេះដឹង ចរិតចំណេះដឹង និងបរិមាណពាក្យថ្មី ត្រូវផ្តល់ឱ្យកុមារទៅតាមវ័យនីមួយៗ
- រូបភាព វិធីសាស្ត្រ មធ្យោបាយណែនាំ ត្រូវឱ្យបានសមស្របតាមវ័យរបស់កុមារ។ ឧទាហរណ៍៖ សង្កេត ផ្លែស្វាយទុំ (ចំពោះថ្នាក់ខ្ពស់)
- បរិមាណចំណេះដឹង៖ ស្គាល់រូបរាង ពណ៌ សាច់ គ្រាប់ រសជាតិស្វាយទុំបានច្បាស់លាស់ និងចេះប្រៀបធៀប។
- ចរិតចំណេះដឹង៖ រាងមូលទ្រវែង ឬរាងមូលកំប៉ោង ស្រួចកន្ទុយ ទៅតាមប្រភេទស្វាយ ពណ៌លឿងទុំ។
- បរិមាណពាក្យថ្មី ផ្លែស្វាយទុំ ផ្អែម ពណ៌លឿងទុំ និងឃ្លា ផ្លែស្វាយទុំមានរសជាតិផ្អែម។
- វិធីសាស្ត្រ និងមធ្យោបាយ៖
  - កុមារសង្កេតដោយខ្លួនឯង គ្រូជួយពន្យល់បង្ហាញប្រាប់ និងបំផុសចម្ងល់របស់កុមារ
  - ប្រើសំណួរខ្លី ងាយយល់ និងឱ្យកុមារបានប៉ះ ស្ទាប កាន់ ហិត ភ្លក់...
  - ល្បែងពង្រឹង
  - ស្វាយទុំល្អ សម្ភារៈបង្រៀនជានាលក្ខណៈសោភ័ណ និងជាក់ស្តែង។

❖ **ការពង្រីកចរិតសកម្ម៖** ចរិតសកម្មរបស់កុមារ ស្តែងឡើងតាមបណ្តារូបភាពខាងក្រោម

- ប្រមូលផ្តុំបម្រុងប្រយ័ត្នក្នុងពេលសង្កេត
- ជំនក់ចិត្តរំភើបក្នុងពេលសង្កេត
- ការថ្នាំងថ្នាក់បង្ហាញឱ្យឃើញជានិច្ចក្នុងពេលសង្កត ទាមទារគ្រូឱ្យយកចិត្តទុកដាក់ជំរុញ និងលើកទឹកចិត្តកុមារជានិច្ច
- ខ្នះខ្នែងនិយាយពីប្រការដែលបានសង្កេត។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- **ការហាត់ពត់សមត្ថភាព៖** ចេះពីរបៀបសង្កេត ចេះគិត ចេះលេង ចេះសម្តែងឡើងយ៉ាងងាយស្រួលក្នុងម៉ោងសិក្សាវិទ្យាសាស្ត្រ។

ជារួម គោលការណ៍ទាំងនេះមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ និងកំណត់ឱ្យគ្នាទៅវិញទៅមក។ ដូច្នេះ គ្រូត្រូវយកចិត្តទុកដាក់ និងក្តាប់ឱ្យបានណែនាំនូវការអនុវត្តគោលការណ៍ជ្រើសរើសមុខសញ្ញា និងខ្លឹមសារឱ្យកុមារសង្កេត។

## ១.៤. ទស្សនៈ និងរបកគំហើញក្នុងបរិបទថ្មី

ខាងក្រោមនេះ គឺជាឧទាហរណ៍ដែលបង្ហាញពីសកម្មភាពការអនុវត្តកម្មវិធីសិក្សាគោលក្នុងប្រទេសមួយចំនួន។ កុមាររៀនបានល្អបំផុតនៅក្នុងបរិយាកាសដែលមានសុវត្ថិភាព និងអាចព្យាករណ៍ដឹងមុនបាន នៅពេលមានអារម្មណ៍ថាខ្លួនមានសុវត្ថិភាពនៅក្នុងបរិយាកាសរបស់ខ្លួនពួកគេកាន់តែយល់ដឹង និងទទួលបានបទពិសោធន៍រៀនសូត្រក៏ដូចជាចំណេះដឹងថ្មីៗ។ បរិយាកាសរៀនសូត្រដែលមានសុវត្ថិភាពសំដៅទៅលើបរិយាកាសទាំងឡាយណាដែលកុមារមិនទទួលរងការរំលោភបំពានជាពាក្យសំដីក្តី ឬជាការរំលោភបំពានរាងកាយក្តី ហើយជាបរិយាកាសដែលថ្នាក់រៀនមានវិជាន និងការរំពឹងទុកច្បាស់លាស់ប្រកបដោយសង្គតិភាពសកម្មភាពក្នុងថ្នាក់រៀន គោរពទៅតាមកាលវិភាគដែលកុមារអាចព្យាករណ៍ដឹងមុនបាន ហើយកុមារបានទទួលការក្រើនរំលឹកនៅពេលដែលពួកគេផ្លាស់ប្តូរពីសកម្មភាពមួយទៅសកម្មភាពមួយទៀត។

កុមាររៀនតាមរយៈការលេង កុមារអភិវឌ្ឍ និងហ្វឹកហាត់ជំនាញរបស់ខ្លួនតាមរយៈការលេង។ ដោយមានការគាំទ្រពីមនុស្សធំ កុមារអាចរៀនពីរបៀបរៀបចំផែនការសកម្មភាពសហការជាមួយនឹងអ្នកដទៃទៀត និងធ្វើសកម្មភាពនៅក្នុងពិភពលោករបស់ខ្លួន ហើយក្នុងពេលជាមួយគ្នាកុមារអាចលេងកម្សាន្តដោយម្ចាស់ការក៏ដូចជាលេងកម្សាន្តជាមួយនឹងមិត្តភក្តិរបស់ពួកគេ។ ការរៀនសូត្រកើតឡើងពីការទំនាក់ទំនងរបស់កុមារទទួលបានព័ត៌មានអំពីអារម្មណ៍របស់អ្នកដទៃ អំពីអ្វីដែលពួកគេចង់បាន ចូលចិត្ត និងមិនចូលចិត្ត និងអ្វីដែលសមស្រប ឬមិនសមស្រប នៅពេលដែលពួកគេប្រាស្រ័យទាក់ទងជាមួយនឹងមិត្តភក្តិ និងអ្នកនៅជុំវិញខ្លួនរបស់ពួកគេ។ តាមរយៈការប្រាស្រ័យទាក់ទងគ្នានៅក្នុងសង្គម កុមាររៀនពីសង្គម ដូចជា ការសម្តែងទឹកមុខ និងភាសាកាយវិការ ជាដើម។ ពួកគេក៏រៀនដឹងថា តើសកម្មភាពរបស់ពួកគេអាចនាំឱ្យមានប្រតិកម្មយ៉ាងដូចម្តេចខ្លះពីអ្នកដទៃ។

កុមារក៏រៀនដឹងពីអ្វីដែលត្រូវរំពឹងទុក ពីការប្រាស្រ័យទាក់ទងនៅក្នុងសង្គមទៅតាមបទពិសោធន៍នៃការប្រាស្រ័យទាក់ទងរបស់ពួកគេជាមួយនឹងអ្នកនៅជុំវិញខ្លួន និងជាមួយមិត្តភក្តិរបស់ពួកគេផងដែរ។ ការនិយាយ គឺជាការរៀនសូត្រ ការរៀនវាក្យសព្ទ (ពាក្យពេចន៍) តាមរយៈការស្តាប់ឮពាក្យដដែល ជាពិសេសពីមនុស្សធំ។ ការនិយាយជាមួយកុមារអំពីតម្រូវការ ការចង់បាន ការគិត និងអារម្មណ៍របស់ពួកគេ នឹងជួយឱ្យពួកគេដឹងពីអារម្មណ៍របស់ខ្លួន និងចេះប្រាស្រ័យទាក់ទងជាមួយអ្នកដទៃទៀត។ ឧទាហរណ៍៖ កុមាររៀនចេះតាមរយៈការស្វែងយល់ កុមារដឹងពីពិភពលោករបស់ខ្លួនតាមរយៈការប៉ះ ការយកវត្ថុអ្វីមួយមកបង្វិលមើលចុះមើលឡើង និងការពិសោធន៍ជាមួយនឹងវត្ថុនានា។ ការឱ្យកុមារចូលរួមក្នុងសកម្មភាពអ្វីមួយដោយឱ្យពួកគេប៉ះនឹងវត្ថុនានា ជួយឱ្យកុមាររៀនសូត្រពីទស្សនាទានថ្មីៗ។ ការហ្វឹកហាត់ជួយជំរុញការរៀនសូត្រក្នុងវ័យកុមារ

តូច បទពិសោធន៍របស់កុមារជាកត្តាសម្រេចការអភិវឌ្ឍខួរក្បាលរបស់ពួកគេ។ ការចូលរួមនៅក្នុងសកម្មភាពថ្មី ជួយនាំឱ្យមានការបង្កើតទំនាក់ទំនងថ្មីៗ បង្កើនភាពស្មុគស្មាញក្នុងខួរក្បាលរបស់កុមារ។

ទំនាក់ទំនងកោសិកានៅក្នុងខួរក្បាលរបស់កុមារដែលត្រូវបានប្រើប្រាស់ញឹកញាប់ និងកាន់តែរឹងមាំ ហើយជួយឱ្យកុមារធ្វើសកម្មភាពកាន់តែលឿន។ ទំនាក់ទំនងកោសិកាខួរក្បាលដែលមិនត្រូវប្រើនឹងស្លាប់ទៅវិញ។ ការផ្ដល់ឱកាសឱ្យកុមារហ្វឹកហាត់ជំនាញថ្មីៗ ឬដោះស្រាយបញ្ហាតាមរបៀបថ្មីៗ ជួយពង្រឹងតំណភ្ជាប់ទំនាក់ទំនងក្នុងខួរក្បាលដែលផ្ដល់ការគាំទ្រដល់សមត្ថភាពទាំងនេះ។ លើសពីនេះ កុមារកសាងទំនុកចិត្តលើខ្លួនឯង និងមានគំនិតវិជ្ជមានពីខ្លួនឯង នៅពេលដែលពួកគេចេះស្ទាត់នូវជំនាញថ្មីៗ និងយកជំនាញថ្មីៗទាំងនេះទៅអនុវត្ត។ នៅពេលដែលកុមារស្ទាត់នឹងជំនាញថ្មីៗ អ្វីមួយ សូមផ្ដល់ឱកាសឱ្យពួកគេបានហ្វឹកហាត់សមត្ថភាពឱ្យកាន់តែមានលក្ខណៈស្មុគស្មាញ។ សកម្មភាពនានា ដែលបង្ហាញក្នុងឯកសារជំនួយស្មារតីនេះរៀបរាប់ពីសកម្មភាពនៅកម្រិតទាប កម្រិតមធ្យម និងកម្រិតខ្ពស់ ដោយបង្ហាញពីឧទាហរណ៍អំពីរបៀបធ្វើឱ្យសកម្មភាពនេះកាន់តែពិបាកទៅៗ នៅពេលដែលកុមារកាន់តែមានភាពស្ទាត់ជំនាញ។ ការហ្វឹកហាត់មិនមែនគ្រាន់តែជាការធ្វើសកម្មភាពអ្វីមួយដដែលៗ នោះទេ ក៏ប៉ុន្តែជាការធ្វើសកម្មភាពដោយមានគោលដៅកំណត់ច្បាស់លាស់ និងត្រូវអមដោយការឆ្លុះបញ្ចាំងលើដំណើរការដែលប្រើប្រាស់សម្រាប់ធ្វើការដោះស្រាយបញ្ហា។

តួនាទីនៃការជួយជ្រោមជ្រែងរបស់មនុស្សធំដល់ការរៀនសូត្ររបស់កុមារកាន់តែមានភាពពាក់ព័ន្ធ គឺជាន័យធៀបសំដៅទៅលើរបៀបដែលមនុស្សពេញវ័យផ្ដល់ការគាំទ្រ និងការណែនាំដល់កុមារឱ្យចេះយកសមត្ថភាព និងអ្វីដែលពួកគេចាប់អារម្មណ៍យកទៅប្រើប្រាស់សម្រាប់ដោះស្រាយបញ្ហាថ្មីៗ បន្ថែមទៀត។ ខណៈពេលដែលពួកគេកំពុងរៀនសូត្រពីមនុស្សធំ និងបរិស្ថានដែលនៅជុំវិញពួកគេ។ ការជួយជ្រោមជ្រែងនេះរួមមាន ការសួរសំណួរដើម្បីពង្រីកវិសាលភាពនៃការគិតរបស់កុមារ ការស្នើឱ្យកុមារប្រើប្រាស់វិធីសាស្ត្រផ្សេងៗ សម្រាប់ដោះស្រាយបញ្ហា ការលើកទឹកចិត្តឱ្យកុមារធ្វើការដោះស្រាយបញ្ហា ប្រើប្រាស់ធនធានប្រកបដោយលក្ខណៈច្នៃប្រឌិត និងបង្ហាញពីការប្រើប្រាស់ឧបករណ៍សម្ភារៈនានា។ ទ្រឹស្តីស្តីពីការជួយជ្រោមជ្រែង ត្រូវបានស្នើឡើងដោយលោក ថេរ៉ូមី ប៊ូស៊ី ក្នុងឆ្នាំ១៩៧៦ ជាផ្នែកមួយនៃទ្រឹស្តីស្ថាបនានិយមនៃសង្គម (Social Constructivist, Theory) ដែលទទួលរងឥទ្ធិពលជាពិសេសពីស្នាដៃនិពន្ធរបស់ចិត្តវិទូជនជាតិរុស្សីឈ្មោះ Vygotsky។ Vygotsky អះអាងថាយើងរៀនសូត្របានល្អបំផុតនៅក្នុងបរិយាកាសសង្គមដែលយើងបង្កើតនូវអត្ថន័យតាមរយៈការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដទៃទៀត។

ទ្រឹស្តីដែលបង្ហាញអំពីផ្នែកអភិវឌ្ឍន៍ល្អបំផុតរបស់មនុស្ស (Zone of Proximal Development Theory) ដែលបង្ហាញថាយើងរៀនកាន់តែចេះ នៅពេលដែលយើងនៅជាមួយមនុស្សផ្សេងទៀត ដែលមានចំណេះដឹងច្រើនជាងយើង បានក្លាយទៅជាគំរូមួយសម្រាប់ម៉ូដែលរបស់លោក ប្រ៊ូណឺ។ លោក ប្រ៊ូណឺ ជឿថានៅពេលដែលកុមារចាប់ផ្ដើមរៀនទស្សនាទានថ្មី ពួកគេត្រូវការឱ្យគេ និងមនុស្សធំផ្សេងទៀត ជួយក្នុងរូបភាពជាការគាំទ្របែបសកម្ម។ នៅពេលចាប់ផ្ដើមដំបូង ពួកគេពឹងផ្អែកលើការជួយគាំទ្ររបស់មនុស្សធំ ប៉ុន្តែនៅពេលដែលពួកគេកាន់តែមានភាពម្ចាស់ការនៅក្នុងការគិតរបស់ពួកគេ និងនៅពេលដែលពួកគេទទួលបានជំនាញ និងចំណេះដឹងថ្មីៗ ការគាំទ្ររបស់មនុស្សធំអាចដកចេញជាបណ្ដើរៗ បាន។ អន្តរកម្មដែលមានការរៀបចំត្រឹមត្រូវរវាងកុមារ និងមនុស្សធំបែបនេះ គឺប្រៀបដូចជាការដាក់រន្ទាលសម្រាប់ជួយដល់ការសាងសង់



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

អគារណាមួយ។ រន្ធាលនេះនឹងត្រូវបានគេដកចេញជាបណ្តើរៗ នៅពេលដែលការងារសំណង់ត្រូវបានបញ្ចប់។ ឱ្យកុមារម្នាក់ៗ អភិវឌ្ឍទៅតាមល្បឿនផ្ទាល់ខ្លួនរបស់ពួកគេ នូវអ្វីដែលពួកគេរំពឹងទុកថាកុមារអាយុពី ៣ ទៅ ៥ឆ្នាំ នឹងអភិវឌ្ឍសមត្ថភាពរៀនសូត្ររបស់កុមារម្នាក់ៗ និងអភិវឌ្ឍសមត្ថភាពទៅតាមល្បឿនផ្ទាល់ខ្លួនរបស់ពួកគេ។

សកម្មភាពនៅក្នុងឯកសារជំនួយស្មារតីនេះ ត្រូវបានបែងចែកជាកម្រិតមូលដ្ឋាន កម្រិតមធ្យម និងកម្រិតខ្ពស់ ដែលជួយអាចយកសកម្មភាពទាំងនេះទៅធ្វើការកែសម្រួល នៅពេលដែលកុមារចេះស្ទាត់ជំនាញនូវសមត្ថភាពអ្វីមួយ។ ដើម្បីកុមាររៀនសូត្របានល្អក្នុងសាលារៀន និងដើម្បីឱ្យពួកគេចេះចុះសម្រុងជាមួយនឹងកុមារដទៃទៀត។ កុមារតូចត្រូវតែចេះអភិវឌ្ឍបំណិនរៀន សូត្រចិត្តសង្គម។ គ្រូអាចរៀបចំបរិយាកាសរៀនសូត្រទៅតាមបែបផែនដែលជួយដល់ការរៀនសូត្រចិត្តសង្គម និងជួយកុមារចេះសម្គាល់ដឹងពីអារម្មណ៍របស់ខ្លួន ចេះកសាងទំនាក់ទំនងបានល្អជាមួយអ្នកដទៃទៀត ចេះដោះស្រាយចំណោទបញ្ហាប្រកបដោយប្រសិទ្ធភាព និងធ្វើការសម្រេចចិត្តប្រកបដោយការទទួលខុសត្រូវ។

## ១.៥. អន្តរបញ្ញត្តិសម្រាប់កុមារ

ក្នុងកំឡុងឆ្នាំ ១៩៩៤ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំកម្រងអត្ថបទមត្តេយ្យសិក្សាដោយនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងមត្តេយ្យសិក្សា ដែលបានបោះពុម្ពផ្សព្វផ្សាយឱ្យប្រើប្រាស់នៅឆ្នាំ ១៩៨៣។ សកម្មភាពទាំងនោះមានគោលបំណងចង់ឱ្យកុមារតូចស្គាល់ជាជំហានដំបូង គឺអំពីបរិស្ថានរស់នៅដំបូងដែលកុមារជួបប្រទះ សមស្របតាមកម្រិតអាយុ ហើយអាចយកការយល់ដឹងទៅប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃបានផង និងធ្វើជាគ្រឹះសម្រាប់បន្តការសិក្សានៅភូមិសិក្សាបន្ទាប់ទៀត។

នៅក្នុងឆ្នាំ ១៩៩៤ ក្រសួងអប់រំ យុវជន និងកីឡា បានបោះពុម្ពផ្សព្វផ្សាយសៀវភៅជាបន្តបន្ទាប់។ នៅឆ្នាំ២០១៥ ក្រសួងអប់រំ យុវជន និងកីឡា បានបោះពុម្ពផ្សព្វផ្សាយសៀវភៅគុកោសល្យបរិស្ថានសម្រាប់មត្តេយ្យសិក្សាចំនួន ២ភាគ ជាស្នាដៃនិពន្ធ និងរៀបរៀងរបស់នាយកដ្ឋានអប់រំកុមារតូច សហការជាមួយអង្គការកុមារកម្ពុជា ENFANTS DE CAMBODGE ដែលបានជួយឧបត្ថម្ភសម្ភារៈ បច្ចេកទេស និងទទួលបានបច្ចេកទេសពីអ្នកគ្រូៗ នៅតាមសាលាដែលបានផ្តល់អត្ថបទអំពីបរិដ្ឋាន ដោយមានការជួយឧបត្ថម្ភក្នុងការបោះពុម្ពជាបន្តបន្ទាប់។ ក្នុងឆ្នាំ១៩៩៥ ដោយអង្គការ UNICEF (unite for children) ដើម្បីប្រើប្រាស់នៅតាមសាលា និងថ្នាក់មត្តេយ្យសិក្សាទូទាំងប្រទេសកម្ពុជាដែលមានគោលបំណងនាំកុមារៈ

- ស្វែងយល់ ដកពិសោធន៍ និងសិក្សាអំពីអ្វីៗ ដែលនៅជុំវិញខ្លួនគេ។ កុមារចង់ស្គាល់ ចង់ដឹង កុមារពិនិត្យសង្កេត ត្រិះរិះពិចារណា និងសួរសំនួរផ្សេងៗ។
- ការប្រើប្រាស់បរិស្ថានដែលជាឧបករណ៍គុកោសល្យ គឺជាមធ្យោបាយមួយដ៏ល្អប្រសើរសម្រាប់ជួយកុមារឱ្យសិក្សាដោយប្រើការសង្កេត ឱ្យកុមារមានការអភិវឌ្ឍន៍នៅលើចំណេះដឹង និងចំណង់របស់គេ។ អ្នកគ្រូត្រូវបានលើកទឹកចិត្តឱ្យចេញធ្វើការទស្សនាសង្កេតនៅក្រៅថ្នាក់ជាមួយកុមារ ដើម្បីស្វែងយល់ និងសង្កេតអំពីភាពសំបូរបែបដែលមាននៅជុំវិញខ្លួន ដូចជា ធម្មជាតិ (រុក្ខជាតិ ដំណាំផ្សេងៗ) បាតុភូតធម្មជាតិ (ភ្លៀង រន្ទះ ផ្លេកបន្ទោរ...) បាតុភូតសង្គម (ពិធីបុណ្យផ្សេងៗ

អាពាហ៍ពិពាហ៍) មធ្យោបាយដឹកជញ្ជូន ( តាម ផ្លូវទឹក ផ្លូវអាកាស ផ្លូវគោក...) សម្ភារៈ និងឧបករណ៍សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ។

- អ្នកគ្រូត្រូវបានលើកទឹកចិត្តឱ្យជួបជាមួយអ្នកសិល្បករ សិប្បករ... ដើម្បីឱ្យគាត់បកស្រាយឱ្យកុមារបានយល់អំពីមុខរបរនេះ។ ដូចនេះ ការចេញទស្សនាសង្កេតអាចជួយបង្កើនទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងសហគមន៍ និងកុមារ ព្រមទាំងបញ្ចូលមនុស្សចាស់ឱ្យរួមចំណែកក្នុងការអប់រំកុមារ។

## ១.៦. អន្តរាគមន៍គ្រប់ជ្រុងជ្រោយ

ការសិក្សារៀនសូត្ររបស់កុមារបានចាប់ផ្ដើមឡើងពីការប្រាប់ញ្ញាណទាំង៥ ទើបអាចបង្កើត និងបកស្រាយបានពីសកម្មភាពសម្បូរបែប សម្រាប់ជំរុញលើកទឹកចិត្តកុមារឱ្យប្រើប្រាស់វិញ្ញាណទាំងអស់បានល្អ និងសមស្របតាមវ័យរបស់កុមារ ស្មារតីក្លាហាន ឈ្លាសវៃ រហ័សរហួន ហ្មត់ចត់ និងអំណត់ក្នុងការនាំកុមារប្រើប្រាស់វិញ្ញាណទាំង៥ ជាជំនួយយ៉ាងសំខាន់ដល់កុមារក្នុងការពិចារណានូវគំនិតប្រតិកម្មនៃអារម្មណ៍ ដែលទទួលបានពីមជ្ឈដ្ឋានជុំវិញ។

ដើម្បីឱ្យកុមារយល់ និងមានចំណេះដឹងកាន់តែទូលាយពីអ្វីដែលនៅជុំវិញខ្លួន តាមរយៈការប្រើប្រាស់វិញ្ញាណដែលជាមូលដ្ឋានគ្រឹះ គ្រូត្រូវធ្វើយ៉ាងណាឱ្យកុមារចាប់អារម្មណ៍ ហើយទុកឱកាសឱ្យកុមារបានប្រើប្រាស់វិញ្ញាណទាំង៥ ព្រមជាមួយការជំរុញលើកទឹកចិត្តកុមារឱ្យហ៊ានឆ្លើយបញ្ជាក់ពីលទ្ធផលដែលបានទទួលពីញាណទាំងឡាយរបស់ខ្លួន។ វិញ្ញាណរួមមាន ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ និងកាយិន្ទ្រិយ៖

❖ ចក្ខុន្ទ្រិយ៖ គឺភ្នែកដែលផ្ដល់ឱ្យយើងមើលឃើញនូវពណ៌ ទម្រង់ផ្សេងៗ ទំហំនៃវត្ថុ។ល។ ដូចនេះពេលសិក្សាវិទ្យាសាស្ត្រ គ្រូត្រូវបង្កលក្ខណៈឱ្យកុមារបានឃើញជាក់ស្ដែងនឹងភ្នែក គឺជាការប្រសើរបំផុត ព្រោះការឃើញនឹងភ្នែកធ្វើឱ្យកុមារឆាប់ចាប់អារម្មណ៍ ងាយយល់ ងាយស្គាល់នូវពណ៌ រាងលក្ខណៈរូបធាតុរបស់មនុស្ស សត្វ វត្ថុ រុក្ខជាតិ។ល។ ចេះប្រៀបធៀប ស្គាល់ពីល័ក្ខខ័ណ្ឌ និងជីវភាពរស់នៅក្នុងសង្គម ស្គាល់ពីបាតុភូតធម្មជាតិ បាតុភូតសង្គម ។ ទន្ទឹមនឹងនេះ គ្រូត្រូវជួយពន្យល់បន្ថែមដើម្បីឱ្យកុមារងាយយល់ យល់បានត្រឹមត្រូវ និងមានគោលដៅច្បាស់លាស់។

ឧទាហរណ៍៖

- គ្រូដាក់កូនបាល់នៅលើផ្ទៃរាបរួចឱ្យកុមារសង្កេត រូបរាង ពណ៌ និងចលនា របស់កូនបាល់ រាងមូល ពណ៌ លឿង... នៅនឹងមួយកន្លែង គ្មានចលនា។
- សង្កេតពណ៌ស្លឹកឈើ អាចឱ្យកុមារដឹងថា ស្លឹកឈើខ្ចី ចាស់ ឬទុំ ទាំងនេះគឺជាការខុសប្លែកគ្នារវាងសណ្ឋាន និងសភាពដែលកុមារមើលឃើញ និងចាប់អារម្មណ៍។

❖ សោតិន្ទ្រិយ៖ សោតិន្ទ្រីយ៍ គឺត្រចៀកដែលផ្ដល់ឱ្យយើងដឹងនូវសំឡេង។ ទារកកើតមកបានអាយុ៣ខែ អាចស្ដាប់ចម្រៀងម្ដាយបំពេរ និងស្គាល់យ៉ាងច្បាស់នូវសំឡេងឪពុកម្ដាយ ឬជីដូនជីតា ដែលនៅក្បែររាល់ថ្ងៃ។ ដូចនេះ ការហ្វឹកហាត់ ទម្លាប់កុមារឱ្យចេះស្ដាប់ពីលក្ខណៈខុសគ្នារវាងសំឡេងពីរ គឺសំឡេងធម្មជាតិ និងសំឡេងមិនធម្មជាតិដូចខាងក្រោម៖

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### សំឡេងធម្មជាតិ

- សំឡេងស្លឹកឈើត្រូវខ្យល់បក់
- សំឡេងទឹកជ្រោះធ្លាក់
- សំឡេងទឹកហូរ
- សំឡេងទឹកភ្លៀងធ្លាក់លើដំបូលផ្ទះ
- សំឡេងសត្វចាបយំ
- សំឡេងសត្វក្អែកបូល ។ល។

### សំឡេងមិនធម្មជាតិ

- សំឡេងសត្វត្រសេកចោះដើមឈើ
- សំឡេងទឹកពុះ
- សំឡេងទម្លាក់គ្រាប់ឃ្លី ឬទម្លាក់វត្ថុផ្សេងៗ
- សំឡេងរលាស់ក្រដាស
- សំឡេងយន្តហោះ ម៉ូតូ រថយន្ត
- ស្នូរទះដៃ
- ទំនុកច្រៀង។ល។

សំឡេងទាំងនេះ ជួយកុមារឱ្យចាប់អារម្មណ៍ និងដឹងថាជាសំឡេងអ្វី? ជាសំឡេងរបស់អ្នកណា? ដើម្បីឱ្យកុមារស្ទាត់ជំនាញក្នុងការស្ដាប់ គ្រូត្រូវស្រាវជ្រាវសំឡេងឱ្យបានច្រើនដោយដកស្រង់ចេញពីកំណាព្យ ទំនុកភ្លេង រឿងនិទាន និងបង្ហាត់បង្រៀនឱ្យកុមារចេះស្ដាប់ ចេះសូត្រកំណាព្យ ច្រៀងចម្រៀង ធ្វើសំឡេងតាមទំនុកភ្លេង ត្រាប់តាមតួអង្គក្នុងរឿង ដូចជា ត្រាប់តាមសំឡេងយក្ស តួអង្គស្លូត ឬកាច សត្វ។ ទន្ទឹមនឹងនេះគ្រូត្រូវចេះលើកទឹកចិត្តកុមារ និងជួយកុមារឱ្យមានជំនឿចិត្តលើខ្លួនឯង ដើម្បីបញ្ចេញយោបល់អំពីប្រភេទសូរសំឡេងទាំងនោះដែលគេបានឮ និងបានចាំ ។

- ❖ **ឃានិន្ទ្រិយៈ** គឺច្រមុះដែលធ្វើឱ្យកុមារស្គាល់ និងដឹងនូវក្លិនផ្សេងៗ។ ដូចនេះ កុមារអាចវិនិច្ឆ័យក្លិនប្លែកៗគ្នា ដែលគេធ្លាប់ស្គាល់ពីមុន និងក្លិនថ្មីៗ ហើយគេមានអារម្មណ៍សប្បាយ ឬមិនសប្បាយទៅតាមចំណូលចិត្ត។

ឧទាហរណ៍៖

- កុមារហិតក្លិនផ្កាផ្កា ឬក្លិនទឹកអប់ «ក្រអូប ធ្វើឱ្យកុមារសប្បាយចិត្ត»
- កុមារហិតក្លិនម្ហូប «ក្លិនឈ្ងុយនៃម្ហូប ធ្វើឱ្យកុមារឃ្លាន ចង់ញ៉ាំ»
- កុមារហិតក្លិនប្រេងសាំង ឬថ្នាំស្អុយ «ក្លិនមិនល្អ ធ្វើឱ្យកុមារពុំសប្បាយចិត្ត»

ទន្ទឹមនឹងនេះ គ្រូត្រូវប្រើសំណួរដើម្បីជួយដល់ការយល់ដឹងរបស់កុមារ ឆ្ពោះទៅរកប្រភេទនៃក្លិន។

ឧទាហរណ៍៖

- តើកូនមានធំក្លិនអ្វីទេ?
- តើក្លិននោះចេញមកពីកន្លែងណា?

- ក្លិននោះជាក្លិនអ្វី?
- តាមរយៈក្លិននេះ តើកូនណាទៅយករបស់នោះបាន?

❖ ជិវ្ហិន្ទ្រិយ៖ គឺអណ្តាតដែលធ្វើឱ្យយើងស្គាល់នូវរសជាតិផ្សេងៗ ។ ដូចនេះ កុមារមុននឹងឆ្លើយថា ផ្អែម ប្រៃ ជូរ ចត់ ល្វីង... បានលុះត្រាតែគេបានភ្លក់រសជាតិរបស់ទាំងនោះសិន។ ការភ្លក់នូវអ្វីដែលអាចបរិភោគបានជាប្រការសំខាន់ក្នុងការទាក់ទាញចំណង់ចំណូលចិត្តកុមារ ឱ្យប្រមូលបម្រុងប្រយ័ត្នក្នុងពេលសង្កេត។ កុមារខ្លះអាចដឹងថាចំណីអាហារដែលញ៉ាំនោះចត់ តែវាមិនអាចនិយាយថាចត់បានទេ វាគ្រាន់តែសម្តែងអាការៈបង្ហាញថាចត់ប៉ុណ្ណោះ។ ហេតុនេះ ត្រូវមានជំនួយពីមនុស្សធំប្រាប់គេថា «ចត់» និងផ្តល់បទពិសោធន៍ឱ្យកុមារដោយយករបស់ដែលមានរសជាតិចត់ដូចគ្នាឱ្យកុមារភ្លក់ ដើម្បីឱ្យកុមារប្រមូលអារម្មណ៍រកនឹកអំពីឈ្មោះនៃរសជាតិអាហារនោះ។

❖ កាយិន្ទ្រិយ៖ គឺជាស្បែកគ្របដណ្តប់សារពាង្គកាយ ធ្វើឱ្យយើងដឹងពីការឈឺចាប់ ក្តៅ ត្រជាក់... ដោយសារការប៉ះពាល់អ្វីៗ ដែលមាននៅជុំវិញខ្លួន ដូចជា អាកាសធាតុ វត្ថុ សត្វ រុក្ខជាតិ ជាដើម។ ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ កុមារតែងមានប្រតិកម្មតបទៅនឹងការទទួលអារម្មណ៍ពីអ្វីដែលគេបានប៉ះស្ទាប ប៉ុន្តែគេមិនចេះប្រាប់ពីអារម្មណ៍ទាំងអស់នោះទេ ។

ឧទាហរណ៍៖

- កុមារយកដៃប៉ះទឹកកក គេដឹងថាត្រជាក់
- ពេលរត់ដួល ឬប៉ះនឹងវត្ថុរឹង គេដឹងថាឈឺ
- កុមារយកដៃកាន់សរសៃសក់ រោមសត្វ ឬសំឡី គេដឹងថាទន់
- កុមារយកដៃស្ទាបវត្ថុនៅក្នុងថង់បិទជិត គេអាចដឹងអំពីលក្ខណៈនៃវត្ថុដូចជា ទ្រង់ទ្រាយ ទំហំ រឹង ឬ ទន់ រលោង ឬ គគ្រាត និងពេលខ្លះកុមារអាចហៅឈ្មោះវត្ថុនោះបាន។

រួមសេចក្តីមក ការទម្លាប់ឱ្យកុមារប្រើវិញ្ញាណទាំង៥ បានត្រឹមត្រូវ ជាមធ្យោបាយជួយកុមារឱ្យមានការអភិវឌ្ឍរូបរាងកាយ បញ្ញា អារម្មណ៍ ភាសានិយាយ និងទំនាក់ទំនងសង្គមបានល្អប្រសើរ។ ដូចនេះ គ្រូមត្តេយ្យសិក្សា និងអ្នកពាក់ព័ន្ធ ចាំបាច់ត្រូវយកចិត្តទុកដាក់ដល់ការជំរុញកុមារឱ្យប្រើវិញ្ញាណទាំង៥ យ៉ាងសកម្មក្នុងពេលបង្រៀន និងរៀន។

## ១.៧. អន្តរកម្មគ្រប់ជ្រុងជ្រោយសម្រាប់កុមារ

អន្តរកម្មនៃការសិក្សាប្រកបដោយគុណភាព កុមារនឹងទទួលបានចំណេះដឹង បំណិន និងឥរិយាបថថ្មីៗបន្ថែមទៀត ពីបរិយាកាសសិក្សារបស់ខ្លួន។ កុមារធ្វើអន្តរកម្មជាមួយពិភពលោក កុមារត្រូវប្រឈមមុខនឹងបញ្ហាសង្គម និងបុគ្គល ដែលបញ្ហាទាំងអស់នោះ ត្រូវបានភ្ញោចកុមារឱ្យចេះប្រើប្រាស់នូវបញ្ញារបស់ពួកគេដើម្បីដោះស្រាយបញ្ហាទាំងនោះ។ កុមារត្រូវការចង់ចេះ ចង់ដឹង និងស្វែងយល់ពីហេតុនិងផល ហេតុនេះជាកត្តាចាំបាច់ដែលត្រូវឱ្យកុមារចូលរៀននៅថ្នាក់មត្តេយ្យសិក្សា ដើម្បីភ្ញោចបញ្ញារបស់ពួកគេឱ្យមានការលូតលាស់ព្រមទាំងត្រូវសិក្សាពីមុខវិជ្ជាជាច្រើន ដើម្បីជាគ្រឹះទៅសិក្សានៅមុខវិជ្ជាផ្សេងៗ ទៀតនៅបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា ដែលចាំបាច់ត្រូវមានការគាំទ្រ និងត្រូវមានការអនុវត្តជាក់ស្តែងប្រកប

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដោយប្រសិទ្ធភាព។ ដើម្បីឱ្យកុមារមានសមត្ថភាពពេញលេញ និងគ្រប់ជ្រុងជ្រោយលើការអភិវឌ្ឍផ្នែកទាំង៥ គឺការអភិវឌ្ឍលើផ្នែករាងកាយនិងសុខភាព ការអភិវឌ្ឍផ្នែកវប្បធម៌និងសីលធម៌ ការអភិវឌ្ឍផ្នែកសង្គមនិងអារម្មណ៍ ការអភិវឌ្ឍផ្នែកពិចារណានិងការយល់ដឹង និងការអភិវឌ្ឍផ្នែកភាសា ដែលត្រូវការអន្តរាគមន៍គ្រួសារ សាលារៀន គ្រូមត្តេយ្យសិក្សា សហគមន៍ និងរដ្ឋអំណាចដើម្បីធានាគុណភាព និងប្រសិទ្ធភាព។

# ជំពូក២
# គោលដៅសិក្សា នៃមុខវិជ្ជា
# វិទ្យាសាស្ត្រ

youtube.com/moeyscambodia
sala.moeys.gov.kh
t.me/moeysnews

## ជំពូក២ គោលដៅសិក្សា នៃមុខវិជ្ជាវិទ្យាសាស្ត្រ

### ២.១. ក្របខណ្ឌអភិវឌ្ឍសមត្ថភាព

កុមារមានការអភិវឌ្ឍន៍ផ្នែកកាយសម្បទា វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ ការអភិវឌ្ឍចំណេះដឹង និងជំនាញ ជាចំណុចចាប់ផ្តើមនៃការទទួលយករបស់កុមារមុននឹងមានការប្រែប្រួលផ្នែកកាយសម្បទា និងចរិយាសម្បទា។ បំណិនជាច្រើនរបស់កុមារ ដូចជា បំណិនដោះស្រាយបញ្ហា អន្តរបុគ្គល ទំនាក់ទំនង និងបរិស្ថាន ជាដើម ត្រូវបានដាក់បញ្ចូលសមស្របតាមការអភិវឌ្ឍរូបរាងកាយ អាយុ និងវប្បធម៌របស់កុមារ។ កុមាររៀនចេះសម្របខ្លួនទៅនឹងបរិស្ថានធម្មជាតិ និងសង្គម ចង់ចេះ ចង់ដឹង ចង់ស្គាល់ ចង់យល់ ចង់ធ្វើឱ្យបានដូចអ្នកដទៃ និងមនុស្សធំ ចង់បង្ហាញអំពីអ្វីដែលជាទីមោទកភាព (ស្នាដៃ) របស់ខ្លួន លទ្ធភាពនៃការអភិវឌ្ឍន៍សមត្ថភាពរបស់កុមារក្នុងការសិក្សាមាន៖

- ទទួលចំណេះដឹងបានទូលំទូលាយ និងមានលក្ខណៈជាប្រព័ន្ធ
- ប្រើវិញ្ញាណទាំង៥ (កាន់ ស្ទាប ហិត ស្តាប់ ភ្លក់) ក្នុងការអនុវត្ត
- មានសមត្ថភាពក្នុងការគិត ប្រៀបធៀប វិភាគងាយៗ
- មានការប្រុងប្រយ័ត្នលើគ្រប់វិស័យ និងរីកចម្រើនចលនា
- មានការអភិវឌ្ឍពាក្យកាន់តែសម្បូរបែប
- មានការអភិវឌ្ឍផ្នែកមនោសញ្ចេតនា សីលធម៌ សោភ័ណ និងសង្គម
- យល់បានត្រឹមត្រូវ និងស៊ីជម្រៅលើប្រធានបទសង្កេត
- ពង្រីកចរិតសកម្ម និងប្រមូលផ្តុំបម្រុងប្រយ័ត្នក្នុងពេលសង្កេត
- មានប្រត្យក្សារម្មណ៍ដើម្បីសម្រេចវត្ថុបំណង
- ចេះសង្កេត ពិនិត្យ ប្រៀបធៀប យល់បាន និងអាចនិយាយឆ្លើយឆ្លងពីអ្វីដែលបានសង្កេត
- មានការអភិវឌ្ឍពាក្យកាន់តែសម្បូរបែប និងចេះនិយាយឆ្លើយឆ្លងបានល្អ
- ជួយកុមារឱ្យមានរំញោច មានការជក់ចិត្តចង់រៀនសូត
- ជួយកុមារឱ្យភ្ជាប់បាន និងចងចាំបានយូរ ពោលគឺចំណេះដឹងនេះត្រូវបានរំលឹក និងពង្រឹងឡើងវិញ រួមចំណែកយ៉ាងសំខាន់ក្នុងការពង្រីកពុទ្ធិ និងភាសារបស់កុមារ
- ហ្វឹកហាត់សមត្ថភាព បម្រុងប្រយ័ត្ន លំនឹក អាកប្បកិរិយា និងភាពរហ័សរហួនរបស់កុមារ។

### ២.២. ការផ្សារភ្ជាប់ទៅនឹងវិទ្យាសាស្ត្រ

កុមារកសាងសមត្ថភាពបានប្រសើរអាស្រ័យលើចំណង់ចំណូលចិត្ត ការព្យាយាមពេញចិត្តពីមជ្ឈដ្ឋានជុំវិញ និងបរិយាកាសសិក្សាអំណោយផលល្អដូចជា៖

- ផ្តល់ដល់កុមារនូវចំណេះដឹងវិទ្យាសាស្ត្រពិតប្រាកដ សមស្របតាមវិទ្យាសាស្ត្រទំនើប
- ផ្តល់ចំណេះដឹងដោយមានវិធីសាស្ត្រសមស្រប
- ទម្លាប់សិស្សឱ្យចេះត្រិះរិះពិចារណាលើគ្រប់ហេតុការណ៍ដោយចេះសិក្សាស្រាវជ្រាវបានត្រឹមត្រូវ។

ការអនុវត្តគោលការណ៍នេះ ក្នុងលំនាំនៃការបង្រៀនគ្រូត្រូវៈ

- ផ្ដល់ដល់សិស្សនៅសញ្ញាណវិទ្យាសាស្ត្រជាមូលដ្ឋាន ដូចជា ទ្រឹស្ដី ទស្សនៈដែលមានជាក់ស្ដែង និងសត្យានុម័ត
- ផ្ដល់ខ្លឹមសារបង្រៀនដែលឆ្លុះបញ្ចាំងពីវប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស សមស្របតាមការអភិវឌ្ឍរបស់ប្រទេសជាតិ និងពិភពលោក
- បកស្រាយចំណេះដឹងវិទ្យាសាស្ត្រមានលក្ខណៈជាប្រព័ន្ធ ដែលមានទំនាក់ទំនងគ្នាយ៉ាងជិតស្និតបំផុត
- ចេះចម្រាញ់ជ្រើសរើសយកចំណេះដឹងចាំបាច់ និងពីមូលដ្ឋានមកបង្រៀនសិស្ស ព្រោះបច្ចុប្បន្នចំណេះដឹង វិទ្យាសាស្ត្រទូលំទូលាយណាស់។ សិស្សមិនអាចទទួលយកបានទាំងអស់ក្នុងរយៈពេលមួយដ៏ខ្លីបានឡើយ។ ទន្ទឹមនឹងនេះ ក្នុងការបង្រៀនត្រូវបន្ថយការធ្វើអត្ថាធិប្បាយ ពន្យល់ បកស្រាយឱ្យបានតិចបំផុត ត្រូវទុកឱកាសឱ្យសិស្សគិត ពិចារណា និងអនុវត្តឱ្យបានច្រើន។
- ជ្រើសរើសខ្លឹមសារបង្រៀនឱ្យមានលក្ខណៈជាប្រព័ន្ធពីងាយទៅលំបាក ហើយពេលបង្រៀនត្រូវចេះផ្សារភ្ជាប់ចំណេះមានស្រាប់ទៅនឹងចំណេះដឹងថ្មីតាមមុខវិជ្ជានីមួយៗ។ ទន្ទឹមនឹងនេះត្រូវចេះផ្សារភ្ជាប់ខ្លឹមសារចំណេះដឹងតាមមុខវិជ្ជានីមួយៗ ក្នុងនោះមុខវិជ្ជាវិទ្យាសាស្ត្រនៅមត្តេយ្យសិក្សា មានប្រធានបទជាច្រើនដែលគ្រូ និងកុមារ ត្រូវអនុវត្តរួមគ្នាមាន៖ សង្កេត ថែទាំដំណាំ និងការចិញ្ចឹមសត្វ យល់ដឹងអាកាសធាតុ( ឧតុនិយម ) បង្ហាត់បង្រៀនកុមារឱ្យយល់ដឹងស្គាល់ពីការប្រែប្រួលអាកាសធាតុ ដូចជា ភ្លៀង រាំង ខ្យល់ មេឃខ្មៅ មានពពកច្រើន។ល។
    - ឧទាហរណ៍៖ នាំកុមារសង្កេតផ្ទៃមេឃមានពពក ផ្ទៃស្រឡះ អាកាសធាតុក្ដៅ...។ កត់ត្រាសីតុណ្ហភាព នាំកុមារពិនិត្យ និងចំណាំការប្រែប្រួលកម្ដៅ។ ពិនិត្យប្រដាប់វាស់កម្ដៅ (Temperature) វត្ថុត្រជាក់ ក្ដៅឧណ្ហៗ និងក្ដៅខ្លាំង។
    - កត់ត្រាកម្ពស់ទឹកភ្លៀង គ្រូបង្កលក្ខណៈឱ្យកុមារពិនិត្យ និងកត់ត្រាកម្ពស់បរិមាណទឹកភ្លៀងដែលនៅក្នុងធុង ពាង កាធុន។ល។ ឧទាហរណ៍៖ ភ្លៀងខ្លាំង និងមានរយៈពេលយូរធ្វើឱ្យពាង ឬធុងដែលត្រងទឹកឆាប់ពេញ ឬមានទឹកដក់ច្រើន លើផ្លូវ លើទីធ្លា។ល។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ២.៣. លទ្ធផលរំពឹងទុកនៃមុខវិជ្ជាវិទ្យាសាស្ត្រ

### ២.៣.១. ប្រធានបទ អាហារូបត្ថម្ភ

| ខ្លឹមសារ | លទ្ធផលរំពឹងទុក |
|---|---|
| ចំណេះដឹងមូលដ្ឋានអំពីក្រុមអាហារ និងអាហារូបត្ថម្ភ | • ប្រាប់បានពីឈ្មោះបន្លែ ផ្លែឈើ សាច់ អាហារ ៣ក្រុម និងសារប្រយោជន៍ការញ៉ាំអាហារផ្សេងៗ បន្លែ ផ្លែឈើ និងសាច់<br>• ញែកបានពីអាហារ ៣ក្រុម ដែលមាន ក្រុមអាហារការពារ ក្រុមអាហារសាងសង់ ក្រុមអាហារថាមពល អាហារមានគុណភាព ឬគ្មានគុណភាព និងសារៈសំខាន់ពីការញ៉ាំអាហារ បន្លែ ផ្លែឈើ និងសាច់<br>• ចូលចិត្តញ៉ាំបន្លែ ផ្លែឈើ  អាហារសំបូរជីវជាតិ និងសហការស្តាប់យោបល់ ឯកភាពគំនិត ដើម្បីសម្រេចការងារក្រុម ។ |
| • សម្គាល់៖ សម្រាប់ថ្នាក់កម្រិតមធ្យម (ប្រាប់បានពីឈ្មោះបន្លែ  ផ្លែឈើចំនួន ៥មុខ) និងសម្រាប់ថ្នាក់កម្រិតទាប(ប្រាប់បានពីឈ្មោះបន្លែ ផ្លែឈើ)។ | |

### ២.៣.២. ប្រធានបទ បំណិនអនាម័យ

| ខ្លឹមសារ | លទ្ធផលរំពឹងទុក |
|---|---|
| ទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារ និងសង្គម | • ប្រាប់ពីទម្លាប់ល្អទាំងឡាយមុន និងក្រោយពេល ញ៉ាំអាហារ ចូលបង្គន់ អនាម័យ និងសម្អាតខ្លួនប្រាណ សម្ភារៈលេងផ្សេងៗ ទីកន្លែងទុកដាក់សំរាមតាមការកំណត់ វិធីការពារក្នុងពេលក្អក កណ្តាស់ សម្អាតច្រមុះ និងកំណត់បានអាហារ បន្លែ ផ្លែឈើ និងសាច់គួរញ៉ាំ ឬមិនគួរញ៉ាំ<br>• លាងសម្អាតដៃតាមពេលវេលាដូចជា មុន និងក្រោយ ពេលញ៉ាំអាហារ បន្លែ ផ្លែឈើ ទឹកស្អាតក្រោយពេលចេញពីបង្គន់ ពេលបានប៉ះពាល់របស់កខ្វក់ ការចោលសំរាមក្នុងធុងសំរាម ខ្ទប់មាត់នៅពេលក្អក កណ្តាស់ ចេះសម្អាតច្រមុះពេលហៀរសំបោរ មានអនាម័យល្អមុនពេលញ៉ាំអាហារ បន្លែ ផ្លែឈើ ទឹកស្អាតចេះងូតទឹក ដុសធ្មេញ សិតសក់ សម្អាតដៃជើង ស្លៀកពាក់ខ្លួនឯងនិងបែងចែកបានពី អាហារ បន្លែ ផ្លែឈើ និងសាច់ដែលគួរញ៉ាំ ឬមិនគួរញ៉ាំ និងរបៀបដែលអាចធ្វើឱ្យញ៉ាំបាន |

| | |
|---|---|
| | • មានទម្លាប់ អនាម័យខ្លួនឯងជាប្រចាំ ដោយការហូបស្អាត ផឹកស្អាត និងការរស់នៅស្អាត។ |
| • សម្គាល់៖ សម្រាប់ថ្នាក់កម្រិតមធ្យម និងកម្រិតទាប (ទម្លាប់ល្អទាំងឡាយមុន និងក្រោយពេល ញ៉ាំអាហារ ចូលបង្គន់និង វិធីការពារក្នុងពេលក្អក កណ្ដាស់ សម្អាតច្រមុះ)។ | |

### ២.៣.៣. ប្រធានបទ ប្រតិបត្តិដោយសុវត្ថិភាព

| ខ្លឹមសារ | លទ្ធផលរំពឹងទុក |
|---|---|
| ការយល់ដឹងពីការប្រតិបត្តិខ្លួនដើម្បីសុវត្ថិភាព | • ប្រាប់ពីគ្រោះថ្នាក់ដែលបណ្ដាលមកពី ការលេងភ្លើង អគ្គិសនី ថ្នាំសម្លាប់សត្វល្អិត ស្លាកសញ្ញាមីន សញ្ញាចរាចរណ៍ វត្ថុមុតស្រួច ទឹកពាង ទឹកស្រះ និងប្រាប់បានពីអាសយដ្ឋានឈ្មោះឪពុកម្ដាយ ឬអ្នកនៅក្នុងផ្ទះជាមួយ ឬអ្នកស្គាល់អាសយដ្ឋានរបស់ខ្លួន ដើម្បីឱ្យគេជួយនៅពេលមានបញ្ហា<br>• បង្ហាញពីឈ្មោះឪពុកម្ដាយ អ្នកនៅក្នុងផ្ទះជាមួយ ឬអ្នកស្គាល់នៅពេលវង្វេងផ្លូវ និងរៀបរាប់បានពីគ្រោះថ្នាក់ ដែលបណ្ដាលមកពីការលេងភ្លើង អគ្គិសនី ថ្នាំសម្លាប់សត្វល្អិត ថ្នាំពេទ្យ ស្លាកសញ្ញាមីន វត្ថុមុតស្រួច ពាងទឹក ឬស្រះទឹក...<br>• ក្លាហានមិនតក់ស្លុតក្នុងការប្រាប់ឈ្មោះឪពុកម្ដាយ ឬអ្នកនៅក្នុងផ្ទះជាមួយ ឬអ្នកស្គាល់នៅពេលវង្វេងផ្លូវ និងចៀសវាងសកម្មភាពមួយចំនួនដែលនាំឱ្យគ្រោះថ្នាក់ ការលេងតាមចិញ្ចើមថ្នល់ និងមនុស្សមិនស្គាល់មុខ។ |

### ២.៣.៤. ប្រធានបទ ការរស់នៅប្រចាំថ្ងៃ

| ខ្លឹមសារ | លទ្ធផលរំពឹងទុក |
|---|---|
| ការស្វែងយល់ដោយការសង្កេត | • ប្រាប់បានពីឈ្មោះសត្វចិញ្ចឹម សត្វព្រៃ សត្វស្លាប ឬលើសពីនេះ និងប្រាប់បានពីរបៀបនៃការពិសោធន៍ និងស្វែងយល់ពីបរិស្ថាន<br>• រៀបរាប់ឈ្មោះសត្វ ចរិតលក្ខណៈ លក្ខខណ្ឌរស់នៅ វដ្ដនៃសត្វ និងការប្រៀបធៀបសត្វ និងសារប្រយោជន៍ និងអាចពិសោធន៍ស្វែងយល់ដោយប្រើសម្ភារៈផ្សេងៗ ក្នុងការលេង ដូចជា លិច |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | អណ្តែត ជ្រាបទឹក និងមិនជ្រាបទឹក វត្ថុរលាយ និងមិនរលាយ ការលាយពណ៌ បណ្តុះគ្រាប់ធញ្ញជាតិ ខ្យល់ ជាដើម<br>• ស្រឡាញ់ ចូលចិត្តចិញ្ចឹម និងថែរក្សាសត្វ មានបម្រុងប្រយ័ត្នក្នុងការពិសោធន៍ និងទុកដាក់សម្ភារៈឱ្យមានសណ្តាប់ធ្នាប់ ហើយមានសុវត្ថិភាព ។ |
| • សម្គាល់៖ ថ្នាក់កម្រិតទាប(ឈ្មោះសត្វ ចិញ្ចឹមចំនួន២)។ | |

| ខ្លឹមសារ | លទ្ធផលរំពឹងទុក |
|---|---|
| អ្វីៗដែលគ្មានជីវិត និងមានជីវិត | • ប្រាប់ឈ្មោះៗ ដែលគ្មានជីវិត និងមានជីវិត<br>• រៀបរាប់ពីសត្វ មនុស្ស រុក្ខជាតិ ទឹក ដី និងវត្ថុដែលគ្មានជីវិត និងមានជីវិត<br>• ស្រឡាញ់ និងចូលរួមថែរក្សាអ្វីៗដែលមានជីវិត។ |
| • សម្គាល់៖ សម្រាប់ថ្នាក់កម្រិតមធ្យម និងកម្រិតទាប(គ្មាន)។ | |

| ខ្លឹមសារ | លទ្ធផលរំពឹងទុក |
|---|---|
| លក្ខណៈមេឃ និងអាកាសធាតុ | • ប្រាប់បានពីអាកាសធាតុ រដូវប្រាំង រដូវវស្សា និងពីផលពិបាកនៃបាតុភូតធម្មជាតិ៖ ភ្លៀង ផ្លេកបន្ទោរ រន្ទះ ផ្គរ ខ្យល់ព្យុះ ទឹកជំនន់ រាំងស្ងួត<br>• ញែកបានពី រដូវប្រាំង រដូវវស្សា និងពីផលពិបាកនៃបាតុភូតធម្មជាតិ៖ ភ្លៀង ផ្លេកបន្ទោរ រន្ទះ ផ្គរ ខ្យល់ព្យុះ ទឹកជំនន់ រាំងស្ងួត<br>• ប្រុងប្រយ័ត្ន និងការពារខ្លួននៅពេលមានបាតុភូតធម្មជាតិ |
| • សម្គាល់៖ សម្រាប់ថ្នាក់កម្រិតទាប(គ្មាន)។ | |

| ខ្លឹមសារ | លទ្ធផលរំពឹងទុក |
|---|---|
| លក្ខណៈរូបធាតុ | • ប្រាប់ពីវត្ថុដែលធ្វើពីឈើ ដែក ជ័រប្លាស្ទិក និងថ្មបាន យ៉ាងតិច ៥ ឬ លើសពីនេះ និងពីភាពខុសគ្នាវត្ថុធាតុ ដើម នៃសម្ភារៈដោយប្រើ បញ្ញត្តិ៖ រឹង ទន់ គ្រើម រលោង សើមស្ងួត...<br>• ញែកបានរវាងវត្ថុដែលធ្វើពីឈើ ដែក ជ័រប្លាស្ទិក ថ្ម និងពីភាពខុសគ្នាវត្ថុធាតុដើមនៃសម្ភារៈដោយប្រើបញ្ញត្តិដូចជា រឹង ទន់ ក្ដៅ ត្រជាក់ គ្រើម រលោង សើមស្ងួត...<br>• ប្រុងប្រយ័ត្នក្នុងការប្រើប្រាស់វត្ថុនានាចៀសវាងគ្រោះថ្នាក់។ |
| • សម្គាល់៖ សម្រាប់ថ្នាក់កម្រិតមធ្យម (ប្រាប់ពីវត្ថុដែលធ្វើពីឈើ ដែក ជ័រប្លាស្ទិក និងថ្មបានយ៉ាងតិច ៤)ចំណែកកម្រិតទាប (ប្រាប់ពីវត្ថុដែលធ្វើពីឈើ ដែក ជ័រប្លាស្ទិកនិងថ្ម មិនកំណត់ចំនួន)។ | |

| ខ្លឹមសារ | លទ្ធផលរំពឹងទុក |
|---|---|
| អំពីរាងកាយផ្ទាល់ខ្លួន | • ប្រាប់ឈ្មោះផ្នែកផ្សេងៗ នៃរាងកាយមនុស្ស<br>• បង្ហាញពីមុខងាររបស់រាងកាយមនុស្សដូចជា ភ្នែកសម្រាប់មើល ត្រចៀកសម្រាប់ស្ដាប់ មាត់សម្រាប់និយាយ និងញ៉ាំបាយ ច្រមុះសម្រាប់ហិតក្លិន ដៃសម្រាប់ធ្វើការងារ ជើងសម្រាប់ដើរ និង មុខងារផ្សេងទៀត<br>• ចាប់អារម្មណ៍ពីការលូតលាស់របស់រាងកាយ ដូចជា សក់ដុះវែង ក្រចកលូតលាស់វែង ខ្លួនលូតកម្ពស់ ជាដើម។ |

| ខ្លឹមសារ | លទ្ធផលរំពឹងទុក |
|---|---|
| **ការប្រើប្រាស់សម្ភារៈតាមបច្ចេកវិទ្យា** | • ប្រាប់ឈ្មោះឧបករណ៍បច្ចេកវិទ្យាសាមញ្ញៗ ដែលប្រើក្នុងជីវភាពរស់នៅប្រចាំថ្ងៃយ៉ាងតិចចំនួន៤ និងឈ្មោះសំណង់សាមញ្ញៗ<br>• បង្ហាញឈ្មោះឧបករណ៍បច្ចេកវិទ្យាសាមញ្ញៗ ដែលប្រើក្នុងជីវភាពរស់នៅប្រចាំថ្ងៃយ៉ាងតិចឱ្យបានចំនួន ៣ ដូចជា ទូរទស្សន៍ កង្ហារ ទូរស័ព្ទ ជាដើម និងការសាងសំណង់ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | សាមញ្ញៗ ដោយប្រើ ក្រដាស ជ័រឥដ្ឋ ឬដុំឥដ្ឋ ដុំឈើ ដូចជាធ្វើទូក កូនឡានជាដើម<br>• មានបម្រុងប្រយ័ត្នខ្ពស់ក្នុងការប៉ះពាល់ និងក្នុងពេលធ្វើសកម្មភាពប្រកបដោយសុវត្ថិភាព។ |

• សម្គាល់៖ សម្រាប់ថ្នាក់កម្រិតមធ្យម (ឈ្មោះឧបករណ៍បច្ចេកវិទ្យាសាមញ្ញៗ ដែលប្រើក្នុងជីវភាពរស់នៅប្រចាំថ្ងៃយ៉ាងតិចចំនួន ៣) ចំណែកថ្នាក់កម្រិតទាប(ប្រាប់ឈ្មោះឧបករណ៍បច្ចេកវិទ្យាសាមញ្ញៗដែល ប្រើក្នុងជីវភាពរស់នៅប្រចាំថ្ងៃមិនកំណត់ចំនួន)។

| ខ្លឹមសារ | លទ្ធផលរំពឹងទុក |
|---|---|
| **មធ្យោបាយធ្វើដំណើរ** | • ប្រាប់មធ្យោបាយធ្វើដំណើរផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស<br>• កំណត់ពីមធ្យោបាយធ្វើដំណើរ ផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស<br>• ប្រុងប្រយ័ត្នស្តាប់ សង្កេត ពិភាក្សា ចូលរួមសហការ មានបម្រុងប្រយ័ត្ន និងសប្បាយរីករាយ។ |

## ២.៣.៥. បំណិនពិចារណា

| ខ្លឹមសារ | លទ្ធផលរំពឹងទុក |
|---|---|
| **ការយល់ដឹងពីហេតុនិងផល** | • ប្រាប់ពីលក្ខណៈរបស់អាកាសធាតុ ស្ថានភាពមុនភ្លៀង ដូចជាមេឃងងឹត ផ្គរលាន់ ផ្លេកបន្ទោរ ខ្យល់ ពីមូលហេតុដែលធ្វើឱ្យវត្ថុប្រែប្រួលនិងពីសកម្មភាពដែលជះឥទ្ធិពល លើវត្ថុនានា ដូចជាចាន ថូ កែវ ធ្លាក់លើកម្រាលវានឹងបែកជាដើម<br>• ទាយទុកនូវបាតុភូតនានា ដូចជា អាចនឹងមានភ្លៀងពេលឃើញមេឃងងឹត ឮផ្គរលាន់ មានខ្យល់ នឹងឃើញផ្លេកបន្ទោរនិងរៀបរាប់ពីព្រឹត្តិការណ៍មុន កំពុង និងក្រោយពេលភ្លៀងធ្លាក់ ហើយអាចបញ្ជាក់បានពីសកម្មភាពដែលបានជះឥទ្ធិពល លើវត្ថុនានាដូចជា ចាន ថូ កែវ ធ្លាក់លើកម្រាលវានឹងបែក ជាដើម។<br>• ប្រុងប្រយ័ត្នមុនពេលភ្លៀង កំពុង និងក្រោយពេលភ្លៀង និងការប្រើប្រាស់វត្ថុនានា ។ |

- សម្គាល់៖ សម្រាប់ថ្នាក់កម្រិតមធ្យម និងកម្រិតទាប(ប្រាប់ពីលក្ខណៈរបស់អាកាសធាតុ ស្ថានភាពអ្វីមួយ)។

## ២.៣.៦. បំណិនក្នុងសង្គម

| ខ្លឹមសារ | លទ្ធផលរំពឹងទុក |
|---|---|
| **ចំណេះដឹងអំពីសហគមន៍** | • ប្រាប់បានឈ្មោះសម្ភារៈតាមមុខរបរ និងពីឈ្មោះ មុខងារ នៃទីកន្លែងសំខាន់ៗ ក្នុងភូមិ<br>• បង្ហាញពីមុខងារសម្ភារៈដូចជា កន្ត្រៃ ស្និតសិតសក់ កាំបិតកោរ សម្រាប់ប្រើប្រាស់ក្នុងមុខរបរកាត់សក់ និងមុខងារទីកន្លែងសំខាន់ៗ ដូចជា សាលារៀន វត្តអារាម ផ្សារ មណ្ឌលសុខភាព<br>• ស្រឡាញ់ មុខរបរសុចរិត និងមានមោទនភាព ចំពោះភូមិឃុំខ្លួន។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# ជំពូក៣

# វិធីសាស្ត្រអនុវត្តការបង្រៀន និងរៀន
# មុខវិជ្ជាវិទ្យាសាស្ត្រ

# ជំពូក៣ វិធីសាស្ត្រអនុវត្តការបង្រៀន និងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ

## ៣.១. សញ្ញាណវិទ្យាសាស្ត្រនៅមត្តេយ្យសិក្សា

និយាយពីពាក្យ **វិទ្យាសាស្ត្រ** គេនឹកដល់បន្ទប់ពិសោធដ៏ទំនើបសម្រាប់មុខវិជ្ជាគីមី ឬ ជីវវិទ្យា ឬ រូបវិទ្យា។ នៅពេលនិយាយអំពីវិទ្យាសាស្ត្រសម្រាប់មត្តេយ្យសិក្សាមានសំណួរចោទសួរថា តើកុមារមត្តេយ្យសិក្សាអាចរៀនមុខវិជ្ជានេះដោយរបៀបណា? *ចម្លើយគឺថា* កុមារអាចរៀនបានច្រើនណាស់។ ផ្អែកលើលទ្ធផលសង្កេតបានឱ្យដឹងថាកុមារអាយុពី ៣ឆ្នាំ ដល់ក្រោម ៦ឆ្នាំ ចាប់បានបញ្ញត្តិមូលដ្ឋាននៃមុខវិជ្ជាដ៏លំបាកនេះ ទៅតាមកម្រិតយល់ដឹងរបស់ខ្លួន។

**វិទ្យាសាស្ត្រ** គឺជាអ្វីដែលនៅជុំវិញខ្លួនយើង។ វិទ្យាសាស្ត្រមានន័យថាជាការសិក្សាតាមប្រព័ន្ធត្រឹមត្រូវអំពីបរិស្ថាន និងអ្វីៗមានជីវិត និងគ្មានជីវិតជាច្រើនដែលរស់នៅក្នុងបរិស្ថាន។ កុមារជួបប្រទះវិទ្យាសាស្ត្រនៅគ្រប់ពេលនៅក្នុងជីវិតប្រចាំថ្ងៃរបស់ខ្លួន ដូចជា៖

- គ្មានអគ្គីសនី គ្មានកង្ហារិល គ្មានខ្យល់ កុមារមានអារម្មណ៍ថាក្តៅ
- ខ្យល់បក់រហើយធ្វើឱ្យញើសស្ងួត
- សម្លៀកបំពាក់កុមារសើមហើយស្ងួតលឿនពេលត្រូវកម្តៅថ្ងៃ
- រុក្ខជាតិដុះចេញពីគ្រាប់

ការសង្កេតបាតុភូតទាំងនេះ គឺ**ជាវិទ្យាសាស្ត្រសម្រាប់កុមារ**។

❖ **មុខវិជ្ជាវិទ្យាសាស្ត្រមានគោលបំណង៖**

- កុមារទទួលបានបទពិសោធន៍ស្តីពីវិទ្យាសាស្ត្រ
- ជំរុញការចូល់ ចង់ដឹង ចង់ស្រាវជ្រាវ ការរកឃើញថ្មី និងស្វែងរកចម្លើយចំពោះសំណួរឆ្ងល់របស់កុមារ
- បង្កើនសមត្ថភាពកុមារក្នុងការសង្កេត ដោះស្រាយបញ្ហា និងវិភាគ
- ជួយកុមារលើផ្នែកភាសា វិញ្ញាណ កាយសម្បទា ស្មារតី បញ្ញា និងការអភិវឌ្ឍផ្នែកសង្គម អភិវឌ្ឍន៍បញ្ញត្តិវិទ្យាសាស្ត្រមូលដ្ឋាន
- បង្កើតមូលដ្ឋានសម្រាប់ការរៀនសូត្រស្មុគស្មាញនាពេលអនាគត។

❖ **វិទ្យាសាស្ត្រចែកចេញជាពីរផ្នែក៖**

- វិទ្យាសាស្ត្ររូប៖ ផ្នែកនេះរួមមានបទពិសោធន៍ទាក់ទងនឹងទឹក ធម្មជាតិ ឧបករណ៍ ដី ថាមពលភ្លើង ថ្ម ធាតុអាកាស បរិយាកាស កញ្ចក់ មេដែក ម៉ាស៊ីន ពណ៌ ការទំនាក់ទំនង គមនាគមន៍ ការពិភាក្សាពីខ្យល់ សំឡេង សីតុណ្ហភាព អគ្គីសនី ចំនួន ប្រវែង លំនឹង។ល។ ឧទាហរណ៍៖ អណ្តែតលិច ការប្រែប្រួលនៃពណ៌...
- វិទ្យាសាស្ត្រជីវៈ៖ ផ្នែកនេះរួមមានបទពិសោធន៍ទាក់ទងនឹងមនុស្ស រុក្ខជាតិ សត្វ និងអាហារ។ សត្វផ្តល់បញ្ញត្តិសំខាន់សម្រាប់ការរៀនសូត្ររបស់កុមារ។ គ្រូអាចជួយកុមារឱ្យនិយាយពីតម្រូវការ និងរូបរាងរបស់សត្វទាក់ទងនឹងតម្រូវការ និងរូបរាងរបស់កុមារ។ តើវាមានជើងប៉ុន្មាន? តើវាមើលថែ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

កូនដោយរបៀបណា? តើវាស៊ីអ្វីជាអាហារ? តើវាដេកដូចម្តេច?។ រុក្ខជាតិផ្តល់បទពិសោធន៍ទាក់ទងទៅនឹងការលូតលាស់ និងសារប្រយោជន៍។

និយាយជារួម ការរួមចំណែកនៃបទពិសោធន៍វិទ្យាសាស្ត្រចំពោះការអភិវឌ្ឍរបស់កុមារមានច្រើនរាប់មិនអស់។ ឧទាហរណ៍៖ ការលូតលាស់នៃរុក្ខជាតិ ដំណាក់កាលកកំណើត...។

❖ **តម្រូវការ និងតម្លៃវិទ្យាសាស្ត្រនៅក្នុងកម្មវិធីមត្តេយ្យសិក្សា**

វិទ្យាសាស្ត្រ ជាផ្នែកមួយសំខាន់នៃកម្មវិធីនៅមត្តេយ្យសិក្សា។ កុមារតូច និងវិទ្យាសាស្ត្រ ហាក់នៅជាមួយគ្នា។ កុមារតូចសកម្មចង់ដឹង ចូលចិត្តកាន់លេង និងពិសោធន៍ជាមួយវត្ថុនានា។ កុមារសួរសំណួរអំពី៖ ដូចម្តេច? ហេតុអ្វី? ឯណា? កុមាររុករកស្វែងយល់ពីបរិស្ថាននៅជុំវិញខ្លួន។ ចំពោះកុមារអ្វីៗ នៅក្នុងបរិស្ថានគឺថ្មី។ កុមាររំភើបរីករាយនៅពេលដែលគេឃើញដង្កូវតូចៗ ចេញពីក្នុងដី ទោងយោលចុះ យោលឡើង ទូកក្រដាសហូរទៅតាមទឹកភ្លៀង ពណ៌ឥន្ទធនូ ពពុះទឹក។ល។ បទពិសោធន៍ទាំងនេះជួយកុមារឱ្យមានការកោតសរសើរដល់ពិភពលោក បរិស្ថានដែលនៅជុំវិញពួកគេ និងរក្សាការឆ្ងល់ ចង់ដឹងបន្តទៅទៀត។

កម្មវិធីសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រត្រូវសង្កត់ធ្ងន់លើលំនាំរៀនសូត្រ។ កុមារត្រូវមានឱកាសចូលរួមក្នុងសកម្មភាពមុខវិជ្ជាវិទ្យាសាស្ត្រ ដូចជា ការសាកសួរ ស្រាវជ្រាវ ចង់ដឹង និងការរកឃើញថ្មី តាមរយៈបំណិនបទពិសោធន៍ខាងមុខវិជ្ជាវិទ្យាសាស្ត្រ ខាងការសង្កេត ការចាត់ចំណាត់ថ្នាក់ ការពិពណ៌នា ការដោះស្រាយបញ្ហា ការបង្កើតទំនាក់ទំនង និងការគិតរកហេតុផលត្រឹមត្រូវ។ នៅពេលផ្តល់បទពិសោធន៍ខាងមុខវិជ្ជាវិទ្យាសាស្ត្រដល់កុមារតូច សំខាន់ត្រូវចងចាំថាកុមារមិនអាចយល់ពីគោលការណ៍ខុសៗគ្នា នៃមុខវិជ្ជាវិទ្យាសាស្ត្រទេ។ សំខាន់សម្រាប់កុមារក្នុងការអភិវឌ្ឍ គឺកុមារឆ្លងកាត់ដំណើរការការរកឃើញថ្មីការស្រាវជ្រាវ ការចង់ដឹង ការឆ្លើយតបតាមរយៈការឆ្ងល់ ចង់ដឹង និងការសង្កេតមើលសេចក្តីលម្អិតនានា។ ដូច្នេះ ការឆ្លងកាត់ និងការសង្កេត ដំណើរការនេះមានសារៈសំខាន់ជាង បើប្រៀបធៀបជាមួយការរៀនសូត្រមុខវិជ្ជាវិទ្យាសាស្ត្រដែលពួកគេមិនយល់។

កុមារតូចៗ នៅមត្តេយ្យសិក្សាមានភាពចង់ដឹង ចង់ឃើញជាធម្មជាតិ។ គេប្រើភាពចង់ឃើញ ចង់ដឹងនេះ ដើម្បីពង្រីកការយល់ដឹងរបស់គេអំពីពិភពលោក និងវិទ្យាសាស្ត្រ។ នៅមត្តេយ្យសិក្សាការអប់រំឱ្យយល់ដឹងអំពីវិទ្យាសាស្ត្រមានគោលបំណង ៖

- ឱ្យកុមារចេះបង្ហាញ និងបញ្ជាក់រាល់ឈ្មោះ រូបរាងរបស់វត្ថុទាំងឡាយដែលមានក្នុងបរិស្ថាន និងបាតុភូតផ្សេងៗ តាមរយៈការសង្កេត និងធ្វើពិសោធន៍
- ឱ្យកុមារមានទម្លាប់ធ្វើអ្វីមួយដោយមានអំណះអំណាង និងច្បាស់លាស់។

❖ **ការរៀបចំផែនការ និងការធ្វើពិសោធន៍វិទ្យាសាស្ត្រ**

មុខវិជ្ជាវិទ្យាសាស្ត្រ អាចត្រូវបានផ្សព្វផ្សាយតាមរយៈសកម្មភាពនីមួយៗ នៃកម្មវិធីប្រចាំថ្ងៃ បទ-ពិសោធន៍វិទ្យាសាស្ត្រអាចរៀបចំយ៉ាងលឿនដោយផ្អែកលើអ្វីដែលកើតឡើងដោយចៃដន្យ និងការបញ្ចេញយោបល់របស់កុមារ។ ឧទាហរណ៍៖ នៅថ្ងៃដែលមានអាកាសធាតុត្រជាក់ ប្រសិនបើកុមារលើកឡើងថាថ្ងៃនេះ «ត្រជាក់ណាស់» គ្រូអាចឆ្លៀតឱកាសនេះផ្តល់បទពិសោធន៍អំពីពិសោធន៍ «ក្តៅ ឬត្រជាក់» ដែលមានការរៀបចំជាមុន ផ្តល់ឱកាសឱ្យកុមាររៀនសូត្រដើម្បីរកដំណោះស្រាយចំពោះបញ្ហាជាក់លាក់។ ស្លឹកឈើរបស់

រុក្ខជាតិខុសៗគ្នា អាចយកមកបិតដើម្បីបង្ហាញពីភាពខុសគ្នានៃស្លឹកឈើ។ ឱកាសជាច្រើនកើតមានដើម្បីបង្រៀនអំពីការធំលូតលាស់។ កុមារមានស្បែកជើងថ្មី ព្រោះស្បែកជើងចាស់តូចពេក។ ធ្មេញថ្មីដុះជំនួសធ្មេញចាស់។ សក់ និងក្រចកដៃជើង ត្រូវការកាត់។ សកម្មភាពដាំដុះអាចរៀបចំនៅក្នុងសួនច្បារសាលាផងដែរ។ គ្រូអាចរៀបចំសម្ភារៈនៅលើតុវិទ្យាសាស្ត្រមួយដើម្បីឱ្យកុមារអាចប្រើប្រាស់បាន។ កុមារអាចរៀបចំដុំថ្មតាមប្រភេទ ក្រុម ពណ៌ ឬទម្រង់រូបរាង។ កញ្ចក់ពង្រីកខុសៗ គ្នា ឱ្យកុមារមើលរបស់នានា និងរកឃើញពីឥទ្ធិពលលើទំហំពិតប្រាកដ។

❖ **តួនាទីរបស់គ្រូ**

ដើម្បីជំរុញកុមារឱ្យមានចំណាប់អារម្មណ៍ខាងផ្នែកវិទ្យាសាស្ត្រ គ្រូត្រូវតែជាមនុស្សចូលចិត្ត ចង់ដឹង ចង់ឃើញ ជួយកុមារបង្កើតការចង់ដឹង និងរីករាយក្នុងការស្រាវជ្រាវក្នុងបរិស្ថាន។ បរិស្ថានសម្បូរបែបមួយដែលមានរបស់គួរឱ្យចាប់អារម្មណ៍ជាច្រើនដែលត្រូវធ្វើ មើល និងជំរុញឱ្យកុមារកាន់តែចង់ដឹង។

**គ្រូមត្តេយ្យសិក្សាត្រូវតែ៖**

- បញ្ជាក់ប្រាប់ ពន្យល់ ពង្រឹង និងពិភាក្សាជាមួយកុមារលើសំណួរជាច្រើន ដែលកើតមានចំពោះកុមារនៅពេលកុមារស្រាវជ្រាវបរិស្ថានជុំវិញខ្លួន អាចធ្វើឱ្យកុមារយល់ដឹងកាន់តែច្រើនពីពិភពលោក និងបរិស្ថានដែលនៅជុំវិញខ្លួន។ ការងារនេះអាចធ្វើតាមរយៈរូបភាព ចម្រៀង រឿងនិទាន ឬ ស្ថានភាពដែលត្រូវបានរៀបចំ។
- ជានិច្ចកាលផ្តល់ព័ត៌មានត្រឹមត្រូវ។ ប្រើប្រាស់ពាក្យពេចន៍ដែលកុមារងាយយល់ តែក៏ត្រូវប្រើនិងកំណត់និយមន័យពាក្យវិទ្យាសាស្ត្រមួយចំនួនដើម្បីបង្កើនពាក្យរបស់កុមារ។
- កំណត់ព្រំដែនដើម្បីឱ្យកុមារស្រាវជ្រាវដោយគ្មានគ្រោះថ្នាក់។
- ធានាថាបទពិសោធន៍ដែលបានរៀបចំមានការងាយស្រួល គ្មានគ្រោះថ្នាក់ កំណត់ដោយតម្រូវការ និងការចាប់អារម្មណ៍របស់កុមារ និងរៀបចំនៅជុំវិញរបស់ដែលកុមារធ្លាប់ស្គាល់។
- យល់ដឹងពីលទ្ធភាពផ្សេងៗ នៃវិទ្យាសាស្ត្រ (រូប សង្គម ជីវៈ) ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ បន្តស្វែងរកគំនិត និងសម្ភារឧបទេស។
- ត្រៀមចាប់យកឱកាសដើម្បីជំរុញបទពិសោធន៍វិទ្យាសាស្ត្រដែលគ្មានការត្រៀមទុក តែក៏ត្រូវផ្តល់បទពិសោធន៍ដែលបានរៀបចំទុកមុនខ្លះដែរ។
- ផ្តល់បទពិសោធន៍គ្រប់ប្រភេទតែត្រូវយកគំនិតរបស់កុមារ។

នៅមត្តេយ្យសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រត្រូវបានបែងចែកជា ៣ ប្រភេទ គឺ **ពិសោធន៍ សង្កេត និង ទស្សនាសង្កេត**។ តាមរយៈសកម្មភាពគោលទាំងនេះ កុមារនឹងទទួលនូវបទពិសោធន៍ស្តីពីវិទ្យាសាស្ត្រ លូតលាស់នូវភាពប៉ិនប្រសប់ខាងការចូលចិត្ត ចង់ដឹង ការចង់ស្រាវជ្រាវ ការរកឃើញថ្មី និងស្វែងរកចម្លើយចំពោះសំណួររបស់គេ។ បែបនេះនឹងបង្កើននូវសមត្ថភាពសង្កេត ដោះស្រាយបញ្ហា និងវិភាគ ថែមទាំងជួយកុមារលូតលាស់ខាងភាសាវិញ្ញាណ កាយសម្បទា ស្មារតី បញ្ញា និងការអភិវឌ្ឍផ្នែកសង្គម អភិវឌ្ឍន៍បញ្ញត្តិវិទ្យាសាស្ត្រមូលដ្ឋាន បង្កើតមូលដ្ឋានសម្រាប់ការរៀនសូត្រស្មុគស្មាញនាពេលអនាគត។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៣.២. ប្រធានបទមុខវិជ្ជាវិទ្យាសាស្ត្រ

យោងតាមសៀវភៅកម្មវិធីសិក្សាលម្អិតនៅកម្រិតមត្តេយ្យសិក្សា ប្រធានបទសម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រមានដូចជា៖

- អាហារូបត្ថម្ភ
- បំណិនអនាម័យ
- ប្រតិបត្តិខ្លួនដើម្បីសុវត្ថិភាព
- ការរស់នៅប្រចាំថ្ងៃ
- បំណិនពិចារណា
- បំណិនក្នុងសង្គម

## ៣.៣. វិធីសាស្ត្របង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនៅមត្តេយ្យសិក្សា

### ៣.៣.១. ទស្សនាសង្កេត

ទស្សនាសង្កេត គឺជាការនាំកុមារចេញទៅសិក្សានៅក្រៅថ្នាក់។ គ្រូត្រូវនាំកុមារឱ្យចេញទៅធ្វើការទស្សនាសង្កេតនៅខាងក្រៅ ដើម្បីឱ្យកុមារស្វែងយល់ និងសង្កេតអំពីភាសាសំបូរបែបដែលនៅជុំវិញខ្លួន ដូចជា ធម្មជាតិ (រុក្ខជាតិ) បាតុភូតធម្មជាតិ (ភ្លៀង រន្ទះ ផ្លេកបន្ទោរ...) បាតុភូតសង្គម (ពិធីបុណ្យអាពាហ៍ពិពាហ៍) មធ្យោបាយដឹកជញ្ជូន (ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស) សម្ភារៈ និងឧបករណ៍សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ។ ដូចនេះការចេញទស្សនាសង្កេតអាចជួយបង្កើនទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងសហគមន៍ និងកុមារ ព្រមទាំងសុំមនុស្សចាស់ឱ្យរួមចំណែកក្នុងការជួយអប់រំកុមារ។

ប្រធានបទនៃការចេញទស្សនាសង្កេត គ្រូត្រូវអនុវត្ត ៤ ដំណាក់កាល៖

- **ការរៀបចំ៖** ជ្រើសរើសប្រធានបទស្របតាមគរុកោសល្យ ទំនាក់ទំនងជាមួយម្ចាស់ទីកន្លែង
- **មុនពេលទស្សនាសង្កេត៖** គ្រូត្រូវបំផុសឱ្យកុមារចាប់អារម្មណ៍លើប្រធានបទសង្កេត ណែនាំសណ្តាប់ធ្នាប់ពេលធ្វើដំណើរ
- **ពេលទស្សនាសង្កេត៖** ពេលកំពុងធ្វើដំណើរ និងពេលកំពុងសង្កេត គ្រូបង្កលក្ខណៈ និងជួយឱ្យកុមារចេះសង្កេត ចាប់អារម្មណ៍នូវអ្វីដែលមាននិងប្លែក។ គ្រូត្រូវជួយកុមារឱ្យសង្កេតនិងប្រៀបធៀប ឱ្យស្គាល់សញ្ញាណ និងប្រើប្រាស់ញាណទាំង ៥ (ស្តាប់ មើល ហិត ភ្លក់ ស្ទាប ចាប់ កាន់ ធ្វើសាកល្បង ឆ្ងល់ ទម្ងន់ ឬវាស់) កុមារអាចពណ៌នាបង្ហាញការចាប់អារម្មណ៍លើអ្វីដែលបានសង្កេត ហើយគ្រូត្រូវតែបញ្ចូលនូវចំណេះដឹងផ្នែកមុខវិជ្ជា បុរេគណិត ភាសា...។
- **ក្រោយពេលទស្សនាសង្កេត៖** គ្រូត្រូវទុកឱកាសឱ្យកុមារនិយាយ បញ្ចេញយោបល់ ឆ្ងល់ និងឱ្យកុមារបានគូរនូវអ្វីដែលកុមារចាប់អារម្មណ៍ ។

ការប្រើប្រាស់មជ្ឈដ្ឋានជុំវិញ មានសារៈសំខាន់ណាស់ក្នុងការផ្តល់ចំណេះដឹងទូទៅ និងការអប់រំសីលធម៌រស់នៅក្នុងសង្គម។ ពោលគឺធ្វើឱ្យកុមារយល់ដឹងពីសញ្ញាណដំបូងនៃគណិតវិទ្យា ភាពរីកចម្រើន ផ្នែកភាសា បញ្ញា សុខភាពល្អ និងធ្វើឱ្យកុមារចាប់អារម្មណ៍នឹងការរស់នៅក្នុងភូមិ ការរស់នៅរបស់មនុស្ស ការរស់-

នៅរបស់មនុស្សធំ កិច្ចការ ការប៉ិនប្រសប់ ពិសេសកុមាររកឃើញនូវអ្វីជាប្រយោជន៍ និងបានប្រាស្រ័យទាក់ទងជាមួយមនុស្សបន្ថែមលើទំនាក់ទំនងតែមួយជាមួយគ្រួសារ និងគ្រូ។

### គ្រូមិនត្រូវភ្លេច ៖

- ដើម្បីសម្រួលការចេញទស្សនាសង្កេត និងធានាសុវត្ថិភាពចំពោះកុមារ គ្រូអាចសំណូមពរ មាតាបិតា ឬមនុស្សធំជួយជូនដំណើរ
- ការត្រៀមចេញទស្សនាសង្កេតត្រូវធ្វើឡើង៖
    - នៅក្នុងថ្នាក់រៀន ឬក្រៅថ្នាក់រៀន
    - នៅទីកន្លែងទស្សនាសង្កេតជាមួយកុមារ និងជាមួយអ្នកដែលកុមារត្រូវជួប
- ណែនាំកុមារពីទំនាក់ទំនងក្នុងសង្គម និងការគួរសម គឺជាផ្នែកមួយដែលត្រូវមានគ្រប់ពេលទស្សនាសង្កេត គ្រូបង្ហាត់កុមារឱ្យចេះរួបរួមជាក្រុម ព្រមទាំងដឹងពីទំនាក់ទំនង និងអាកប្បកិរិយា ដែលត្រូវប្រកាន់យកនៅពេលទស្សនាសង្កេត និងរំលឹកកុមារអំពីវិន័យនៅតាមផ្លូវ
- ទុកឱកាសឱ្យកុមារនិយាយ គ្រូមិនត្រូវនិយាយច្រើនពេកទេ។ ការសន្ទនាត្រូវធ្វើឡើងរវាងកុមារ និងអ្នកដែលគេបានជួប។
- ក្នុងសកម្មភាពនីមួយៗគ្រូត្រូវជួយរំលឹកនូវចំណេះដឹងទាំងឡាយដែលកុមារបានទទួលរួចមកហើយ
- អប់រំកុមារឱ្យមានការប្រុងប្រយ័ត្ន មានសណ្ដាប់ធ្នាប់ ការស្រឡាញ់ ការគោរព ឬការថែទាំ នៅក្នុងពេលដឹកនាំសកម្មភាពកុមារ។

ឧទាហរណ៍៖

| សកម្មភាព និងការប្រើប្រាស់សម្ភារៈ | លទ្ធផលដែលទទួលបាន |
|---|---|
| • ពេលដែលកុមារឆ្លងកាត់បទពិសោធន៍... | • កុមារនឹង... |
| • ប្រើថ្នាំពណ៌ប្រភេទផ្សេងៗ ប្រើសម្ភារៈសម្រាប់គូរ ប្រើក្រដាស រកវិធីសូន្យជីឥដ្ឋជារូប | • ពិនិត្យរកឃើញគុណភាពនៃវត្ថុនានា |
| • ស្វែងរកវិធីនានាដើម្បីសម្រួចខ្មៅដៃ សង្កេតមើលការប្រែប្រួលនៃវត្ថុនានា នៅពេលដែលថ្នាំស្ងួត សង្កេតមើលថា តើថ្នាំពណ៌លាយចូលគ្នារបៀបណា? | • ពិនិត្យពិច័យរកបញ្ញត្តិ ឬរបៀបប្រែប្រួលរបស់វត្ថុ ឬអង្គធាតុមានជីវិត និងគ្មានជីវិត |
| • ប្រើភាសាដើម្បីពណ៌នាការប្រែប្រួលដែលគេសង្កេតឃើញ សាកសួរសំណួរ ទស្សន៍ទាយថា តើវត្ថុមួយនឹងប្រែប្រួល ឬផ្លាស់ប្ដូរយ៉ាងដូចម្ដេច? និងសាកល្បងគិតគូរ... | • លូតលាស់នូវបំណិនប្រសប់ខាងសាកសួរ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

*រូបភាពទី 2 ៖ ទីកន្លែងសម្រាប់សកម្មភាពទស្សនាសង្កេត*



ព្រះបរមរាជវាំង



វត្តភ្នំ



ព្រះវិហារ



បុណ្យចូលឆ្នាំខ្មែរ



ទេសភាពវាលស្រែ



មុខរបរអ្នកភូមិ

### ៣.៣.២. សង្កេត

សង្កេត គឺជាសកម្មភាពគោលមួយនៅក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ។ ផ្នែកនេះរួមមានបទពិសោធន៍ទាក់ទងទៅនឹងមនុស្ស រុក្ខជាតិ អាហារ និងបរិស្ថាននៅជុំវិញខ្លួន។ កុមារស្វែងយល់ ដកពិសោធន៍ និងសិក្សាអំពីអ្វីៗដែលនៅជុំវិញខ្លួនគេ កុមារចង់ដឹង ពិនិត្យសង្កេត ត្រិះរិះពិចារណា និងសួរសំណួរផ្សេងៗ។ ការផ្តល់ការសង្កេតដល់កុមារគឺជាមធ្យោបាយមួយដ៏ល្អប្រសើរ សម្រាប់ជួយកុមារឱ្យសិក្សាដោយប្រើការសង្កេត ដើម្បីឱ្យកុមារមានការអភិវឌ្ឍនូវចំណេះដឹង និងបំណិនរស់នៅប្រចាំថ្ងៃ។ សកម្មភាពសង្កេតមាន ២ ប្រភេទ គឺ៖

- សង្កេត និងសន្ទនាពីវត្ថុពិត
- សង្កេត និងសន្ទនាលើផ្ទាំងរូបភាព

### ❖ សង្កេត និងសន្ទនាពីវត្ថុពិត

លក្ខណៈពិសេសដែលត្រូវសង្កេតគឺវត្ថុពិត ដូចជា រុក្ខជាតិ សត្វ អាហារ និងមនុស្ស។ ឆ្លងកាត់ការសង្កេត និងសន្ទនា គ្រូត្រូវហាត់ពត់រាល់សកម្មភាពសង្កេតរបស់កុមារ «គ្រប់ញាណរបស់កុមារត្រូវធ្វើការ» ផ្តល់ និងពង្រឹងចំណេះដឹងថ្មីៗ ពាក្យថ្មី និងហាត់ពត់រាល់ការត្រិះរិះរបស់កុមារ។ វិធីសំខាន់ គឺវិធីសង្កេត សន្ទនា និងប្រើល្បែង។

*រូបភាពទី 3 ៖ ការសង្កេតវត្ថុពិត*



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

*រូបភាពទី 4 ៖ ប្រភព គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ*












- លក្ខណៈនៃការសង្កេតវត្ថុពិតក្នុងបំណងឱ្យកុមារ៖
  - ស្គាល់ឈ្មោះមុខងារ ចរិតលក្ខណៈ របៀបប្រើ របៀបការពារ និងថែរក្សា
  - ស្គាល់លក្ខណៈខុសគ្នា និងដូចគ្នារបស់វត្ថុដែលត្រូវសង្កេត
  - យល់ពីទំនាក់ទំនងរវាងមុខសញ្ញាសង្កេត និងបរិស្ថានងាយៗ ដោយសមហេតុផល
- មេរៀនសង្កេតពីវត្ថុពិតនៅមត្តេយ្យសិក្សាមាន៖
  - សត្វចិញ្ចឹមក្នុងស្រុក
  - សម្ភារៈប្រើប្រាស់
  - រុក្ខជាតិ
  - មធ្យោបាយធ្វើដំណើរ

> គ្រប់មេរៀនសង្កេតពីវត្ថុពិត គ្រូត្រូវមានគំនិតច្នៃប្រឌិត និងចេះប្រើគំនិតនោះ ឱ្យសមស្របទៅនឹងស្ថានភាពជាក់ស្តែងនៃស្ថានភាពមូលដ្ឋាននីមួយៗ។

### ❖ សង្កេត និងសន្ទនាលើផ្ទាំងរូបភាព

លក្ខណៈពិសេស គឺផ្ទាំងគំនូរ ឬ រូបភាព ដូចជា ផ្ទាំងគំនូរស្តីពីសត្វ ផ្ទាំងគំនូរដែលមានខ្លឹមសារពីជីវិតរស់នៅមាន៖ បុណ្យភ្ជុំបិណ្ឌ បុណ្យចូលឆ្នាំខ្មែរ ចម្ការកៅស៊ូ ការនេសាទ... និងផ្ទាំងគំនូរស្តីពីបាតុភូតធម្មជាតិ ដូចជា ខ្យល់ ភ្លៀង រដូវប្រាំង រដូវរងារ...។ ក្នុងការបង្រៀនមេរៀនសង្កេតលើផ្ទាំងរូបភាព គ្រូត្រូវប្រើវិធីសង្កេត សន្ទនា ប្រើល្បែង និងអានអត្ថបទអក្សរសាស្ត្រដើម្បីរៀបរាប់។

*រូបភាពទី 5 ៖ សង្កេតដោយប្រើផ្ទាំងរូបភាព*





youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews











- គោលបំណងនៃការសង្កេតផ្ទាំងរូបភាព គឺឱ្យកុមារស្គាល់ឈ្មោះផ្ទាំងរូបភាព និងទំនាក់ទំនងរវាងផ្នែកនានាក្នុងផ្ទាំងរូបភាព និងនាំកុមារឱ្យចាប់អារម្មណ៍ពីខ្លឹមសារនៃផ្ទាំងគំនូរ។
- ដើម្បីបង្រៀនមេរៀនសង្កេតផ្ទាំងគំនូរគ្រូត្រូវ៖
  - រៀបចំផ្ទាំងរូបភាពដែលមានខ្នាត ៥០ ស.ម X ៣០ ស.ម
  - ជានាលក្ខណៈជាក់ស្តែង (ដូចរូបពិត) ប្រធានបទច្បាស់លាស់ និងមានសោភ័ណ។

### ៣.៣.៣. ពិសោធន៍

ពិសោធន៍ គឺជាមេរៀនមួយដែលទាក់ទងនឹងការរុករកស្រាវជ្រាវ។ មេរៀននេះ ទាមទារឱ្យកុមារបង្ហាញពីហេតុផលជាក់ស្តែង ដែលកើតចេញពីការធ្វើពិសោធន៍ ដែលជាការរុករកស្រាវជ្រាវ (ជារបៀបលេង) របស់កុមារ។ ហេតុនេះ ពិសោធន៍ទាមទារឱ្យគ្រូមាន៖

- សម្ភារៈជាក់ស្តែង និងរៀបចំជាស្រេចប្រកបដោយសុវត្ថិភាព
- ប្រើប្រាស់សំណួរដាក់បញ្ហាឱ្យឆ្លើយតបនឹងវត្ថុបំណងនៃមេរៀនក្នុងគោលបំណងឱ្យកុមារបានគិត
- ឱ្យកុមារអនុវត្តសកម្មភាពពិសោធន៍តាមក្រុមដោយអនុវត្តឱ្យបានគ្រប់គ្នា
- ឱ្យកុមារសាកល្បងប្រើប្រាស់គំនូសតាងពីអ្វីដែលគេបានពិសោធន៍ឃើញព្រមទាំងបកស្រាយ ពន្យល់ និងធ្វើអំណះអំណាង

- បូកសរុប ឬសន្និដ្ឋាន ស្ដីពីលទ្ធផលពិសោធន៍ ដោយសរុបលើចំណេះដឹងវិទ្យាសាស្ត្រ ចំណេះដឹងភាសា និងបំណិនក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដើម្បីឱ្យកុមារមានទឹកចិត្តស្រឡាញ់ធម្មជាតិ ស្រឡាញ់បរិស្ថាន និងយល់ពីជីវិតនៃការរស់នៅ។

ការបង្រៀនមេរៀនពិសោធន៍សម្រាប់ថ្នាក់មត្តេយ្យសិក្សា គឺគ្រូមិនត្រូវផ្ដោតខ្លាំងលើខ្លឹមសារពិសោធន៍ ដូចនៅថ្នាក់បឋមសិក្សា ឬមធ្យមសិក្សានោះទេ គឺគ្រូគ្រាន់តែជាអ្នកសម្របសម្រួល រីឯសកម្មភាពអនុវត្តស្ថិតនៅលើកុមារ ដែលគេប្រើប្រាស់សម្ភារៈជារបៀបល្បែង តែជាល្បែងរុករក និងស្រាវជ្រាវ។ ហេតុនេះគ្រូត្រូវចេះបត់បែន និងអនុវត្តជាក់ស្ដែងតាមស្ថានភាព និងកម្រិតអាយុរបស់កុមារ។

## ៣.៤. ការគ្រប់គ្រងដំណើរការបង្រៀន

### ៣.៤.១. លំនាំបង្រៀន

#### ក. ទស្សនាសង្កេត

❖ **មុនពេលទស្សនាសង្កេត**

- បំផុសឱ្យកុមារចាប់អារម្មណ៍នូវអ្វីដែលទាក់ទងនឹងប្រធានបទថ្មី ដោយប្រើសំណួរបំផុស ឬកំណាព្យ ឬពាក្យបណ្ដៅ...
- ឱ្យដំបូន្មាន និងណែនាំសណ្ដាប់ធ្នាប់ដល់កុមារពេលដើរតាមផ្លូវ និងទៅដល់ទីកន្លែង

❖ **នៅតាមផ្លូវ**

- ឱ្យកុមារសង្កេតអ្វីដែលបានឃើញនៅតាមផ្លូវ
- ទាញអារម្មណ៍កុមារពេលជិតទៅដល់ទីកន្លែងដែលត្រូវសង្កេត ដោយឱ្យកុមារឈប់ស្ដាប់ ឬសង្កេតពីចម្ងាយ រួចប៉ាន់ស្មានទស្សន៍ទាយ

❖ **ពេលកំពុងទស្សនាសង្កេត**

- ឱ្យកុមារធ្វើការគួរសម (ជម្រាបសួរ...) ជាមួយម្ចាស់ទីកន្លែង
- ឱ្យកុមារសង្កេតសេរី និងសន្ទនាគ្នា
- បំផុស និងផ្ដល់យោបល់ឱ្យកុមារសង្កេត និងតាមដានសម្របសម្រួលកុមារ
- ឱ្យកុមារធ្វើទំនាក់ទំនងជាមួយម្ចាស់ទីកន្លែង គ្រូជាអ្នកសម្របសម្រួល
- ឱ្យកុមារសាកល្បងអនុវត្ត ដោយមានការសម្របសម្រួលពីម្ចាស់ទីកន្លែង

❖ **ក្រោយពេលទស្សនាសង្កេត (អាចនៅទីកន្លែងផ្ទាល់ ឬត្រឡប់មកដល់សាលារៀនវិញ)**

- កុមារឱ្យសន្ទនាគ្នាជាមួយមិត្តភក្តិឡើងវិញពីអ្វីដែលគេបានសង្កេត ឬនាំលេងល្បែងពង្រឹង ឬនាំកុមារគូរសេរីនូវអ្វីដែលគេម្នាក់ៗ បានសង្កេត ឬចាប់អារម្មណ៍

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### មុនពេលដឹកនាំកុមារទស្សនាសង្កេតគ្រូត្រូវ៖

- ធ្វើបញ្ជីស្រង់អ្វីដែលមាននៅជុំវិញសាលា និងនៅក្នុងសហគមន៍ (រុក្ខជាតិ សត្វ មនុស្ស ការងារសង្គម...)
- ជ្រើសរើសសកម្មភាពមួយតាមកម្មវិធីសិក្សា និងស្របតាមប្រធានបទ
- ធ្វើទំនាក់ទំនងជាមួយម្ចាស់ទីកន្លែង
- អាចដូរសកម្មភាពបានប្រសិនបើក្នុងតំបន់គ្មានសកម្មភាពដែលបានកំណត់ក្នុងកម្មវិធីសិក្សា។

### ឧទាហរណ៍៖ ទស្សនាសង្កេត វត្ត



❖ មុនពេលទស្សនាសង្កត

- នៅពេលបុណ្យភ្ជុំបិណ្ឌ និងបុណ្យចូលឆ្នាំខ្មែរតើយាយតាម៉ាក់ប៉ាធ្វើចង្ហាន់យកទៅណា?
- ណែនាំកុមារឱ្យដើរប្រកាន់ស្តាំ មិនប្រទ្បែងគ្នា និងជម្រាបសួរម្ចាស់ទីកន្លែង

❖ នៅតាមដងផ្លូវ

- តើនៅតាមដងផ្លូវកូនឃើញមានអ្វីខ្លះ?
- តើនៅខាងមុខ កូនឃើញមានអ្វីខ្លះ?

❖ ដល់ទីកន្លែងដែលត្រូវទស្សនាសង្កត

- នាំកុមារសំពះគួរសមគណៈកម្មការវត្ត និងអាចារ្យវត្ត
- នាំកុមារថ្វាយបង្គំព្រះពុទ្ធប្បដិមា ព្រះសង្ឃ គោរពចាស់ព្រឹទ្ធាចារ្យ
- ឱ្យកុមារសង្កេត និងប្រាប់ពីអត្ថន័យនៃទីកន្លែងសំខាន់ៗ ក្នុងវត្តដូចជា ព្រះវិហារ សាលាឆទាន ចេតិយ ដងទង់ ព្រះពុទ្ធប្បដិមា... ដោយមានការណែនាំពីព្រះសង្ឃ គ្រូជួយបំផុសផ្តល់យោបល់

និងអនុវត្តដោយមាន ការសម្របសម្រួលពីចាស់ព្រឹទ្ធាចារ្យ ដូចជា របៀបថ្វាយបង្គំព្រះសង្ឃ ការស្តាប់ឱវាទព្រះសង្ឃ ជាដើម

❖ ក្រោយពេលត្រឡប់មកដល់សាលារៀនវិញគ្រូនាំកុមារធ្វើសកម្មភាពផ្សេងៗ ដែលកុមារបានឃើញ។

### ខ.សង្កេត

- បង្ហាញរូបភាព ឬវត្ថុជាក់ស្តែងឱ្យកុមារសង្កេតដោយពញ្ញាក់អារម្មណ៍
- បំផុសគំនិតឱ្យកុមារសង្កេត ទុកពេលសង្កេត និងឱ្យកុមាររៀបរាប់ពីអ្វីដែលគេបានសង្កេត (ផ្នែកខាងក្រៅ ផ្នែកខាងក្នុង ដោយប្រើញ្ញាណទាំងប្រាំ)
- បំពេញបន្ថែមនូវអ្វីដែលកុមារមិនទាន់ស្គាល់ (បន្ថែមចំណេះដឹងថ្មី ផលប្រយោជន៍ និងផលប៉ះពាល់)
- សង្ខេបយកខ្លឹមសារៈសំខាន់ៗ របស់មេរៀន សម្រាប់ចំណេះដឹងថ្មីរបស់កុមារ
- បំផុសរកចំណងជើងមេរៀន។

> ចំពោះការសង្កេត គ្រូអាចអនុវត្តបត់បែនតាមស្ថានភាពជាក់ស្តែង ក្រុមតូច ឬក្រុមធំ និងធានាសម្ភារៈដែលយកមកសង្កេតមានអនាម័យ និងសុវត្ថិភាព។

### ឧទាហរណ៍៖ សង្កេត ផ្លែក្រូច





- បង្ហាញថង់អាថ៌កំបាំងមួយដែលមានផ្លែក្រូចនៅខាងក្នុងសម្រាប់កុមារទស្សន៍ទាយ
- ឱ្យកុមារស្ទាប ហិតពីខាងក្រៅ ខាងក្នុង និងទាយឈ្មោះវត្ថុដែលនៅក្នុងថង់នោះ
- ឱ្យកុមារលូកយកផ្លែក្រូចមកបង្ហាញ និងប្រាប់ឈ្មោះ ផ្ទៀងផ្ទាត់ចម្លើយទស្សន៍ទាយ
- នាំកុមារសង្កេតលក្ខណៈរូបផ្គុំខាងក្រៅរបស់ផ្លែក្រូច (ពណ៌ រាង ទង សណ្តង ក្លិន...)
  តើកូនសង្កេតឃើញលក្ខណៈខាងក្រៅរបស់ផ្លែក្រូចមានអ្វីខ្លះ?
- កុមារឆ្លើយតបសំណួរ និងចង្អុលប្រាប់ផ្នែកផ្សេងៗ នៃផ្លែក្រូច
- នាំកុមារសង្កេតផ្នែកក្នុងផ្លែក្រូច



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ចិត ឬបកសម្បកផ្លែក្រូច (សម្បកខាងក្នុងពណ៌ស សម្បកខាងក្រៅមានពណ៌លឿងលាយបៃតង)
- កុមាររៀបរាប់អំពីសម្បក ភ្លៃប សាច់ កំពឹស ទឹកគ្រាប់ ពណ៌...
- ឱ្យកុមារភ្លក់រសជាតិផ្លែក្រូច

- តើកូនចូលចិត្តញ៉ាំផ្លែក្រូចដែរឬទេ? ហេតុអ្វី?
- នៅផ្ទះកូន តើមានដើមក្រូចដែរឬទេ? ហើយកូនត្រូវធ្វើដូចម្ដេចដើម្បីឱ្យដើមក្រូចមានផ្លែល្អ?
- ឱ្យកុមារ១ ឬ២នាក់ ឡើងរៀបរាប់ឡើងវិញពីលក្ខណៈផ្លែក្រូច ផលប្រយោជន៍ និងការថែទាំ
- សង្ខេបខ្លឹមសារមេរៀននិងផ្សារភ្ជាប់ចំណេះដឹងថ្មីៗ ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ
- តើថ្ងៃនេះ អ្នកគ្រូនាំកូនសង្កេតពីផ្លែអ្វី?

## គ.ពិសោធន៍

- បង្ហាញសម្ភារៈឱ្យកុមារប្រាប់ឈ្មោះ
- ដាក់បញ្ហាឱ្យកុមារប៉ាន់ស្មាន ឬទស្សន៍ទាយ (បញ្ហាឆ្លើយតបនឹងវត្ថុបំណងមេរៀន)
- កត់ត្រាចម្លើយប៉ាន់ស្មានរបស់កុមារ
- បែងចែកសម្ភារៈពិសោធន៍តាមក្រុម
- កុមារពិសោធ ឬអនុវត្ត
- សម្របសម្រួលតាមក្រុម និងជំរុញការពិសោធរបស់កុមារឱ្យឆ្លើយតបនឹងវត្ថុបំណងមេរៀន
- តំណាងក្រុមឡើងរាយការណ៍ពីលទ្ធផលនៃការពិសោធ
- ផ្ទៀងផ្ទាត់លទ្ធផលនៃការពិសោធទៅនឹងចម្លើយប៉ាន់ស្មានរបស់កុមារ
- បំផុសរកចំណងជើងដែលបានពិសោធន៍
- បូកសរុប និងសន្និដ្ឋាន៖
  - ចំណេះដឹងវិទ្យាសាស្ត្រ៖ នាំកុមារឱ្យដឹងពីហេតុនិងផលដែលកើតចេញពីការពិសោធ
  - ចំណេះដឹងភាសា៖ នាំកុមារអានពាក្យថ្មីៗ ដែលចេញពីការពិសោធ និងយល់ន័យនៃពាក្យទាំងនោះ
  - ការអប់រំ៖ ផ្សារភ្ជាប់ចំណេះដឹងទៅនឹងជីវភាពប្រចាំថ្ងៃ។

គ្រូត្រូវត្រៀមសម្ភារៈសម្រាប់ពិសោធន៍តាមក្រុម និងធ្វើការពិសោធខ្លួនឯងជាមុន។

ឧទាហរណ៍៖ ពិសោធន៍ លិច អណ្តែត (បន្លែ)



- បង្ហាញបន្លែដែលមាននៅក្នុងថង់ម្តងមួយៗឱ្យកុមារប្រាប់ឈ្មោះ(ផ្លែថាវ ល្ហុងខ្ចី ដំឡូងបារាំង...) និងសម្ភារៈដែលត្រូវប្រើក្នុងពេលពិសោធន៍
- ដាក់បញ្ហា៖ គ្រូមានបន្លែ និងសម្ភារៈទាំងអស់នេះ កូនទាំងអស់គ្នាយកទៅសង្កេត តើវាមានអ្វីកើតឡើងនៅពេលដាក់វាទៅក្នុងទឹក?
- កត់ត្រាចម្លើយប៉ាន់ស្មានរបស់កុមារ
- បែងចែកកុមារ និងសម្ភារៈដើម្បីឱ្យកុមារពិសោធតាមក្រុម
- កុមារអនុវត្តការពិសោធ
- សម្របសម្រួលតាមក្រុម និងជំរុញការពិសោធរបស់កុមារឱ្យឆ្លើយតបនឹងវត្ថុបំណងមេរៀន
- តំណាងក្រុមឡើងរាយការណ៍ពីលទ្ធផលនៃការពិសោធ ៖ ផ្លែថាវ ល្ហុងខ្ចី អណ្តែតលើទឹក និង ដំឡូងបារាំង លិចទៅក្នុងទឹក...
- ផ្ទៀងផ្ទាត់លទ្ធផលនៃការពិសោធទៅនឹងចម្លើយប៉ាន់ស្មានរបស់កុមារ
- តើយើងពិសោធន៍អំពីអ្វីថ្ងៃនេះ?
- បូកសរុប និងសន្និដ្ឋាន
    - ចំណេះដឹងវិទ្យាសាស្ត្រ៖ បន្លែដែលធ្ងន់ គឺលិចចូលក្នុងទឹក បន្លែដែលស្រាលគឺអណ្តែតលើទឹក
    - ចំណេះដឹងភាសា៖ នាំកុមារថាតាមពាក្យថ្មីៗ និងអត្ថន័យនៃពាក្យលិច (គឺលិចចុះទៅក្នុងទឹក) អណ្តែត(ស្ថិតនៅលើទឹក)
    - ការអប់រំ៖ ពេលកូនទៅផ្ទះវិញ កូនឱ្យប៉ាម៉ាក់ស្ងោបន្លែគ្រប់មុខឱ្យកូនញ៉ាំ ទើបជួយកូនឱ្យមានសុខភាពល្អ។ បើមានអ្នកណាលង់ទឹក ត្រូវតោងរករបស់ណាដែលអណ្តែតទឹក។

## ៣.៤.២. ការអនុវត្ត

ដើម្បីពង្រឹងប្រសិទ្ធភាពការងារសម្រាប់អនុវត្តការរៀន និងបង្រៀនមាន៖

- ការរៀន និងបង្រៀនត្រូវអនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌល
- ការសិក្សារបស់កុមារត្រូវធ្វើតាមរយៈការលេង និងសហការ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- កុមារត្រូវបានផ្តល់ទំនុកចិត្ត ការលើកទឹកចិត្ត និងការទទួលខុសត្រូវក្នុងការរៀនសូត្រប្រកបដោយសុវត្ថិភាព និងភាពកក់ក្តៅ
- អន្តរកម្មនៃការសិក្សាប្រកបដោយគុណភាព កុមារនឹងទទួលបានចំណេះដឹង បំណិន និងឥរិយាបថថ្មីៗ បន្ថែមទៀតពីបរិយាកាសសិក្សារបស់ខ្លួន
- កុមារជាអ្នកកសាងសមត្ថភាពខ្លួនឯង គ្រូជាអ្នកណែនាំ និងសម្របសម្រួលដើម្បីឱ្យកុមាររៀនសូត្របានប្រសើរ
- ការរៀបចំកិច្ចតែងការបង្រៀនត្រូវធ្វើតាមគោលវិធីចម្រុះ
- បង្កើតយន្តការតាមដានការរៀនសូត្ររបស់កុមារប្រកបដោយប្រសិទ្ធភាព
- ការរៀន និងបង្រៀនត្រូវដំណើរការស្របតាមអាយុ វប្បធម៌ និងសីលធម៌
- ការរៀន និងបង្រៀនត្រូវមានលក្ខណៈជាក់ស្តែង និងវិទ្យាសាស្ត្រ
- សាលារៀន និងគ្រូបង្រៀនត្រូវធ្វើអន្តរកម្មជាមួយអាណាព្យាបាល សហគមន៍ និងរដ្ឋអំណាចដើម្បីធានាគុណភាព និងប្រសិទ្ធភាព។

## ៣.៤.៣. សកម្មភាពចម្រុះនៃមុខវិជ្ជាវិទ្យាសាស្ត្រ

❖ យុទ្ធសាស្ត្រសម្រាប់ការរុករករបស់កុមារ

ការរៀនសូត្ររបស់កុមារត្រូវបានអភិវឌ្ឍន៍ នៅពេលដែលពួកគេមានឱកាសស្វែងរកហេតុ និងផលនូវអ្វីដែលកើតឡើងនៅក្នុងពិភពលោក។ គ្រូបង្រៀនអាចរៀបចំផែនការ និងចូលរួមជាមួយកុមារ នៅក្នុងសកម្មភាពរុករក សង្កេត ដើម្បីស្វែងរកចម្លើយ និងយល់ពីអ្វីដែលពួកគេចង់បាន តាមរយៈការរកឃើញរបស់កុមារដោយប្រើសួរសំណួរ និងណែនាំសម្ភារៈ រួមទាំងការផ្តល់ធនធានគ្រប់បែបយ៉ាងដើម្បីបង្កើនស្មារតី ចង់ដឹង ចង់ឃើញ នាំឱ្យកើតមានអារម្មណ៍រំភើបចំពោះការរកឃើញរបកគំហើញថ្មីរបស់ពួកគេ។

❖ **យុទ្ធសាស្ត្រដែលលើកទឹកចិត្តដល់កុមារក្នុងការរកឃើញអ្វីមួយរួមមាន៖**

- ការសួរសំណួរ
- ការផ្តល់ឱកាសសម្រាប់ការពិសោធន៍សាមញ្ញៗ
- ការគាំទ្ររបស់សហគមន៍ចំពោះសកម្មភាពថ្នាក់រៀន
- ការដឹកនាំការធ្វើដំណើរតាមបរិវេណខាងក្រៅថ្នាក់ និងសាលារៀន
- ការផ្តល់ឱកាសសម្រាប់សកម្មភាពនៅខាងក្រៅ
- ការប្រើប្រាស់ដ្យាក្រាម និងអ្នករៀបចំក្រាហ្វិច
- ការប្រើប្រាស់សៀវភៅអក្សរសាស្ត្រ និងសៀវភៅព័ត៌មានរបស់កុមារ
- ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា និងប្រព័ន្ធផ្សព្វផ្សាយ
- បណ្តុះគំនិតឱ្យស្រឡាញ់ ចូលចិត្ត និងយកចិត្តទុកដាក់ដល់បរិស្ថាន។

## ការសួរសំណួរ

សំណួរល្អធ្វើឱ្យកុមាររំភើបចិត្ត ទាក់ទាញអារម្មណ៍ និងលើកទឹកចិត្តកុមារឱ្យឆ្លើយតបភ្លាមៗ ដោយភាពជឿជាក់។ ការសួរសំណួរត្រឹមត្រូវទៅកាន់កុមារអាចនាំឱ្យពួកគេកំណត់ទិស និងគោលបំណងច្បាស់លាស់ជំរុញដល់ការចូលរួម និងបង្កើតចំណាប់អារម្មណ៍ថ្មី ដោយបង្កើតជាសំណួរផ្សេងៗ ទៀត ដោយឯកឯង។ សំណួរល្អជាសំណួរដែលគាំទ្រដល់ការរុករក និងការត្រិះរិះពិចារណាមានការផ្ដោតអារម្មណ៍ច្បាស់លាស់ ភាពច្បាស់លាស់នៃសំណួរ សំឡេងសួរសមស្រប និងអាចអនុវត្តដូចចំណុចខាងក្រោម៖

- ជំរុញ និងរក្សាចំណាប់អារម្មណ៍របស់កុមារ
- ស្វែងយល់អំពីចំណេះដឹង ឬសមត្ថភាពមានស្រាប់របស់កុមារ
- អភិវឌ្ឍការគិតពិចារណា និងអាកប្បកិរិយាសួរសំណួរដេញដោលរបស់កុមារ
- ពង្រីកការគិតរបស់កុមារ
- វាយតម្លៃលទ្ធផលនៃការសម្រេចគោលដៅសិក្សារបស់កុមារ

គ្រូត្រូវផ្ដល់ឱ្យកុមារនូវពេលវេលាគ្រប់គ្រាន់ដើម្បីឆ្លើយតបនឹងសំណួរដែលបានសួរ។ ទុកពេលវេលាដើម្បីឱ្យកុមារបានគិតពិចារណាមុនឆ្លើយ ហើយមិនបង្ហាញពីអារម្មណ៍ធុញទ្រាន់ ឬរំខានដល់ការគិតរបស់ពួកគេ ដើម្បីឱ្យកុមារឆ្លើយតបសំណួរបានត្រឹមត្រូវ។ គ្រូអាចបង្កើត និងសួរសំណួរដែលបើក ដូចជា «ហេតុអ្វី? យ៉ាងម៉េច?តើនឹងមានអ្វីកើតឡើងប្រសិនបើ? តើកូនគិតយ៉ាងណា?» ដើម្បីពង្រីកការគិតរបស់កុមារអំឡុងពេលធ្វើការងារក្រុម ឬពេលដែលកុមារកំពុងលេងនៅឯសាលា ឬទីកន្លែងណាមួយ។ សំណួរបើកជំរុញឱ្យមានការពិភាក្សា អាចប្រើដើម្បីលើកទឹកចិត្តកុមារឱ្យចេះដោះស្រាយបញ្ហា បង្កើតការប៉ាន់ស្មាន និងបង្កើតជាគំនិត ឬការសន្និដ្ឋានអំពីសកម្មភាពរបស់ពួកគេ។ សំណួរទាំងនេះក៏ជួយជំរុញឱ្យកុមារមានអារម្មណ៍ចូលចង់ដឹង និងចង់ឃើញ។ ពេលខ្លះ គ្រូក៏អាចសួរសំណួរបិទដែរ ឬសំណួរដែលត្រូវការចម្លើយសាមញ្ញខ្លី និងត្រឹមត្រូវដើម្បីជួយកុមារចងចាំព័ត៌មាន និងផ្ដោតការយកចិត្តទុកដាក់របស់ពួកគេ។ គ្រូគួរចៀសវាងសួរដេញដោលសំណួរដែលទាមទារចម្លើយ«មែន» ឬ«ទេ»។

ឧទាហរណ៍មួយចំនួននៃសំណួរបើកដើម្បីលើកទឹកចិត្តកុមារ ចង់ដឹង ចង់ឃើញ និងការគិតត្រិះរិះពិចារណា៖

- តើកូនគិតថានឹងមានអ្វីកើតឡើងប្រសិនបើអ្នកចាក់ទឹកចូលក្នុងដបទឹកដាក់ខ្យង?
- តើហេតុអ្វីបានជាកូនគិតថាខ្យងផ្លាស់ទីយឺតលើផ្ទៃស្ងួត?
- តើកូនអាចធ្វើឱ្យខ្យងផ្លាស់ទីលឿនជាងមុនយ៉ាងដូចម្ដេច?
- តើមានវិធីណាខ្លះដើម្បីធ្វើឱ្យខ្យងផ្លាស់ទីលឿនជាងមុន?
- ហេតុអ្វីបានជាខ្យងមានសំបក?
- តើខ្យងខុសគ្នាយ៉ាងណាពីដង្កូវ?

ឧទាហរណ៍មួយចំនួននៃសំណួរងាយៗ ដើម្បីជួយរំលឹកព័ត៌មាន និងផ្ដោតការយកចិត្តទុកដាក់៖

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- តើខ្យងមានពណ៌អ្វី?
- តើសម្បកខ្យងជាអ្វី? តើវាមានអារម្មណ៍យ៉ាងណា?
- តើពណ៌និងស្លាកស្នាមអ្វីខ្លះដែលកូនអាចរកបាននៅលើសម្បកខ្យង?
- តើខ្យងចូលចិត្តបន្លែប្រភេទអ្វី?

## ការផ្ដល់ឱកាសសម្រាប់ការពិសោធន៍សាមញ្ញៗ

កុមារនិយាយបណ្ដើរចាប់យកវត្ថុបណ្ដើរ ដែលពួកគេអាចប៉ះបានដោយគ្រូត្រូវរៀបចំ និងផ្លាស់ប្ដូរបរិយាកាស និងបង្កឱកាសឱ្យពួកគេស្វែងយល់ពីរពីការប្រែប្រួលនៅក្នុងពេលអនុវត្តថាមានអ្វីកើតឡើង។ ការពិសោធន៍ធ្វើឱ្យកុមារបង្ហាញភាពខុសគ្នានៃជំនាញផ្ទាល់ខ្លួនដែលឆ្លុះបញ្ចាំងពីដំណើរការ និងការចិញ្ចឹមបីបាច់របស់គ្រួសារពួកគេ។ កុមារធ្វើការប្ដេជ្ញាចិត្តវិជ្ជមាននៅពេលពួកគេធ្វើការសង្កេតសាកល្បងគំនិតប្រមូលព័ត៌មាននិងបង្កើតរបកគំហើញថ្មីៗ តាមរយៈការអនុវត្តការពិសោធន៍សាមញ្ញៗ ដែលត្រូវបានរៀបចំដោយខ្លួនឯងនិងឆ្លើយសំណួរដែលពួកគេឆ្ងល់កន្លងមក។

នៅក្នុងដំណើរការនៃការពិសោធន៍ គំនិតពិបាកៗ នាំឱ្យកុមារកើតមានគំនិតធុញថប់ មិនចង់ចូលរួមព្រោះហួសពីសមត្ថភាពពួកគេដែលត្រូវស្វែងយល់ពីបញ្ហាទាំងនេះ។ ទោះជាយ៉ាងណាក៏ដោយការអភិវឌ្ឍកុមារមុនចូលសាលាមិនមានការរីកចម្រើនល្អប្រសើរទេលើផ្នែកវិទ្យាសាស្ត្រ។ ផ្ទុយទៅវិញ គ្រូត្រូវបានលើកទឹកចិត្តដោយធ្វើការពន្យល់កុមារតាមការយល់ដឹង និងតាមពាក្យសំដីរបស់កុមារផ្ទាល់។ កុមារធ្វើតាមការណែនាំសាមញ្ញៗ ដើម្បីអនុវត្តការពិសោធន៍រកឱ្យឃើញ តើអ្វីៗ នឹងដំណើរការយ៉ាងដូចម្ដេច?

ឧទាហរណ៍នៃការពិសោធន៍សាមញ្ញៗ

ការពិសោធន៍របស់កុមារការលេងជាមួយទឹក៖

- ទស្សន៍ទាយ និងកំណត់ថា តើវត្ថុមួយណានឹងអណ្ដែតទឹក ហើយវត្ថុមួយណានឹងលិចទឹក?
- ទស្សន៍ទាយ និងកំណត់ថា តើសម្ភារៈអ្វីខ្លះដែលនឹងរលាយនៅក្នុងទឹក?
- ទស្សន៍ទាយថា តើធុងមួយណាផ្ទុកទឹកច្រើន ឬតិច ដោយរកចំនួនពែងទឹកដែលត្រូវការដើម្បីបំពេញធុងដែលមានរាង និងទំហំ ខុសៗគ្នា
- សង្កេតមើលរបៀបការផ្លាស់ប្ដូររបស់ទឹកតាមវត្ថុដែលផ្ទុក
- ទស្សន៍ទាយទុកមុនថា តើសម្ភារៈណាខ្លះ(កំណាត់ ឬក្រដាស)នឹងស្ងួតលឿនជាង មុនមានពន្លឺព្រះអាទិត្យ?
- ប៉ាន់ស្មាន និងសង្កេតមើលថា តើនឹងមានអ្វីកើតឡើងនៅពេលលក្ខណ៍ពណ៌អាហារត្រូវបានដាក់ចូលក្នុងទឹក?

កុមារនឹងទស្សន៍ទាយថា វត្ថុមួយណានឹងអណ្តែត ហើយមួយណាវានឹងលិច ដោយការរៀបចំការពិសោធន៍ដ៏សាមញ្ញមួយ ដើម្បីសាកល្បងការទស្សន៍ទាយ។ ការរកឃើញរបស់កុមារនឹងពន្យល់ថាពីការប៉ាន់ស្មាន និងការពិសោធន៍ជាក់ស្តែង។

### ការគាំទ្ររបស់សហគមន៍ចំពោះសកម្មភាពថ្នាក់រៀន

ការអញ្ជើញអ្នកជំនាញ ឬមនុស្សដែលធ្វើការនៅក្នុងសហគមន៍ ដូចជា អ្នកសិប្បកម្ម ប៉ូលីស អ្នកពន្លត់អគ្គីភ័យ នាយកសាលា គ្រូពេទ្យ គិលានុបដ្ឋាយិកា ពេទ្យសត្វ ចុងភៅ ស្ថាបត្យករ អ្នកបើកបរ ក្រុមយុវជនជំនាន់ក្រោយ និងមនុស្សដែលធ្វើការនៅកន្លែងដូចជា បណ្ណាល័យ ផ្សារទំនើប សួនសត្វ សារមន្ទីរ សិល្បករ វិចិត្រករ គឺជាធនធានដ៏ល្អបំផុតដែលនឹងជួយកុមារឱ្យរកចម្លើយនៃសំណួររបស់ពួកគេ។ អ្នកជំនាញ ឬធនធានមនុស្សទាំងនេះ អាចត្រូវបានអញ្ជើញឱ្យនិយាយអំពីការងារ តួនាទី ភារកិច្ច និងសម្ភារៈដែលពួកគេប្រើ។ សមាជិកគ្រួសាររបស់កុមារក៏អាចត្រូវបានអញ្ជើញឱ្យផ្តល់ព័ត៌មានពីតួនាទី ចំណាប់អារម្មណ៍ ចំណង់ចំណូលចិត្ត និងជំនាញដល់កុមារផងដែរ។ ដើម្បីប្រមូលព័ត៌មាន កុមារអាចបង្កើតសំណួរជាច្រើនជាមុន ដើម្បីសម្ភាសន៍អ្នកជំនាញ ឬធនធានមនុស្សដែលនៅក្នុងសហគមន៍។ ការអញ្ជើញមនុស្សដែលមានធនធានមកថ្នាក់រៀនបង្កើនការយល់ដឹងនិងជំនួយដល់កុមារ។ កុមារឱ្យតម្លៃចំពោះតួនាទីរបស់សមាជិកគ្រួសារ និងមនុស្សដែលធ្វើការនៅក្នុងសហគមន៍ ។ ការចូលរួមពីធនធានសហគមន៍ និងសមាជិកគ្រួសារ បង្កើនបទពិសោធន៍ការរៀនសូត្ររបស់កុមារ និងលើកទឹកចិត្តសហគមន៍ និងក្រុមគ្រួសារ ក្នុងការចូលរួមអប់រំកុមារ។ សកម្មភាពនេះជួយពង្រឹងការភ្ជាប់ទំនាក់ទំនងគ្រួសារ សហគមន៍ទៅនឹងសាលារៀន។

ឧទាហរណ៍អំពីអ្នកជំនាញ ឬបុគ្គលដែលជាធនធានមនុស្សនៅក្នុងសហគមន៍៖

- ស្ថាបត្យករដើម្បីនិយាយអំពីការរចនាអាគារ និងសំណង់
- ឪពុកម្តាយដែលមានទារកទើបនឹងកើតដើម្បីជួយកុមារឱ្យយល់ដឹងពីរបៀបដែលពួកគេមានលូតលាស់ និងអភិវឌ្ឍន៍
- ឪពុកម្តាយ ឬជីដូនជីតា ដែលពូកែចម្អិន និងធ្វើម្ហូបដើម្បីនិយាយអំពីម្ហូប
- អ្នកថែសួនចូលរួមចែករំលែកបទពិសោធន៍ និងបង្ហាញអំពីចំណាប់អារម្មណ៍ក្នុងការថែទាំរុក្ខជាតិឱ្យមានការរីកលូតលាស់
- អ្នកចូលចិត្តកីឡា កីឡាករ អាចចែករំលែកបទពិសោធន៍អំពីលំហាត់ប្រាណ ប្រភេទអាហារដែលត្រូវបរិភោគដើម្បីមានសុខភាពល្អនិងរាងកាយរឹងមាំ
- វេជ្ជបណ្ឌិតបង្ហាញពីរបៀបដែលពួកគេប្រើប្រាស់សម្ភារៈ ឧបករណ៍ នៅក្នុងផ្នែកវេជ្ជសាស្ត្ររបស់ពួកគេ ដើម្បីធ្វើការពិនិត្យសុខភាព និងជួយអ្នករបួស
- ទន្តពេទ្យនិយាយអំពីការថែទាំសុខភាពមាត់ធ្មេញ និងអ្វីដែលពួកគេធ្វើនៅពេលមានអ្នកមកជួបពិភាក្សាជាមួយនៅគ្លីនិចធ្មេញដើម្បីបន្ធូរបន្ថយការភ័យខ្លាចរបស់កុមារដែលអាចកើតមាននៅពេលទៅជួបពេទ្យធ្មេញ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ប៉ូលីស អ្នកពន្លត់អគ្គីភ័យ និយាយអំពីរបៀបដែលពួកគេជួយសហគមន៍ និងបង្ហាញពីការណែនាំជាមូលដ្ឋានដើម្បីធានាសុវត្ថិភាពសាធារណៈ និងសុវត្ថិភាពផ្ទាល់ខ្លួននៅក្នុងផ្ទះ។

### ការដឹកនាំការធ្វើដំណើរតាមបរិវេណខាងក្រៅថ្នាក់ និងសាលារៀន

ការធ្វើដំណើរទៅទីកន្លែងខាងក្រៅថ្នាក់រៀនបង្កើនចំណាប់អារម្មណ៍ និងការយល់ដឹងរបស់កុមារ អំពីបរិស្ថាន និងពិភពខាងក្រៅជុំវិញកុមារ ដោយផ្តល់ឱ្យកុមារទទួលបានព័ត៌មានពិតប្រាកដដែលកើតមាននៅក្នុងសង្គមបានល្អិតល្អន់ជាងនេះ។ ការធ្វើដំណើរទស្សនាសង្កេតខាងក្រៅក៏លើកកម្ពស់ការគោរព ការកោតសរសើរ និងអារម្មណ៍រំភើប។ លើសពីនេះ ដំណើរកម្សាន្តនៅខាងក្រៅបានផ្តល់ឱកាសឱ្យកុមារធ្វើអន្តរកម្មសហការ និងការប្រាស្រ័យទាក់ទងជាមួយមនុស្សផ្សេងទៀត។

ដំណើរកម្សាន្តនៅខាងក្រៅមានគោលបំណងនៃការបង្រៀន និងការរៀនសូត្រ ដែលកំណត់ដោយគ្រូ ហើយពាក់ព័ន្ធនឹងកុមារការចូលរួម និងការចូលរួមយ៉ាងសកម្មក្នុងដំណើរកម្សាន្ត។ ឧទាហរណ៍ ការធ្វើដំណើរទៅកសិដ្ឋានដាំបន្លែ ផ្តល់ជូនកុមារនូវបទពិសោធន៍ដោយប្រើញាណទាំង៥ ដើម្បីប្រមូលព័ត៌មាននិងទទួលបានការយល់ដឹងអំពីរបៀបដាំបន្លែ ការប្រមូលផល និងដឹកជញ្ជូនទៅកាន់ទីផ្សារសម្រាប់លក់។

សម្រាប់ការធ្វើដំណើរទៅខាងក្រៅ ត្រូវចាំបាច់ត្រូវរៀបចំផែនការដោយប្រុងប្រយ័ត្ន អនុញ្ញាតឱ្យកុមារទៅអនុវត្ត ជំនាញដំណើរការ ដូចជា ធ្វើការសង្កេត និងកត់ត្រារបៀបពីការរៀបចំ ការចាត់ថ្នាក់...។

ឧទាហរណ៍ ទីកន្លែងគួរឱ្យចាប់អារម្មណ៍សម្រាប់ការធ្វើដំណើរទស្សនកិច្ចនៅខាងក្រៅ៖

- ហាងលក់នំ ហាងកាត់សក់ ហាងលក់កាហ្វេ គ្លីនិក កន្លែងចិញ្ចឹមសត្វ អាងចិញ្ចឹមត្រី កន្លែងលក់ផ្កា
- ប៉ុស្តិ៍ប៉ូលីស ស្ថានីយ៍ពន្លត់អគ្គីភ័យ មជ្ឈមណ្ឌលសហគមន៍ ក្លឹបហាត់ប្រាណ
- សាលាបឋមសិក្សា
- កន្លែងបណ្តុះកូនឈើ សួនផ្កា ចំការបន្លែ
- ភោជនីយដ្ឋាន
- ទីកន្លែងសំខាន់ៗ ក្នុងសហគមន៍ ដូចជា វត្តអារាម ភ្នំ ប្រាសាទ...

បង្កើតរូបភាព ឬផ្ទាំងរូបភាព ដើម្បីបង្ហាញពីរបស់របរដែលកុមារបានសង្កេត ឬរៀន បន្ទាប់ពីបានទៅទស្សនានៅទីកន្លែងណាមួយរួចមក និងជួយឱ្យកុមារដឹង ដោយពង្រឹងចំណេះដឹងតាមរយៈការឆ្លុះបញ្ចាំងពីការរៀនសូត្ររបស់ពួកគេ។

### ការផ្តល់ឱកាសសម្រាប់សកម្មភាពនៅខាងក្រៅ

បរិយាកាសខាងក្រៅផ្តល់ជូនកុមារនូវការទំនាក់ទំនងផ្ទាល់ជាមួយពិភពធម្មជាតិ។ វាក៏អាចធ្វើឱ្យកុមារមានសកម្មភាពរាងកាយ និងលើកទឹកចិត្តឱ្យកុមាររុករកដោយសេរី តាមរយៈអារម្មណ៍ និងបទពិសោធន៍ផ្ទាល់ខ្លួន ។ កុមារអាចហិតក្លិនផ្កា និងរុក្ខជាតិ ស្តាប់សំឡេងយន្តហោះឆ្លងកាត់ បក្សាបក្សី មានអារម្មណ៍ថាស្មៅទន់នៅ

លើជើងរបស់កុមារ និងបទពិសោធន៍នៃខ្យល់បក់នៅលើមុខរបស់កុមារ។ នៅពេលកុមារស្វែងយល់ពីបរិយាកាសខាងក្រៅដូចជា ការជីកដី រើសយកក្រួស និងថ្ម ដែលមានរាង និងទំហំខុសៗគ្នា កុមារបានរៀនអំពីធម្មជាតិ ដោយធ្វើការត្រិះរិះពិចារណាពីកម្រិត ធ្ងន់ ស្រាល គ្រើម រលោង ធំ តូច...។ ញ្ញាណទាំង៥ គឺជាបទពិសោធន៍អាចជួយជំរុញអារម្មណ៍របស់កុមារឱ្យឆ្ងល់ និងពង្រឹងភាពវិជ្ជមាន មានឥរិយាបថស្រឡាញ់បរិស្ថាន និងបណ្ដុះស្មារតីខិតខំការរៀនសូត្រ។

### ការប្រើប្រាស់ដ្យាក្រាម និងអ្នករៀបចំក្រាហ្វិច

ការគូររូបភាព លំហូរនៃគំនូសតាង ឬដ្យាក្រាម គឺជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការជួយកុមារយល់ពីលំដាប់លំដោយនៃព្រឹត្តិការណ៍ជាច្រើន និងការផ្លាស់ប្ដូរ។ ដោយមើលឃើញតំណាងឱ្យវដ្ដជីវិតនៃសត្វមួយ ការលូតលាស់របស់រុក្ខជាតិ និងរបៀបចម្អិនអាហារ ធ្វើឱ្យកុមារមានដំណើរការផ្លាស់ប្ដូរដោយមើលឃើញ និងធ្វើឱ្យយល់ពីអ្វីដែលពួកគេជួបប្រទះ ឬបទពិសោធន៍របស់កុមារ។ កុមារនឹងទទួលបាននូវពាក្យវាក្យស័ព្ទថ្មីៗ ដើម្បីរៀន និងអ្វីដែលកុមារត្រូវកំណត់អត្តសញ្ញាណដូចជា ផ្នែកផ្សេងៗរបស់សត្វ រុក្ខជាតិ ឧបករណ៍វិទ្យាសាស្ត្រ និងឧបករណ៍ផ្សេងៗ។ ការគូររូបភាពនៃរបស់ទាំងនេះ ជួយឱ្យកុមារចងចាំព័ត៌មាន ហើយបង្ហាញរូបភាពទាំងនេះនៅលើក្ដារខៀន ឬតាមជញ្ជាំងដែលអាចឱ្យកុមារយកធ្វើជាយោងនៅពេលពួកគេត្រូវព័ត៌មាននៅពេលក្រោយ។

អ្នករៀបចំក្រាហ្វិចអាចត្រូវបានប្រើដើម្បីបញ្ជាក់ និងលម្អិតគ្រប់ប្រភេទនៃព័ត៌មាន។ គ្រូអាចប្រើអ្នករៀបចំក្រាហ្វិចដើម្បី៖

- ណែនាំកុមារតាមរយៈដំណើរការនៃការគិត
- ជួយកុមារឱ្យចាត់ថ្នាក់ និងទំនាក់ទំនងនៃគំនិតរបស់ពួកគេ
- ជួយកុមារដោយផ្ដល់ជូននូវការបង្ហាញនូវទស្សនទាន គំនិត និងទំនាក់ទំនងរបស់ពួកគេ

គ្រូបង្រៀនអាចប្រើជាដ្យាក្រាម Venn ដែលជួយកុមារចេះធ្វើការប្រៀបធៀប និងអ្វីៗ ដែលផ្ទុយគ្នា។ ការរៀបចំផ្សេងទៀត អាចជួយកុមារឱ្យចេះរៀបចំព្រឹត្តិការណ៍តាមលំដាប់លំដោយដូចជា ខ្សែសង្វាក់ម្ហូបអាហារ វដ្ដសត្វ វដ្ដទឹក...។ គំនូសតាង KWL ជួយកុមារ និងគ្រូឱ្យដឹងពីអ្វីដែលពួកគេបានដឹងដែលជាចំណេះដឹងមានស្រាប់របស់កុមារ(K) តើមានអ្វីផ្សេងៗទៀតដែលពួកគេចង់ដឹង(W) និងអ្វីដែលពួកគេបានរៀន(L)។ អ្នករៀបចំក្រាហ្វិចក៏អាចប្រើ ដើម្បីជួយកុមារក្នុងការរៀបចំគំនិតរបស់ពួកគេនៅពេលធ្វើការសង្កេត ឬការពិសោធន៍។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ឧទាហរណ៍៖ ដ្យាក្រាម Venn សម្រាប់ការប្រៀបធៀប




## <u>គំនូសតាង KWL</u>

| **អ្វីៗដែលយើងស្គាល់ពី...(K)** | **អ្វីៗដែលយើងចង់ដឹងបន្ថែមពី...(W)** | **អ្វីៗដែលយើងបានរៀនពី...(L)** |
|---|---|---|
| | | |
| | | |
| | | |

## <u>ដ្យាក្រាមសម្រាប់រៀបព្រឹត្តិការណ៍តាមលំដាប់លំដោយ</u>



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ដ្យាក្រាមសម្រាប់គំនិតស្វែងយល់




### ការប្រើប្រាស់សៀវភៅអក្សរសាស្ត្រ និងសៀវភៅព័ត៌មានរបស់កុមារ

យើងត្រូវមានសៀវភៅរូបភាព សៀវភៅរឿងនិទាន និងសៀវភៅដែលបង្ហាញអំពីបរិស្ថាន ជាច្រើនដែលបានសរសេរជាពិសេសសម្រាប់កុមារតូចៗ។ ប្រយោគក្នុងសៀវភៅទាំងនោះ គឺសាមញ្ញ ហើយត្រូវបានបង្ហាញរូបភាពយ៉ាងរស់រវើក។ សៀវភៅទាំងនោះ គឺជាភ្នាក់ងាររំញោចដ៏ល្អសម្រាប់គំនិតដែលកុមារចង់ដឹងចង់ឃើញ។ សៀវភៅអក្សរសាស្ត្ររបស់កុមារមិនត្រឹមតែផ្តល់ចំណេះដឹង និងជំរុញដំណើរការជំនាញប៉ុណ្ណោះទេ វាក៏ធ្វើឱ្យកុមារមានការចង់ដឹង ចង់លឺ និងផ្តល់ឱកាសឱ្យកុមារសាកសួរដើម្បីដោះស្រាយការងឿងឆ្ងល់។ អក្សរសាស្ត្រធ្វើឱ្យកុមារមានចំណាប់អារម្មណ៍ក្នុងការរៀនសូត្រពីពិភពលោក ដោយបង្ហាញចំណេះដឹងទៅតាមបរិបទមេរៀនដែលទាក់ទង ហើយខ្លឹមសារមេរៀនជួយកុមារឱ្យយល់ពីទំនាក់ទំនង និងដំណើរការយ៉ាងដូចម្តេចខ្លះ?

### ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា និងអន្តរកម្មប្រព័ន្ធផ្សព្វផ្សាយ

បច្ចេកវិទ្យា និងអន្តរកម្មប្រព័ន្ធផ្សព្វផ្សាយ គឺជាឧបករណ៍ដែលអាចលើកកម្ពស់ការបង្រៀនប្រកបដោយប្រសិទ្ធភាព និងការរៀនសូត្រ នៅពេលពួកគេត្រូវបានជ្រើសរើស ប្រើប្រាស់ និងវាយតម្លៃដោយ

ផ្ទាល់ និងតាមមធ្យោបាយសមស្រប។ រូបថត វីដេអូ ឌីវីឌី ភាពយន្ត ស្លាយកម្មវិធី ទូរទស្សន៍ សៀវភៅអេឡិច-ត្រូនិក អ៊ីនធឺណិត កម្មវិធីសូហ្វវែរ ដែលទាក់ទងនឹងប្រធានបទពិភាក្សាអាចត្រូវបានប្រើ និងបង្ហាញដល់កុមារ ដើម្បីពង្រឹងនិងពង្រីកចំណេះដឹងរបស់ពួកគេអំពីការវិវដ្តសាកលលោក។ កុមារក៏អាចប្រើបច្ចេកវិទ្យា និងអន្តរកម្មប្រព័ន្ធផ្សព្វផ្សាយ ដើម្បីស្វែងរកព័ត៌មានរៀន ជំនាញថ្មី ឬទំនាក់ទំនងជាមួយអ្នកដទៃ។ នៅពេលប្រើឧបករណ៍ទាំងនេះ គ្រូគួរតែពិនិត្យ និងធានាថាខ្លឹមសារមេរៀនសមស្របនឹងអាយុកុមារ និងឆ្លើយតបតាមគោលបំណងនៃមេរៀន។ ដូចគ្នានឹងធនធាន ឬឧបករណ៍ដទៃទៀតដែរ បច្ចេកវិទ្យានិងអន្តរកម្មប្រព័ន្ធផ្សព្វផ្សាយគួរតែត្រូវបានប្រើប្រាស់កម្រិតមធ្យម ដើម្បីលើកកម្ពស់ការយល់ដឹងកុមារ ហើយត្រូវបានបញ្ចូលទៅជាបទពិសោធន៍ក្នុងថ្នាក់រៀន។

បណ្តុះគំនិតឱ្យស្រឡាញ់ ចូលចិត្ត និងយកចិត្តទុកដាក់ដល់បរិស្ថាន។

ចំណាប់អារម្មណ៍ និងការដឹងគុណចំពោះពិភពធម្មជាតិ និងបរិស្ថាននឹងជួយដល់ការចង់ដឹង ចង់ឃើញរបស់កុមារអំពីបរិស្ថានរបស់ពួកគេ។ នៅពេលដែលគ្រូបង្រៀនជាអ្នកសង្កេតការណ៍ដែលចាប់អារម្មណ៍ចង់ដឹងចង់ឃើញ និងគោរពការយល់ដឹងរបស់កុមារអំពីបរិស្ថាន។ អារម្មណ៍ផ្ទាល់ខ្លួនរបស់គ្រូ ការងឿងឆ្ងល់ និងការចាប់អារម្មណ៍ក្នុងការស្វែងយល់បន្ថែមអំពីអ្វីមួយគឺមានសារៈសំខាន់ ដូចដែលបានបង្ហាញអាកប្ប-កិរិយា និងជំនាញដែលគ្រូចង់បានសម្រាប់កុមារ។ គ្រូត្រូវលើកទឹកចិត្តឱ្យប្រើភាសាដូចជា ខ្ញុំឆ្ងល់នៅកន្លែងណា? របៀបម៉េច?ហេតុអ្វី?... នៅពេលគិត កុមារក៏យកគម្រូប់តាម និងបង្ហាញអាកប្បកិរិយាវិជ្ជមានចំពោះបរិស្ថានដោយសង្កេតមើលប្រតិកម្ម និងអាកប្បកិរិយារបស់មនុស្សពេញវ័យ។ តាមរយៈការឆ្លើយតបរបស់មនុស្សពេញវ័យចំពោះវត្ថុផ្សេងៗ ដូចជា ថ្ម សម្បករុក្ខជាតិ សត្វ វប្បធម៌នៃជាតិសាសន៍ផ្សេងៗគ្នា ទម្លាប់បោះចោលសំរាម ការកែច្នៃ និងប្រើប្រាស់ឡើងវិញនូវសំណល់សំរាម។ កុមាររៀនថែទាំ និងគោរពបរិស្ថាន។

## ៣.៥. ដំណើរការបង្រៀន

- ខាងក្រោមនេះ ជាចំណាងជើងមេរៀន និងឧទាហរណ៍មួយចំនួន ទាក់ទងនឹងប្រធានបទវិទ្យាសាស្ត្រ
- លោកគ្រូ អ្នកគ្រូ អាចជ្រើសរើសមេរៀន ឬសកម្មភាពផ្សេងៗ ក្រៅពីនេះ ដែលគាំទ្រដល់ប្រធានបទ និងប្រើប្រាស់ឱ្យបានសមស្របតាមកម្រិតថ្នាក់

មេរៀនមួយចំនួនដែលពាក់ព័ន្ធនឹងប្រធានបទអាហារូបត្ថម្ភ

| ទស្សនាសង្កេត | សង្កេត | ពិសោធន៍ | សកម្មភាពគោលផ្សេងៗ |
|---|---|---|---|
| • ដើមឈើហូបផ្លែ<br>• សួនបន្លែ<br>• កន្លែងចិញ្ចឹមសត្វ | • បន្លែ (ជាមើម ជាស្លឹក និងជាផ្លែ)<br>• ផ្លែឈើ<br>• ក្រុមសាច់<br>• ក្រុមស៊ុតរបស់សត្វ<br>• គ្រាប់ធញ្ញជាតិ<br>• អាហារ ៣ក្រុម | • ភ្លក់រសជាតិផ្លែឈើ<br>• ភ្លក់រសជាតិបន្លែ | • ល្បែង៖ ចំណាត់ថ្នាក់បន្លែ និងផ្លែឈើ<br>• ល្បែង៖ ស្លសម្លកកូរ<br>• ល្បែង៖ ចំណាត់ថ្នាក់ក្រុមអាហារ (ក្រុមបន្លែ ក្រុមសាច់)<br>• ល្បែង៖ ប្រព័ន្ធគ្រួសារបន្លែ<br>• រឿងនិទាន៖ បាយ |

## ឧទាហរណ៍៖ សង្កេត ផ្លែស្វាយទុំ





### ១. ថ្នាក់កម្រិតទាប

#### ក. វត្ថុបំណង៖

- ប្រាប់ឈ្មោះផ្នែកខាងក្រៅ ផ្នែកខាងក្នុង និងរសជាតិផ្លែស្វាយទុំ ឬលើសពីនេះ បានត្រឹមត្រូវ
- កំណត់ពីផ្លែស្វាយទុំបានត្រឹមត្រូវ
- ចូលចិត្តញ៉ាំផ្លែឈើដើម្បីមានសុខភាពល្អរឹងមាំ ដាំដុះបន្ថែម ថែរក្សា និងស្រឡាញ់ធម្មជាតិ។

#### ខ. សម្ភារឧបទេស៖

- ផ្លែស្វាយទុំ ៤ ឬ ៥ផ្លែ សម្រាប់កុមារសង្កេតជាក្រុមតូចៗ
- ផ្លែស្វាយទុំចិតជាចំណិតតូចៗ សម្រាប់កុមារភ្លក់

#### គ. ការរៀបចំ៖

- ចែកកុមារជាក្រុមតូចៗ ៤ ឬ៥ក្រុម តាមសិស្សសរុបជាក់ស្តែងនៅក្នុងថ្នាក់រៀន

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### ឃ. ដំណើរការសកម្មភាព៖

- យកផ្លែស្វាយទុំដាក់ស្ដែងមកបង្ហាញដោយប្រើប្រាស់វិធីពញ្ញាក់អារម្មណ៍កុមារ (ដាក់ក្នុងថង់កំណាត់ពណ៌ឱ្យកុមារសង្កេត ឬហិត ឬស្ទាប រួចទស្សន៍ទាយ)
- អាចឱ្យកុមារសង្កេតជារួម ឬសង្កេតតាមក្រុមតូចៗ ដោយបំផុសគំនិតកុមារឱ្យសង្កេត និងរៀបរាប់ ឬរាយការណ៍តាមក្រុមពីអ្វីដែលកុមារបានស្គាល់ពីផ្លែស្វាយទុំ (ចំណេះដឹងមានស្រាប់របស់កុមារដោយប្រើញ្ញាណទាំងប្រាំ)
- បន្ថែមនូវគំនិតថ្មីៗ ដល់កុមារតាមរយៈការប្រើសំណួរបំផុស (ចំណេះដឹងថ្មី) ទាក់ទងនឹងផ្នែកខាងក្រៅ រូបរាង ពណ៌ សម្បក ទង ផ្នែកខាងក្នុង សាច់ គ្រាប់ ឬលើសពីនេះ
- ពុះផ្លែស្វាយទុំឱ្យកុមារសង្កេត និងឱ្យភ្លក់រសជាតិដែលបានរៀបចំរួច
- សង្ខេបខ្លឹមសារៈសំខាន់ៗ នៃមេរៀនឡើងវិញ
- សួរកុមារពីមេរៀនដែលរៀនថ្ងៃនេះ។

## ២. ថ្នាក់កម្រិតមធ្យម

### ក. វត្ថុបំណង៖

- ប្រាប់ឈ្មោះផ្នែកខាងក្រៅ ផ្នែកខាងក្នុង និងរសជាតិផ្លែស្វាយទុំ ឬលើសពីនេះ បានត្រឹមត្រូវ
- កំណត់ពីផ្លែស្វាយទុំបានត្រឹមត្រូវ
- ចូលចិត្តញ៉ាំផ្លែឈើដើម្បីមានសុខភាពល្អរឹងមាំ ដាំដុះបន្ថែម ថែរក្សា និងស្រឡាញ់ធម្មជាតិ។

### ខ. សម្ភារឧបទេស៖

- ផ្លែស្វាយទុំ ៤ ឬ ៥ផ្លែ សម្រាប់កុមារសង្កេតជាក្រុមតូចៗ
- ផ្លែស្វាយទុំចិតជាចំណិតតូចៗ សម្រាប់កុមារភ្លក់

### គ. ការរៀបចំ៖

- ចែកកុមារជាក្រុមតូចៗ ៤ ឬ៥ក្រុម តាមសិស្សសរុបជាក់ស្ដែងនៅក្នុងថ្នាក់រៀន

### ឃ. ដំណើរការសកម្មភាព៖

- យកផ្លែស្វាយទុំដាក់ស្ដែងមកបង្ហាញដោយប្រើប្រាស់វិធីពញ្ញាក់អារម្មណ៍កុមារ (ដាក់ក្នុងថង់កំណាត់ពណ៌ឱ្យកុមារសង្កេត ឬហិត ឬស្ទាប រួចទស្សន៍ទាយ)
- អាចឱ្យកុមារសង្កេតជារួម ឬសង្កេតតាមក្រុមតូចៗ ដោយបំផុសគំនិតកុមារឱ្យសង្កេត និងរៀបរាប់ ឬរាយការណ៍តាមក្រុមពីអ្វីដែលកុមារបានស្គាល់ពីផ្លែស្វាយទុំ (ចំណេះដឹងមានស្រាប់របស់កុមារដោយប្រើញ្ញាណទាំងប្រាំ)
- បន្ថែមនូវគំនិតថ្មីៗ ដល់កុមារតាមរយៈការប្រើសំណួរបំផុស (ចំណេះដឹងថ្មី) ទាក់ទងនឹងផ្នែកខាងក្រៅ រូបរាង ពណ៌ សម្បក ទង ផ្នែកខាងក្នុង សាច់ គ្រាប់ ពណ៌សាច់ គ្រាប់ ឬលើសពីនេះ

- ពុះផ្លែស្វាយទុំឱ្យកុមារសង្កេត និងឱ្យភ្លក់រសជាតិដែលបានរៀបចំរួច
- សង្ខេបខ្លឹមសារៈសំខាន់ៗ នៃមេរៀនឡើងវិញ។

### ៣. ថ្នាក់កម្រិតខ្ពស់

#### ក. វត្ថុបំណង៖

- ប្រាប់ឈ្មោះផ្នែកខាងក្រៅ ផ្នែកខាងក្នុង និងរសជាតិផ្លែស្វាយទុំ ផលប្រយោជន៍ ឬលើសពីនេះបានត្រឹមត្រូវ
- កំណត់ពីផ្លែស្វាយទុំបានត្រឹមត្រូវ
- ចូលចិត្តញ៉ាំផ្លែឈើដើម្បីមានសុខភាពល្អរឹងមាំ ដាំដុះបន្ថែម ថែរក្សា និងស្រឡាញ់ធម្មជាតិ។

#### ខ. សម្ភារឧបទេស៖

- ផ្លែស្វាយទុំ ៤ ឬ ៥ផ្លែ សម្រាប់កុមារសង្កេតជាក្រុមតូចៗ
- ផ្លែស្វាយទុំចិតជាចំណិតតូចៗ សម្រាប់កុមារភ្លក់

#### គ. ការរៀបចំ៖

- ចែកកុមារជាក្រុមតូចៗ ៤ ឬ៥ក្រុម តាមសិស្សសរុបជាក់ស្តែងនៅក្នុងថ្នាក់រៀន

#### ឃ. ដំណើរការសកម្មភាព៖

- យកផ្លែស្វាយទុំដាក់ស្តែងមកបង្ហាញដោយប្រើប្រាស់វិធីពញ្ញាក់អារម្មណ៍កុមារ(ដាក់ក្នុងថង់កំណាត់ពណ៌ឱ្យកុមារសង្កេត ឬហិត ឬស្ទាប រួចទស្សន៍ទាយ)
- អាចឱ្យកុមារសង្កេតជារួម ឬសង្កេតតាមក្រុមតូចៗ ដោយបំផុសគំនិតកុមារឱ្យសង្កេត និងរៀបរាប់ ឬរាយការណ៍តាមក្រុមពីអ្វីដែលកុមារបានស្គាល់ពីផ្លែស្វាយទុំ (ចំណេះដឹងមានស្រាប់របស់កុមារដោយប្រើញាណទាំងប្រាំ)
- បន្ថែមនូវគំនិតថ្មីៗ ដល់កុមារតាមរយៈការប្រើសំណួរបំផុស(ចំណេះដឹងថ្មី) ទាក់ទងនឹងផ្នែកខាងក្រៅ រូបរាង ពណ៌ សម្បក ទង ផ្នែកខាងក្នុង សាច់ គ្រាប់ ពណ៌សាច់ គ្រាប់ លក្ខណៈរូបធាតុ ទន់ រលោង ផលប្រយោជន៍ ឬលើសពីនេះ
- ពុះផ្លែស្វាយទុំឱ្យកុមារសង្កេត និងឱ្យភ្លក់រសជាតិដែលបានរៀបចំរួច
- សង្ខេបខ្លឹមសារៈសំខាន់ៗ នៃមេរៀនឡើងវិញ។

**មេរៀនមួយចំនួនដែលពាក់ព័ន្ធនឹងប្រធានបទបំណិនអនាម័យ**

| ទស្សនាសង្កេត | សង្កេត | ពិសោធន៍ | សកម្មភាពគោលផ្សេងៗ |
|---|---|---|---|
| • កន្លែងទុកដាក់សំរាមតាមប្រភេទ | • ការលាងដៃ<br>• សម្អាតអនាម័យខ្លួនប្រាណ | | • សន្ទនា៖ មុន និងក្រោយញ៉ាំអាហារ<br>• រឿងនិទាន៖ ធុងសំរាម |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | | |
|---|---|---|---|
| | • អាហារដែលគួរញុំា និងអាហារមិនគួរញុំា | | • សន្ទនា៖ ការសម្អាតច្រមុះ ការក្អកកណ្តាស<br>• ចម្រៀង៖ ត្រូវសម្អាតខ្លួនប្រាណ<br>• សន្ទនា៖ អនាម័យមាត់ធ្មេញ<br>• សន្ទនា៖ អនាម័យសម្លៀកបំពាក់ និងសម្ភារៈប្រើប្រាស់ |

## ឧទាហរណ៍៖ ទស្សនាសង្កេត បរិស្ថានសាលារៀន







### ១. ថ្នាក់កម្រិតទាប

#### ក. វត្ថុបំណង៖

- ប្រាប់ពីអ្វីៗ ដែលនៅជុំវិញសាលារៀនបានត្រឹមត្រូវ
- ធ្វើអនាម័យ សម្អាតបរិស្ថាន និងទុកដាក់សំរាមបានត្រឹមត្រូវ
- ទម្លាប់មានអនាម័យល្អក្នុងការរស់នៅ និងស្រឡាញ់បរិស្ថាន។

#### ខ. សម្ភារឧបទេស៖

- បរិវេណក្នុង និងក្រៅសាលារៀន

គ. ការរៀបចំ៖

- កុមារទាំងអស់ក្នុងថ្នាក់ចេញសង្កេត និងត្រៀមគ្រូជំនួយ ឬមាតាបិតាដើម្បីជួយសម្របសម្រួលក្នុងដំណើរការទស្សនាសង្កេត

ឃ. ដំណើរការសកម្មភាព៖

- ទំនាក់ទំនងជាមួយនាយក/នាយិកាសាលា ប្រាប់ពីគោលបំណង ពិភាក្សាលើមេរៀនដែលត្រូវនាំកុមារទស្សនាសង្កេត និងត្រៀមរៀបចំទីកន្លែង
- ជូនដំណឹងដល់មាតាបិតាកុមារដើម្បីជួយផ្តល់សម្ភារៈផ្សេងៗ ដល់កុមារ

*មុនពេលទស្សនាសង្កេត*

- ប្រើសំណួរបំផុសឱ្យកុមារប្រាប់ពីអ្វីៗ ដែលនៅជុំវិញសាលារៀន អនាម័យ បរិស្ថានស្អាត និងកង្វក់
- ធ្វើការណែនាំពីសណ្តាប់ធ្នាប់ពេលដើរទស្សនាសង្កេត និងពេលទៅដល់ទីកន្លែង

*នៅតាមផ្លូវ*

- ទុកឱកាសឱ្យកុមារសង្កេតអ្វីៗ ដែលនៅតាមផ្លូវ និងឱ្យកុមាររៀបរាប់
- ទាញចំណាប់អារម្មណ៍កុមារនៅពេលជិតដល់ទីកន្លែងដែលត្រូវទស្សនាសង្កេត

*ពេលកំពុងទស្សនាសង្កេត*

- ឱ្យកុមារសង្កេតនៅទីកន្លែងដែលមានសំរាម និងចែកជាក្រុមតូចៗ ដើម្បីប្រមូលសំរាមទៅតាមប្រភេទ(ប្រើស្រោមដៃពាក់ដៃ ម៉ាស ប្រដាប់ចាប់សំរាម ថង់ដាក់សំរាម...)
- សម្របសម្រួលកុមារតាមក្រុមដោយបំផុសឱ្យកុមារអនុវត្ត សាកសួរពីឈ្មោះ ប្រភេទសំរាម ការសម្អាតបរិស្ថាន ការកែច្នៃសំរាម...
- កុមារអនុវត្ត

*ក្រោយពេលទស្សនាសង្កេត*

- កុមារតាមក្រុមប្រមូលសំរាមទៅទុកដាក់តាមទីកន្លែងកំណត់
- កុមារទាំងអស់ធ្វើការលាងសម្អាតដៃ
- កុមារធ្វើការជ្រើសរើសប្រភេទសំរាមផ្សេងៗ ដើម្បីកែច្នៃប្រើប្រាស់ឡើងវិញ។ ឧទាហរណ៍៖ បំពង់បឺតកាត់ធ្វើជាខ្សែក ផ្កា... កាត់ដបទឹកសុទ្ធទុកបណ្តុះគ្រាប់ធញ្ញជាតិ ឡាំងក្រដាសតាមស្ថានភាពជាក់ស្តែង។

- ថ្នាក់កម្រិតមធ្យម និងថ្នាក់កម្រិតខ្ពស់ អនុវត្តតាមលំនាំសកម្មភាពដូចថ្នាក់កម្រិតទាប។
- គ្រូមត្តេយ្យសិក្សាអាចច្នៃប្រឌិតសកម្មភាពតាមការបត់បែនតាមស្ថានភាពជាក់ស្តែងដោយបន្ថែមទៅលើខ្លឹមសារសកម្មភាព និងបង្កើនកម្រិតសំណួរ ឬការអនុវត្ត។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**មេរៀនមួយចំនួនដែលពាក់ព័ន្ធនឹងប្រធានបទប្រតិបត្តិដោយសុវត្ថិភាព**

| ទស្សនាសង្កេត | សង្កេត | ពិសោធន៍ | សកម្មភាពគោលផ្សេងៗ |
|---|---|---|---|
| | • វត្ថុមុខស្រួចនាំឱ្យគ្រោះថ្នាក់<br>• ទីកន្លែងនាំឱ្យមានគ្រោះថ្នាក់<br>• សម្ភារៈអគ្គិសនី (កង្ហា ឆ្នាំងអ៊ុត ឆ្នាំងដាំបាយ...)<br>• វត្ថុដែលនាំឱ្យមានគ្រោះថ្នាក់<br>• ស្លាកសញ្ញាចរាចរ | | • សន្ទនា៖ ប្រភេទថ្នាំសម្លាប់សត្វល្អិត និងថ្នាំផ្សេងៗ<br>• ល្បែង៖ បាទ/ចាស ឬទេ ថ្នាំបណ្តាលឱ្យមានគ្រោះថ្នាក់<br>• ល្បែង៖ តាថាគ្រឿងចរន្តអគ្គីសនី<br>• ល្បែង៖ ចំណាត់ថ្នាក់គ្រឿងអគ្គីសនី ឬមិនប្រើអគ្គីសនី<br>• ល្បែង៖ គោរពភ្លើងចរាចរណ៍<br>• សន្ទនា៖ ដំណោះស្រាយនៅពេលវង្វេងផ្លូវ |

## ឧទាហរណ៍៖ ល្បែង គោរពភ្លើងចរាចរណ៍



### ១. ថ្នាក់កម្រិតទាប

ក. វត្ថុបំណង៖

– ប្រាប់ពីអត្ថន័យនៃភ្លើងសញ្ញាចរាចរណ៍បានត្រឹមត្រូវ

– អនុវត្តការលេងល្បែងគោរពភ្លើងសញ្ញាចរាចរណ៍បានត្រឹមត្រូវ

– មានភាពសប្បាយរីករាយ សហការគ្នា និងគោរពច្បាប់ចរាចរណ៍។

ខ. សម្ភារឧបទេស៖

– រូបភាពភ្លើងសញ្ញាចរាចរណ៍

គ. ការរៀបចំ៖

– កុមារទាំងអស់តោងស្មាគ្នាតម្រង់ជួរ មួយជួរ ឬពីរជួរ ឬតាមការច្នៃប្រឌិត

ឃ. ដំណើរការសកម្មភាព៖

- បង្ហាញស្លាកភ្លើងសញ្ញាចរាចរណ៍(ពណ៌បៃតង ពណ៌ក្រហម និងពណ៌លឿង) ម្ដងមួយៗ ឱ្យកុមារប្រាប់ឈ្មោះ
- ឱ្យកុមារប្រាប់អត្ថន័យនៃភ្លើងសញ្ញាចរាចរណ៍
- នាំកុមារលេងល្បែង ដោយចែកក្រុមកុមារតាមជាក់ស្ដែងតោងស្មាបន្តគ្នា ច្រៀងចម្រៀង ឬធ្វើចលនាទៅមុខតាមចង្វាក់ភ្លេង និងអនុវត្តតាមសញ្ញាគ្រូបង្ហាញ៖ គ្រូលើកដៃជាសញ្ញាឱ្យទៅមុខ កុមារតោងស្មាដើរទៅមុខតិចៗ បើគ្រូលើកស្លាកសញ្ញាពណ៌បៃតងកុមារទាំងអស់តោងស្មាដើរទៅមុខលឿន បើគ្រូលើកស្លាកសញ្ញាពណ៌លឿងកុមារទាំងអស់តោងស្មាដើរទៅមុខយឺតៗ ថ្នមៗ បើគ្រូលើកស្លាកសញ្ញាពណ៌ក្រហមកុមារទាំងអស់ឈរស្ងៀម
- នាំកុមារលេងដោយលើកស្លាកសញ្ញាភ្លើងចរាចរណ៍ឆ្លាស់ពណ៌គ្នា។

## ២. ថ្នាក់កម្រិតមធ្យម

ក. វត្ថុបំណង៖

- ប្រាប់ពីអត្ថន័យនៃភ្លើងសញ្ញាចរាចរណ៍បានត្រឹមត្រូវ
- អនុវត្តការលេងល្បែងគោរពភ្លើងសញ្ញាចរាចរណ៍បានត្រឹមត្រូវ
- មានភាពសប្បាយរីករាយ សហការគ្នា និងគោរពច្បាប់ចរាចរណ៍។

ខ. សម្ភារឧបទេស៖

- រូបភាពភ្លើងសញ្ញាចរាចរណ៍

គ. ការរៀបចំ៖

- កុមារទាំងអស់តោងស្មាគ្នាតម្រង់ជួរ មួយជួរ ឬពីរជួរ ឬតាមការច្នៃប្រឌិត

ឃ. ដំណើរការសកម្មភាព៖

- បង្ហាញស្លាកភ្លើងសញ្ញាចរាចរណ៍(ពណ៌បៃតង ពណ៌ក្រហម និងពណ៌លឿង) ម្ដងមួយៗ ឱ្យកុមារប្រាប់ឈ្មោះ
- ឱ្យកុមារប្រាប់អត្ថន័យនៃភ្លើងសញ្ញាចរាចរណ៍
- នាំកុមារលេងល្បែង ដោយចែកក្រុមកុមារតាមជាក់ស្ដែងតោងស្មាបន្តគ្នា ច្រៀងចម្រៀង ឬធ្វើចលនាទៅមុខតាមចង្វាក់ភ្លេង និងអនុវត្តតាមសញ្ញាគ្រូបង្ហាញ៖ គ្រូលើកដៃជាសញ្ញាឱ្យទៅមុខ កុមារតោងស្មាដើរទៅមុខតិចៗ បើគ្រូលើកស្លាកសញ្ញាពណ៌បៃតងកុមារទាំងអស់តោងស្មាដើរទៅមុខលឿន បើគ្រូលើកស្លាកសញ្ញាពណ៌លឿងកុមារទាំងអស់តោងស្មាដើរទៅមុខយឺតៗ ថ្នមៗ បើគ្រូលើកស្លាកសញ្ញាពណ៌ក្រហមកុមារទាំងអស់ឈរស្ងៀម
- នាំកុមារលេងដោយលើកស្លាកសញ្ញាភ្លើងចរាចរណ៍ឆ្លាស់ពណ៌គ្នា និងឱ្យកុមារលេងដោយខ្លួនឯង ធ្វើជាអ្នកលើកស្លាកសញ្ញាភ្លើងចរាចរណ៍ និងអ្នកឈរតោងស្មាគ្នា។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### ៣. ថ្នាក់កម្រិតខ្ពស់

#### ក. វត្ថុបំណង៖

- ប្រាប់ពីអត្ថន័យនៃភ្លើងសញ្ញាចរាចរណ៍បានត្រឹមត្រូវ
- អនុវត្តការលេងល្បែងគោរពភ្លើងសញ្ញាចរាចរណ៍បានត្រឹមត្រូវ
- មានភាពសប្បាយរីករាយ សហការគ្នា និងគោរពច្បាប់ចរាចរណ៍។

#### ខ. សម្ភារឧបទេស៖

- រូបភាពភ្លើងសញ្ញាចរាចរណ៍

#### គ. ការរៀបចំ៖

- កុមារទាំងអស់តោងស្មាគ្នាតម្រង់ជួរ មួយជួរ ឬពីរជួរ ឬតាមការច្នៃប្រឌិត

#### ឃ. ដំណើរការសកម្មភាព៖

- បង្ហាញស្លាកភ្លើងសញ្ញាចរាចរណ៍( ពណ៌បៃតង ពណ៌ក្រហម និងពណ៌លឿង ) ម្តងមួយៗ ឱ្យកុមារប្រាប់ឈ្មោះ
- ឱ្យកុមារប្រាប់អត្ថន័យនៃភ្លើងសញ្ញាចរាចរណ៍
- នាំកុមារលេងល្បែង ដោយចែកក្រុមកុមារតាមជាក់ស្តែងតោងស្មាបន្តគ្នា ច្រៀងចម្រៀង ឬធ្វើចលនាទៅមុខតាមចង្វាក់ភ្លេង និងអនុវត្តតាមសញ្ញាគ្រូបង្ហាញ៖ គ្រូលើកដៃជាសញ្ញាឱ្យទៅមុខ កុមារតោងស្មាដើរទៅមុខតិចៗ បើគ្រូលើកស្លាកសញ្ញាពណ៌បៃតងកុមារទាំងអស់តោងស្មាដើរទៅមុខលឿន បើគ្រូលើកស្លាកសញ្ញាពណ៌លឿងកុមារទាំងអស់តោងស្មាដើរទៅមុខយឺតៗ ថ្នមៗ បើគ្រូលើកស្លាកសញ្ញាពណ៌ក្រហមកុមារទាំងអស់ឈរស្ងៀម
- នាំកុមារលេងដោយលើកស្លាកសញ្ញាភ្លើងចរាចរណ៍ឆ្លាស់ពណ៌គ្នា និងឱ្យកុមារលេងដោយខ្លួនឯង ធ្វើជាអ្នកលើកស្លាកសញ្ញាភ្លើងចរាចរណ៍ និងអ្នកឈរតោងស្មាគ្នា។

**មេរៀនមួយចំនួនដែលពាក់ព័ន្ធនឹងប្រធានបទការរស់នៅប្រចាំថ្ងៃ**

**ខ្លឹមសារ ការស្វែងយល់ដោយការសង្កេត**

| ទស្សនាសង្កេត | សង្កេត | ពិសោធន៍ | សកម្មភាពគោលផ្សេងៗ |
|---|---|---|---|
| • សួនសត្វ<br>• សួនរុក្ខជាតិ | • ការលូតលាស់ការដាំគ្រាប់ធញ្ញជាតិ<br>• សត្វចិញ្ចឹម<br>• សត្វរស់ក្នុងទឹក (ត្រីក្តាម ខ្យង...)<br>• វដ្តនៃសត្វមាន់<br>• សត្វរស់នៅក្នុងព្រៃ | • បណ្តុះគ្រាប់ធញ្ញជាតិ<br>• ការលាយពណ៌<br>• លិច អណ្តែត<br>• វត្ថុរលាយ និងមិនរលាយ<br>• ភ្លក់រសជាតិអាហារ<br>• ការយកពណ៌ចេញពីផ្កានិងស្លឹក | |

| | | | |
|---|---|---|---|
| | • ប្រៀបធៀបសត្វមាន់ និងសត្វទា... | • ការជ្រលក់ពណ៌<br>• វត្ថុជ្រាប និងមិនជ្រាបទឹក | |

## ឧទាហរណ៍៖ ពិសោធន៍ បណ្ដុះគ្រាប់ត្រកួន




### ១. ថ្នាក់កម្រិតខ្ពស់ (ចំណែកថ្នាក់កម្រិតទាប និងមធ្យម មិនអនុវត្តសកម្មភាពគោលពិសោធន៍ទេ)

ក. វត្ថុបំណង៖

– ប្រាប់ពីរបៀបបណ្ដុះគ្រាប់ត្រកួនបានត្រឹមត្រូវ

– អនុវត្តការបណ្ដុះគ្រាប់ធញ្ញជាតិតាមដំណាក់កាល និងតាមដានការលូតលាស់របស់រុក្ខជាតិបានត្រឹមត្រូវ

– សហការគ្នា ព្យាយាម ប្រុងប្រយ័ត្ន ទុកដាក់សម្ភារៈឱ្យមានសណ្ដាប់ធ្នាប់ និងស្រឡាញ់ធម្មជាតិ។

ខ. សម្ភារឧបទេស៖

– ដើមត្រកួន គ្រាប់ត្រកួន ដី ទឹក ជីធម្មជាតិ ធើង ដប ឬប្រដាប់ដាក់ដីបាន

គ. ការរៀបចំ៖

– អនុវត្តជាក្រុមតូចៗ

ឃ. ដំណើរការសកម្មភាព៖

– គ្រូបង្ហាញសម្ភារៈឱ្យកុមារប្រាប់ឈ្មោះម្ដងមួយៗ រហូតអស់សម្ភារៈ

– គ្រូបង្ហាញដើមត្រកួនដែលបានបណ្ដុះនិងមានដើម ស្លឹក រួចដាក់បញ្ហា ឬសំណួរគន្លឹះ៖ ដើម្បីបានដើមត្រកួននេះ តើយើងត្រូវធ្វើដូចម្ដេចខ្លះ?

– កុមារផ្ដល់ចម្លើយប៉ាន់ស្មាន រួចគ្រូសរសេរចម្លើយដាក់ជ្រុងម្ខាងនៅលើក្ដារខៀន

– បែងចែកសម្ភារៈឱ្យកុមារតាមក្រុមយកទៅអនុវត្ត



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ពិភាក្សាជាមួយក្រុមកុមារពីការ បំបែកដី រួចលាយដីជាមួយជីធម្មជាតិ ច្រកដីដាក់ចូលដប ដាក់គ្រាប់ត្រកួនចូលដី និងស្រោចទឹកសើមតិចៗ រួចយកទៅដាក់កន្លែងកំណត់ដែលមានខ្យល់ និងពន្លឺគ្រប់គ្រាន់
- កុមាររាយការណ៍ពីលទ្ធផលនៃការបណ្ដុះគ្រាប់ត្រកួន
- បំផុសរកចំណងជើងដែលបានពិសោធន៍
- ក្រោយពេលគ្រាប់ធញ្ញជាតិដុះចេញត្រួយ នាំកុមារពិនិត្យសង្កេតនៅទីតាំងផ្ទាល់
- ឱ្យកុមារប្រើតារាងផ្ទៀងផ្ទាត់ការលូតលាស់របស់គ្រាប់ត្រកួនជារៀងរាល់ថ្ងៃ
- បូកសរុប និងសន្និដ្ឋាន៖
  - ចំណេះដឹងវិទ្យាសាស្ត្រ ៖ គ្រាប់ត្រកួនលូតលាស់បានល្អដោយសារដីមានជីជាតិ ការស្រោចទឹក ពន្លឺ និងខ្យល់អាកាសគ្រប់គ្រាន់
  - ចំណេះដឹងភាសា ៖ នាំកុមារអានពាក្យថ្មីៗ ដើមត្រកួន គ្រាប់ត្រកួន ដី ទឹក ជីធម្មជាតិ ផើង ដប បណ្ដុះ
  - ការអប់រំ ៖ សហការគ្នា ព្យាយាម ប្រុងប្រយ័ត្ន ទុកដាក់សម្ភារៈឱ្យមានសណ្ដាប់ធ្នាប់ និងស្រឡាញ់ធម្មជាតិ។

> - គ្រូត្រូវត្រៀមសម្ភារៈសម្រាប់ពិសោធន៍តាមក្រុម និងធ្វើការពិសោធខ្លួនឯងជាមុន
> - មេរៀននេះសម្រាប់តែថ្នាក់កម្រិតខ្ពស់ប៉ុណ្ណោះ

**មេរៀនមួយចំនួនដែលពាក់ព័ន្ធនឹងប្រធានបទការរស់នៅប្រចាំថ្ងៃ**

**ខ្លឹមសារ អ្វីៗ ដែលគ្មានជីវិត និងមានជីវិត**

| ទស្សនាសង្កេត | សង្កេត | ពិសោធន៍ | សកម្មភាពគោលផ្សេងៗ |
|---|---|---|---|
| • ដើមឈើក្នុងបរិវេណសាលារៀន | • រូបភាពសត្វរស់ និងសត្វស្លាប់ | | • សន្ទនា៖ អ្វីខ្លះដែលមានជីវិត និងគ្មានជីវិត<br>• ល្បែង៖ ប្រព័ន្ធគ្រួសារ (អ្វីៗដែលមានជីវិត និងគ្មានជីវិត)<br>• ល្បែង៖ តាថាអ្វីៗដែលមានជីវិត និងគ្មានជីវិត<br>• ល្បែង៖ គ្រាប់តាមអ្វីដែលមានជីវិត |

## ឧទាហរណ៍៖ សន្ទនា អ្វីៗដែលមានជីវិត និងគ្មានជីវិត

### ១. ថ្នាក់កម្រិតទាប

ក. វត្ថុបំណង៖

- ប្រាប់ពីអ្វីៗនៅជុំវិញខ្លួនទាំងមានជីវិត និងគ្មានជីវិតបានត្រឹមត្រូវ
- កំណត់ពីលក្ខណៈមនុស្ស សត្វ វត្ថុ រុក្ខជាតិដែលមានជីវិត និងគ្មានជីវិតបានត្រឹមត្រូវ
- ស្រឡាញ់ និងចូលរួមថែរក្សាអ្វីៗ ដែលមានជីវិត។

ខ. សម្ភារឧបទេស៖

- គ្មាន

គ. ការរៀបចំ៖

- សន្ទនាជាដៃគូ និងនិយាយប្រាប់មិត្តភក្តិនៅក្នុងថ្នាក់រៀនទាំងអស់

ឃ. ដំណើរការសកម្មភាព៖

- បំផុសសំណួរពីអ្វីៗដែលកុមារបានស្គាល់នៅជុំវិញខ្លួន
- សន្ទនាជាមួយគ្រូនិងកុមារប្រាប់អំពីអ្វីដែលមានជីវិត និងគ្មានជីវិតម្នាក់មួយៗ ឬលើសពីនេះ
- ឱ្យកុមារចាប់ដៃគូពីរៗនាក់ ដែលខ្លួនពេញចិត្ត
- ណែនាំពីខ្លឹមសារដែលកុមារត្រូវសន្ទនា
- ទុកឱកាសឱ្យកុមារសន្ទនា ផ្លាស់ប្តូរវេនគ្នា និងចេះរង់ចាំវេនគ្នាក្នុងពេលតែមួយ
- សម្របសម្រួលកុមារពេលកំពុងសន្ទនា និងលើកទឹកចិត្តកុមារបានសន្ទនា
- ឱ្យកុមារឡើងរៀបរាប់ពីអ្វីដែលកុមារបានសន្ទនា (តាមស្ថានភាព និងពេលវេលាជាក់ស្តែង)។

## ២. ថ្នាក់កម្រិតមធ្យម

ក. វត្ថុបំណង៖

- ប្រាប់ពីអ្វីៗ នៅជុំវិញខ្លួនទាំងមានជីវិត និងគ្មានជីវិតបានត្រឹមត្រូវ
- កំណត់ពីលក្ខណៈមនុស្ស សត្វ វត្ថុ រុក្ខជាតិដែលមានជីវិត និងគ្មានជីវិតបានត្រឹមត្រូវ
- ស្រឡាញ់ និងចូលរួមថែរក្សាអ្វីៗ ដែលមានជីវិត។

ខ. សម្ភារឧបទេស៖

- គ្មាន

គ. ការរៀបចំ៖

- សន្ទនាជាដៃគូ និងនិយាយប្រាប់មិត្តភក្តិនៅក្នុងថ្នាក់រៀនទាំងអស់

ឃ. ដំណើរការសកម្មភាព៖

- បំផុសសំណួរពីអ្វីៗដែលកុមារបានស្គាល់នៅជុំវិញខ្លួន
- សន្ទនាជាមួយគ្រូនិងកុមារប្រាប់អំពីអ្វីដែលមានជីវិត និងគ្មានជីវិតម្នាក់មួយៗ ឬលើសពីនេះ
- ឱ្យកុមារចាប់ដៃគូពីរៗនាក់ ដែលខ្លួនពេញចិត្ត

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ណែនាំពីខ្លឹមសារដែលកុមារត្រូវសន្ទនា (ប្រាប់អំពីអ្វីដែលមានជីវិត និងគ្មានជីវិតចាប់ពីពីរឡើងទៅ ឬលើសពីនេះ
- ទុកឱកាសឱ្យកុមារសន្ទនា ផ្លាស់ប្តូរវេនគ្នា និងចេះរងចាំវេនគ្នាក្នុងពេលតែមួយ
- សម្របសម្រួលកុមារពេលកំពុងសន្ទនា និងលើកទឹកចិត្តកុមារបានសន្ទនា
- ឱ្យកុមារឡើងរៀបរាប់ពីអ្វីដែលកុមារបានសន្ទនា (តាមស្ថានភាព និងពេលវេលាជាក់ស្តែង)។

## ៣. ថ្នាក់កម្រិតខ្ពស់

### ក. វត្ថុបំណង៖

- ប្រាប់ពីអ្វីៗ នៅជុំវិញខ្លួនទាំងមានជីវិត និងគ្មានជីវិតបានត្រឹមត្រូវ
- កំណត់ពីលក្ខណៈមនុស្ស សត្វ វត្ថុ រុក្ខជាតិដែលមានជីវិត និងគ្មានជីវិតបានត្រឹមត្រូវ
- ស្រឡាញ់ និងចូលរួមថែរក្សាអ្វីៗ ដែលមានជីវិត។

### ខ. សម្ភារឧបទេស៖

- គ្មាន

### គ. ការរៀបចំ៖

- សន្ទនាជាដៃគូ និងនិយាយប្រាប់មិត្តភក្តិនៅក្នុងថ្នាក់រៀនទាំងអស់

### ឃ. ដំណើរការសកម្មភាព៖

- បំផុសសំណួរពីអ្វីៗ ដែលកុមារបានស្គាល់នៅជុំវិញខ្លួន
- សន្ទនាជាមួយគ្រូនិងកុមារប្រាប់អំពីអ្វីដែលមានជីវិត និងគ្មានជីវិតម្នាក់មួយៗ ឬលើសពីនេះ
- ឱ្យកុមារចាប់ដៃគូពីរៗនាក់ ដែលខ្លួនពេញចិត្ត
- ណែនាំពីខ្លឹមសារដែលកុមារត្រូវសន្ទនា (ប្រាប់អំពីអ្វីដែលមានជីវិត និងគ្មានជីវិតចាប់ពីពីរឡើងទៅ ឬលើសពីនេះ
- ទុកឱកាសឱ្យកុមារសន្ទនា ផ្លាស់ប្តូរវេនគ្នា និងចេះរងចាំវេនគ្នាក្នុងពេលតែមួយ
- សម្របសម្រួលកុមារពេលកំពុងសន្ទនា និងលើកទឹកចិត្តកុមារបានសន្ទនា
- ឱ្យកុមារឡើងរៀបរាប់ពីអ្វីដែលកុមារបានសន្ទនា (តាមស្ថានភាព និងពេលវេលាជាក់ស្តែង)។

**មេរៀនមួយចំនួនដែលពាក់ព័ន្ធនឹងប្រធានបទការរស់នៅប្រចាំថ្ងៃ**

**ខ្លឹមសារ លក្ខណៈមេឃ និងអាកាសធាតុ**

| ទស្សនាសង្កេត | សង្កេត | ពិសោធន៍ | សកម្មភាពគោលផ្សេងៗ |
|---|---|---|---|
| • មេឃ និងអាកាសធាតុ | • អាកាសធាតុនិងរដូវវស្សា<br>• រដូវវស្សា<br>• រដូវប្រាំង | | • ល្បែង៖ ទំនាក់ទំនងរាងកាយទៅនឹងសម្ភារៈប្រើប្រាស់តាមរដូវ<br>• សន្ទនា៖ យើងការពារខ្លួននឹងអាកាសធាតុថ្ងៃនេះ |

| | | | |
|---|---|---|---|
| | • ទឹកជំនន់ | | • រឿងនិទានៈ តាព្រហ្ម និងសត្វគីង្គក់<br>• រឿងនិទានៈ ខ្យល់ព្យុះ<br>• សន្ទនាៈ ផលពិបាកនៃទឹកជំនន់ និងគ្រោះរាំងស្ងួត<br>• ល្បែងៈ ការពារខ្លួនពីបាតុភូតធម្មជាតិ |

**ឧទាហរណ៍ៈ សង្កេត ផ្ទាំងរូបភាពរដូវវស្សា**





youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ១. ថ្នាក់កម្រិតទាប

### ក. វត្ថុបំណង៖

- ប្រាប់ពីទិដ្ឋភាពទូទៅនៃរដូវវស្សាបានត្រឹមត្រូវ
- កំណត់លក្ខណៈអាកាសធាតុរដូវវស្សាបានត្រឹមត្រូវ
- ប្រុងប្រយ័ត្ន និងការពារខ្លួននៅរដូវវស្សា។

### ខ. សម្ភារឧបទេស៖

- ផ្ទាំងរូបភាពរដូវវស្សា ឬវីដេអូខ្លីៗ អំពីរដូវវស្សា

### គ. ការរៀបចំ៖

- កុមារក្នុងថ្នាក់ទាំងអស់ចូលរួមសង្កេត

### ឃ. ដំណើរការសកម្មភាព៖

- បំផុសគំនិតកុមារស្វែងយល់ពីអាកាសធាតុផ្សេងៗ នៅក្នុងតំបន់ដែលរស់នៅ ឬក្នុងប្រទេសកម្ពុជា
- បង្ហាញផ្ទាំងរូបភាពរដូវវស្សាឱ្យកុមារសង្កេត (គ្រូអាចបង្ហាញរូបភាពតាមរបៀបផ្សេងៗ)
- ប្រើសំណួរ៖
    - កូនឃើញអ្វីខ្លះ?
    - កូនធ្លាប់ឃើញរបៀបនេះនៅកន្លែងណាខ្លះ?
- ទុកពេលឱ្យកុមារសង្កេតជារួម ឬតាមក្រុម ដោយទុកពេលឱ្យកុមារសង្កេត និងពិភាក្សាក្នុងក្រុម
- កុមាររៀបរាប់នូវអ្វីដែលគេបានដឹង និងតាមរយៈផ្ទាំងរូបភាព គ្រូជួយបំពេញបន្ថែម
- សង្ខេបខ្លឹមសារៈសំខាន់ៗ នៃរដូវវស្សា ដូចជា ទិដ្ឋភាពរដូវវស្សា លក្ខណៈអាកាសធាតុ មនុស្ស សត្វ រុក្ខជាតិ ផលប្រយោជន៍ ការការពារខ្លួន...
- បំផុសរកចំណងជើងមេរៀន។

## ២. ថ្នាក់កម្រិតមធ្យម

### ក. វត្ថុបំណង៖

- ប្រាប់ពីទិដ្ឋភាពទូទៅនៃរដូវវស្សាបានត្រឹមត្រូវ
- កំណត់លក្ខណៈអាកាសធាតុរដូវវស្សាបានត្រឹមត្រូវ
- ប្រុងប្រយ័ត្ន និងការពារខ្លួននៅរដូវវស្សា។

### ខ. សម្ភារឧបទេស៖

- ផ្ទាំងរូបភាពរដូវវស្សា ឬវីដេអូខ្លីៗ អំពីរដូវវស្សា

### គ. ការរៀបចំ៖

- កុមារក្នុងថ្នាក់ទាំងអស់ចូលរួមសង្កេត

ឃ. ដំណើរការសកម្មភាព៖

- បំផុសគំនិតកុមារស្វែងយល់ពីអាកាសធាតុផ្សេងៗ នៅក្នុងតំបន់ដែលរស់នៅ ឬក្នុងប្រទេសកម្ពុជា
- បង្ហាញផ្ទាំងរូបភាពរដូវវស្សាឱ្យកុមារសង្កេត (គ្រូអាចបង្ហាញរូបភាពតាមរបៀបផ្សេងៗ)
- ប្រើសំណួរ៖
    - កូនឃើញអ្វីខ្លះ?
    - កូនធ្លាប់ឃើញរបៀបនេះនៅកន្លែងណាខ្លះ?
    - តើនៅពេលមានភ្លៀងធ្លាប់បែបនេះ តើកូនធ្វើដូចម្ដេចកុំឱ្យត្រូវទឹកភ្លៀង?
- ទុកពេលឱ្យកុមារសង្កេតជារួម ឬតាមក្រុម ដោយទុកពេលឱ្យកុមារសង្កេត និងពិភាក្សាក្នុងក្រុម
- កុមាររៀបរាប់នូវអ្វីដែលគេបានដឹង និងតាមរយៈផ្ទាំងរូបភាព គ្រូជួយបំពេញបន្ថែម
- សង្ខេបខ្លឹមសារៈសំខាន់ៗ នៃរដូវវស្សា ដូចជា ទិដ្ឋភាពរដូវវស្សា លក្ខណៈអាកាសធាតុ មនុស្សសត្វ រុក្ខជាតិ ផលប្រយោជន៍ ការការពារខ្លួន...
- បំផុសរកចំណងជើងមេរៀន។

## ៣. ថ្នាក់កម្រិតខ្ពស់

ក. វត្ថុបំណង៖

- ប្រាប់ពីទិដ្ឋភាពទូទៅនៃរដូវវស្សាបានត្រឹមត្រូវ
- កំណត់លក្ខណៈអាកាសធាតុរដូវវស្សាបានត្រឹមត្រូវ
- ប្រុងប្រយ័ត្ន និងការពារខ្លួននៅរដូវវស្សា។

ខ. សម្ភារឧបទេស៖

- ផ្ទាំងរូបភាពរដូវវស្សា ឬវីដេអូខ្លីៗ អំពីរដូវវស្សា

គ. ការរៀបចំ៖

- កុមារក្នុងថ្នាក់ទាំងអស់ចូលរួមសង្កេត

ឃ. ដំណើរការសកម្មភាព៖

- បំផុសគំនិតកុមារស្វែងយល់ពីអាកាសធាតុផ្សេងៗ នៅក្នុងតំបន់ដែលរស់នៅ ឬក្នុងប្រទេសកម្ពុជា
- បង្ហាញផ្ទាំងរូបភាពរដូវវស្សាឱ្យកុមារសង្កេត (គ្រូអាចបង្ហាញរូបភាពតាមរបៀបផ្សេងៗ)
- ប្រើសំណួរ៖
    - កូនឃើញអ្វីខ្លះ?

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- កូនធ្លាប់ឃើញរបៀបនេះនៅកន្លែងណាខ្លះ?
- តើនៅពេលមានភ្លៀងធ្លាប់បែបនេះ តើកូនធ្វើដូចម្តេចកុំឱ្យត្រូវទឹកភ្លៀង?
- តើហេតុអ្វីបានជាកូនធ្វើដូច្នេះ?

– ទុកពេលឱ្យកុមារសង្កេតជារួម ឬតាមក្រុម ដោយទុកពេលឱ្យកុមារសង្កេត និងពិភាក្សាក្នុងក្រុម
– កុមាររៀបរាប់នូវអ្វីដែលគេបានដឹង និងតាមរយៈផ្ទាំងរូបភាព គ្រូជួយបំពេញបន្ថែម
– សង្ខេបខ្លឹមសារៈសំខាន់ៗ នៃរដូវវស្សា ដូចជា ទិដ្ឋភាពរដូវវស្សា លក្ខណៈអាកាសធាតុ មនុស្ស សត្វ រុក្ខជាតិ ផលប្រយោជន៍ ការការពារខ្លួន...
– បំផុសរកចំណងជើងមេរៀន។

**មេរៀនមួយចំនួនដែលពាក់ព័ន្ធនឹងប្រធានបទការរស់នៅប្រចាំថ្ងៃ**
**ខ្លឹមសារ លក្ខណៈរូបធាតុ**

| ទស្សនាសង្កេត | សង្កេត | ពិសោធន៍ | សកម្មភាពគោលផ្សេងៗ |
|---|---|---|---|
| | • វត្ថុធ្វើអំពីឈើ<br>• វត្ថុធ្វើអំពីជ័រ<br>• វត្ថុធ្វើអំពីដែក<br>• សម្ភារៈផ្ទះបាយ | • វត្ថុរឹង និងទន់ | • ល្បែង៖ ចង់ទិព្វទាយវត្ថុធាតុដើមនៃវត្ថុ<br>• ល្បែង៖ ចំណាត់ថ្នាក់ក្រុមវត្ថុធាតុដើម |

ឧទាហរណ៍៖ សង្កេត វត្ថុធ្វើអំពីឈើ



## ១. ថ្នាក់កម្រិតទាប

### ក. វត្ថុបំណង៖

- ប្រាប់ពីឈ្មោះវត្ថុផ្សេងៗ ធ្វើអំពីឈើបានត្រឹមត្រូវ
- កំណត់លក្ខណៈរូបធាតុឈើបានត្រឹមត្រូវ
- ប្រុងប្រយ័ត្នក្នុងការប្រើប្រាស់វត្ថុនានាចៀសវាងគ្រោះថ្នាក់។

### ខ. សម្ភារឧបទេស៖

- សម្ភារៈក្នុងថ្នាក់រៀនធ្វើអំពីឈើ និងសម្ភារៈដែលគ្រូបានត្រៀម

### គ. ការរៀបចំ៖

- កុមារក្នុងថ្នាក់ទាំងអស់ចូលរួមសង្កេត

### ឃ. ដំណើរការសកម្មភាព៖

- បង្ហាញវត្ថុផ្សេងៗ ដែលធ្វើពីឈើដែលបានត្រៀមទុក
- ទុកពេលឱ្យកុមារសង្កេត ពិភាក្សា និងរៀបរាប់ពីអ្វីដែលកុមារបានឃើញដោយប្រើញ្ញាណទាំងប្រាំ
- បំពេញបន្ថែមនូវអ្វីដែលកុមារមិនទាន់ស្គាល់
- សង្ខេបខ្លឹមសារៈសំខាន់ៗ ដូចជា វត្ថុធ្វើអំពីឈើ លក្ខណៈ រូបរាង រឹង គ្រើម រលោង ផលប្រយោជន៍ការកែច្នៃ ការការពារ និងដាំដុះដើមឈើបន្ថែម
- បំផុសរកចំណងជើងមេរៀន។

*សម្គាល់៖ បន្ទាប់មកគ្រូអាចឱ្យកុមារប្រើប្រាស់ដុំឈើតូចៗ ច្នៃប្រឌិតដោយរៀបជាវត្ថុផ្សេងៗ។*

## ២. ថ្នាក់កម្រិតមធ្យម

### ក. វត្ថុបំណង៖

- ប្រាប់ពីឈ្មោះវត្ថុផ្សេងៗ ធ្វើអំពីឈើបានត្រឹមត្រូវ
- កំណត់លក្ខណៈរូបធាតុឈើបានត្រឹមត្រូវ
- ប្រុងប្រយ័ត្នក្នុងការប្រើប្រាស់វត្ថុនានាចៀសវាងគ្រោះថ្នាក់។

### ខ. សម្ភារឧបទេស៖

- សម្ភារៈក្នុងថ្នាក់រៀនធ្វើអំពីឈើ និងសម្ភារៈដែលគ្រូបានត្រៀម

### គ. ការរៀបចំ៖

- កុមារក្នុងថ្នាក់ទាំងអស់ចូលរួមសង្កេត

### ឃ. ដំណើរការសកម្មភាព៖

- បង្ហាញវត្ថុផ្សេងៗ ដែលធ្វើពីឈើដែលបានត្រៀមទុក

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ទុកពេលឱ្យកុមារសង្កេត ពិភាក្សា និងរៀបរាប់ពីអ្វីដែលកុមារបានឃើញដោយប្រើញ្ញាណទាំងប្រាំ
- សំនួរ៖តើផ្ទះកូនមានសម្ភារណាធ្វើអំពីឈើខ្លះកូន?
- បំពេញបន្ថែមនូវអ្វីដែលកុមារមិនទាន់ស្គាល់
- សង្ខេបខ្លឹមសារៈសំខាន់ៗ ដូចជា វត្ថុធ្វើអំពីឈើ លក្ខណៈ រូបរាង រឹង គ្រើម រលោង ផលប្រយោជន៍ការកែច្នៃ ការការពារ និងដាំដុះដើមឈើបន្ថែម
- បំផុសរកចំណងជើងមេរៀន។

*សម្គាល់៖ បន្ទាប់មកគ្រូអាចឱ្យកុមារប្រើប្រាស់ដុំឈើតូចៗ ច្នៃប្រឌិតដោយរៀបជាវត្ថុផ្សេងៗ។*

## ៣. ថ្នាក់កម្រិតខ្ពស់

### ក. វត្ថុបំណង៖

- ប្រាប់ពីឈ្មោះវត្ថុផ្សេងៗ ធ្វើអំពីឈើបានត្រឹមត្រូវ
- កំណត់លក្ខណៈរូបធាតុឈើបានត្រឹមត្រូវ
- ប្រុងប្រយ័ត្នក្នុងការប្រើប្រាស់វត្ថុនានាចៀសវាងគ្រោះថ្នាក់។

### ខ. សម្ភារឧបទេស៖

- សម្ភារៈក្នុងថ្នាក់រៀនធ្វើអំពីឈើ និងសម្ភារៈដែលគ្រូបានត្រៀម

### គ. ការរៀបចំ៖

- កុមារក្នុងថ្នាក់ទាំងអស់ចូលរួមសង្កេត

### ឃ. ដំណើរការសកម្មភាព៖

- បង្ហាញវត្ថុផ្សេងៗ ដែលធ្វើពីឈើដែលបានត្រៀមទុក
- ទុកពេលឱ្យកុមារសង្កេត ពិភាក្សា និងរៀបរាប់ពីអ្វីដែលកុមារបានឃើញដោយប្រើញ្ញាណទាំងប្រាំ
- សំណួរ៖
    - តើផ្ទះកូនមានសម្ភារៈណាធ្វើអំពីឈើខ្លះកូន?
    - តើនៅកន្លែងណាទៀតកូនឃើញសម្ភារៈបែបនេះដែរ?
- បំពេញបន្ថែមនូវអ្វីដែលកុមារមិនទាន់ស្គាល់
- សង្ខេបខ្លឹមសារៈសំខាន់ៗ ដូចជា វត្ថុធ្វើអំពីឈើ លក្ខណៈ រូបរាង រឹង គ្រើម រលោង ផលប្រយោជន៍ ការកែច្នៃ ការការពារ និងដាំដុះដើមឈើបន្ថែម
- បំផុសរកចំណងជើងមេរៀន។

*សម្គាល់៖ បន្ទាប់មកគ្រូអាចឱ្យកុមារប្រើប្រាស់ដុំឈើតូចៗ ច្នៃប្រឌិតដោយរៀបជាវត្ថុផ្សេងៗ។*

## មេរៀនមួយចំនួនដែលពាក់ព័ន្ធនឹងប្រធានបទការរស់នៅប្រចាំថ្ងៃ

## ខ្លឹមសារ អំពីរាងកាយផ្ទាល់ខ្លួន

| ទស្សនាសង្កេត | សង្កេត | ពិសោធន៍ | សកម្មភាពគោលផ្សេងៗ |
|---|---|---|---|
| | • រាងកាយកុមារប្រុស និងកុមារស្រី | | • ល្បែង៖ ចង់ទិព្វរាងកាយមនុស្ស<br>• ល្បែង៖ ផ្គុំរូបមនុស្ស<br>• ល្បែង៖ តាថារាងកាយមនុស្ស<br>• សន្ទនា៖ មុខងាររបស់វិញ្ញាណទាំង៥<br>• ចម្រៀង៖ វិញ្ញាណទាំង៥ |

**ឧទាហរណ៍៖ សង្កេត រាងកាយកុមារា កុមារី**



### ១. ថ្នាក់កម្រិតទាប

ក. វត្ថុបំណង៖

- ប្រាប់ពីឈ្មោះផ្នែកផ្សេងៗ នៃរាងកាយមនុស្សបានត្រឹមត្រូវ
- បង្ហាញពីរូបផ្គុំនៃរាងកាយមនុស្សបានត្រឹមត្រូវ
- ប្រុងប្រយ័ត្នក្នុងការប្រើប្រាស់ផ្នែកផ្សេងៗ នៃរាងកាយ និងចាប់អារម្មណ៍ពីការលូតលាស់របស់រាងកាយ។

ខ. សម្ភារឧបទេស៖

- កុមារា និងកុមារី ក្នុងថ្នាក់រៀនជាក់ស្តែង

គ. ការរៀបចំ៖

- កុមារក្នុងថ្នាក់ទាំងអស់ចូលរួមសង្កេត

ឃ. ដំណើរការសកម្មភាព៖

- ជ្រើសរើសកុមារពីរនាក់ ម្នាក់ជាកុមារា ម្នាក់ជាកុមារី មកបង្ហាញកុមារដទៃទៀត
- ទុកពេលឱ្យកុមារសង្កេត ពិភាក្សា និងរៀបរាប់ពីអ្វីផ្នែកផ្សេងៗនៃរាងកាយ និងតួនាទីរបស់វា
- បំពេញបន្ថែមនូវអ្វីដែលកុមារមិនទាន់ស្គាល់



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- សង្ខេបខ្លឹមសារៈសំខាន់ៗ នៃមេរៀន
- បំផុសរកចំណងជើងមេរៀន។

*សម្គាល់៖ បន្ទាប់មកគ្រូអាចឱ្យកុមារលេងល្បែងផ្គូផ្គងរូបភាពរាងកាយមនុស្សទៅនឹងសម្ភារៈប្រើប្រាស់។*

## ២. ថ្នាក់កម្រិតមធ្យម

### ក. វត្ថុបំណង៖

- ប្រាប់ពីឈ្មោះផ្នែកផ្សេងៗ នៃរាងកាយមនុស្សបានត្រឹមត្រូវ
- បង្ហាញពីរូបផ្គុំនៃរាងកាយមនុស្សបានត្រឹមត្រូវ
- ប្រុងប្រយ័ត្នក្នុងការប្រើប្រាស់ផ្នែកផ្សេងៗ នៃរាងកាយ និងចាប់អារម្មណ៍ពីការលូតលាស់របស់រាងកាយ។

### ខ. សម្ភារឧបទេស៖

- កុមារា និងកុមារី ក្នុងថ្នាក់រៀនជាក់ស្តែង

### គ. ការរៀបចំ៖

- កុមារក្នុងថ្នាក់ទាំងអស់ចូលរួមសង្កេត

### ឃ. ដំណើរការសកម្មភាព៖

- ជ្រើសរើសកុមារពីរនាក់ ម្នាក់ជាកុមារា ម្នាក់ជាកុមារី មកបង្ហាញកុមារដទៃទៀត
- ទុកពេលឱ្យកុមារសង្កេត ពិភាក្សា និងរៀបរាប់ពីអ្វីផ្នែកផ្សេងៗនៃរាងកាយ និងតួនាទីរបស់វា
- សួរបន្ថែមមានអ្វីលើរូបនេះដែលកូនមិនទាន់រៀបរាប់អស់ ?
- បំពេញបន្ថែមនូវអ្វីដែលកុមារមិនទាន់ស្គាល់
- សង្ខេបខ្លឹមសារៈសំខាន់ៗ នៃមេរៀន
- បំផុសរកចំណងជើងមេរៀន។

*សម្គាល់៖ បន្ទាប់មកគ្រូអាចឱ្យកុមារលេងល្បែងផ្គូផ្គងរូបភាពរាងកាយមនុស្សទៅនឹងសម្ភារៈប្រើប្រាស់។*

## ៣. ថ្នាក់កម្រិតខ្ពស់

### ក. វត្ថុបំណង៖

- ប្រាប់ពីឈ្មោះផ្នែកផ្សេងៗ នៃរាងកាយមនុស្សបានត្រឹមត្រូវ
- បង្ហាញពីរូបផ្គុំនៃរាងកាយមនុស្សបានត្រឹមត្រូវ
- ប្រុងប្រយ័ត្នក្នុងការប្រើប្រាស់ផ្នែកផ្សេងៗ នៃរាងកាយ និងចាប់អារម្មណ៍ពីការលូតលាស់របស់រាងកាយ។

### ខ. សម្ភារឧបទេស៖

- កុមារា និងកុមារី ក្នុងថ្នាក់រៀនជាក់ស្តែង

គ. ការរៀបចំ៖

- កុមារក្នុងថ្នាក់ទាំងអស់ចូលរួមសង្កេត

ឃ. ដំណើរការសកម្មភាព៖

- ជ្រើសរើសកុមារពីរនាក់ ម្នាក់ជាកុមារា ម្នាក់ជាកុមារី មកបង្ហាញកុមារដទៃទៀត
- ទុកពេលឱ្យកុមារសង្កេត ពិភាក្សា និងរៀបរាប់ពីអ្វីផ្នែកផ្សេងៗនៃរាងកាយ និងតួនាទីរបស់វា
- សួរបន្ថែមហេតុអ្វីបានជាកូនយករូបមួយនេះ?
- បំពេញបន្ថែមនូវអ្វីដែលកុមារមិនទាន់ស្គាល់
- សង្ខេបខ្លឹមសារៈសំខាន់ៗ នៃមេរៀន
- បំផុសរកចំណងជើងមេរៀន។

*សម្គាល់៖ បន្ទាប់មកគ្រូអាចឱ្យកុមារលេងល្បែងផ្គូផ្គងរូបភាពរាងកាយមនុស្សទៅនឹងសម្ភារៈប្រើប្រាស់។*

**មេរៀនមួយចំនួនដែលពាក់ព័ន្ធនឹងប្រធានបទការរស់នៅប្រចាំថ្ងៃ**

**ខ្លឹមសារ ការប្រើប្រាស់សម្ភារៈតាមបច្ចេកវិទ្យា**

| ទស្សនាសង្កេត | សង្កេត | ពិសោធន៍ | សកម្មភាពគោលផ្សេងៗ |
|---|---|---|---|
| | • កង្ហា<br>• ទូរទស្សន៍<br>• អាគុយ<br>• ទូរស័ព្ទ | | • សន្ទនា៖ ឧបករណ៍បច្ចេកវិទ្យាដែលប្រើប្រាស់ប្រចាំថ្ងៃ<br>• ល្បែង៖ គូសភ្ជាប់វត្ថុទៅ នឹងរាងកាយមនុស្ស<br>• ល្បែងសាងសង់៖ សេរី<br>• ល្បែង៖ រៀបចំបរិស្ថានសាលារៀន |

ឧទាហរណ៍៖ សង្កេត កង្ហា






youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ១. ថ្នាក់កម្រិតទាប

### ក. វត្ថុបំណង៖

- ប្រាប់ពីឈ្មោះផ្នែកផ្សេងៗ នៃរូបផ្គុំកង្ហាបានត្រឹមត្រូវ
- ប្រើប្រាស់កង្ហាបានត្រឹមត្រូវ
- ប្រុងប្រយ័ត្នក្នុងការប្រើប្រាស់សម្ភារៈដោយប្រើអគ្គិសនី។

### ខ. សម្ភារឧបទេស៖

- កង្ហា

### គ. ការរៀបចំ៖

- កុមារក្នុងថ្នាក់ទាំងអស់ចូលរួមសង្កេត

### ឃ. ដំណើរការសកម្មភាព៖

- បំផុសកុមារឱ្យប្រាប់ពីសម្ភារៈផ្សេងៗ ដែលប្រើប្រាស់ដោយបច្ចេកវិទ្យា
- បង្ហាញកង្ហាបញ្ឈរមួយដែលប្រើប្រាស់ចរន្តអគ្គិសនីឱ្យកុមារសង្កេត
- ទុកពេលឱ្យកុមារសង្កេត ពិភាក្សា និងរៀបរាប់ពីអ្វីផ្នែកផ្សេងៗនៃរាងកាយ និងតួនាទីរបស់វា
- បំពេញបន្ថែមនូវអ្វីដែលកុមារមិនទាន់ស្គាល់ ពីរបៀបប្រើប្រាស់ ការប្រុងប្រយ័ត្ន
- សង្ខេបខ្លឹមសារៈសំខាន់ៗ នៃមេរៀន និងឱ្យកុមារសាកល្បងប្រើប្រាស់
- បំផុសរកចំណងជើងមេរៀន។

## ២. ថ្នាក់កម្រិតមធ្យម

### ក. វត្ថុបំណង៖

- ប្រាប់ពីឈ្មោះផ្នែកផ្សេងៗ នៃរូបផ្គុំកង្ហាបានត្រឹមត្រូវ
- ប្រើប្រាស់កង្ហាបានត្រឹមត្រូវ
- ប្រុងប្រយ័ត្នក្នុងការប្រើប្រាស់សម្ភារៈដោយប្រើអគ្គិសនី។

### ខ. សម្ភារឧបទេស៖

- កង្ហា

### គ. ការរៀបចំ៖

- កុមារក្នុងថ្នាក់ទាំងអស់ចូលរួមសង្កេត

### ឃ. ដំណើរការសកម្មភាព៖

- បំផុសកុមារឱ្យប្រាប់ពីសម្ភារៈផ្សេងៗ ដែលប្រើប្រាស់ដោយបច្ចេកវិទ្យា
- បង្ហាញកង្ហាបញ្ឈរមួយដែលប្រើប្រាស់ចរន្តអគ្គិសនីឱ្យកុមារសង្កេត
- ទុកពេលឱ្យកុមារសង្កេត ពិភាក្សា និងរៀបរាប់ពីអ្វីផ្នែកផ្សេងៗនៃរាងកាយ និងតួនាទីរបស់វា

- បំពេញបន្ថែមនូវអ្វីដែលកុមារមិនទាន់ស្គាល់ ពីរបៀបប្រើប្រាស់ ការប្រុងប្រយ័ត្ន
- កុមារអនុវត្តការប្រើប្រាស់កង្ហា
- សង្ខេបខ្លឹមសារៈសំខាន់ៗ នៃមេរៀន និងឱ្យកុមារសាកល្បងប្រើប្រាស់
- បំផុសរកចំណងជើងមេរៀន។

## ២. ថ្នាក់កម្រិតខ្ពស់

### ក. វត្ថុបំណង៖

- ប្រាប់ពីឈ្មោះផ្នែកផ្សេងៗ នៃរូបផ្តុំកង្ហាបានត្រឹមត្រូវ
- ប្រើប្រាស់កង្ហាបានត្រឹមត្រូវ
- ប្រុងប្រយ័ត្នក្នុងការប្រើប្រាស់សម្ភារៈដោយប្រើអគ្គិសនី។

### ខ. សម្ភារឧបទេស៖

- កង្ហា

### គ. ការរៀបចំ៖

- កុមារក្នុងថ្នាក់ទាំងអស់ចូលរួមសង្កេត

### ឃ. ដំណើរការសកម្មភាព៖

- បំផុសកុមារឱ្យប្រាប់ពីសម្ភារៈផ្សេងៗ ដែលប្រើប្រាស់ដោយបច្ចេកវិទ្យា
- បង្ហាញកង្ហាបញ្ឈរមួយដែលប្រើប្រាស់ចរន្តអគ្គិសនីឱ្យកុមារសង្កេត
- ទុកពេលឱ្យកុមារសង្កេត ពិភាក្សា និងរៀបរាប់ពីអ្វីផ្នែកផ្សេងៗនៃរាងកាយនិងតួនាទីរបស់វា
- បំពេញបន្ថែមនូវអ្វីដែលកុមារមិនទាន់ស្គាល់ ពីរបៀបប្រើប្រាស់ ការប្រុងប្រយ័ត្ន
- កុមារអនុវត្តការប្រើប្រាស់កង្ហា
- សង្ខេបខ្លឹមសារៈសំខាន់ៗ នៃមេរៀន និងឱ្យកុមារសាកល្បងប្រើប្រាស់
- បំផុសរកចំណងជើងមេរៀន។

**មេរៀនមួយចំនួនដែលពាក់ព័ន្ធនឹងប្រធានបទការរស់នៅប្រចាំថ្ងៃ**

**ខ្លឹមសារ មធ្យោបាយធ្វើដំណើរ**

| ទស្សនាសង្កេត | សង្កេត | ពិសោធន៍ | សកម្មភាពគោលផ្សេងៗ |
|---|---|---|---|
| | • មធ្យោបាយធ្វើដំណើរផ្លូវគោក<br>• មធ្យោបាយធ្វើដំណើរផ្លូវអាកាស និងផ្លូវទឹក | | • ល្បែង៖ ទឹក គោក និង អាកាស<br>• ល្បែង៖ ផ្គុំរូបមធ្យោបាយធ្វើដំណើរ<br>• រឿងនិទាន៖ ទូកខ្ញុំនៅឯណា?<br>• រឿងនិទាន៖ សួនកុមារ<br>• ល្បែង៖ គូសភ្ជាប់យានជំនិះទៅនឹងទីកន្លែង |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | | |
|---|---|---|---|
| | | | • ល្បែង ៖ ចំណាត់ថ្នាក់មធ្យោបាយធ្វើដំណើរ<br>• ល្បែង ៖ តាថាឈ្មោះយានជំនិះ |

ឧទាហរណ៍៖ សង្កេត កង់




## ១. ថ្នាក់កម្រិតទាប

### ក. វត្ថុបំណង៖

- ប្រាប់បានពីផ្នែកផ្សេងៗ របស់កង់ ផ្នែកខាងមុខ ផ្នែកកណ្ដាល និងផ្នែកខាងក្រោយ បានត្រឹមត្រូវ
- ចង្អុលបង្ហាញពីផ្នែកផ្សេងៗ នៃកង់ដូចជា កង់ ដៃកង់ កែប កាំ ឬលើសពីនេះ បានត្រឹមត្រូវ
- បង្ហាញពីផលប្រយោជន៍នៃការប្រើប្រាស់កង់ជាមធ្យោបាយធ្វើដំណើរ មានការប្រុងប្រយ័ត្ន និងការថែទាំ។

### ខ. សម្ភារឧបទេស៖

- កង់

### គ. ការរៀបចំ៖

- កុមារក្នុងថ្នាក់ទាំងអស់ចូលរួមសង្កេត

### ឃ. ដំណើរការសកម្មភាព៖

- បំផុសកុមារឱ្យរៀបរាប់ពីមធ្យោបាយធ្វើដំណើរផ្សេងៗ
- បង្ហាញកង់តូចមួយឱ្យកុមារសង្កេត

- ទុកពេលឱ្យកុមារសង្កេត ពិភាក្សា និងរៀបរាប់ពីអ្វីផ្នែកផ្សេងៗនៃកង់ និងតួនាទីរបស់វា (ផ្នែកខាងមុខ ផ្នែកកណ្ដាល និងផ្នែកខាងក្រោយ)
- បំពេញបន្ថែមនូវអ្វីដែលកុមារមិនទាន់ស្គាល់ ពីរបៀបប្រើប្រាស់ ការប្រុងប្រយ័ត្ន
- សង្ខេបខ្លឹមសារៈសំខាន់ៗ នៃមេរៀន
- បំផុសរកចំណងជើងមេរៀន។

## ២. ថ្នាក់កម្រិតមធ្យម

### ក. វត្ថុបំណង៖

- ប្រាប់បានពីផ្នែកផ្សេងៗ របស់កង់ ផ្នែកខាងមុខ ផ្នែកកណ្ដាល និងផ្នែកខាងក្រោយ បានត្រឹមត្រូវ
- ចង្អុលបង្ហាញពីផ្នែកផ្សេងៗ នៃកង់ដូចជា កង់ ដៃកង់ កែប កាំ ឬលើសពីនេះ បានត្រឹមត្រូវ
- បង្ហាញពីផលប្រយោជន៍នៃការប្រើប្រាស់កង់ជាមធ្យោបាយធ្វើដំណើរ មានការប្រុងប្រយ័ត្ន និងការថែទាំ។

### ខ. សម្ភារឧបទេស៖

- កង់

### គ. ការរៀបចំ៖

- កុមារក្នុងថ្នាក់ទាំងអស់ចូលរួមសង្កេត

### ឃ. ដំណើរការសកម្មភាព៖

- បំផុសកុមារឱ្យរៀបរាប់ពីមធ្យោបាយធ្វើដំណើរផ្សេងៗ
- បង្ហាញកង់តូចមួយឱ្យកុមារសង្កេត
- ទុកពេលឱ្យកុមារសង្កេត ពិភាក្សា និងរៀបរាប់ពីអ្វីផ្នែកផ្សេងៗនៃកង់ និងតួនាទីរបស់វា (ផ្នែកខាងមុខ ផ្នែកកណ្ដាល និងផ្នែកខាងក្រោយ)
- បំពេញបន្ថែមនូវអ្វីដែលកុមារមិនទាន់ស្គាល់ ពីរបៀបប្រើប្រាស់ ការប្រុងប្រយ័ត្ន
- កុមារអនុវត្តការប្រើប្រាស់កង់
- សង្ខេបខ្លឹមសារៈសំខាន់ៗ នៃមេរៀន
- បំផុសរកចំណងជើងមេរៀន។

## ៣. ថ្នាក់កម្រិតខ្ពស់

### ក. វត្ថុបំណង៖

- ប្រាប់បានពីផ្នែកផ្សេងៗ របស់កង់ ផ្នែកខាងមុខ ផ្នែកកណ្ដាល និងផ្នែកខាងក្រោយ បានត្រឹមត្រូវ
- ចង្អុលបង្ហាញពីផ្នែកផ្សេងៗ នៃកង់ដូចជា កង់ ដៃកង់ កែប កាំ ឬលើសពីនេះ បានត្រឹមត្រូវ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- បង្ហាញពីផលប្រយោជន៍នៃការប្រើប្រាស់កង់ជាមធ្យោបាយធ្វើដំណើរ មានការប្រុងប្រយ័ត្ន និងការថែទាំ។

ខ. សម្ភារឧបទេស៖

- កង់

គ. ការរៀបចំ៖

- កុមារក្នុងថ្នាក់ទាំងអស់ចូលរួមសង្កេត

ឃ. ដំណើរការសកម្មភាព៖

- បំផុសកុមារឱ្យរៀបរាប់ពីមធ្យោបាយធ្វើដំណើរផ្សេងៗ
- បង្ហាញកង់តូចមួយឱ្យកុមារសង្កេត
- ទុកពេលឱ្យកុមារសង្កេត ពិភាក្សា និងរៀបរាប់ពីអ្វីផ្នែកផ្សេងៗនៃកង់ និងតួនាទីរបស់វា (ផ្នែកខាងមុខ ផ្នែកកណ្តាល និងផ្នែកខាងក្រោយ)
- បំពេញបន្ថែមនូវអ្វីដែលកុមារមិនទាន់ស្គាល់ ពីរបៀបប្រើប្រាស់ ការប្រុងប្រយ័ត្ន
- កុមារអនុវត្តការប្រើប្រាស់កង់
- សង្ខេបខ្លឹមសារៈសំខាន់ៗ នៃមេរៀន
- បំផុសរកចំណងជើងមេរៀន។

**មេរៀនមួយចំនួនដែលពាក់ព័ន្ធនឹងប្រធានបទការយល់ដឹងពីហេតុនិងផល**

| ទស្សនាសង្កេត | សង្កេត | ពិសោធន៍ | សកម្មភាពគោលផ្សេងៗ |
|---|---|---|---|
| | • ព្រឹត្តិការណ៍មុនពេលភ្លៀង<br>• ព្រឹត្តិការណ៍ក្នុងពេល និងក្រោយពេលភ្លៀង<br>• វិធីការពារខ្លួនពេលមានផ្លេកបន្ទោរភ្លៀង | | • សន្ទនា៖ ឧបករណ៍បច្ចេកវិទ្យាដែលប្រើប្រាស់ប្រចាំថ្ងៃ<br>• ល្បែង៖ គូសភ្ជាប់វត្ថុទៅ នឹងរាងកាយមនុស្ស<br>• ល្បែង៖ ភ្លៀងធ្លាក់<br>• រឿងនិទាន៖ មេអំបៅមួយគូ<br>• រឿងនិទាន៖ ពពក និងកូនផ្កា<br>• សន្ទនា៖ ការប្រែប្រួលរបស់វត្ថុ<br>• រឿងនិទាន៖ រមៀល |

## ឧទាហរណ៍៖ សង្កេត ព្រឹត្តិការណ៍មុនពេលភ្លៀង



### ១. ថ្នាក់កម្រិតទាប

#### ក. វត្ថុបំណង៖

- ប្រាប់ពីសកម្មភាពផ្សេងៗ ទាក់ទងនឹងមនុស្ស សត្វ រុក្ខជាតិ អាកាសធាតុ មុនពេលភ្លៀងបានត្រឹមត្រូវ
- ទាយទុកមុនពីព្រឹត្តិការណ៍មុនពេលភ្លៀងបានត្រឹមត្រូវ
- ប្រុងប្រយ័ត្នមុនពេលភ្លៀង។

#### ខ. សម្ភារឧបទេស៖

- ផ្ទាំងរូបភាព ឬវីដេអូខ្លីៗ ពីព្រឹត្តិការណ៍មុនពេលភ្លៀង

#### គ. ការរៀបចំ៖

- កុមារក្នុងថ្នាក់ទាំងអស់ចូលរួមសង្កេត

#### ឃ. ដំណើរការសកម្មភាព៖

- បំផុសគំនិតកុមារស្វែងយល់ពីអាកាសធាតុផ្សេងៗ នៅក្នុងតំបន់ដែលរស់នៅ ឬប្រទេសកម្ពុជា
- បង្ហាញផ្ទាំងរូបភាពហេតុការណ៍ផ្ទាល់ទាក់ទងនឹងព្រឹត្តិការណ៍មុនពេលភ្លៀងឱ្យកុមារសង្កេត
- ទុកពេលឱ្យកុមារសង្កេតជារួម ឬតាមក្រុម ដោយទុកពេលឱ្យកុមារសង្កេត និងពិភាក្សាក្នុងក្រុម
- កុមាររៀបរាប់នូវអ្វីដែលគេបានដឹង និងតាមរយៈផ្ទាំងរូបភាព គ្រូជួយបំពេញបន្ថែម
- សង្ខេបខ្លឹមសារៈសំខាន់ៗ នៃព្រឹត្តិការណ៍មុនពេលភ្លៀង ដូចជា ពពកខ្មៅ ខ្យល់បក់ខ្លាំងៗ ជាសញ្ញាដែលបង្ហាញថាមេឃនឹងភ្លៀង
- បំផុសរកចំណងជើងមេរៀន។

### ២. ថ្នាក់កម្រិតមធ្យម

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ក. វត្ថុបំណង៖

- ប្រាប់ពីសកម្មភាពផ្សេងៗ ទាក់ទងនឹងមនុស្ស សត្វ រុក្ខជាតិ អាកាសធាតុ មុនពេលភ្លៀងបានត្រឹមត្រូវ
- ទាយទុកមុនពីព្រឹត្តិការណ៍មុនពេលភ្លៀងបានត្រឹមត្រូវ
- ប្រុងប្រយ័ត្នមុនពេលភ្លៀង។

ខ. សម្ភារឧបទេស៖

- ផ្ទាំងរូបភាព ឬវីដេអូខ្លីៗ ពីព្រឹត្តិការណ៍មុនពេលភ្លៀង

គ. ការរៀបចំ៖

- កុមារក្នុងថ្នាក់ទាំងអស់ចូលរួមសង្កេត

ឃ. ដំណើរការសកម្មភាព៖

- បំផុសគំនិតកុមារស្វែងយល់ពីអាកាសធាតុផ្សេងៗ នៅក្នុងតំបន់ដែលរស់នៅ ឬប្រទេសកម្ពុជា
- បង្ហាញផ្ទាំងរូបភាពហេតុការណ៍ផ្ទាល់ទាក់ទងនឹងព្រឹត្តិការណ៍មុនពេលភ្លៀងឱ្យកុមារសង្កេត
- ទុកពេលឱ្យកុមារសង្កេតជារួម ឬតាមក្រុម ដោយទុកពេលឱ្យកុមារសង្កេត និងពិភាក្សាក្នុងក្រុម
- កុមាររៀបរាប់នូវអ្វីដែលគេបានដឹង និងតាមរយៈផ្ទាំងរូបភាព គ្រូជួយបំពេញបន្ថែម
- សួរបន្ថែម តើកូនធ្លាប់ជួបមេឃបែបនេះទេ?
- សង្ខេបខ្លឹមសារៈសំខាន់ៗ នៃព្រឹត្តិការណ៍មុនពេលភ្លៀង ដូចជា ពពកខ្មៅ ខ្យល់បក់ខ្លាំងៗ ជាសញ្ញាដែលបង្ហាញថាមេឃនឹងភ្លៀង...
- បំផុសរកចំណងជើងមេរៀន។

## ៣. ថ្នាក់កម្រិតខ្ពស់

ក. វត្ថុបំណង៖

- ប្រាប់ពីសកម្មភាពផ្សេងៗ ទាក់ទងនឹងមនុស្ស សត្វ រុក្ខជាតិ អាកាសធាតុ មុនពេលភ្លៀងបានត្រឹមត្រូវ
- ទាយទុកមុនពីព្រឹត្តិការណ៍មុនពេលភ្លៀងបានត្រឹមត្រូវ
- ប្រុងប្រយ័ត្នមុនពេលភ្លៀង។

ខ. សម្ភារឧបទេស៖

- ផ្ទាំងរូបភាព ឬវីដេអូខ្លីៗ ពីព្រឹត្តិការណ៍មុនពេលភ្លៀង

គ. ការរៀបចំ៖

- កុមារក្នុងថ្នាក់ទាំងអស់ចូលរួមសង្កេត

ឃ. ដំណើរការសកម្មភាព៖

- បំផុសគំនិតកុមារស្វែងយល់ពីអាកាសធាតុផ្សេងៗ នៅក្នុងតំបន់ដែលរស់នៅ ឬប្រទេសកម្ពុជា
- បង្ហាញផ្ទាំងរូបភាពហេតុការណ៍ផ្ទាល់ទាក់ទងនឹងព្រឹត្តិការណ៍មុនពេលភ្លៀងឱ្យកុមារសង្កេត
- ទុកពេលឱ្យកុមារសង្កេតជារួម ឬតាមក្រុម ដោយទុកពេលឱ្យកុមារសង្កេត និងពិភាក្សាក្នុងក្រុម
- កុមាររៀបរាប់នូវអ្វីដែលគេបានដឹង និងតាមរយៈផ្ទាំងរូបភាព គ្រូជួយបំពេញបន្ថែម
- សួរបន្ថែម៖
  - តើកូនធ្លាប់ជួបមេឃបែបនេះទេ?
  - តើកូនឃើញនៅកន្លែងណា?
  - តើកូនមានអារម្មណ៍បែបណា?
- សង្ខេបខ្លឹមសារៈសំខាន់ៗ នៃព្រឹត្តិការណ៍មុនពេលភ្លៀង ដូចជា ពពកខ្មៅ ខ្យល់បក់ខ្លាំងៗ ជាសញ្ញាដែលបង្ហាញថាមេឃនឹងភ្លៀង
- បំផុសរកចំណងជើងមេរៀន។

**មេរៀនមួយចំនួនដែលពាក់ព័ន្ធនឹងប្រធានបទចំណេះដឹងអំពីសហគមន៍**

| ទស្សនាសង្កេត | សង្កេត | ពិសោធន៍ | សកម្មភាពគោលផ្សេងៗ |
|---|---|---|---|
| • វត្ត<br>• មុខរបរក្នុងភូមិ | • មណ្ឌលសុខភាព<br>• សាលាឃុំ | | • ល្បែង៖ ប្រព័ន្ធគ្រួសារអំពីមុខរបរ<br>• ល្បែង៖ គូសភ្ជាប់វត្ថុទៅនឹងរាងកាយមនុស្ស<br>• ចម្រៀង៖ ឱផ្ទៃស្រុកខ្មែរ<br>• រឿងនិទាន៖ ជីវភាពភូមិខ្ញុំ<br>• ល្បែង៖ ចំណាត់ថ្នាក់សម្ភារៈសម្រាប់វត្ត និងមណ្ឌលសុខភាព |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# ជំពូក ៤

# ការរៀបចំបរិស្ថានសិក្សា នៃមុខវិជ្ជា

# វិទ្យាសាស្ត្រ

## ជំពូកទី ៤ ការរៀបចំបរិស្ថានសិក្សា នៃមុខវិជ្ជាវិទ្យាសាស្ត្រ

បរិស្ថានសិក្សាជាទីមេត្រីរបស់កុមារសំដៅទៅលើការរៀបចំថ្នាក់រៀនតាមលក្ខណៈគរុកោសល្យ មានផាសុកភាព សុវត្ថិភាព ជាទីទាក់ទាញកុមារឱ្យចេះស្រឡាញ់ថ្នាក់រៀន និងចូលចិត្តរៀនសូត្រ។ ការរៀបចំថ្នាក់រៀនដោយផ្អែកតាមគរុកោសល្យប្រកបដោយផាសុកភាពល្អ ទាំងផ្លូវកាយ និងផ្លូវចិត្ត គ្រូមត្តេយ្យសិក្សាត្រូវតែរៀបចំតាមវិធីដូចខាងក្រោម៖

- ថ្នាក់រៀនត្រូវមានពន្លឺគ្រប់គ្រាន់
- ថ្នាក់រៀនត្រូវមានខ្យល់អាកាសចេញចូលគ្រប់គ្រាន់
- ថ្នាក់រៀនត្រូវមានទីកន្លែងសម្រាប់កុមារលេងមានសុវត្ថិភាព អនាម័យ សម្រាប់កុមារអនុវត្តសកម្មភាពជាក្រុមតូច ក្រុមមធ្យម ក្រុមធំ
- ថ្នាក់រៀនត្រូវមានជ្រុងសិក្សាព្រមទាំងសម្ភារៈសម្បូរបែប ហើយត្រូវមានអនាម័យ សុវត្ថិភាព និងត្រូវឧស្សាហ៍ផ្លាស់ប្តូរ
- តុ កៅអី ក្តារខៀន ដែលកុមារអង្គុយត្រូវស្របតាមវ័យ ធានាសុវត្ថិភាពស្របតាមមេរៀន(អង្គុយជារាងអក្សរអ៊ុយ កន្លះរង្វង់ លើកន្ទេល លើឥដ្ឋ ជាដើម)
- សម្ភារៈដែលនៅខាងឆ្វេង ខាងស្តាំក្តារខៀន ដូចជា តារាងឈ្មោះក្រុមកុមារ សកម្មភាពប្រចាំថ្ងៃ តារាងអូសលេខប្រចាំខែ តារាងប្រចាំសប្តាហ៍ ជាដើម ត្រូវរៀបចំយ៉ាងណាឱ្យកុមារបានអនុវត្ត និងពិនិត្យកិច្ចការរបស់ពួកគេបានងាយស្រួល ព្រមទាំងទុកដាក់បានត្រឹមត្រូវ
- កុមាររៀនតាមរយៈការលេង ដូចនេះ គ្រូត្រូវរៀបចំបរិស្ថានសិក្សាក្នុង និងក្រៅថ្នាក់រៀន ទៅតាមសកម្មភាពប្រចាំថ្ងៃ ធ្វើយ៉ាងណាឱ្យកុមារផ្តោតអារម្មណ៍សកម្មភាពក្នុងថ្នាក់ និងកុមារចូលរួមលេង។ កុមារចូលចិត្តលេង ហើយការលេង គឺកុមារមិននៅតែមួយកន្លែងនោះទេ គេតែងតែផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយ និងពីសកម្មភាពមួយសកម្មភាពមួយទៀតដើម្បីលេង ដូចនេះ ការរៀបចំទីកន្លែងសម្រាប់កុមារលេងមានសារៈសំខាន់ណាស់ ព្រោះថាកុមារបានលេងកុមារនឹងទទួលបានការអភិវឌ្ឍពេញលេញ។

> ការរៀបចំទីកន្លែងសម្រាប់កុមារអនុវត្តសកម្មភាពក្នុងថ្នាក់ ឬក្រៅថ្នាក់ អាស្រ័យលើខ្លឹមសារមេរៀន ដោយធានាបាននូវលក្ខណៈគរុកោសល្យ។

### ៤.១. យន្តការអនុវត្ត

កុមារពិតជាសប្បាយរីករាយនៅពេលឃើញគ្រូបានរៀបចំសម្ភារៈលេងជាច្រើន និងសម្បូរបែប នៅក្នុងថ្នាក់ និងក្រៅថ្នាក់របស់ពួកគេ ព្រោះថាកុមារលេងគឺរៀន រៀនគឺលេង។ ដូចនេះ គ្រូគប្បីរៀបចំឱ្យមានសម្ភារៈល្បែងសម្រាប់កុមារលេងទាំងក្នុង និងក្រៅថ្នាក់ ដើម្បីឆ្លើយតបនឹងការអភិវឌ្ឍគ្រប់ផ្នែករបស់កុមារ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ✚ ក្នុងថ្នាក់

ថ្នាក់មត្តេយ្យសិក្សាត្រូវបានរៀបចំជ្រុងសិក្សាសម្រាប់កុមារ ដើម្បីជួយឱ្យកុមារធ្វើការជាក្រុមតូចៗ និងផ្តោតលើការអភិវឌ្ឍ ការយល់ដឹងជាច្រើន នៅពេលពួកគេលេង។ នៅតាមជ្រុងគ្រូរៀបចំមានគោលបំណងឱ្យកុមារចេះធ្វើការស្វែងយល់ពីអ្វីដែលពួកគេចង់បង្កើតថ្មី ដើម្បីលើកកម្ពស់ចំណេះដឹង ជំនាញ និងការសម្រេចចិត្ត។ ទីធ្លាបែបនេះនៅក្នុងថ្នាក់រៀន ជាទូទៅត្រូវបានគេដាក់ឈ្មោះថាជ្រុងសិក្សាសម្រាប់កុមារដែលជាកន្លែងសម្រាប់កុមារចូលរួមនៅក្នុងសកម្មភាពផ្សេងៗគ្នា។ គ្រូបានផ្តល់ឱ្យពួកគេស្វែងរកសម្ភារៈជាច្រើន ស្វែងយល់ពីព័ត៌មាន និងដំណោះស្រាយ ហើយធ្វើសេចក្តីសន្និដ្ឋានអំពីសំណួរដែលពួកគេបានសួរ ឬសម្មតិកម្មដែលពួកគេបានបង្កើត។ គេអាចបង្កើតទីធ្លាសិក្សាផ្សេងទៀតដែរួមមាន ទីធ្លាសិក្សាពីធម្មជាតិ និងទីធ្លាសម្រាប់អ្នករុករក។

ការស្វែងរកចំណេះដឹង និងជំនាញក្នុងការស្វែងយល់ពិភពខាងក្រៅ ក៏អាចត្រូវបានដាក់បញ្ចូលទៅក្នុងទីធ្លាសិក្សាផ្សេងទៀតផងដែរដូចជា ទីធ្លាសាងសង់ ឬទីធ្លាលេងកម្សាន្ត ទីធ្លាសិល្បៈ និងសិប្បកម្ម ប្រសិនបើគ្រូបង្រៀនរៀបចំ និងបង្កើតរចនាសម្ព័ន្ធរបស់វាដោយប្រុងប្រយ័ត្នសម្រាប់កុមារដើម្បី៖

- ចូលរួមក្នុងបទពិសោធន៍ដ៏មានអត្ថន័យ
- ធ្វើការលេង និងប្រាស្រ័យទាក់ទងជាមួយមិត្តភក្តិ និងគ្រូបង្រៀនរបស់ពួកគេ
- មានលទ្ធភាពប្រើប្រាស់ឧបករណ៍ ដើម្បីជួយដោះស្រាយបញ្ហា និងការធ្វើពិសោធន៍

## ✚ ក្រៅថ្នាក់

សាលាមត្តេយ្យសិក្សាត្រូវរៀបចំបរិស្ថានខាងក្រៅថ្នាក់ឱ្យមានលក្ខណៈជាពិសេសសម្រាប់កុមារ៖

- រៀនអំពីវត្ថុដែលពួកគេបានឃើញនៅក្នុងបរិស្ថាន
- ស្វែងរកប្រធានបទថ្មីៗ ក្នុងការទាក់ទាញចំណាប់អារម្មណ៍
- អភិវឌ្ឍជំនាញជាជំហានៗ ដូចជា ការសង្កេត ការដោះស្រាយបញ្ហា និងការសម្រេចចិត្ត

កុមារអាចចូលទស្សនាហើយចូលទស្សនាទៀត នៅទីកន្លែងសាធារណៈ ឬរុក្ខជាតិផ្សេងៗ ដែលមាននៅក្នុងបរិស្ថានជុំវិញសាលា ដើម្បីឱ្យកុមារចេះពិភាក្សាគ្នាជាមួយគ្រូ មិត្តរួមថ្នាក់ អំពីអ្វីដែលបានឃើញ ប៉ះ ស្ទាប ហិតក្លិន ដើម្បីពង្រីកការយល់ដឹងរបស់កុមារ។ តាមរយៈគ្រូបានអនុវត្តទៅតាមប្រធានបទផ្សេងៗ ដែលបានកំណត់ ហើយគ្រូអាចផ្លាស់ប្តូរជាប្រចាំទៅតាមទីកន្លែងនិងមជ្ឈដ្ឋានដែលមាន ប៉ុន្តែគ្រូត្រូវទុកឱកាសគ្រប់គ្រាន់ដើម្បីឱ្យកុមារគ្រប់គ្នាបានទៅទស្សនាកន្លែងនោះ ហើយបកស្រាយអ្វីដែលបានឃើញ ដើម្បីដោះស្រាយចម្ងល់របស់ពួកគេដែលកើតឡើងគ្រប់ពេលនោះ ។

ទីធ្លានៅខាងក្រៅសាលាអាចក្លាយជាបទពិសោធន៍នៃការស្វែងរកសម្រាប់កុមារតូចៗ។ ការរៀនសូត្រនៅខាងក្រៅថ្នាក់រៀនអាចជួយជំរុញភាពចង់ដឹង ចង់ឃើញ និងអារម្មណ៍របស់កុមារ ព្រោះនេះជាឱកាសរបស់កុមារក្នុងការស្វែងរកជាមួយការមើលឃើញបែបធម្មជាតិ និងសម្រួលដល់ការសិក្សា។ ឧទាហរណ៍៖ កុមារអាចពិនិត្យមើលថា តើមេដែកអាចត្រូវបានស្រូបទាញជាមួយរបង ទោងយោល ជញ្ជាំងឥដ្ឋ ដី ជាដើម ឬទេ?

សកម្មភាពនៅខាងក្រៅក៏ផ្តល់ឱ្យកុមារនូវឱកាសជាច្រើន ដើម្បីអភិវឌ្ឍជំនាញទាក់ទងនឹងសង្គម ដូចជា ការប្រាស្រ័យទាក់ទងផ្ទាល់មាត់ ការផ្លាស់ប្តូរ ការចែករំលែក ការធ្វើការរួមគ្នា និងការកសាងមិត្តភាព។

ការរៀបចំទីធ្លាខាងក្រៅដើម្បីសម្រួលដល់ការរៀនសូត្ររបស់កុមារ និងជួយបង្កើតឱកាសកាន់តែច្រើនសម្រាប់ការរុករក ការប្រាស្រ័យទាក់ទង និងការកម្សាន្តដោយមានគោលបំណងផងដែរ។ គ្រូអាចរៀបចំទីកន្លែងដូចជា៖

❖ **ទីធ្លាលេងទឹក និងខ្សាច់៖**

➢ រៀបចំកន្លែងសម្រាប់កុមារអាចលេងទឹក និងខ្សាច់ ដើម្បីឱ្យកុមារការអភិវឌ្ឍគណិតវិទ្យា និងវិទ្យាសាស្ត្រនៅពេលដែលពួកគេចាក់ទឹក សង្កេតមើលធុងអណ្ដែត និងរុករកដីខ្សាច់សើម និងស្ងួត។ លើសពីនេះទៀតនៅពេលពួកគេរៀបចំឧបករណ៍ផ្សេងៗគ្នា ដូចជា បំពង់ ដំណក់ទឹក ដប កន្ត្រៃ ប៉ែល និងធុង។

➢ គ្រូអាចផ្តល់សម្ភារៈជាច្រើនប្រភេទនៅពេលកុមារលេង ទឹក និងខ្សាច់ ដូចជា ម្សៅសាប៊ូរាវ និងម្សៅលាយពណ៌ផ្សេងទៀត ដើម្បីកុមារអាចបង្កើតគំនិងថ្មីៗ។ ហើយកុមារអាចធ្វើការប្រៀបធៀបពីភាពស្រដៀងគ្នា និងភាពខុសគ្នា រវាងទឹកស្អាតនិងទឹកសាប៊ូ ឬខ្សាច់សើម និងស្ងួត បន្ទាប់មកធ្វើការកត់កត់ត្រាទុក នៅពេលចូលក្នុងថ្នាក់វិញដើម្បីបង្ហាញប្រាប់គ្រូពីលទ្ធផលដែលបានលេងខាងក្រៅថ្នាក់។

❖ **សួនបន្លែ ឬផ្កា៖**

➢ គ្រូទុកពេលវេលាឱ្យកុមារសង្កេតរុក្ខជាតិ ផ្កា សត្វល្អិត ស្រមោច មេអំបៅ ដង្កូវ ដែលមាននៅក្នុងសួន ធ្វើឱ្យកុមារមានការអភិវឌ្ឍចំណេះដឹងដោយខ្លួនឯងអំពីបរិស្ថានដែលនៅជុំវិញខ្លួនដែលខ្លួនរស់នៅប្រចាំថ្ងៃត្រូវជួបប្រទះ។ បរិស្ថានដែលកុមារជួបប្រទះជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេទទួលខុសត្រូវចំពោះការបង្កើនគំនិតយល់ដឹងដោយខ្លួនឯង។

## ៤.២. ការស្វែងរកការគាំទ្រផ្សេងៗ

### ៤.២.១. ការគាំទ្រពីសាលា និងគ្រូបង្រៀន

- គ្រូត្រូវមានការយកចិត្តទុកដាក់ពេលជ្រើសរើសឯកសារ និងការរៀបចំទីកន្លែង ជម្រើសនៃសម្ភារៈ និងឧបករណ៍ ដែលមានសុវត្ថិភាពសម្រាប់កុមារសិក្សាវិទ្យាសាស្ត្រ អនុវត្តដើម្បីឆ្លើយតបតាមគោលបំណង និងគោលដៅរបស់កម្មវិធីសិក្សា
- គ្រូត្រូវអនុវត្តសកម្មភាពបង្ហាញ និងសម្របសម្រួលដល់កុមារក្នុងការប្រើប្រាស់សម្ភារៈ និងឧបករណ៍នានា នៅកន្លែងពិសោធន៍ ទស្សនាសង្កេត សង្កេត។
- **ឧទាហរណ៍៖** ចំណងជើងមេរៀនអំពី «និមិត្តសញ្ញា ឬ សញ្ញានៅជុំវិញយើង» គ្រូត្រូវរៀបចំស្លាកទុកបង្ហាញរូបថត ឬ គំនូសតាង ឬ ផ្ទាំងរូបភាព ដែលជាឧទាហរណ៍ផ្សេងៗគ្នា បានពីការបោះពុម្ពផ្សាយអំពីបរិស្ថាន (ស្លាកផ្លូវ ស្លាកផ្សាយពាណិជ្ជកម្ម ស្លាកសញ្ញាសម្រាប់ហាង) នៅជុំវិញយើង និងទីកន្លែងដែលពួកគេបានរកឃើញ និងមុខងាររបស់ពួកវា។ កុមារអាចយោងទៅលើធនធាន

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដើម្បីបង្កើតសញ្ញា និងនិមិត្តសញ្ញារបស់ពួកគេសម្រាប់ថ្នាក់រៀន សាលាមត្តេយ្យ និងសម្រាប់កន្លែងរស់នៅរបស់ពួកគេផងដែរ។

| សម្ភារៈធម្មជាតិ | វត្ថុមានជីវិត |
|---|---|
| • ផ្កា ផ្លែឈើ និងបន្លែ<br>• គ្រាប់ធញ្ញជាតិ ស្លឹកឈើ<br>• ឈើ មែកឈើ ធាងឈើ<br>• សម្បកខ្យង<br>• ស្លាបសត្វ<br>• ដុំថ្ម ត្បូង គ្រួស<br>• រុក្ខជាតិ និងគ្រឿងទេស<br><br>រួមបញ្ចូលទាំងវត្ថុធម្មជាតិនៅក្នុងបរិស្ថានសិក្សា ផ្តល់ឱ្យកុមារនូវឱកាសក្នុងការទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយធម្មជាតិ។ វត្ថុធាតុដើមធម្មជាតិ ផ្តល់ឱ្យកុមារនូវក្នុងកម្រិតមួយនៃបទពិសោធន៍ដោយការប្រើប្រាស់ញ្ញាណ។ ពួកគេក៏អាចបង្កើន បទពិសោធន៍រៀនជាមួយនឹងក្លិន ពណ៌ សំឡេង និងធាតុផ្សំ។ ការកោតសរសើរនៃពិភពធម្មជាតិត្រូវបានពង្រឹងបន្ថែមទៀត នៅពេលសម្ភារៈធម្មជាតិត្រូវបានដាក់បញ្ចូលទៅក្នុងបរិស្ថាននៃទីធ្លាខាងក្នុង។ | • រុក្ខជាតិ ដី<br>• អាងចិញ្ចឹមត្រី<br>• គំរូផ្ទាល់នៃសត្វល្អិត និងសត្វតូចៗ ផ្សេងទៀត (ឧទាហណ៍៖ ដង្កូវ ដង្កូវមេអំបៅ ខ្យង កូនក្អុក)<br><br>ដើម្បីឱ្យកុមារសិក្សាអំពីរុក្ខជាតិនិងសត្វ គំរូផ្ទាល់នៃរុក្ខជាតិនិងសត្វទាំងនេះ អាចដាក់បញ្ចូលនៅក្នុងមជ្ឈមណ្ឌលស្វែងរកសម្រាប់កុមារ ដើម្បីសង្កេតមើលលក្ខណៈពិសេស និងលំនាំនៃភាពលូតលាស់ ។ កុមារត្រូវតែរៀនថែរក្សាវត្ថុមានជីវិតទាំងនេះ និងសង្កេតមើលគោលការណ៍សុវត្ថិភាព និងទទួលខុសត្រូវនៅពេលយកសត្វចិញ្ចឹមទៅថ្នាក់រៀនរបស់ពួកគេ។ ពួកគេត្រូវតែរៀន នាំយករាល់សត្វទាំងអស់ទៅជម្រកធម្មជាតិរបស់ពួកវាវិញ បន្ទាប់ពីការសង្កេតរបស់ពួកគេធ្វើរួចរាល់។ កុមារអាចរៀនអំពីទំនួលខុសត្រូវ ដោយការថែទាំសម្រាប់សត្វ និងរុក្ខជាតិ ។ ឧទាហរណ៍៖ ពួកគេដាំសណ្តែក នៅក្នុងកែវក្រដាស។ ពួកគេអាចដាក់វេនគ្នាក្នុងការស្រោចទឹក ហើយក៏អាចមើលពីការលូតលាស់ដែលកើតមានឡើង និងធ្វើការកត់ត្រាទុក (ឧទាហរណ៍៖ បម្រែបម្រួលកម្ពស់នៃរុក្ខជាតិ ឬទំហំ និងពណ៌នៃស្លឹក) ។ |

| ឧបករណ៍វិទ្យាសាស្ត្រ | សម្ភារៈអាចប្រើប្រាស់ឡើងវិញ |
|---|---|
| ឧបករណ៍សង្កេត៖<br>• វ៉ែនតាកែវពង្រីក កែវមើល<br>• កញ្ចក់<br>• ភ្លើងពិល<br>ឧបករណ៍វាស់វែង៖<br>• ជញ្ជីងថ្លឹង កែវរង្វាល់<br>• ខ្សែ ខ្សែពួរ<br>• បន្ទះក្រដាស<br>• គូបសម្រាប់ផ្គុំ<br>សម្ភារៈសម្រាប់ផ្ទេរ៖<br>• បំពង់បន្តក់ទឹក<br>• ដង្កៀប តម្រៀតផ្លាស្ទិច<br>• តម្រង ឧបករណ៍សម្រាប់វែង ជីវឡៅផ្លាស្ទិច<br>ផ្សេងៗ៖<br>• មេដែក វ៉ក ស្ពឺ<br>• កង្ហារក្រដាស ឬផ្លាស្ទិច (Pinwheel) កន្តឹងខ្យល់ (wind chimes)<br>• ក្រណាត់ រោមសត្វ<br>• ថ្មម៉ាប ប៊ូតុងចុច អង្កាំ<br>ដើម្បីឱ្យកុមារចូលរួមយ៉ាងសកម្មក្នុងការពិសោធន៍សាមញ្ញ ដើម្បីរកឱ្យឃើញនូវរបៀបដំណើរការ និងរបៀបកើតឡើងរបស់អ្វីមួយ វាចាំបាច់ណាស់ដែលពួកគេមានឧបករណ៍ ឬបច្ចេកវិទ្យាសាមញ្ញ (ឧទាហរណ៍៖ កែវពង្រីក កែវរង្វាល់ អំពូល ពិល ។ល។ ) ដើម្បីសម្រួលដល់ការអង្កេត រួមទាំងសម្ភារៈពួកគេចង់ស្វែងយល់បន្ថែមទៀត (ឧទាហរណ៍៖ ម៉ាស៊ីនតូច វ៉ក មេដែក ។ល។) | • ដបប្លាស្ទិច ធុងថ្នា<br>• ម្ទូរក្រដាស (toilet roll)<br>• ប្រអប់ក្រដាសកាតុង (Cardboard box)<br>• ប្រអប់ក្រដាសសម្រាប់ដាក់មាន់ពង (egg cartons)<br>• ចានអាលុយមីញ៉ូម<br>• កំប៉ុងអាលុយមីញ៉ូម<br>• គម្របដប<br>• ឈើជងការ៉េម<br>• ដបថ្មចាស់ៗ (អាចប្រើសម្រាប់រក្សាទុក)<br>• ទស្សនាវដ្ដី និងកាសែតចាស់ៗ<br><br>ដើម្បីលើកកម្ពស់ការយល់ដឹងរបស់កុមារអំពីរបៀបថែរក្សាបរិស្ថាន និងរបៀបរក្សាទុកសម្ភារៈដែលអាចប្រើប្រាស់ឡើងវិញបានអាចទុកក្នុងមជ្ឈមណ្ឌលស្វែងរក (Discovery Centre)។ ដោយសារកុមារជាអ្នកជ្រើសរើសសម្ភារៈសម្រាប់ប្រើប្រាស់ឡើងវិញ ធ្វើគំរូ បង្កើតសម្ភារៈថ្មី ឬធ្វើគម្រោងបែបសិល្បៈ ទើបពួកគេអភិវឌ្ឍភាពច្នៃប្រឌិត និងអាកប្បកិរិយាប្រកបដោយទំនួលខុសត្រូវដើម្បីបរិស្ថាន។ |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| សម្ភារៈសម្រាប់មើល | សម្ភារៈសម្រាប់ធ្វើកំណត់ត្រា |
|---|---|
| • ព័ត៌មាន ឬសៀវភៅរឿងប្រឌិត ផ្ទាំងរូបភាព សៀវភៅរូបភាព<br>• ផែនទី ភូគោល សៀវភៅផែនទី<br>• រូបថត កាតប៉ូស្តាល់ និងរូបភាព<br>• វីដេអូ<br><br>ដើម្បីលើកកម្ពស់ការយល់ដឹងពីភូមិសាស្ត្រ និង ប្រវត្តិសាស្ត្ររបស់កុមារ ផែនដី ផែនទីរបស់ ប្រទេសកម្ពុជា និងរូបភាពនៃកន្លែងរស់នៅអាច ត្រូវបានបង្ហាញ។ គ្រូអាចប្រាប់ទៅកុមារឱ្យបង្ហាញ ពីអត្តសញ្ញាណនៃតំបន់ដែលជីដូនជីតារបស់ ពួកគេមក។ គេអាចធ្វើតារាងពីផ្នែកផ្សេងៗ នៃ ពិភពលោកដែលបុព្វបុរសរបស់ពួកគេបានមក។ ការប្រមូលផ្តុំនៃរូបថតចាស់ៗ ពណ៌សខ្មៅ និងវត្ថុ ផ្សេងៗទៀត ដែលរំលឹកអំពីមនុស្សនៅអតីតកាល អាចត្រូវបានបង្ហាញទៅកុមារ ដើម្បីមើលហើយ ប្រៀបធៀបជាមួយរបស់ប្រើប្រាស់សព្វថ្ងៃ។ | • ក្រដាស ខ្មៅដៃ គូល័រទៀន គូល័រឈើ ហ្វឺត<br>• ម៉ាស៊ីនថតសំឡេង<br>• ម៉ាស៊ីនថត<br><br>នៅក្នុងមជ្ឈមណ្ឌលស្វែងរក កុមារនឹងត្រូវបានឱ្យ ធ្វើការអង្កេត និងបង្កើតការសង្កេតជាច្រើន។ ដូចនេះ វាមានសារៈសំខាន់សម្រាប់ពួកគេដែល ត្រូវមានកំណត់ត្រាសំឡេងសម្រាប់ការសង្កេត និងស្វែងរក។ ក្រៅពីការធ្វើកំណត់ត្រា ដោយការ គូរ ឬសរសេរ វាមានសារៈសំខាន់ផងដែរសម្រាប់ ពួកគេដូចជា ម៉ាស៊ីនថតរូប ម៉ាស៊ីនថតសំឡេង ដើម្បីផ្តិតយករូបភាព និងសំឡេង សម្រាប់ការ សង្កេត និងស្វែងរក ។ |

### ៤.៤.២. ការគាំទ្រពីមាតាបិតា អាណាព្យាបាល និងពីសហគមន៍

សាលារៀន នាយក នាយិកា និង គ្រូអាចស្នើសុំឱ្យមាតាបិតាកុមារ ឬសហគមន៍ ជួយសម្របសម្រួលសម្ភារៈមួយចំនួនដើម្បីឱ្យកុមារបានសិក្សាកាន់តែល្អប្រសើរមានដូចជា សម្ភារៈ និងឧបករណ៍ជាមូលដ្ឋានដែលត្រូវផលិតក្នុងការបង្រៀន។ សម្ភារៈ និងឧបករណ៍ទាំងនេះរួមមាន វត្ថុជាតុដើមធម្មជាតិ វត្ថុមានជីវិត ឧបករណ៍វិទ្យាសាស្ត្រ សម្ភារៈសម្រាប់មើល និងសម្ភារៈកែច្នៃ។ សម្ភារៈ និងឧបករណ៍បន្ថែមផ្សេងទៀត ដើម្បីបំពេញបន្ថែមនូវប្រធានបទមានស្រាប់ដែលកំពុងសិក្សា។

# ជំពូក ៥

# ការពិនិត្យតាមដាន និងវាយតម្លៃ

youtube.com/moeyscambodia
sala.moeys.gov.kh
t.me/moeysnews

# ជំពូក៥ ការពិនិត្យតាមដាន និងវាយតម្លៃ

សកម្មភាពពាក់ព័ន្ធនឹងការធ្វើពិសោធន៍ សង្កេត និងទស្សនាសង្កេត គឺជាផ្នែកមួយកើតមានក្នុងគំនិតកុមារពីធម្មជាតិ ពីកំណើតរបស់ពួកគេ។ ទាំងនេះរួមមាន ការលាយពណ៌ លាបពណ៌លើផ្ទាំងក្រដាស ឬកំណាត់ស ការដាំគ្រាប់ពូជបន្លែ ផ្កា ការសង្កេត សត្វ ដែលមានក្នុងបរិស្ថានដែលតែងជួបប្រទះ។ ភស្តុតាងខាងលើ និងអ្វីដែលកុមារត្រូវស្វែងយល់ និងស្គាល់ ជួបជាប្រចាំថ្ងៃក្នុងជីវិតរបស់ពួកគេ។

## ៥.១. តួនាទីរបស់កុមារ

- សង្កេត ពិសោធ ជាប្រចាំថ្ងៃនៅសាលាមត្តេយ្យ និងបរិស្ថាន ហើយផ្តល់ព័ត៌មានទៅកាន់គ្រូ
- កុមារអនុវត្តសកម្មភាព គ្រូគ្រាន់តែនៅជិតសម្របសម្រួល និងផ្តល់ឱកាសឱ្យកុមារបកស្រាយពីអ្វីដែលពួកគេកំពុងសង្កេតឃើញ
- កុមារចូលរួមក្នុងសង្កេតអំពីអ្វីដែលគេតែងជួបក្នុងបរិស្ថាន សំណួរជាច្រើនបានកើតឡើងហើយពួកគេនឹងសួរសំណួរទាំងនេះទៅកាន់គ្រូ៖
    - តើនេះជាអ្វី?
    - តើហេតុអ្វីវាកើតក្នុងបរិស្ថាននេះ?
    - តើពេលណាវាលូតលាស់?
- រាល់ការសង្កេតកុមារតែងចងចាំ ឬកត់ត្រា ឬផ្តិតជាប់រូបថតជាភស្តុតាងជូនទៅគ្រូ។

### លទ្ធផលការសង្កេតរបស់កុមារ

- អារម្មណ៍រំភើប អស្ចារ្យ និងចង់ដឹង ចង់ឃើញ នៅក្នុងបរិស្ថានដែលពួកគេរស់នៅ
- ឥរិយាបថឆ្ពោះទៅរកការសង្កេត និងពិសោធន៍
- ឥរិយាបថឆ្ពោះទៅរកបរិស្ថានដែលនៅជុំវិញពួកគេ។

## ៥.២. តួនាទីរបស់គ្រូ

- សម្របសម្រួលប្រមូលព័ត៌មានដែលចេញពីការបកស្រាយរបស់កុមារទុកជាភស្តុតាងនូវអ្វីដែលកុមារមានការអភិវឌ្ឍ
- ផ្តល់ឱកាសឱ្យកុមារបានស្វែងយល់ពីបរិស្ថានជុំវិញខ្លួនពួកគេ
- បង្កើតឱកាស និងបទពិសោធន៍ សមស្របជាងមុនសម្រាប់កុមារ ដើម្បីពិនិត្យមើលពង្រឹងនិងឆ្លុះបញ្ចាំងពីការរៀនសូត្ររបស់ពួកគេ
- ចូលរួមសង្កេត និងចងក្រងឯកសារជាមួយកុមារ ដើម្បីទទួលបានព័ត៌មាននិងស្វែងយល់អំពីគោលដៅសិក្សារបស់កុមារ

### ការវាយតម្លៃលទ្ធផលការសង្កេតរបស់កុមារ

នៅពេលសង្កេតមើលកុមាររកឃើញនូវអ្វីដែលកើតមានក្នុងបរិស្ថានរស់នៅរបស់ពួកគេ។ សូមចងចាំនូវសំណួរដូចខាងក្រោម៖

- តើកុមារសួរសំណួរអ្វីខ្លះ?
- តើកុមារនិយាយអ្វីខ្លះក្នុងអំឡុងការអង្កេតរបស់ពួកគេ?
- តើសម្ភារៈ ឬឧបករណ៍អ្វីខ្លះ ដែលកុមារជ្រើសរើសដើម្បីប្រមូលព័ត៌មាននិងបានរកឃើញ?
- តើកុមារមានប្រតិកម្មយ៉ាងណាចំពោះសម្ភារៈថ្មីដែលបានណែនាំនៅក្នុងថ្នាក់រៀន?
- តើព័ត៌មានលម្អិតប៉ុន្មានដែលពួកគេបានសង្កេត?
- តើពួកគេបានផ្តល់យោបល់អ្វីខ្លះអំពីការរកឃើញរបស់ពួកគេ?
- តើកុមារមានទំនាក់ទំនងគ្នាលើដំណើរការអនុវត្ត និងការគិតរបស់ពួកគេយ៉ាងដូចម្តេច?
- តើព័ត៌មានដែលប្រមូលបានពីការអនុវត្តបានបង្ហាញពីអ្វីដែលជាចំណាប់អារម្មណ៍ និងការចង់ដឹងចង់ឃើញរបស់កុមារឬទេ?
- តើកុមារកត់ត្រា និងរាយការណ៍ពីអ្វីដែលពួកគេបានរៀន និងរកឃើញយ៉ាងដូចម្តេច?
- តើការកត់ត្រារបស់កុមារបង្ហាញអ្វីខ្លះអំពីការយល់ដឹងរបស់ពួកគេ?
- តើពួកគេមានការយល់ច្រឡំ?
- តើពួកគេបង្ហាញសកម្មភាពពីការយល់ឃើញនូវអ្វីដែលគេធ្លាប់ជួបប្រទះពីមុនឬទេ?

គំនិតយល់ឃើញរបស់កុមារក្រោយពីការសង្កេត ពិសោធន៍ ឬទស្សនាសង្កេត បានស្តែងឡើងតាមរយៈសំណួរដែលពួកគេសួរ គ្រូត្រូវពិចារណាពីការអភិវឌ្ឍរបស់កុមារថា៖

- តើកុមារអាចអនុវត្តអ្វីដែលពួកគេបានរៀនឬអត់?
- តើកុមារបានយល់ច្រឡំចំណេះដឹង និងគំនិតដែលទទួលបានថ្មីៗ ឬទេ?

ដើម្បីវាយតម្លៃលើការអភិវឌ្ឍកុមារបានត្រឹមត្រូវគ្រូអាចពិចារណាលើ៖ ការសរុបភស្តុតាងផ្សេងៗគ្នាដែលកុមារបានបង្ហាញ ទោះជាភស្តុតាងដែលកុមារកំពុងធ្វើជាលក្ខណៈបុគ្គល ឬជាលក្ខណៈក្រុមក៏ដោយ។ ខាងក្រោមនេះ ជាឧទាហរណ៍ពីរបៀបដែលអាចវាយតម្លៃការរីកចម្រើននៃគំនិតកុមារមួយចំនួន៖

ឧទាហរណ៍៖ សកម្មភាពកុមារមត្តេយ្យធ្វើទស្សនាសង្កេតសួនបន្លែក្នុងបរិវេណសាលា ដើម្បីរកមើលមានសត្វល្អិតអ្វីក្នុងនោះ នៅពេលដើររកមើលស្រាប់តែកុមារសំបានស្រែកឡើងភ្លាមៗថា «មានខ្យង»។ កុមារផ្សេងទៀតក៏ស្ទុះមកមើលជាមួយកុមារសំដែរ ហើយកំពុងសំឡឹងមើលខ្យងនៅក្រោមដើមស្ពៃ។ កុមារទាំងអស់បង្ហាញចិត្តរំភើបហើយក៏កើតឡើងនូវសំណួរ៖

- តើវាមានជីវិតទេឬ?
- ហេតុអ្វីវាមិនផ្លាស់ទីទៅណាអ៊ីចឹង?
- តើវានឹងទៅណា?

កុមារសំបានរើសខ្យងហើយសួរទៅគ្រូថា «តើគាត់អាចយកខ្យងចូលទៅថ្នាក់រៀនបានដែរឬទេ ដើម្បីពិនិត្យមើលរូបរាងវាបន្ថែមទៀត? គ្រូបានផ្តល់ឱកាសឱ្យកុមារសំយកខ្យងទៅក្នុងថ្នាក់រៀនបាន ប៉ុន្តែគ្រូបានពន្យល់ទៅកុមារសំក៏ដូចជាកុមារដទៃទៀតថា ក្រោយពីពិនិត្យរួចហើយឱ្យកុមារទាំងអស់ត្រូវយកខ្យងនេះមក

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដាក់ក្នុងសួនបន្លែនេះវិញ ព្រោះជាជម្រកធម្មជាតិរបស់សត្វ ។ កុមារសំ និងកុមារផ្សេងទៀត បានឆ្លើយតបវិញថា បើមិនដូច្នេះទេ វានឹងត្រូវស្លាប់មែនទេអ្នកគ្រូ?...

## កំណត់ត្រារួមរបស់គ្រូ៖

- កុមារសំបានជួបទស្សនាសង្កេតឃើញខ្យងនៅពេលដើរលេងក្នុងសួនបន្លែ ហើយឈប់ដើម្បីមើលវា
- កុមារសំ និងកុមារដទៃមិនខ្លាចខ្យងទេ ហើយថែមទាំងយកវាមកថ្នមៗ ជាមួយដៃទទេ
- កុមារសំ និងកុមារដទៃចង់ដឹងអំពីខ្យងហើយក៏សួរសំណួរអំពីវា

## ការបកស្រាយរបស់កុមារ

កុមារសំបានបង្ហាញពីសត្វមានជីវិតដែលគេបានឃើញក្នុងសួនបន្លែ ចែករំលែកទៅកាន់មិត្តភក្តិ និងគ្រូ។ កុមារសំបានបង្ហាញនូវអារម្មណ៍រំភើប ចង់ដឹង ចង់ឃើញ និងចង់ប៉ះខ្យង ដើម្បីយល់ដឹងបន្ថែមអំពីខ្យង។ កុមារសំ បានដឹងអំពីតម្រូវការបន្ថែមនៃជីវិត ភាវៈរស់ និងបង្ហាញពីការស្រឡាញ់ចំពោះសត្វមានជីវិត។

## ការផ្តល់ឱកាសឱ្យកុមារសំ និងកុមារក្នុងថ្នាក់ទាំងអស់នូវ៖

- ឱ្យកុមារសំ និងកុមារដទៃទៀត បានសង្កេតមើលខ្យង និងលើកទឹកចិត្តឱ្យពួកគេនិយាយអំពីការសង្កេតរបស់ពួកគេហើយសួរសំណួរអំពីសត្វខ្យង
- លើកទឹកចិត្តឱ្យកុមារសំ និងកុមារដទៃកត់ត្រា ឬគូរ (បើអាចអំពីអ្វីដែលគាត់បានរកឃើញដើម្បីធ្វើឱ្យការសិក្សា និងការគិតរបស់ពួកគេ)
- ឱ្យកុមារបានពណ៌នាអំពីអ្វីដែលបានសង្កេតឃើញ
- សរសេរសំណួរដែលកុមារសំ និងកុមារទាំងអស់បានសួរអំពីខ្យង និងជួយកុមារ ដើម្បីរកចម្លើយដោយស្វែងរកព័ត៌មានពីសៀវភៅរឿង ទស្សនាវដ្តី ប្រភពព័ត៌មាន ឬតាមរយៈឱ្យកុមារសួរឪពុកម្តាយរបស់ពួកគេ និងអ្នកជំនាញដើម្បីធ្វើការពិសោធន៍ងាយៗ។

## ការចងក្រងស្នាដៃកុមារ

គ្រូអាចកត់ត្រាចំណុចសំខាន់ដែលជាពិសោធន៍របស់កុមារសំ ដែលបានរកឃើញចំណេះដឹងថ្មី និងការចាប់អារម្មណ៍ការរស់នៅរបស់សត្វខ្យងក្នុងបិស្ថានរបស់គេដោយរួមបញ្ចូលភស្តុតាងជាគំនូរដែលបង្ហាញពីការយល់ឃើញពីលក្ខណៈពិសេស ពណ៌សម្បក រូបរាង ទំហំ ផ្នែករាងកាយ ជាដើម។

ការចងក្រងការសន្ទនារបស់កុមារសំ ជាមួយមិត្តភក្តិរបស់គេនៅពេលសង្កេតខ្យង និងធ្វើការពិសោធន៍ងាយៗ គឺជាការតាមដាន នៃការអភិវឌ្ឍចំណេះដឹងរបស់សំ និងកុមារដទៃទៀត ក្នុងដំណើរទស្សនាសង្កេតសួនបន្លែលើដំណើរជីវិតសត្វខ្យង។

## សរុបសេចក្តី

ការសង្កេត និងតាមដានការរៀននិងការអភិវឌ្ឍរបស់កុមារ គឺជាផ្នែកសំខាន់មួយនៃដំណើររៀន និងបង្រៀន។ គ្រូគឺជាអ្នកលើកទឹកចិត្តកុមារឱ្យផ្តល់ព័ត៌មានអំពីអ្វីដែលបានរកឃើញថ្មី ដើម្បីសម្រេចបានគោលដៅនៃការរៀនសូត្ររបស់កុមារក្នុងបរិស្ថានរស់នៅប្រចាំថ្ងៃ។ លទ្ធផលទាំងអស់នេះ អាចសម្រេចបានតាមរយៈការសង្កេត ការកត់ត្រា នៃការផ្លាស់ប្តូរឥរិយាបថរបស់កុមារចំពោះសង្កេត ពិសោធន៍ នូវអ្វីដែលកើតមានឡើងនៅជុំវិញខ្លួនរបស់ពួកគេ ក៏ដូចជាការទទួលបានចំណេះដឹង និងជំនាញពីបទពិសោធន៍រៀនសូត្រ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ឧបសម្ព័ន្ធទី ១ ខ្លឹមសារនៃសកម្មភាពគោល

### ១. សន្ទនា ៖ មុន និងក្រោយញ៉ាំអាហារ

- ដើម្បីមានសុខភាពល្អ តើកូនត្រូវធ្វើដូចម្តេចខ្លះ?
  - ➢ មានអនាម័យចំណីអាហារ និងខ្លួនប្រាណ ហូបចំណីអាហារបីក្រុមមានជីវជាតិគ្រប់គ្រាន់ និងបរិស្ថានស្អាត
- មុនពេលញ៉ាំអាហារ តើកូនត្រូវធ្វើដូចម្តេចខ្លះ?
  - ➢ ត្រូវលាងសម្អាតដៃនឹងសាប៊ូ
- ក្រោយពេលញ៉ាំអាហាររួច តើកូនត្រូវធ្វើដូចម្តេចខ្លះ?
  - ➢ ត្រូវលាងសម្អាតដៃនឹងសាប៊ូ
- ឱ្យកុមារចាប់ដៃគូពីរៗនាក់ សន្ទនាគ្នាពីសកម្មភាពមុនពេលញ៉ាំអាហារ និងក្រោយពេលញ៉ាំអាហារ
- ទុកពេលឱ្យកុមារបាននិយាយរៀបរាប់ប្រាប់ដៃគូ
- ធ្វើការបូកសរុបលទ្ធផលពិភាក្សារបស់កុមារ និងខ្លឹមសារមេរៀន

*បញ្ជាក់ ៖ ការសន្ទនាអាចជាដៃគូរវាងគ្រូនិងកុមារម្នាក់ កុមារនិងកុមារ គ្រូនិងកុមារទាំងអស់។*

### ២. ល្បែង

#### ២.១. ទំនាក់ទំនងរវាងកាយទៅនឹងសម្ភារៈប្រើប្រាស់

❖ **របៀបលេង៖**

- បង្ហាញផ្ទាំងរូបភាពផ្នែកផ្សេងៗ នៃរាងកាយ និងសម្ភារៈប្រើប្រាស់
- ឱ្យកុមារប្រាប់ឈ្មោះរូបភាព និងណែនាំកុមារឱ្យគូសភ្ជាប់។

*បញ្ជាក់៖ ចំពោះសម្ភារៈគឺប្រើផ្ទាំងរូបភាពដែលម្ខាងជារូបផ្នែកផ្សេងៗនៃរាងកាយ និងម្ខាងទៀតជាសម្ភារៈប្រើប្រាស់ ដោយទុកចន្លោះកណ្តាលសម្រាប់ឱ្យកុមារគូសភ្ជាប់។*

#### ២.២. បាទ ចាស ឬទេ (ថ្នាំបណ្តាលឱ្យមានគ្រោះថ្នាក់)

❖ **របៀបលេង ៖**

- បំផុសសំណួរទៅកាន់កុមារទាក់ទងនឹងថ្នាំដែលបណ្តាលឱ្យមានគ្រោះថ្នាក់
- នៅពេលលេងគ្រូហៅឈ្មោះថ្នាំដែលបណ្តាលឱ្យមានគ្រោះថ្នាក់ កុមារត្រូវធ្វើសញ្ញា «បាទ ចាស» គឺក្តាប់ដៃដូចជាងក់ក្បាល តែបើមិនមែនជាថ្នាំគ្រោះថ្នាក់ទេកុមារត្រូវធ្វើសញ្ញា«ទេ» លាបាតដៃគ្រវី។ ឧទាហរណ៍៖ គ្រូហៅឈ្មោះ ថ្នាំអង់ទ្រីន ថ្នាំបាញ់ស្មៅ ថ្នាំបាញ់មូស ទឹកក្រូច ធូបមូស ថ្នាំពេទ្យ ទឹកដោះគោ... (គ្រូអាចជ្រើសរើសពាក្យផ្សេងៗ ទៀតបាន)
- កុមារធ្វើតាមសញ្ញា បាទ ចាស ឬទេ តាមឈ្មោះថ្នាំដែលគ្រូបានហៅ
- ប្រាប់ចម្លើយត្រឹមត្រូវ និងផ្តល់ការអប់រំកុមារឱ្យមានការប្រុងប្រយ័ត្ន។

*បញ្ជាក់៖ គ្រូអាចធ្វើសញ្ញាផ្សេងៗ ទៀតតំណាងឱ្យពាក្យ បាទ ចាស ឬទេ តាមខ្លឹមសារមេរៀន។*

### ២.៣. ប្រព័ន្ធគ្រួសារ វុក្ខជាតិ

- ❖ **របៀបលេង**
  - ➢ **រុក្ខជាតិរស់នៅក្នុងទឹក៖** កុមារទាំងអស់ឈរជារង្វង់រួចប្រាប់ឈ្មោះរុក្ខជាតិដែលរស់នៅក្នុងទឹកឱ្យបានម្នាក់មួយៗ ដោយមិនជាន់ឈ្មោះគ្នា។ ក្នុងករណីដែលកុមារឆ្លើយមិនត្រឹមត្រូវ ឬរកនឹកមិនឃើញ ត្រូវរំលងទៅកុមារបន្តទៀត។ លេងរបៀបនេះជាបន្តបន្ទាប់។
  - ➢ **រុក្ខជាតិរស់នៅលើគោក** (របៀបលេងដូចខាងលើ)
  - ➢ ពេលលេងចប់នាំកុមារច្រៀងរាំទាំងអស់គ្នា។

### ២.៤. ថង់ទិព្វ រាងកាយមនុស្ស

- ❖ **របៀបលេង**
  - បង្ហាញបណ្ណរូបភាពផ្នែកផ្សេងៗ នៃរាងកាយមនុស្ស (ក្បាល ភ្នែក ច្រមុះ ត្រចៀក មាត់ ដៃ ជើង...) ឱ្យកុមារសង្កេត និងប្រាប់ឈ្មោះបណ្ណរូបភាពទាំងនោះម្តងមួយៗ
  - ដាក់បណ្ណរូបភាពទាំងនេះក្នុងថង់ ដោយឱ្យកុមារអង្គុយ ឬឈរជារង្វង់ រួចឱ្យថង់ទៅកុមារហុចបន្តគ្នា និងច្រៀង
  - ឱ្យសញ្ញាបញ្ឈប់ ថង់នោះនៅដៃកុមារណា កុមារនោះត្រូវយកបណ្ណរូបភាព១ ក្នុងថង់មកមើល ហើយប្រាប់ឈ្មោះ និងមុខងារនៃរូបភាពនោះ
  - កុមារលេងរបៀបនេះបន្តទៀតរហូតដល់ម៉ោងគ្រូកំណត់។

### ២.៥. ផ្គុំរូបមនុស្ស

- ❖ **របៀបលេង**
  - បង្ហាញរូបមនុស្សដែលផ្គុំរួចជាគំរូ
  - បំផុសសំណួរលើផ្នែកផ្សេងៗ នៃរាងកាយមនុស្សឱ្យកុមារឆ្លើយ
  - ណែនាំកុមារឱ្យផ្គុំរូបភាពតាមរូបគំរូជាបុគ្គល ឬក្រុមតូច។

*បញ្ជាក់៖ បំណែកនៃរូបមនុស្សអាចផលិតចេញពីក្រដាស ឬបន្ទះឈើដែលមានបំណែកយ៉ាងតិច ៥បំណែក។*

### ២.៦. តាថា រាងកាយមនុស្ស

- ❖ **របៀបលេង**
  - បំផុសសំណួរទាក់ទងនឹងរាងកាយមនុស្សឱ្យកុមារប្រាប់ឈ្មោះ។ ឧទាហរណ៍៖ តើមាត់កូននៅឯណា? ចិញ្ចើម? ថ្ពាស?...
  - ប្រាប់កុមារថា៖ នៅពេលឮពាក្យថាតាថា ផ្នែកនៃរាងកាយណាមួយកូនត្រូវចង្អុលកន្លែងនោះ។ ឧទាហរណ៍៖ គ្រូនិយាយ«*តាថាមាត់*» កុមារចង្អុលមាត់ ...។ បើមិនឮពាក្យ «*តាថា*» កូនត្រូវនៅស្ងៀម។ ឧទាហរណ៍៖ គ្រូនិយាយ «*មាត់*» កុមារត្រូវនៅស្ងៀម...។
  - ការលេងល្បែងនេះ ដាជំបូងគ្រូថាពាក្យមួយៗ យឺតៗ លុះដល់ពេលកុមារលេងស្ទាត់ហើយ គ្រូចាប់ផ្តើមនិយាយកាន់តែលឿន។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ២.៧. ចំណាត់ថ្នាក់បន្លែ និងផ្លែឈើ

❖ **របៀបលេង**

- លើកបណ្ណកូនកាសរូបភាពសម្ភារៈបន្លែ និងផ្លែឈើ ម្តងមួយៗឱ្យកុមារប្រាប់ឈ្មោះ
- ណែនាំកុមារឱ្យរើសកូនកាសរូបភាពដាក់ទៅតាមប្រភេទបន្លែ និងផ្លែឈើ។

## ២.៨. ស្លសម្លកកូរ

❖ **របៀបលេង**

- បង្ហាញកូនកាសរូបភាព ឱ្យកុមារប្រាប់ឈ្មោះ (រូបផ្លែចេកខ្ចី ផ្លែល្ពៅ ផ្លែត្រប់វែង ផ្លែល្ហុងខ្ចី ផ្លែខ្នុរខ្ចី ស្លឹកម្រុំ ស្លឹកបាស ត្រីអណ្តែង ឬត្រីឆ្លាំង សាច់ជ្រូក ត្រីងៀត ទឹកខ្មេះ គ្រឿងផ្សំមានដូចជា អំបិល ទឹកត្រី ស្ករត្នោត គ្រឿងបុក និងទឹក រួចបិទលើក្តារខៀន
- ប្រាប់ពីបន្លែ ត្រីសាច់ និងគ្រឿងផ្សំសម្រាប់ស្លសម្លកកូរ
- ឱ្យកុមារជ្រើសរើសយកឈ្មោះរូបភាពដែលបិទលើក្តារខៀនម្នាក់មួយៗ
- ឱ្យកុមារប្រាប់ឈ្មោះខ្លួនតាមរូបភាពដែលបានជ្រើសរើសម្នាក់មួយៗ និងចងចាំឈ្មោះរបស់ខ្លួន និងមិត្តភក្តិ។ ឧទាហរណ៍៖ ខ្ញុំឈ្មោះផ្លែត្រប់វែង មិត្តភក្តិខ្ញុំឈ្មោះ ទឹកខ្មេះ
- គូររង្វង់លើកម្រាលឥដ្ឋ ឬផ្ទៃដី ធ្វើជាឆ្នាំងសម្លសមល្មម ដែលកុមាររត់ចូលអាចនៅសល់ចំនួន៤ ឬ ៥នាក់
- គ្រូស្រែកថា៖ «ស្លសម្លកកូរ» កុមារដែលមានឈ្មោះជាបន្លែ ត្រីសាច់ និងគ្រឿងផ្សំ ត្រូវរត់ចូលក្នុងឆ្នាំងសម្ល។ ឯអ្នកជាត្រីងៀត និងទឹកខ្មេះ មិនត្រូវរត់ចូលឆ្នាំងសម្លឡើយ គឺត្រូវរត់កាន់ដៃគ្នាជុំវិញឆ្នាំងសម្ល។ប្រសិនបើអ្នកជាបន្លែ ត្រីសាច់ និងគ្រឿងផ្សំណារត់ចូលក្នុងឆ្នាំងមិនទាន់ ត្រូវប៉ារកអ្នកចាញ់ ២នាក់ មកប្តូរឈ្មោះជាត្រីងៀត និងទឹកខ្មេះវិញ។ ប៉ុន្តែបើត្រីងៀត និងទឹកខ្មេះ រត់ចូលឆ្នាំងសម្លដែរ នោះនឹងត្រូវរក្សាឈ្មោះដដែល ហើយត្រូវឱ្យរាំច្រៀង ដូចអ្នកនៅក្រៅឆ្នាំងសម្លដែរ។

*បញ្ជាក់៖*

- *ឱ្យកុមារលេងរួមគ្នា១ថ្នាក់ ធ្វើឆ្នាំងសម្ល ១ ២ ឬ ៣ឆ្នាំង ទៅតាមចំនួនកុមារជាក់ស្តែង*
- *រង្វង់ឆ្នាំងសម្លត្រូវដាក់ចំនួនកុមារមិនគ្រប់ ដើម្បីឱ្យសល់កុមារនៅក្រៅឆ្នាំង៤ ឬ៥នាក់ ដើម្បីងាយស្រួលដល់គ្រូចំណាំ*
- *អាចចែកបណ្ណរូបភាពឱ្យកុមារពាក់នៅនឹង«ក»កុមារម្នាក់១ ទៅតាមលទ្ធភាពរបស់គ្រូ។*

## ២.៩. អ្វីៗ ដែលមានជីវិត និងគ្មានជីវិត

❖ **របៀបលេង**

- ឱ្យកុមារតាមក្រុម ពិភាក្សារកឈ្មោះអ្វីៗ ដែលមានជីវិត និងគ្មានជីវិត ដោយកំណត់ពេលវេលាជាក់លាក់ ឧទាហរណ៍៖ ឱ្យកុមាររកអ្វីៗដែលមានជីវិតចំនួន ៥ និងគ្មានជីវិតចំនួន ៥
- កុមារផ្តល់អំណោះអំណាងដល់ក្រុមធំ។

## ២.១០. ភ្លៀងធ្លាក់

❖ **របៀបលេង**

– ឱ្យកុមារទាំងអស់ឈរជារង្វង់ ហើយដកកុមារម្នាក់មកឈរនៅកណ្ដាលរង្វង់ធ្វើជាអ្នកដឹកនាំ
– នៅពេលឮអ្នកដឹកនាំបញ្ជាថា៖
  ➢ ផ្គរ ៖ កុមារទាំងអស់ត្រូវយកដៃខ្ទប់ត្រចៀកទាំងសងខាង
  ➢ ខ្យល់ ៖ កុមារទាំងអស់ត្រូវយោកដៃ យោកខ្លួន ទៅឆ្វេងទៅស្ដាំ
  ➢ ភ្លៀង ៖ កុមារទាំងអស់ត្រូវយកដៃទទូលក្បាល
  ➢ ផ្លេកបន្ទោរ ៖ កុមារទាំងអស់ត្រូវខ្ទប់ត្រចៀក និងឱនក្បាលអង្គុយចុះ
  ➢ ផ្គរ ខ្យល់ ភ្លៀង ផ្លេកបន្ទោរ ៖ កុមារទាំងអស់ត្រូវធ្វើកាយវិការទាំង៤ខាងលើ បន្តបន្ទាប់ ឡើងវិញ
– ប្រសិនបើកុមារណាធ្វើមិនទាន់ត្រឹមត្រូវ ត្រូវឱ្យរាំច្រៀង
– នាំកុមារលេងរបៀបនេះដោយលើកដំបូងគ្រូហៅយឺតៗ ជាបន្តបន្ទាប់កាន់តែញាប់។

## ២.១១. ការពារខ្លួនពីបាតុភូតធម្មជាតិ

❖ **របៀបលេង**

– បំផុសសំណួរឱ្យកុមាររៀបរាប់អំពីវិធីការពារខ្លួនពីបាតុភូតធម្មជាតិ
– ចែកកុមារជា ៤ក្រុម ស្មើគ្នា គឺក្រុមខ្យល់ព្យុះ ក្រុមទឹកជំនន់ ក្រុមផ្គររន្ទះ និងក្រុមភ្លៀង
– ណែនាំពីរបៀបលេងដល់កុមារទាំងអស់៖
  ➢ នៅពេលគ្រូស្រែកថា«*ខ្យល់ព្យុះ*»។ ក្រុមខ្យល់ព្យុះ ត្រូវរត់ដេញចាប់កុមារទាំងបីក្រុមផ្សេងទៀត យកមកធ្វើជាសមាជិករបស់ខ្លួន។ ក្នុងករណីក្រុមខ្យល់ព្យុះហៀបនឹងចាប់បាន កុមារដែលត្រូវគេដេញចាប់ត្រូវស្រែកថា«*ផ្ទះថ្ម*» ដើម្បីរួចខ្លួន។
  ➢ នៅពេលគ្រូស្រែកថា«*ទឹកជំនន់*»។ ក្រុមទឹកជំនន់ ត្រូវរត់ដេញចាប់កុមារទាំងបីក្រុមផ្សេងទៀត យកមកធ្វើជាសមាជិករបស់ខ្លួន។ ក្នុងករណីក្រុមទឹកជំនន់ហៀបនឹងចាប់បាន កុមារដែលត្រូវគេដេញចាប់ត្រូវស្រែកថា«*ឱបវត្ថុអណ្ដែត*» ដើម្បីរួចខ្លួន។
  ➢ នៅពេលគ្រូស្រែកថា«*ផ្គររន្ទះ*»។ ក្រុមផ្គររន្ទះ ត្រូវរត់ដេញចាប់កុមារទាំងបីក្រុមផ្សេងទៀត យកមកធ្វើជាសមាជិករបស់ខ្លួន។ ក្នុងករណីក្រុមផ្គររន្ទះហៀបនឹងចាប់បាន កុមារដែលត្រូវគេដេញចាប់ត្រូវ*អង្គុយចោងហោងយកដៃខ្ទប់ត្រចៀកទាំងសងខាង* ដើម្បីរួចខ្លួន។
  ➢ នៅពេលគ្រូស្រែកថា«*ភ្លៀង*»។ ក្រុមភ្លៀង ត្រូវរត់ដេញចាប់កុមារទាំងបីក្រុមផ្សេងទៀត យកមកធ្វើជាសមាជិករបស់ខ្លួន។ ក្នុងករណីក្រុមភ្លៀងហៀបនឹងចាប់បាន កុមារដែលត្រូវគេដេញចាប់ត្រូវស្រែកថា«*ពាក់អាវភ្លៀង*» ដើម្បីរួចខ្លួន។
– នាំកុមារលេង និងរាប់ចំនួន ដើម្បីដឹងថាក្រុមណាចាប់បានកុមារច្រើនជាងគេក្រោយពីលេងចប់។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

*បញ្ជាក់ ៖*

- *ដើម្បីងាយស្រួលចំណាំ គ្រូអាចដាក់សញ្ញាសម្គាល់ក្រុមដូចជា កាត់ក្រដាសពណ៌ទំហំ ២ស.ម ព័ទ្ធជុំវិញក្បាលកុមារដោយកៀបឃ្នាប*
- *នៅពេលកុមារលេងសប្បាយភ្លេចខ្លួន គ្រូត្រូវប្រកាសប្តូរក្រុមឱ្យរត់ដេញចាប់គេវិញម្តង ដើម្បីបង្កើនបម្រុងប្រយ័ត្ន។*

## ២.១២. រៀបចំបរិស្ថានសាលារៀន

❖ **របៀបលេង**

- បង្ហាញ និងចែកសម្ភារៈឱ្យកុមារប្រាប់ឈ្មោះ (សម្បកកេស ខ្សាច់ ដុំឈើសំណង់ ឬដុំក្រួសតូចៗដែលអាចត្រួតគងលើគ្នាបាន មែកឈើតូចៗ ដើមស្មៅ ផ្កាស្មៅ...)ឬនាំកុមារទៅរកនៅខាងក្រៅ
- ឱ្យកុមារតាមក្រុមរៀបចំបរិស្ថានសាលារៀន ដែលមានរបង ទីធ្លា សួនច្បារតូចៗ និងថ្នាក់រៀន
- ក្រុមណាដែលរៀបហើយបានមុនគេ ត្រូវទះដៃប្រាប់ជាសញ្ញា
- ឱ្យក្រុមនីមួយៗ រៀបរាប់អំពីការរៀបចំបរិស្ថានសាលារៀនរបស់ខ្លួន និងផ្តល់យោបល់ឱ្យគ្នាទៅវិញទៅមក ដើម្បីកែលម្អសាលារៀនឱ្យកាន់តែស្រស់ស្អាត។

*បញ្ជាក់៖ បើឱ្យកុមារលេងនៅខាងក្រៅថ្នាក់ គ្រូអាចឱ្យកុមារលេងក្នុងអាងខ្សាច់ ឬដីផុសស្អាត ធានាបាននូវអនាម័យ និងសុវត្ថិភាព។*

## ២.១៣. គូសភ្ជាប់វត្ថុទៅនឹងរាងកាយមនុស្ស

❖ **របៀបលេង**

- បង្ហាញផ្ទាំងរូបភាពឱ្យកុមារប្រាប់ឈ្មោះ(កុមារី ក្រាសសិតសក់ ទូរស័ព្ទ ស្រោមជើង នាឡិកា...)
- ណែនាំ និងចែករូបភាពឱ្យកុមារគូសភ្ជាប់។

## ២.១៤. ទឹក គោក អាកាស

❖ **របៀបលេង**

- ឱ្យកុមារឈរជារង្វង់ រួចគ្រូណែនាំពីរបៀបលេង ដោយនិយាយថា ៖
  - ➢ ទឹក គឺកុមារត្រូវរកប្រភេទសត្វដែលរស់នៅក្នុងទឹក ដូចជា ត្រី កូនក្អាត់ ក្តាម ខ្យងកង្កែប...
  - ➢ គោក គឺកុមារត្រូវរកប្រភេទសត្វដែលរស់នៅលើដី ដូចជា គោ ក្របី ឆ្មា ទន្សាយ...
  - ➢ អាកាស គឺកុមារត្រូវរកប្រភេទសត្វហើរ ដូចជា ព្រាប លលក ប្រជៀវ ប្រវឹក...
- នៅពេលដែលគ្រូចង្អុលទៅលើកុមារណាម្នាក់ ហើយគាត់និយាយថាគោក ឬទឹក ឬអាកាស កុមារនោះត្រូវប្រាប់ឈ្មោះសត្វដែលរស់នៅលើគោក ឬក្នុងទឹក ឬសត្វហើរ ឱ្យបានមួយ
- ចង្អុលទៅកាន់កុមារម្នាក់ម្តងៗ ឆ្លាស់គ្នាជាច្រើនលើកច្រើនសាឱ្យបានគ្រប់គ្នា។

## ៣. រឿងនិទាន

### ៣.១. ធុងសំរាម

វេលាម៉ោងប្រាំមួយល្ងាច នាថ្ងៃអាទិត្យនេះ នាងធីម និងមិត្តភក្តិ បាននាំគ្នារត់លេងនៅតាមខឿនជុំវិញសួនច្បារសាធារណៈដែលស្ថិតនៅខាងមុខផ្ទះ។ ស្រាប់តែឮសំឡេងយំខ្លាំងៗ នាងធីមខំដើររកសំឡេងទើបដឹងថា ធុងសំរាមយំ នាងក៏សួរថា៖ ហេតុអ្វីបានជាបងធុងសំរាមយំ?

- **ធុងសំរាម៖** ខ្ញុំយំព្រោះប្អូនៗ ពុំមានចិត្តរើសសំរាមមកដាក់ក្នុងធុងខ្ញុំសោះ។
- **នាងធីម៖** សំរាមទាំងនោះកង្វក់ណាស់ពុំមែនពួកខ្ញុំចោលទេ។ ខ្ញុំប្រញាប់រត់លេងបន្តទៀតសិន។
- **ធុងសំរាម៖** ឈប់សិនៗ ខ្ញុំសូមអង្វរ ! សូមរើសថង់ដែលស្អាតម្នាក់មួយស៊កដៃចូល ហើយដើររើសសំរាមដាក់ក្នុងធុងឱ្យខ្ញុំផងណា។ នាងធីម និងមិត្តភក្តិនាំគ្នាដើររើសសំរាម។
- **ធុងសំរាម៖** ឈប់សិនៗ កុំអាលដាក់ឱ្យខ្ញុំ សូមដាក់សម្បកដបនេះ ទៅក្នុងធុងសំរាមពណ៌លឿងដែលនៅត្រង់នោះ។
- **នាងធីម និងមិត្តភក្តិ៖** ហេតុអ្វីទៅបងធុងសំរាម?
- **ធុងសំរាម៖** ប្អូនៗ ចាំស្តាប់ណា! ធុងសំរាមក្រហម គឺជារូបខ្ញុំដាក់តែសំរាមងាយរលួយ។ ធុងសំរាមលឿងដែលកំពុងញញឹមចូលចិត្តតែសំរាមប្រភេទដប ឯធុងសំរាមខៀវវិញចូលចិត្តតែប្រភេទសំរាមក្រដាស។

នាងធីម និងមិត្តភក្តិ ស្តាប់យល់ហើយក៏នាំគ្នាដើររើសសំរាមដាក់តាមប្រភេទ។

- **ធុងសំរាមក្រហម លឿង ខៀវ និយាយព្រមគ្នាថា ៖** អរគុណណាស់កុមារៗ ប្រញាប់ទៅលាងដៃសិនសឹមនាំគ្នារត់លេងបន្តទៀត ឮទេ !
- **កុមារៗ ឆ្លើយព្រមគ្នា ៖** បាទ! ចាស! រួចក៏នាំគ្នារត់ទៅលាងដៃដោយសប្បាយចិត្ត ពីព្រោះពួកគេបានធ្វើអំពើល្អរួមគ្នាសម្អាតទីសួនច្បារសាធារណៈ ធ្វើឱ្យមនុស្សចាស់ដែលអង្គុយលេងនៅក្បែរទីនោះកោតសរសើរគ្រប់ៗគ្នា។

### ៣.២. បាយ

ថ្ងៃមួយ នៅពេលដែលខ្ញុំកំពុងហូបបាយតែម្នាក់ឯង ខ្ញុំស្រមៃឃើញគ្រាប់បាយចេះនិយាយរឿងប្រាប់ខ្ញុំ។ «ពីមុនខ្ញុំជាគ្រាប់ស្រូវដែលគេដាក់ក្នុងជង្រុក។ ដល់រដូវធ្វើស្រែគេយកខ្ញុំទៅសាបព្រួស ដក ស្ទូង។ លុះខ្ញុំទុំ គេច្រូតកាត់ខ្ញុំរួចបោកបែន ហើយកិន បុក ឱ្យទៅជាអង្ករ។ ទីបំផុតគេយកខ្ញុំទៅដាំចម្អិនជាបាយ ដូចអ្នកឃើញខ្ញុំនៅទីនេះ»។

កសិករ កម្មករ ព្រមទាំងគ្រួសារអ្នកនឿយហត់ណាស់ ក្នុងការធ្វើឱ្យរូបខ្ញុំក្លាយជាអាហារសម្រាប់អ្នក។ ដូចនេះ កុំខ្ជះខ្ជាយខ្ញុំ ព្រោះខ្ញុំជាវត្ថុចាំបាច់សម្រាប់ជីវិតអ្នក និងមនុស្សទូទៅ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៣.៣. ជីវភាពភូមិខ្ញុំ

ថ្ងៃនេះ មានអាកាសធាតុល្អ ខ្យល់ជំនោរបក់មករំភើយៗ មកពីទិសខាងកើត។ នៅចំកណ្ដាលភូមិ ក្រោមម្លប់ដើមឈើដ៏ធំត្រឈឹងត្រឈៃ មានកុមារពីរនាក់អង្គុយលើគ្រែដដែកគ្នា។

- **សុភា៖** សួស្ដីលីដា! ទៅណាមកណា? សុខសប្បាយជាទេ?
- **លីដា៖** ចាស សុខសប្បាយទេ។ សុភាគ្នាមកនេះគឺមកលេងនឹងសម្លាញ់ឯងណាសុភា។
- **សុភា៖** អូ! រីករាយណាស់ដែលសម្លាញ់មកដល់ទីនេះ!
- **លីដា៖** សុភា! គ្នាមើលទៅក្នុងភូមិឯងហាក់ដូចជាសប្បាយហើយមានសម្រស់ពណ៌បៃតងល្អណាស់ តើគេប្រកបមុខរបរអ្វីដែរ?
- **សុភា៖** លីដា! អ្នកភូមិរបស់ខ្ញុំភាគច្រើន គឺប្រកបមុខរបរចម្រុះដូចជា ដាំបន្លែ ធ្វើស្រែចម្ការ នេសាទត្រី ចិញ្ចឹមសត្វជ្រូក គោ មាន់ ទា ខ្លះត្បាញរវៃ កាត់ដេរសម្លៀកបំពាក់ លក់ដូរបន្តិចបន្តួចនៅផ្ទះ ធ្វើជាងឈើ កាត់សក់ ដំដែក ធ្វើកាំបិត ពូថៅ និងចប ពិសេសទៅទៀតធ្វើជាគ្រូបង្រៀន គ្រូពេទ្យទាហាន ប៉ូលីស ជាដើម។
- **លីដា៖** ល្អណាស់ៗ! សម្លាញ់ភូមិឯងពិតជាមានការរីកចម្រើនល្អមែន គ្នាចង់ដឹងថាចុះគ្រួសារឯងវិញ រាល់ថ្ងៃប្រកបមុខរបរអ្វីដែរ បានជាមានជីវភាពធូរធារម្ល៉េះ?
- **សុភា៖** ម្ដាយឪពុករបស់ខ្ញុំធ្វើស្រែចម្ការ ហើយគាត់បានមានប្រសាសន៍ថា យើងទាំងអស់គ្នាចង់បាន ញុំាឆ្ងាញ់ ស្លៀកពាក់ល្អ រស់នៅប្រកបដោយសុភមង្គលនោះ ត្រូវតែខំជ្រើសរើសមុខរបរណាស្របតាមច្បាប់ ពិសេសយើងត្រូវតែខំរៀនទើបប្រកបមុខរបរអ្វីៗ បានជោគជ័យ។
- **លីដា៖** សម្លាញ់! ភ្លៀងរលឹមតក់ៗស្រក់លើខ្ញុំហើយ ខ្ញុំសូមលាសម្លាញ់ហើយណា!
- **សុភា៖** ចាស! ទៅចុះសូមឱ្យលីដាបានសុខសប្បាយ។

## ៣.៤. មេអំបៅមួយគូ

ក្នុងសួនមួយមានមេអំបៅមួយគូ មួយមានពណ៌ក្រហម មួយទៀតពណ៌លឿង។ មេអំបៅទាំងពីរជាមិត្តភក្តិជិតស្និទ្ធស្រឡាញ់គ្នាដូចបងប្អូនបង្កើត។ ថ្ងៃណាក៏ដូចថ្ងៃណា មេអំបៅមួយគូនេះតែងតែបបួលគ្នាហើរ ផ្លេលផ្លាត់លេងយ៉ាងសប្បាយរីករាយនៅក្នុងសួនច្បារដែលមានផ្កាកូឡាបក្រហម និងផ្កាស្ពៃរឿង។

ថ្ងៃមួយមេអំបៅទាំងគូកំពុងតែហិចហើរចុះឡើង សើចលេងសប្បាយក្អាកក្អាយក្នុងសួនច្បារ ស្រាប់តែផ្ទៃមេឃប្រែជាងងឹត ភ្លៀងធ្លាក់មកយ៉ាងខ្លាំង ដំណក់ទឹកធំៗ ធ្លាក់មកប៉ះលើស្លឹកឈើលាន់ឮប្រាវៗ ធ្វើឱ្យមេអំបៅទាំងពីរភ័យរន្ធត់។ វាហើរតម្រង់ទៅដើមផ្កាកូឡាបដែលនៅជិតនោះ រួចនិយាយថា៖ បងកូឡាបអើយ! ស្លាបខ្ញុំទទឹកជោកអស់ហើយ យើងខ្ញុំរងាណាស់! យើងខ្ញុំសុំចូលជ្រកក្រោមមែកផ្ការបស់បងផងណា។

- **កូឡាបឆ្លើយ៖** មេអំបៅមានពណ៌ក្រហមដូចផ្កាកូឡាបខ្ញុំទើបអាចជ្រកបាន រីឯមេអំបៅពណ៌លឿងហើរទៅវិញទៅខ្ញុំមិនឱ្យជ្រកទេ។
- **មេអំបៅទាំងគូសម្លឹងមើលមុខគ្នា ហើយមេអំបៅពណ៌ក្រហមនិយាយអង្វរថា៖** បងកូឡាបអើយ! យើងទាំងពីរជាមិត្តនឹងគ្នា សូមបងមេត្តាឱ្យយើងទាំងពីរនាក់ជ្រកផង។ ផ្កាកូឡាបឆ្លើយដាច់ខាតមិនព្រមឱ្យ

មេអំបៅពណ៌លឿងចូលជ្រកឡើយ។ មេអំបៅទាំងគូអស់សង្ឃឹមក៏នាំគ្នាហើរទៅសុំផ្កាស្បៃរឿងជ្រកម្ដង។

- **មេអំបៅទាំងគូនិយាយព្រមៗគ្នាថា៖** បងផ្កាស្បៃរឿងអើយ! ស្លាបខ្ញុំទទឹកជោកអស់ហើយ យើងខ្ញុំរងាណាស់យើងខ្ញុំសុំចូលជ្រកក្រោមមែកផ្ការបស់បងផងណា។
- **ផ្កាស្បៃរឿងនិយាយថា ៖** មេអំបៅពណ៌លឿងដូចផ្កាស្បៃរឿងខ្ញុំ ទើបអាចជ្រកបាន រីឯមេអំបៅពណ៌ក្រហមហើរទៅវិញទៅ។ ខ្ញុំមិនឱ្យជ្រកទេ។

ទោះបីមេអំបៅទាំងពីរខិតខំអង្វរយ៉ាងណា ក៏ផ្កាស្បៃរឿងអនុញ្ញាតឱ្យតែមេអំបៅពណ៌លឿងជ្រកប៉ុណ្ណោះ។ ភ្លៀងធ្លាក់កាន់តែខ្លាំងធ្វើឱ្យស្លាបមេអំបៅកាន់តែទទឹកជោកជាំហើរលែងរួច ធ្លាក់មកលើដី រងាញ័រខ្លួនចំប្រប់ ពុំព្រមបែកគ្នាឡើយ។ មួយសន្ទុះក្រោយមកភ្លៀងក៏រាំង ព្រះអាទិត្យដែលនៅខ្ពស់លើពួដ៏អាកាសក៏បានសម្លឹងមើលចុះក្រោម លោកញញឹមហើយសរសើរមេអំបៅទាំងគូដែលចេះស្រឡាញ់គ្នា។ ដើម្បីស្រោចស្រង់អាយុជីវិតមេអំបៅ លោកបានបញ្ចេញពន្លឺ ផ្ទៃមេឃស្រឡះថៃងថាំង ធ្វើឱ្យស្លាបរបស់មេអំបៅទាំងពីរធាប់ស្ងួត ហើយទទះស្លាប ហោះហើរឆាបលេងប្រឡែងពេញក្នុងសួនច្បារ។

- **មេអំបៅទាំងគូនិយាយព្រមៗគ្នាថា ៖** សូមអគុណបងព្រះអាទិត្យខ្លាំងណាស់ យើងខ្ញុំមិនចងកំហឹងនឹងផ្កាកូឡាប និងផ្កាស្បៃរឿងឡើយ។ ពីព្រោះផ្កាកូឡាប និងផ្កាស្បៃរឿង បានធ្វើឱ្យអារម្មណ៍យើងខ្ញុំស្រស់ថ្លាជានិច្ច។ ឯផ្កាកូឡាប និងផ្កាស្បៃរឿងក៏បានសារភាពកំហុសរបស់ខ្លួន ហើយសន្យាថាអំណេះតទៅនឹងខិតខំកែខ្លួនឱ្យល្អប្រសើរ។

## ៣.៥. ពពក និងផ្កា

នៅមុខផ្ទះមួយមានដើមផ្កាក្លាំងងារមួយដើមធំកំពុងបញ្ចេញផ្កាយ៉ាងច្រើនក្រអូបឈ្ងុយឈ្ងប់។ លោកតាម្ចាស់ផ្ទះបានកាត់មែកផ្កាក្លាំងងារបំបែកផ្សាំដាក់ក្នុងកូនជាលជាច្រើន ដើម្បីទុកចែកចាយញាតិមិត្ត។ លោកតាថែដាក់ដី និងស្រោចទឹកជារៀងរាល់ថ្ងៃ។

ថ្ងៃមួយលោកតាបានដួលជំពប់ជើងនឹងដុំថ្ម។ អ្នកជិតខាងក៏ស្ទុះមកគ្រាហ៍លោកតាយកទៅព្យាបាលនៅឯមន្ទីរពេទ្យ។ កូនផ្កាក្នុងជាលគ្មានអ្នកស្រោចទឹក ស្រពោនបន្តបន្ទាប់គួរឱ្យអាណិត ព្រោះមិនអាចទប់ទល់នឹងភាពខ្សោះទឹកបាន។ ដើមផ្កាក្លាំងងារធំបានស្រែកហៅពពកឱ្យបង្អុរភ្លៀងស្រោចស្រង់កូនផ្កា ដោយនិយាយថា៖ រុក្ខជាតិធំៗ ដូចពូកខ្ញុំមានឫសជ្រៅអាចទ្រាំបានយូរថ្ងៃ។ សូមពពកជួយកូនផ្កាតូចៗ នេះសិនទៅ។ ពពកឆ្លើយថា៖ មិនបានទេខ្ញុំបានសន្យាទៅផ្ដល់ទឹកភ្លៀងជូនលោកម្ចាស់នៅភូមិឯឆ្ងាយនោះ ហើយចាំថ្ងៃខានស្អែក ខ្ញុំនឹងត្រឡប់មកបង្អុរភ្លៀងស្រោចឱ្យពួក អ្នក។ ក្រោយមកពពកបានត្រឡប់មកតាមពាក្យសន្យាមែន តែអ្វីៗបានហួសអស់ទៅហើយ។ កូនផ្កាដែលត្រូវសង្គ្រោះ ជាច្រើននោះបានស្វិតអស់រលីង។ ពពកយំអាណិតស្រណោះកូនផ្កានឹកស្ដាយក្រោយព្រោះតែចង់ផ្គាប់ផ្គុនលោកម្ចាស់ពេក មិនបានគិតឱ្យបានច្បាស់លាស់ពីជីវិតរបស់កូនផ្កាតូចៗ។ ឃើញដូច្នេះ ដើមផ្កាក្លាំងងារធំនោះ មិននិយាយវែងឆ្ងាយទេ គ្រាន់តែពោលយ៉ាងខ្លីថា៖ ហ៊ឺ! ពពកអើយប្រសិនបើអ្នកគិតឱ្យបានច្បាស់លាស់ម្ល៉េះសមកូនផ្កាមិនស្លាប់ទេ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### ៣.៦. ទូកខ្ញុំនៅឯណា?

ទីណូ និងទីទី មានទូកមួយយ៉ាងល្អ។ ថ្ងៃនេះ គេទាំងពីរនាក់កំពុងអុំទូកលេងនៅក្នុងស្ទឹងមួយយ៉ាងធំ ស្រាប់តែពេលនោះមានកូនដំរីសមួយកាន់សន្ទូចស្រែកថា៖ បងទីណូ! បងទីទី! ឱ្យខ្ញុំជិះទូកជាមួយបងផង បានឬទេ? ទេ! យើងកំពុងជិះទូកយ៉ាងសប្បាយ យើងមិនឱ្យអូនដំរីជិះទេ។

ពេលដូច្នេះហើយ អ្នកទាំងពីរនាក់អុំទូកទៅបាត់រហូតដល់ពេលព្រលប់ទើបមកដល់ច្រាំងវិញ។

- **ទីទី និយាយទៅកាន់ទីណូថា ៖** ទីណូឯងចងទូកទៅ!
- **ទីណូ៖** ទេ! ខ្ញុំហត់ណាស់ ទីទីឯងចងវិញទៅ!
- **ទីទី៖** ចំណែកខ្ញុំក៏ហត់ដែរ។ អ្នកទាំងពីរប្រចាំគ្នាហើយក៏រត់ឡើងច្រាំងសំដៅទៅផ្ទះយ៉ាងលឿន។ លុះព្រឹកឡើងទីទី និងទីណូ ក៏ត្រឡប់មកមាត់ស្ទឹងស្រាប់តែ។
- **ទីទី៖** យី! ទូកយើងទៅណាហើយ?
- **ទីណូបន្ទោស៖** នោះ!មកពីទីទីឯងខ្ជិលមិនព្រមចងទូក។
- **ទីទី៖** ទីណូឯងក៏ខ្ជិលដូចខ្ញុំដែរ។

វំពេចនោះ **កូនដំរីក៏មកដល់៖** មិនអីទេបងទាំងពីរចាំខ្ញុំជួយរកណា៎!

- **ទីទី៖** តើត្រូវធ្វើដូចម្ដេចទើបយើងរកឃើញ?
- **កូនដំរី៖** ខ្ញុំនឹកឃើញហើយ!

ថាតែប៉ុណ្ណោះកូនដំរីក៏ស្ទុះរឹងសំដៅទៅចម្ការចេក។ មួយសន្ទុះក្រោយមកកូនដំរីសលីចេកបីដើមដែលដោតភ្ជាប់គ្នាជាក្បូនមួយ។

- **ទីណូ៖** អូនដំរីសពូកែមែន! ប៉ុណ្ណេះយើងអាចរកទូកឃើញហើយ។ យើងទាំងពីរនាក់បងប្អូនសូមអរគុណអូនដំរីសយ៉ាងច្រើន។ ទីទី ទីណូ កូនដំរី ក៏នាំគ្នាជិះក្បូនយ៉ាងរីករាយទៅរកទូកបានដូចបំណង។

## ៤. ចម្រៀង

### ៤.១. ត្រូវសំអាតខ្លួនប្រាណ (លំនាំបទយីកេ)

| | |
|---|---|
| កូនប្រុសកូនស្រីថៃខ្លួនប្រាណ | រក្សាឱ្យបានអើយកុំទុកយូរ |
| យើងត្រូវជុះលាងអើយនឹងសាប៊ូ | កុំឱ្យក្លិនជូរស្អាតជានិច្ច។ |

### ៤.២. ឱ! ផ្ទៃស្រុកខ្មែរ

| | | |
|---|---|---|
| ឱ! ផ្ទៃស្រុកខ្មែរៗ | យប់ខែភ្លឺថ្លា | អ្នកស្រុកធ្វើការ |
| លោកអើយអ្នកអើយ | អ្នកស្រុកធ្វើការ | អឺអឹងអើយធ្វើការគ្រប់ដៃ។ |
| មានជាងឈូសឈើៗ | រៀបធ្វើផ្ទះថ្មី | រីពួកស្រីៗ |
| លោកអើយអ្នកអើយ | រីពួកស្រីៗ | អឺអឹងអើយស្រិតស្វែអង្ករ។ |
| មានជាងចម្លាក់ៗ | មានអ្នកកូរស្ករ | កញ្ញារូបល្អ |
| លោកអើយអ្នកអើយ | កញ្ញារូបល្អ | អឺអឹងអើយអង្គុយត្បាញហូល។ |

ឧបសម្ព័ន្ធទី ២

# គរុកោសល្យរៀន និងបង្រៀន
# ដើម្បីឆ្លើយតបសមភាពយេនឌ័រ រវាងកុមារី និងកុមារ
# នៅមត្តេយ្យសិក្សា



## សម្រាប់ជំនួយដល់គ្រូមត្តេយ្យសិក្សាដឹកនាំ
## សកម្មភាពរៀន និងបង្រៀន

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ១. សេចក្តីផ្តើម

សមភាពយេនឌ័រ មិនមែនគ្រាន់តែជាមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែវាគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការកសាង រក្សាសន្តិភាព ភាពរុងរឿង និងស្ថិរភាពក្នុងសង្គមលើពិភពលោកផងដែរ។ ការផ្តល់ឱ្យស្ត្រី និងកុមារីនូវភាពស្មើគ្នាក្នុងការទទួលបាននូវការអប់រំ ការថែទាំសុខភាព ការងារដ៏ត្រឹមត្រូវ និងការត្រៀមជាស្រេចក្នុងការចូលរួមក្នុងដំណើរការសម្រេចចិត្តផ្សេងៗ ក្នុងសង្គមមួយដែលមានសមភាព និងស្ថិរភាព។

## ២. ស្ថានភាពទូទៅ

ផ្អែកលើស្ថានភាពជាក់ស្តែងក្នុងសង្គមកម្ពុជា ជារឿយៗ ឪពុកម្តាយ និងអ្នកថែកុមារមិនបានដឹងថាពួកគាត់បានបន្តបង្ហាញនូវផ្នត់គំនិតលម្អៀង ជំនឿអំពីតួនាទីខុសគ្នារវាងបុរស និងស្ត្រីនោះទេ។ កុមារីមួយចំនួនត្រូវបានទទួលការថែទាំ និងចិញ្ចឹមបីបាច់ខុសគ្នាពីកុមារា។ ជាទូទៅកុមារីត្រូវបានរៀបចំឱ្យស្លៀកពាក់ទៅតាមពណ៌ ដូចជា ពណ៌ផ្កាឈូក ពណ៌ក្រហម ពណ៌ស្វាយ ជាដើម ហើយប្រដាប់លេងទៀតសោត គឺកូនក្រមុំ តុក្កតា និងប្រដាប់ប្រដាផ្ទះបាយ គឺសម្រាប់កុមារីលេង រីឯបាល់ និងកូនឡាន សម្រាប់កុមារាលេង។ កូនស្រីត្រូវបានបង្រៀនឱ្យស្តាប់បង្គាប់ និងសុភាពរាបសា រីឯកុមារាត្រូវបានបង្រៀនឱ្យក្លាហាន និងរឹងមាំ។ ជួនកាលកុមារីត្រូវបានការពារហ្មត់ចត់ជាងកុមារា។ ទន្ទឹមនឹងនេះកុមារាត្រូវបានបង្រៀនមិនឱ្យយំព្រោះជាសញ្ញាបង្ហាញថាទន់ខ្សោយ។

នៅតាមសាលារៀន យើងសង្កេតឃើញថា ការរៀបចំសកម្មភាពរៀន និងបង្រៀននៅកម្រិតមត្តេយ្យសិក្សាមួយចំនួន មិនទាន់ទទួលបាននូវបរិយាកាសរៀនសូត្រដែលមានលក្ខណៈសមភាពយេនឌ័រ រវាងកុមារី និងកុមារានៅឡើយទេ។ កត្តាទាំងអស់នោះ គឺដោយសារតែចំណេះដឹង និងការអនុវត្តរបស់គ្រូផ្អែកលើផ្នត់គំនិតអវិជ្ជមានដែលបន្សល់ទុកតាំងពីដើមមក និងផ្អែកទៅលើកម្រិតចំណេះដឹងរបស់គ្រូ ជាពិសេសគ្រូមត្តេយ្យសិក្សាដែលមានការបណ្តុះបណ្តាលមិនទាន់គ្រប់គ្រាន់នៅឡើយ។ បញ្ហាដែលបានបន្សល់ទុកទាំងនោះមានដូចជា កុមារីធាប់ភ័យខ្លាចនៅពេលកុមារាស្រែកសម្លុត មិនសូវមានទំនុកចិត្តក្នុងការដឹកនាំក្រុម មិនហ៊ានហក់លោតខ្លាំងដូចកុមារា (ឡើងទីខ្ពស់ ឬលេងបាល់ទាត់...) មិនហ៊ានជ្រើសរើសពណ៌ដែលខ្លួនចូលចិត្ត ត្រូវបានមនុស្សចាស់បង្អាក់មិនឱ្យហក់លោតច្រើនពេកទេ ព្រោះខ្លួនជាកូនស្រី មិនសូវក្លាហានក្នុងការនិយាយខ្លាចខុស ហើយត្រូវបានគ្រូឱ្យធ្វើតែការងារណាដែលកុមារីធ្លាប់ធ្វើទៅតាមទម្លាប់ពីដើមមក ដូចជាការរៀបចំថ្នាក់ ជូត ឬទុកដាក់សម្ភារៈ(មិនប្រើកុមារា)។ល។ ចំណែកកុមារាមួយចំនួនក៏នៅមិនទាន់មានសមភាពដែរ ដូចជា កុមារាមានសកម្មភាពពើស និងចូលចិត្តស្រែកសម្លុតដាក់កុមារី និងកុមារាខ្លះដណ្តើមល្បែងលេងពីកុមារី និងមិនអាចរើសយកអ្វីដែលជារបស់ចំណូលចិត្តរបស់កុមារី ពេលខ្លះកុមារាមិនអាចលេងល្បែងដែលកុមារីមានទម្លាប់លេង។

បើយើងគិតឱ្យបានល្អិតល្អន់ យើងឃើញថា ទាំងនេះគឺជាកត្តាសំខាន់ដែលយើងមិនត្រូវមើលរំលងឡើយ ព្រោះទម្លាប់នៃភាពមិនមានសមភាពនេះហើយ ដែលធ្វើឱ្យជះឥទ្ធិពលអវិជ្ជមានដល់សង្គមនៅពេលដែលកុមារទាំងនោះបានក្លាយទៅជាមនុស្សពេញវ័យ។

## ៣. គរុកោសល្យនៃសកម្មភាពបង្រៀននិងរៀនឆ្លើយតបសមភាពយេនឌ័ររវាងកុមារា និងកុមារី

គរុកោសល្យនៃសកម្មភាពរៀន និងបង្រៀន ឆ្លើយតបទៅនឹងសមភាពយេនឌ័រ សំដៅទៅលើសកម្មភាពដែលផ្តោតសំខាន់ទៅលើតម្រូវការនៃការសិក្សាជាក់លាក់របស់កុមារី និងកុមារា។ ទាំងនេះតម្រូវឱ្យគ្រូ និងគណៈគ្រប់គ្រងសាលារៀន គឺជាអ្នកដែលឆ្លើយតបទៅនឹងសមភាពយេនឌ័រនៅក្នុងដំណើរការនៃសកម្មភាពរៀននិងបង្រៀន។

គរុកោសល្យនៃសកម្មភាពបង្រៀនដែលឆ្លើយតបទៅនឹងសមភាពយេនឌ័រ នឹងត្រូវបានលើកកម្ពស់ឱ្យមានការឆ្លុះបញ្ចាំងអំពីជំនឿរបស់ពួកគាត់ផ្ទាល់ទៅលើតួនាទីយេនឌ័រ ដែលមានតាំងពីយូរណាស់មកហើយ។ ការអនុវត្តបន្តិចម្តងៗ ជាបន្តបន្ទាប់ វានឹងជួយគ្រូក្នុងការផ្តល់ឱកាសស្មើគ្នារវាងកុមារី និងកុមារា ក្នុងការចូលរួមសកម្មភាពរៀនសូត្រ និងលេងល្បែង នៅមត្តេយ្យសិក្សាមិនចំពោះតែកុមារី ឬកុមារានោះទេ។ បន្ថែមពីលើនេះទៅទៀត គរុកោសល្យនៃសកម្មភាពរៀន និងបង្រៀន ឱ្យឆ្លើយតបទៅនឹងសមភាពយេនឌ័រ នឹងបង្ហាញផ្លូវគ្រូក្នុងការជួយឱ្យសកម្មភាពដោយស្មើភាពគ្នារវាងកុមារី និងកុមារា។

### ហេតុអ្វីបានជាត្រូវមានគរុកោសល្យនៃការអប់រំរបស់គ្រូឱ្យឆ្លើយតបទៅនឹងសមភាពយេនឌ័ររវាងកុមារា និងកុមារី?

គរុកោសល្យនៃការអប់រំកុមារដែលតម្រូវឱ្យមានការឆ្លើយតបទៅនឹងសមភាពរវាងកុមារា និងកុមារី គឺត្រូវតែមានទំនាក់ទំនងនៅក្នុងដំណើរការរៀននិងបង្រៀន សកម្មភាពក្នុងនិងក្រៅថ្នាក់រៀន ដែលមានតួនាទីសំខាន់ ដើម្បីកំណត់ឱ្យកុមារទទួលបាននូវការបន្តចូលរួម និងការអនុវត្តសមត្ថភាពរៀននៅក្នុងថ្នាក់រៀន។ ក្នុងនាមជាគ្រូមត្តេយ្យសិក្សា អ្នកអាចជួយកុមារឱ្យមានទំនាក់ទំនងដោយសមភាពរវាងកុមារា និងកុមារី ក្នុងលក្ខណៈជាវិជ្ជមានដោយទទួលបាននូវឱកាសរៀនសូត្រ និងអភិវឌ្ឍន៍ស្មើគ្នា។

## ៤. គោលបំណងនៃឯកសារ

ឯកសារនេះ រៀបចំឡើងដើម្បីជាជំនួយបន្ថែមដល់គ្រូមត្តេយ្យសិក្សា ធ្វើឱ្យកាន់តែប្រសើរឡើងនូវ៖

- ការរៀបចំផែនការបង្រៀន
- ការបង្រៀន និងបរិស្ថានសិក្សា
- ការរៀបចំកន្លែងអង្គុយ ក្នុងពេលរៀន
- ការលេងក្នុងនិងក្រៅថ្នាក់
- ការប្រើភាសាក្នុងការប្រាស្រ័យទាក់ទងជាមួយកុមារពេលដឹកនាំសកម្មភាពរៀននិងបង្រៀន
- ការធ្វើការទំនាក់ទំនងជាមួយឪពុកម្តាយ ឬអាណាព្យាបាល។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៥. ខ្លឹមសារៈសំខាន់ៗ

**ខ្លឹមសារសំខាន់ៗ ដែលត្រូវយកចិត្តទុកដាក់**




### ក. ការរៀបចំផែនការបង្រៀន

គ្រូត្រូវមានផែនការបង្រៀនដែលបានរៀបចំជាស្រេចនូវសម្ភារៈបង្រៀន សម្រាប់មេរៀននីមួយៗ ឆ្លើយតបទៅនឹងតម្រូវការ និងលទ្ធផលសិក្សារបស់កុមារ។ គ្រូគួរត្រៀម និងគិតទៅដល់ចំណុចមួយចំនួនដូចខាងក្រោម៖

- តើត្រូវបង្រៀនដូចម្តេច ដើម្បីតម្រូវទៅនឹងចំនួនកុមារដែលមាននៅក្នុងថ្នាក់?
- រៀបចំបរិស្ថានថ្នាក់រៀន គិតបញ្ចូលរបៀបអង្គុយរបស់កុមារ

- តើកុមារត្រូវការប្រើសម្ភារៈអ្វីខ្លះ?
- តើត្រូវនិយាយយ៉ាងដូចម្តេច ដើម្បីធ្វើការទំនាក់ទំនងជាមួយកុមារ ឱ្យមានលក្ខណៈរីករាយ និងស្មើភាព?
- តើត្រូវធ្វើអ្វីខ្លះដើម្បីឱ្យមានការទំនាក់ទំនងជាមួយឪពុកម្តាយ ឬអាណាព្យាបាលកុមារក្នុងការជួយយកចិត្តទុកដាក់ជាមួយកូនស្មើៗគ្នា នៅផ្ទះបន្ថែមទៀត?

## គន្លឹះសំខាន់ៗ ក្នុងពេលរៀបចំផែនការបង្រៀន

- ធានាថាកុមាររីករាយ និងចូលចិត្តសកម្មភាពដែលអ្នករៀបចំ ចៀសវាងការផ្តោតតែទៅលើកុមារី ឬកុមារា
- គ្រូអាចនិយាយចែករំលែកនូវបទពិសោធន៍ជាក់ស្តែងរបស់អ្នក ដែលកំពុងតែប្រឈមនឹងទទួលខុសត្រូវ ឧទាហរណ៍៖ ពេលខ្លះប្តីរបស់អ្នកគ្រូ ដាំស្ល បោកគក់ខោអាវ លាងចាន...
- នៅក្នុងមេរៀនអំពីមុខរបរ គ្រូគួរនិយាយពិភាក្សាអំពីការទទួលខុសត្រូវរបស់មុខជំនាញនីមួយៗ ដែលបុរស និងស្ត្រីក៏អាចធ្វើបានដូចគ្នា
- ចៀសវាងការសន្និដ្ឋានក្នុងអំឡុងការសន្ទនា ដូចជា ឪពុកដែលមិនចេះដាំស្លគឺជាឪពុកមិនល្អ ជាដើម
- នៅពេលដែលអ្នកធ្វើផែនការ ចូរអ្នកចាំថាអ្នកចង់ឱ្យកុមារទទួលស្គាល់ និងយល់អំពីកុមារី និងកុមារា ស្ត្រីនិងបុរស

### ខ. ការបង្រៀន និងបរិយាកាសសិក្សា

- **ការបង្រៀន៖** នៅក្នុងមេរៀនមួយ គ្រូបង្កឱកាសសម្រាប់កុមារ ដើម្បីធ្វើការប្រាស្រ័យទាក់ទងជាមួយមិត្តរបស់ពួកគេពីម្នាក់ទៅម្នាក់ទៀត ប្រើប្រាស់វិធីសាស្ត្រធ្វើការងារជាក្រុមដែលអាចលើកទឹកចិត្តកុមារទាំងអស់ឱ្យមានឱកាសបានការចូលរួមមតិយោបល់ ការសហការគ្នាក្នុងការធ្វើការងារ ហើយនៅពេលដែលកុមារបានធ្វើការងារជាមួយដៃគូ ពួកគេនឹងបានអភិវឌ្ឍន៍បំណិនក្នុងការនិយាយប្រាស្រ័យទាក់ទងគ្នាយ៉ាងមានប្រសិទ្ធភាព ធ្វើឱ្យពួកគេមានទំនុកចិត្តចំពោះខ្លួនគេផ្ទាល់ និងមានភាពស្និទ្ធស្នាលជាមួយកុមារផ្ទុយភេទក្នុងការប្រាស្រ័យទាក់ទងទៀតផង។ បំណិនសង្គមទាំងនោះ គឺយើងពិតជាត្រូវការប្រើប្រាស់ក្នុងជីវិតនៅពេលដែលពួកគេក្លាយជាមនុស្សធំ នៅពេលដែលពួកគេនឹងត្រូវធ្វើការទំនាក់ទំនងគ្នាក្នុងការងារដែលមានបុរស និងស្រីធ្វើការជាមួយគ្នា។
- **បរិយាកាសសិក្សា៖** សកម្មភាពនៃការបង្រៀននិងការរៀន អាចធ្វើឡើងនៅក្នុង និងក្រៅថ្នាក់។ ការឆ្លើយតបបែបសមភាពរវាងកុមារី និងកុមារា ក្នុងសកម្មភាពរៀននិងបង្រៀន អាចកំណត់បានតាមរយៈការរៀបចំកន្លែងធ្វើសកម្មភាព ឬកន្លែងអង្គុយរៀនរបស់កុមារ ការរៀបចំគ្រប់គ្រងថ្នាក់



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

រៀន ការរៀបចំការងារជាក្រុមរបស់កុមារ ការរៀបចំសកម្មភាពរៀនក្នុងនិងក្រៅថ្នាក់ដោយរៀបចំសកម្មភាពរៀនតាម

- រយៈពេលការលេងរបស់កុមារ ( Learning Through Play )។



## គ. ការរៀបចំកន្លែងអង្គុយក្នុងពេលធ្វើសកម្មភាពរៀន

- បែងចែកកុមារជាក្រុមការងារ ដែលក្នុងក្រុមនីមួយៗ មានកុមារី និងកុមារា លាយគ្នាដើម្បីឱ្យពួកគេបានចូលរួមធ្វើការងារ ឬលេងជាក្រុមដែលមានចម្រុះភេទ
- ផ្លាស់ប្តូរក្រុមជាប្រចាំ ដើម្បីឱ្យកុមារបានចូលរួម និងបានផ្សារភ្ជាប់ទំនាក់ទំនងរវាងគ្នានិងគ្នាជាមួយមិត្ត និងទំនាក់ទំនងបន្តពីម្នាក់ទៅម្នាក់ទៀតនៅក្នុងថ្នាក់រៀន
- រៀបកុមារឱ្យអង្គុយជារាងរង្វង់ ដោយឆ្លាស់គ្នារវាងកុមារីនិងកុមារាដើម្បីឱ្យពួកគាត់បានធ្វើការរួមគ្នាចូលរួមបានគ្រប់គ្នា ស្មើភាពគ្នា និងមានការទំនាក់ទំនងគ្នារវាងភេទផ្សេងគ្នា។



### ឃ. ការលេងក្នុងថ្នាក់ និងក្រៅថ្នាក់

ការរៀនតាមរយៈការលេង(Learning Through Play) គឺជាមធ្យោបាយដ៏សំខាន់ណាស់ និងមានប្រសិទ្ធភាពបំផុតជាពិសេស គឺចំពោះកុមារវ័យមត្តេយ្យសិក្សា។ សម្ភារៈល្បែង និងការប្រាស្រ័យទាក់ទងគ្នាក្នុងការលេងជាមួយដៃគូនឹងជួយឱ្យកុមារបានលេងទាំងអស់គ្នា និងដោះស្រាយបញ្ហាក្នុងការលេងរួមគ្នា។ ការលេងគឺនាំឱ្យកុមារបានរៀន ហើយកុមារអាចលេងជាមួយកុមារដ៏ទៃដែលមានក្រុមអាយុចម្រុះ និងភេទផ្សេងគ្នា។ យ៉ាងណាក៏ដោយក៏កុមារា និងកុមារី ច្រើនតែចូលចិត្តលេងអ្វីផ្សេងពីគ្នា ដែលជាហេតុផលធ្វើឱ្យពួកគាត់យល់ថាកុមារី និងកុមារា គឺមានភាពខុសគ្នាឆ្ងាយមិនអាចធ្វើអ្វីដូចគ្នាបានទេ។ កុមារាចូលចិត្តលេងអ្វីដែលពើសជាង ប្រទាឡឹមជាង រហ័សរហួនជាង ត្រូវការទីកន្លែងទូលាយ ដូចជា កុមារាចូលចិត្តលេងបាល់ទាត់ នៅពេលដែលកុមារីចូលចិត្តលេងល្បែងដែលងាយៗ យឺតៗ ដូចជា លេងឆ្កឹះគ្រាប់ក្រួស ជាដើម។ កំណត់សម្គាល់ទាំងអស់ខាងលើនេះ នឹងមានការជះឥទ្ធិពលដល់ការគិត និងលទ្ធផលរបស់កុមារ។




- អ្នកត្រូវចងចាំថាកុមារី និងកុមារាមានរាងកាយមាំមួន និងត្រូវការធ្វើចលនាដូចគ្នារហូតដល់ពេលដែលពួកគេពេញវ័យ ប៉ុន្តែកុមារីច្រើនតែអាចបង្ហាញពីអត្តចរិតទំនាក់ទំនងសង្គមបានប្រសើរជាង
- លើកទឹកចិត្តកុមារលេងល្បែងជាក្រុម ដែលមានសមាសភាពកុមារីលាយចម្រុះជាមួយកុមារាក្នុងការលេង ឬធ្វើការងារជាក្រុម។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ល្បែងមួយចំនួនមានការលេងដោយកុមារា ឬក៏កុមារី តែប៉ុណ្ណោះ ពួកគាត់មិនដែលលេងចូលគ្នាទេ ឧទាហរណ៍ បាល់ លេងកូនក្រមុំ លេងល្បែងសំណង់ និងលេងលោតអន្ទាក់ ។ល។ ដូច្នេះ គ្រូត្រូវលើកទឹកចិត្ត និងរៀបចំសកម្មភាពបង្រៀនអំពីរបៀបលេងដល់កុមារឱ្យពួកគាត់អាចលេងជាមួយគ្នាបាន។
- លើកសរសើរ កុមារី កុមារា ដែលមានការផ្លាស់ប្តូរបាននូវទម្លាប់លេងជាមួយគ្នា និងចេះផ្តល់តម្លៃឱ្យគ្នាទៅវិញទៅមក។





### ង. ការប្រាស្រ័យទាក់ទង និងការប្រើប្រាស់ការនិយាយជាមួយកុមារ

ការប្រាស្រ័យទាក់ទងរវាងគ្រូ និងសិស្ស គឺជាកត្តាដ៏សំខាន់បំផុតដែលត្រូវប្រើជាមួយកុមារក្នុងថ្នាក់រៀន ព្រោះវាត្រូវតែជាភាសាដែលឆ្លើយតបទៅនឹងសមភាពយេនឌ័រ។ ការនិយាយស្តី ដែលមានលក្ខណៈឆ្លើយតបទៅនឹងសមភាពយេនឌ័រដែលវាអាចធ្វើឱ្យកុមារមានអារម្មណ៍ថា ត្រូវទទួលបានការគោរព និងឱ្យតម្លៃ ដូចជា ការលើកទឹកចិត្តកុមារដែលនឹងធ្វើឱ្យការរៀនសូត្របានប្រសើរឡើង បន្ថែមពីនេះទៀត បានបង្កបរិយាកាសល្អក្នុងការសិក្សាដែលកុមារអាចបញ្ចេញគំនិតខ្លួនឯងដោយសេរី ក្រោមការសម្របសម្រួលពីសំណាក់គ្រូមត្តេយ្យសិក្សា។

ការរៀនដែលមានការផ្តល់តម្លៃឱ្យកុមារ ធ្វើឱ្យកុមារមានទំនុកចិត្ត មានសេចក្តីក្លាហាន និងមានអារម្មណ៍ត្រូវបានលើកទឹកចិត្ត មានការយកចិត្តទុកដាក់ ដែលនាំឱ្យលទ្ធផលនៃការសិក្សារបស់ពួកគេកាន់តែប្រសើរឡើង។ ផ្ទុយទៅវិញ ការនិយាយ ឬប្រើភាសាមិនល្អ និងកាយវិការដែលមិនសមរម្យ ដូចជា កាយវិការទឹកមុខ ប្រើភ្នែកសម្លក់ បែបគំរាមកំហែង ទៅលើកុមារី ឬកុមារា អាចធ្វើឱ្យកុមារចម្លងតាមនូវទស្សនៈអវិជ្ជមានចំពោះសមភាពយេនឌ័រ និងជាសារដែលកុមារនឹងរៀនតាមរយៈការប្រាស្រ័យទាក់ទងពីមនុស្សម្នាក់ទៅម្នាក់ទៀតផងដែរ។

### ច. ការប្រាស្រ័យទាក់ទងរវាងគ្រូ និងឪពុកម្ដាយ

ជារឿយៗ ឪពុកម្ដាយ និងអ្នកមើលថែកុមារ មិនបានដឹងថាពួកគាត់ បន្តការបង្ហាញនូវអត្តចរិត និងជំនឿអំពីតួនាទីខុសគ្នារវាងបុរស និងស្ត្រីនោះទេ ហើយកុមារាភាគច្រើនថែទាំនិងចិញ្ចឹមខុសគ្នាពីកុមារី។ ជាទូទៅកុមារីត្រូវបានរៀបចំឱ្យស្លៀកពាក់ទៅតាមពណ៌ ដូចជា ពណ៌ផ្កាឈូក ពណ៌ស្វាយ ហើយសម្ភារៈលេងទៀតសោតមាន ដូចជា កូនក្រមុំ តុក្កតា គឺសម្រាប់កុមារីលេង រីឯបាល់ ឬកូនឡាន សម្រាប់តែកុមារាលេង។ កូនស្រីត្រូវបានបង្រៀនឱ្យស្ដាប់បង្គាប់ សុភាពរាបសា  កុមារាត្រូវបានបង្រៀនឱ្យក្លាហានរឹងមាំ ជួនកាលកុមារីត្រូវបានការពារហួសចត់ជាងកុមារា។ ទន្ទឹមនឹងនេះដែរ កុមារាត្រូវបានបង្រៀនមិនឱ្យយំ ព្រោះជាសញ្ញាបង្ហាញថា ទន់ខ្សោយ។ ឪពុកម្ដាយ ក៏បានបង្ហាញនូវទស្សនៈលម្អៀងមួយចំនួន ដូចជា ស្ត្រីត្រូវធ្វើការងារផ្ទះ ដូចជា បោសសម្អាតផ្ទះ បោកគក់ខោអាវ ធ្វើម្ហូប ជាដើម។ ចំណែកបុរសធ្វើការងារក្រៅផ្ទះ។ ដើម្បីដោះស្រាយបញ្ហាផ្នត់គំនិតអវិជ្ជមានអំពីសមភាពយេនឌ័រនៅក្នុងគ្រួសារ និងសហគមន៍របស់កុមារ អ្នកត្រូវធ្វើការជិតស្និទ្ធជាមួយសហគមន៍។

**ចំណុចដែលគ្រូវយកចិត្តទុកដាក់បន្ថែម ដើម្បីចូលរួមចំណែក លើកកម្ពស់សមភាព រវាងកុមារា និងកុមារី ចំពោះការប្រាស្រ័យទាក់ទង រវាងគ្រូ និងឪពុកម្ដាយ**

- *នៅពេលដែលកុមារបង្ហាញអំពីចរិតរើសអើង ត្រូវព្យាយាមទទួលព័ត៌មានបន្ថែមអំពីស្ថានភាព និងហេតុផលដែលនាំឱ្យកុមារមានចរិតបែបនេះ*
- *ព្យាយាមរកពេលសន្ទនាជាលក្ខណៈឯកជន ជាមួយឪពុកម្ដាយ ឬ អាណាព្យាបាលកុមារ ដើម្បីពិភាក្សារកឱកាសចំណេញស្មើគ្នានិងគោរពការជួយរបស់ពួកគាត់។*
- *ត្រូវចងចាំថា ការគោរពគ្នាទៅវិញទៅមកគឺជាចំណុចសំខាន់ដើម្បីមានការជួយពីឪពុក*



### ៦. ការវាស់វែង និងវាយតម្លៃការប្រែប្រួលរបស់កុមារ

- ការវាយតម្លៃការរីកចម្រើនរបស់កុមារនឹងប្រើប្រាស់សម្រាប់គ្រូ ឪពុកម្ដាយ និងគ្រួសាររបស់កុមារនូវព័ត៌មានសំខាន់ៗ មួយចំនួនអំពីការរីកចម្រើនរបស់កុមារ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ព័ត៌មានសំខាន់ៗ បានមកពីការវាយតម្លៃក៏ត្រូវបានប្រើប្រាស់ផងដែរ សម្រាប់ប្រសិទ្ធភាពនៃសកម្មភាពបង្រៀននិងរៀន ដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសិក្សារបស់កុមារ។
- នៅពេលធ្វើការវាយតម្លៃ អ្នកនឹងត្រូវមានមោទនភាពព្រោះអ្នកដឹងថា អ្វីដែលអ្នកកំពុងធ្វើគឺត្រឹមត្រូវដូចដែលមានគ្រោងទុក។
- ការសង្កេតរបស់អ្នកទៅលើកុមារី និងកុមារា នឹងជួយអ្នកឱ្យវាយតម្លៃអំពីការប្រាស្រ័យទាក់ទងក្នុងសមភាពយេនឌ័រ។
- ប្រើប្រាស់ព័ត៌មាន ដែលអ្នកបានប្រមូល ដើម្បីជួយកុមារឱ្យប្រសើរឡើងនូវ អត្តចរិត អាកប្បកិរិយាតម្លៃ និងការសិក្សារៀនសូត្រ។





**គន្លឹះសំខាន់ៗ៖**

- វិធីដែលល្អបំផុតក្នុងការវាយតម្លៃកុមារគឺ «ការសង្កេត»។ តាមរយៈការសង្កេត អ្នកនឹងបានដឹងថា តើមានផ្នត់គំនិតអ្វីខ្លះដែលរារាំងនៅក្នុងថ្នាក់ដែលជាឧបសគ្គក្នុងការសិក្សារបស់កុមារ។
- លើកទឹកចិត្តកុមារឱ្យលេងល្បែងណាដែលជាធម្មតាលេងដោយភេទផ្ទុយបាន ដូចជាបាល់ បាញ់កៅស៊ូកង លោតអន្ទាក់ កូនក្រមុំ។ល។
- អ្នកអាចសួរសំណួរទៅកុមារម្នាក់ៗ អ្នកនឹងបានដឹងអំពី ការយល់ដឹង ផ្នត់គំនិត និងការអនុវត្តរបស់កុមារជុំវិញរឿងរ៉ាវនៃផ្នត់គំនិតយេនឌ័រ។
- នៅពេលអ្នកធ្វើការសង្កេត អ្នកគួរផ្តោតទៅលើ ការបញ្ចេញមតិ ការធ្វើកាយវិការ ការច្រៀង រាំ និងគូររូបរបស់កុមារ។ល។

## ឧទាហរណ៍មួយអំពីឧបករណ៍សម្រាប់ធ្វើការសង្កេតៈ

គំរូឧទាហរណ៍នេះ គឺមានប្រយោជន៍សម្រាប់ធ្វើការសង្កេតអាកប្បកិរិយារបស់កុមារ។
បញ្ជាក់៖ អ្នកអាចកែសម្រួលទៅតាមតម្រូវការជាក់ស្តែងនៃថ្នាក់រៀនរបស់អ្នក។

| ឈ្មោះរបស់កុមារ | ចំណុចដែលធ្វើបាន | យោបល់បន្ថែម |
|---|---|---|
| ការប្រាស្រ័យទាក់ទងជាមួយដៃគូ | ✓ | ជាមួយអ្នកណា? |
| ការប្រាស្រ័យទាក់ទងជាមួយដៃគូដែលជាភេទផ្ទុយគ្នា | ✓ | ជាមួយអ្នកណា? |
| មិនមានការខុសគ្នានៅពេលធ្វើការទំនាក់ទំនងពេលនិយាយទៅកាន់ដៃគូជាភេទផ្ទុយគ្នា | ✓ | ធ្វើការអធិប្បាយ |
| លេងនៅក្បែរកុមារដែលមានភេទផ្ទុយ | ✓ | ជាមួយអ្នកណា? |
| ចូលរួមលេងជាមួយដៃគូដែលជាភេទផ្ទុយ | × | លេងជាមួយអ្នកណា? |
| ចូលរួមលេងជាមួយសម្ភារៈរៀន | × | សម្ភារៈអ្វីខ្លះ? |
| ចូលរួមលេងជាមួយសម្ភារៈ ដែលមិនមានផ្នត់គំនិតយេនឌ័រ | ✓ | លេងដូចម្តេច? |
| រូបដែលកុមារបានគូរ រួចមាន រូបកុមារា និងរូបកុមារី | ✓ | ធ្វើការអធិប្បាយ |
| បាននិទានរឿងប្រាប់អំពី សាច់រឿងដែលមានតួអង្គទាំងពីរភេទ | ✓ | ធ្វើការអធិប្បាយ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## យេនឌ័រ និងការសិក្សាវិទ្យាសាស្ត្រ

ដើម្បីឆ្លើយតបសមភាពយេនឌ័រនៅក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ គ្រូមត្តេយ្យសិក្សា ត្រូវយកចិត្តទុកដាក់៖

- ផ្តល់ឱកាសឱ្យកុមារទាំងអស់បានលេង និងធ្វើសកម្មភាពពិសោធន៍ដូចគ្នា ដោយមិនមានការរើសអើងរវាងកុមារី និងកុមារា
- មិនត្រូវនិយាយបង្អាប់កុមារា ឬកុមារី ដែលធ្វើកិច្ចការមិនទាន់បានល្អ ប៉ុន្តែត្រូវយកចិត្តទុកដាក់ពន្យល់បន្ថែម និងជួយពួកគេដោយបរិយាកាសរីករាយចំពោះកុមារដែលមិនទាន់អាចធ្វើបាន
- ត្រូវមានការឆ្នៃប្រឌិតរកសកម្មភាពដែលកុមារទាំងពីរភេទមានការចាប់អារម្មណ៍ក្នុងការរៀនវិទ្យាសាស្ត្រ ដូចជា លាយជីវជាតិ ឬម្សៅ ដើម្បីសូនរូបសត្វ សាកល្បងបណ្តុះ ដាំ គ្រាប់ធញ្ញជាតិ។ល។
- ត្រូវសង្កេត និងលើកទឹកចិត្តកុមារទាំងពីរភេទឱ្យសកម្មដូចគ្នាក្នុងគ្រប់ប្រភេទសកម្មភាពដោយរំលឹកអំពីអត្ថប្រយោជន៍នៃការរៀនវិទ្យាសាស្ត្រសម្រាប់ពួកគេ។
- សង្កេតមើលសកម្មភាពកុមារ និងណែនាំកុមារ ឱ្យចេះគោរពគ្នាទៅវិញទៅមករវាងកុមារីនិងកុមារា និងមានការយោគយល់អធ្យាស្រ័យដល់គ្នាដោយមិនរើសអើង។
- លើកទឹកចិត្តកុមារីនៅពេលដែលពួកគាត់អាចធ្វើកិច្ចការដែលកុមារាអាចធ្វើបាន និងលើកទឹកចិត្តកុមារា នៅពេលដែលកុមារាអាចធ្វើកិច្ចការដែលកុមារីធ្វើបាន។

# ឯកសារពិគ្រោះ


1. ក្រសួងអប់រំ យុវជន និងកីឡា. (ឆ្នាំ១៩៩៤-១៩៩៥). *គរុកោសល្យនៃបរិដ្ឋានសំរាប់សាលាមត្តេយ្យ ភាគ១ និងភាគ២.* រាជធានីភ្នំពេញ: ឧបត្ថម្ភការបោះពុម្ពដោយ unicef
2. ក្រសួងអប់រំ យុវជន និងកីឡា. (ព.ស ២៥៤៨ គ.ស ២០០៤). *សេចក្តីព្រាងឯកសារសម្រាប់គ្រូកម្មវិធីអប់រំកុមារដែលមិនបានឆ្លងកាត់សាលាមត្តេយ្យសិក្សា.* រាជធានីភ្នំពេញ: ឧបត្ថម្ភដោយអង្គការយូនីសេហ្វ/ស៊ីដា.
3. ក្រសួងអប់រំ យុវជន និងកីឡា. (២០០៧). *សៀវភៅកុបនិងពិភពលោកដ៏ធំទូលាយ.* ឧបត្ថម្ភដោយយូនីសេហ្វ unicef.
4. ក្រសួងអប់រំ យុវជន និងកីឡា. (២០០៨). *កម្មវិធីមត្តេយ្យសិក្សាសហគមន៍.* រាជធានីភ្នំពេញ: ឧបត្ថម្ភដោយអង្គការ unicef.
5. ក្រសួងអប់រំ យុវជន និងកីឡា. (២០០៨). *កម្មវិធីមត្តេយ្យសិក្សាកុមារអាយុ៥ឆ្នាំ.* រាជធានីភ្នំពេញ: ឧបត្ថម្ភដោយអង្គការ យូនីសេហ្វ/ស៊ីដា.
6. ក្រសួងអប់រំ យុវជន និងកីឡា. (កុម្ភៈ ២០១០). *ឯកសារធេនធានអភិវឌ្ឍកុមារតូច.* រាជធានីភ្នំពេញ: ឧបត្ថម្ភដោយអង្គការ unicef.
7. ក្រសួងអប់រំ យុវជន និងកីឡា. (ឆ្នាំ២០១៣). *វិទ្យាសាស្ត្រងាយៗនៅមត្តេយ្យសិក្សាសម្រាប់បណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា.* រាជធានីភ្នំពេញ: នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ.
8. Ministry of Education. (2013). *Nurturing Early Learners A Curriculum for Kindergartens in Singapore*. Republic of Singapore: ISBN: 978-981-07-8551-2 Designed by LOUD! Productions Pte Ltd.
9. ក្រសួងអប់រំ យុវជន និងកីឡា. (ឆ្នាំសិក្សា ២០១៥-២០១៦). *គរុកោសល្យសម្រាប់បណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា.* រាជធានីភ្នំពេញ: សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម.
10. ក្រសួងអប់រំ យុវជន និងកីឡា. (ឆ្នាំ២០១៦). *ចិត្តវិទ្យាសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនមត្តេយ្យសិក្សា.* រាជធានីភ្នំពេញ: នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ.
11. ក្រសួងអប់រំ យុវជន និងកីឡា. (២០១៨). *កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ.* រាជធានីភ្នំពេញ: បោះពុម្ពលើកទី២ ប្រើប្រាស់ថវិកាកម្មវិធីឆ្នាំ ២០២០ របស់អង្គភាពថវិកានាយកដ្ឋានអប់រំកុមារតូច.
12. ក្រសួងអប់រំ យុវជន និងកីឡា. (ខែកញ្ញា ឆ្នាំ២០២១). *កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សាសហគមន៍.* រាជធានីភ្នំពេញ: បោះពុម្ពលើកទី១ ថវិកាកម្មវិធីឆ្នាំ២០២១.



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ឧបត្ថម្ភការបោះពុម្ព

PLAN INTERNATIONAL